# ព្រះ
# ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
ខុទ្ទកនិកាយ បេតវត្ថុ ថេរគាថា
បញ្ចមភាគ
# ៥៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០២

សុត្តន្តបិដក
ខុទ្ទកនិកាយ បេតវត្ថុ ថេរគាថា
បញ្ចមភាគ
៥៦

## សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស បេតវត្ថុ

## បញ្ចមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### បឋមោ ឧរគវគ្គោ

### បឋមំ ខេត្តូបមាបេតវត្ថុ

(១) ខេត្តូបមា អរហន្តោ ទាយកា កស្សកូបមា
ពីជូបមំ ទេយ្យធម្មំ ឯត្តោ និព្វត្តតេ ផលំ
ឯតំ ពីជំ កសិ ខេត្តំ បេតានំ ទាយកស្ស ច
តំ បេតា បរិភុញ្ជន្តិ ទាតា បុញ្ញេន វឌ្ឍតិ
ឥធេវ កុសលំ កត្វា បេតេ ច បដិបូជិយ
សគ្គញ្ច កមតិ ឋានំ កម្មំ កត្វាន ភទ្ទកន្តិ ។

ខេត្តូបមាបេតវត្ថុ បឋមំ ។

## សុត្តន្តបិដក

## ខុទ្ទកនិកាយ បេតវត្ថុ

## បញ្ចមភាគ

*សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

### ឧរគវគ្គ ទី ១

### រឿងខេត្តូបមាប្រេត ទី១

*(១) ពួកព្រះអរហន្ត ដូចស្រែ ពួកទាយក ដូចអ្នកភ្ជួររាស់ ទេយ្យធម៌ ដូចពូជ ផលរមែងកើតមកអំពីព្រះអរហន្ត នឹងទាយកនឹងទេយ្យធម៌នុ៎ះ ឯពូជនឹងការភ្ជួររាស់នឹងស្រែនុ៎ះ តែងមានដល់ពួកប្រេតទាំងឡាយផង ដល់ទាយកផង ប្រេតទាំងឡាយ តែងបរិភោគនូវផលនៃទាននោះ ទាយកអ្នកឲ្យទាន តែងចំរើនដោយបុណ្យ ក្នុងលោកនេះ បុគ្គលធ្វើកុសលហើយ គួរតែបូជាចំពោះប្រេតទាំងឡាយ ព្រោះថា បុគ្គលធ្វើកុសលកម្ម ដ៏ចំរើន រមែងទៅកាន់ឋានសួគ៌ ។*

ចប់ រឿងខេត្តូបមាប្រេត ទី ១ ។

## ទុតិយំ សូករប្បេតវត្ថុ

(២) កាយោ តេ សព្វសោវណ្ណោ សព្វា ឱភាសតេ ទិសា
មុខំ តេ សូករស្សេវ កឹ កម្មមកាសិ[១] បុរេ ។
កាយេន សញ្ញតោ អាសឹ វាចាយាសឹ អសញ្ញតោ
តេន មេ តាទិសោ វណ្ណោ យថា បស្សសិ នារទ[២]
តំ ត្យាហំ នារទ ព្រូមិ សាមំ ទិដ្ឋមិទំ តយា
មា កាសិ មុខសា បាបំ មា ខោ សូករមុខោ អហូតិ ។

សូករប្បេតវត្ថុ ទុតិយំ ។

## តតិយំ បូតិមុខប្បេតវត្ថុ

(៣) ទិព្វំ សុភំ ធារេសិ វណ្ណធាតុំ
វេហាសយំ តិដ្ឋសិ អន្តលិក្ខេ
មុខញ្ច តេ កិមិយោ បូតិគន្ធំ
ខាទន្តិ កឹ កម្មមកាសិ បុព្វេ ។
សមណោ អហំ បាបោ ទុក្ខវាចោ[៣]
តបស្សិរូបោ មុខសា អសញ្ញតោ
លទ្ធា ច មេ តបសា វណ្ណធាតុ[៤]

១ ម. កម្មមករី ។ ២ ម. នារាទ ។ ៣ ម. ទុដ្ឋវាចោ ។ ៤ ម. វណ្ណធាតុំ ។



## រឿងសូករប្រេត ទី ២

(២) (ព្រះនារទត្ថេរសួរថា) កាយទាំងមូលរបស់អ្នក មានសម្បុរដូចជាមាស មានរស្មីភ្លឺស្វាង សព្វទិស តែមាត់របស់អ្នកដូចមាត់ជ្រូក តើអំពីកាលមុន អ្នកបានធ្វើអំពើដូចម្តេច ។

(ប្រេតតបថា) បពិត្រព្រះនារទៈ ខ្ញុំជាបុគ្គលបានសង្រួមកាយ តែមិនបានសង្រួមវាចា ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ដូចលោកម្ចាស់បានឃើញស្រាប់ហើយ បពិត្រព្រះនារទៈ ខ្ញុំសូមទូលរឿងនោះ ដល់លោកម្ចាស់ រឿងនេះ លោកម្ចាស់បានឃើញ ដោយខ្លួនឯងស្រាប់ហើយ លោកកុំធ្វើបាប ដោយមាត់ កុំមានមាត់ដូចមាត់ជ្រូកឡើយ ។

ចប់ រឿងសូករប្រេត ទី ២ ។

## រឿងបូតិមុខប្រេត ទី ៣

(៣) (ព្រះនារទត្ថេរសួរថា) អ្នកទ្រទ្រង់នូវវណ្ណធាតុ គឺកាយជាទិព្វ ដ៏ល្អ ឋិតនៅក្នុងអាកាសវេហាស៍ ទាស់តែដង្កូវទាំងឡាយ ទំពាស៊ីនូវមាត់របស់អ្នក ដែលមានក្លិនស្អុយ តើអំពីកាលមុន អ្នកបានធ្វើអំពើដូចម្តេច ។

(ប្រេតតបថា) ខ្ញុំជាសមណៈលាមក មានវាចាអាក្រក់ ប្រព្រឹត្តតបធម៌ មិនសង្រួមមាត់ ឯវណ្ណធាតុខ្ញុំបាននេះហើយ ដោយតបធម៌

មុខញ្ច មេ បេសុណិយេន បូតិ ។

តយិទំ តយា នារទ សាមំ ទិដ្ឋំ

អនុកម្បកា យេ កុសលា វទេយ្យុំ

មា បេសុណំ មា ច មុសា អភាណិ

យក្ខោ តុវំ ហោហិសិ កាមកាមី ។

បូតិមុខប្បេតវត្ថុ តតិយំ ។

## ចតុត្ថំ បិដ្ឋធីតលិកប្បេតវត្ថុ

(៤) យំ កិញ្ចារម្មណំ កត្វា ទជ្ជា ទានមមច្ឆរី

បុព្វេ បេតេ អារព្ភ អថ វា វត្ថុទេវតា

ចត្តារោ ច[១] មហារាជេ លោកបាលេ យសស្សិនោ[២]

កុវេរំ ធតរដ្ឋញ្ច វិរូបក្ខំ[៣] វិរូឡ្ហកំ

តេ ចេវ[៤] បូជិតា ហោន្តិ ទាយកា ច អនិប្ផលា ។

ន ហិ រុណ្ណំ វា សោកោ វា យា វញ្ញា បរិទេវនា

ន តំ បេតស្ស អត្ថាយ ឯវំ តិដ្ឋន្តិ ញាតយោ[៥] ។

---

១ ម. ច ។ ២ ម.ឱ. យសស្សិនេ ។ ៣ ម. វិរូបក្ខញ្ច ។ ៤ ម. តេ ចេវ ។ ៥ ម. ញាតកា ។



មាត់របស់ខ្ញុំ មានក្លិនស្អុយ ព្រោះតែពោលពាក្យញុះញង់ ។ បពិត្រព្រះនារទៈ អំពើនោះ លោកម្ចាស់បានឃើញខ្លួនឯងស្រាប់ហើយ អ្នកឈ្លាសទាំងឡាយ ជាអ្នកអនុគ្រោះ គប្បីពោលថា អ្នកកុំពោលពាក្យញុះញង់ កុំពោលពាក្យកុហក ទើបអ្នកនឹងបានជាទេវបុត្រ មានកាមតាមសេចក្ដីប្រាថ្នា ។

ចប់ រឿងបូតិមុខប្រេត ទី ៣ ។

## រឿងបិដ្ឋធីតលិកប្រេត ទី ៤

(៤) (ព្រះសម្ពុទ្ធទ្រង់សំដែងថា) បុគ្គលមិនមានសេចក្ដីកំណាញ់ គួរធ្វើនូវហេតុណាមួយ ឲ្យជាអារម្មណ៍ហើយគប្បីឲ្យទាន គឺប្រារព្ធនូវបុព្វបុរសទាំងឡាយមានមាតាបិតាជាដើម ដែលចំណាកទៅកាន់បរលោកហើយ ឬនូវទេវតាទាំងឡាយ ដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានទីផ្ទះជាដើម នូវស្ដេចធំទាំង ៤ ដែលរក្សាលោក ជាអ្នកមានយសបរិវារ គឺព្រះបាទកុវេរៈ ១ ធតរដ្ឋៈ ១ វិរូបក្ខៈ ១ វិរូឡ្ហកៈ ១ ហើយឲ្យនូវទានចុះ ដ្បិតទាំងឡាយមានស្ដេចធំជាដើមនោះឈ្មោះថា ជាបុគ្គលដែលទាយកនោះបានបូជាហើយ ឯទាយកទាំងឡាយមិនមែនជាមិនមានផលទេ ។ ការយំក្ដី សោកសៅក្ដី ឬការខ្សឹកខ្សួលណាដទៃក្ដី បុគ្គលមិនគប្បីធ្វើទេ កិច្ចមានយំសោកជាដើមនោះ មិនជាប្រយោជន៍ ដល់អ្នកដែលទៅកាន់បរលោកទេ ញាតិទាំងឡាយ (ដែលទៅកាន់បរលោកនោះ) ក៏ឋិតនៅយ៉ាងនោះដដែល (មិនបានដឹងបានឮឡើយ) ។

អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុប្បតិដ្ឋិតា
ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតីតិ ។

បិដ្ឋធីតលិកបេតវត្ថុ ចតុត្ថំ ។

## បញ្ចមំ តិរោកុឌ្ឌបេតវត្ថុ

(៥) តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ ។
បហូតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ
ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា ។
ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ
ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។
តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា
បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ



ណែកទក្ខិណាទាន ដែលបុគ្គលបានឲ្យហើយនេះឯង ជាទានដំកល់ទៅល្អក្នុងព្រះសង្ឃ រមែងសម្រេចផល ដើម្បីជាប្រយោជន៍ដល់ញាតិ ដែលទៅកាន់លោកខាងនាយនោះអស់កាលជាយូរអង្វែង តាមឋានៈតិចដែលគួរសម្រេចបាន ។

ចប់ រឿងបិដ្ឋធីតលិកប្រេត ទី ៤ ។

## រឿងតិរោកុឌ្ឌប្រេត ទី ៥

(៥) (ព្រះសម្ពុទ្ធទ្រង់សំដែងថា) ប្រេតទាំងឡាយ មកកាន់ផ្ទះរបស់ខ្លួន ឋិតនៅខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ឋិតក្បែរក្រែង និងក្បាលផ្ទះទាំងឡាយខ្លះ ។ កាលបើបាយ ទឹក បង្អែម ចំណាប់ដ៏ច្រើន ដែលពួកញាតិចូលទៅតាំងទុកហើយ ញាតិណាមួយ មិននឹករលឹកដល់ប្រេតទាំងឡាយនោះ ព្រោះបច្ច័យ គឺកម្មរបស់សត្វទាំងឡាយ ។ ជនទាំងឡាយណា ជាអ្នកអនុគ្រោះ ជនទាំងនោះ រមែងឲ្យនូវទឹកនិងភោជន ដ៏ហ្មត់ចត់ប្រសើរ ជារបស់គួរតាមកាល ដើម្បីញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរសំរេចដល់ញាតិទាំងឡាយ សូមឲ្យញាតិទាំងឡាយ ដល់នូវសេចក្តីសុខចុះ ។ ឯប្រេតជាញាតិទាំងនោះ មកប្រជុំគ្នាក្នុងទីដែលឲ្យទាននោះ ជាអ្នកមកល្អហើយ កាលបើបាយនិងទឹកដ៏ច្រើន (ដែលគេឧទ្ទិសដល់ខ្លួន) តែងអនុមោទនា ដោយគោរពថា

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ
អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា ។
ន ហិ តត្ថ កសី អត្ថិ គោរក្ខេត្ថ ន វិជ្ជតិ
វណិជ្ជា តាទិសី នត្ថិ ហិរញ្ញេន កយាកយំ ។
ឥតោ ទិន្នេន យាបេន្តិ បេតា កាលគតា តហឹ
ឧន្នមេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។
យថា វារិវហា បូរា បរិបូរេន្តិ សាគរំ
ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។
អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។



យើងទាំងឡាយបាន (ទទួលផល) ព្រោះហេតុនៃពួកញាតិណា សូមញាតិទាំងនោះ របស់យើង រស់នៅអស់កាលយូរចុះ ការបូជា ឈ្មោះថាញាតិទាំងឡាយបានធ្វើហើយ ដល់ពួកយើង ឯអ្នកឲ្យទាន មិនមែនជាមិនបានផលឡើយ ។ កសិកម្មគឺការភ្ជួររាស់ ក៏មិនមាន ក្នុងភូមិនៃប្រេតនោះ គោរក្ខកម្មគឺការរក្សាគោ ក៏មិនមាន ក្នុងភូមិនៃប្រេតនោះ វាណិជ្ជកម្មគឺការជួញប្រែដែលជាហេតុបាននូវសម្បត្តិ ដូច្នោះ ក៏មិនមាន ការលក់ចេញទិញចូល ដោយប្រាក់ក៏មិនមាន ។ បុគ្គលទាំងឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយសារតែផលទានដែលញាតិឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទាប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ ផ្លូវទឹកទាំងឡាយ ដ៏ពេញ រមែងញ៉ាំងសាគរឲ្យពេញប្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរលឹកឃើញនូវឧបការគុណដែលញាតិមិត្តជាដើម បានធ្វើដល់ខ្លួន ក្នុងកាលមុនថា អ្នកឯណោះបានឲ្យ (របស់នេះ) ដល់អាត្មាអញ អ្នកឯណោះបានធ្វើ(គុណនេះ) ដល់អាត្មាអញ ជនទាំងនោះ ជាញាតិមិត្ត ជាសំឡាញ់របស់អាត្មាអញ ដូច្នេះហើយ គួរឲ្យទក្ខិណាទាន ដល់ប្រេតទាំងឡាយ ។

ន ហិ រុណ្ណំ វា សោកោ វា យា ចញ្ញា បរិទេវនា
ន តំ បេតស្ស អត្ថាយ[១] ឯវំ តិដ្ឋន្តិ ញាតយោ ។
អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុប្បតិដ្ឋិតា
ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។
សោ ញាតិធម្មោ ច អយំ និទស្សិតោ
បេតាន បូជា ច កតា ឧឡារា
ពលញ្ច ភិក្ខូនមនុប្បទិន្នំ
តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ ។

តិរោកុដ្ឌបេតវត្ថុ បញ្ចមំ ។

## ឆដ្ឋមំ បញ្ចបុត្តខាទកបេតវត្ថុ

(៦) នគ្គា ទុព្វណ្ណរូបាសិ ទុគ្គន្ធា បូតិ វាយសិ
មក្ខិកាហិ បរិកិណ្ណា កា នុ ត្វំ ឥធ តិដ្ឋសីតិ ។

១ ម. ន តំ បេតានមត្ថាយ ។



ការយំក្តី ការសោកក្តី ឬសេចក្តីខ្សឹកខ្សួលណាដទៃក្តី បុគ្គលមិនគប្បីធ្វើឡើយ ព្រោះកិច្ចមានយំសោកជាដើម មិនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ (ដែលទៅកាន់បរលោកនោះ) ក៏ឋិតនៅយ៉ាងនោះដដែល (ឥតបានដឹងឮឡើយ) ។ ចំណែកទក្ខិណាទាន ដែលបុគ្គលបានឲ្យហើយនេះឯង ជាទានដ៏តម្កល់ទុកទៅល្អហើយ ក្នុងព្រះសង្ឃ រមែងសម្រេចផលដើម្បីជាប្រយោជន៍ដល់ញាតិនោះ អស់កាលដ៏យូរអង្វែង តាមឋានៈគឺទីដែលគួរសម្រេចបាន ។

ក៏ញាតិធម៌នោះ មហាបពិត្របានសំដែងជាបែបយ៉ាងហើយ
ការបូជាដ៏ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ មហាបពិត្របាន
ធ្វើហើយ កំឡាំងកាយរបស់ភិក្ខុទាំងឡាយ មហាបពិត្របាន
ចំពេញហើយ បុណ្យដ៏ច្រើនមហាបពិត្រក៏បានសន្សំហើយ ។

ចប់ រឿងតិរោកុដ្ឌប្រេត ទី ៥ ។

## រឿងបញ្ចបុត្តខាទកប្រេត ទី ៦

(៦) (ព្រះថេរៈទាំងឡាយសួរថា) នាងជាស្រីអាក្រាត មានរូប មានសម្បុរអាក្រក់ មានក្លិនអាក្រក់ស្អុយ តែងបក់ចេញទៅ នាងមានរុយរោមរោមហើយ តើនាងជាស្រីអ្វី មកឋិតនៅក្នុងទីនេះ ។

បេតវត្ថុស្មឹ បឋមស្ស ឧរគវគ្គស្ស ឆដ្ឋមំ បញ្ចបុត្តខាទកប្បេតវត្ថុ

អហំ ភន្តេ បេតិម្ហិ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា ។
កាលេន បញ្ច បុត្តានិ សាយំ បញ្ច បុនាបរេ
វិជាយិត្វាន ខាទាមិ តេបិ ន ហោន្តិ មេ អលំ ។
បរិឌយ្ហតិ ធូមាយតិ ខុទាយ ហទយំ មម
បានីយំ ន លភេ បាតុំ បស្ស មំ ព្យសនំ គតន្តិ ។
កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បុត្តមំសានិ ខាទសីតិ ។
សបតី មេ គព្ភិនី អាសិ តស្សា បាបំ អចេតយឹ
សាហំ បទុដ្ឋមនសា អការឹ គព្ភបាតនំ ។
តស្សា ទ្វេមាសិកោ គព្ភោ លោហិតញ្ញេវ បគ្ឃរិ
តទស្សា មាតា កុបិតា មយ្ហំ ញាតី សមានយិ
សបថញ្ច មំ ការេសិ បរិភាសាបយិ ច មំ ។
សាហំ ឃោរញ្ច សបថំ មុសាភណំ អភាសិសំ
បុត្តមំសានិ ខាទាមិ សចេ តំ បកតំ(១) មយា ។

១ ឱ. សបថិញ្ច កតំ ។



សុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ

(ប្រេតស្រីតបថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្ដីទុក្ខ ជាយមលោកបេត្ត ស្លាប់អំពីមនុស្សលោកនេះហើយ បាននៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ គឺវេលាព្រឹក ខ្ញុំសម្រាលកូន៥នាក់ គឺវេលាល្ងាច សម្រាលកូន៥នាក់ទៀត រួចហើយខ្ញុំស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំក្ដៅក្រហាយហុយផ្សែង ព្រោះតែសេចក្ដីស្រេកឃ្លាន ខ្ញុំផឹកទឹកក៏មិនបាន លោកម្ចាស់ចូរមើលខ្ញុំ ដែលជាអ្នកដល់នូវសេចក្ដីវិនាសចុះ ។

(ព្រះថេរៈទាំងឡាយសួរថា) ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត តើដូចម្ដេច នាងទំពាស៊ីសាច់កូន តើព្រោះវិបាករបស់កម្មដូចម្ដេច ។

(ប្រេតស្រីតបថា) ស្រីរួមប្ដីរបស់ខ្ញុំ ជាស្រីមានគភ៌ ខ្ញុំបានគិតនូវអំពើដ៏អាក្រក់ដល់ស្រីរួមប្ដីនោះ ខ្ញុំនោះមានចិត្តប្រទូស្ត បានធ្វើនូវការញ៉ាំងគភ៌ឲ្យធ្លាក់ចុះ ។ គភ៌របស់ស្រីរួមប្ដីនោះ បានតែត្រឹម២ខែ ឈាមក៏ហូរចេញមក ឯមាតារបស់ស្រីរួមប្ដីនោះក៏ក្រេវក្រោធនឹងខ្ញុំ ហើយបានបបួលញាតិទាំងឡាយ ញ៉ាំងខ្ញុំឲ្យធ្វើសម្បថផង ឲ្យផ្ដាសាខ្ញុំផង ។ ខ្ញុំនោះ ក៏បានពោលនូវសម្បថដ៏ឃោរឃៅផង នូវពាក្យមុសាវាទផងថា បើខ្ញុំបានធ្វើអំពើអាក្រក់មែន សូមឲ្យខ្ញុំទំពាស៊ីនូវសាច់នៃកូន ។

តស្ស កម្មវិបាកេន [១] មុសាវាទស្ស ចូភយំ
បុត្តមំសានិ ខាទាមិ បុព្វលោហិតមក្ខិតាតិ [២] ។

បញ្ចបុត្តខាទិកប្បេតវត្ថុ ឆដ្ឋំ ។

# សត្តមំ សត្តបុត្តខាទិកប្បេតវត្ថុ

(៧) នគ្គា ទុព្វណ្ណរូបាសិ ទុគ្គន្ធា បូតិ វាយសិ
មក្ខិកាហិ បរិកិណ្ណា កា នុ ត្វំ ឥធ តិដ្ឋសីតិ ។
អហំ ភទន្តេ បេតិម្ហិ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកមិតោ គតា ។
កាលេន សត្តបុត្តានិ សាយំ សត្ត បុនាបរេ
វិជាយិត្វាន ខាទាមិ តេបិ ន ហោន្តិ មេ អលំ ។
បរិឌយ្ហតិ ធូមាយតិ ខុទាយ ហទយំ មម
និព្វុតឹ នាធិគច្ឆាមិ អគ្គិទឌ្ឍាវ អាតបេតិ [៣] ។

១ ម. កម្មស្ស វិបាកេ ។ ២ ម. មក្ខិតន្តិ ។ ៣ ម. អាតបេ ។



ដោយផលនៃកម្មនោះផង ដោយផលនៃមុសាវាទផង ទាំងពីរនេះ ខ្ញុំទើបបានទំពាស៊ីសាច់កូន ទួនប្រឡាក់ដោយខ្ទុះនិងឈាមដូច្នេះ ។

ចប់ រឿងបញ្ចបុត្តខាទិកប្រេត ទី៦ ។

# រឿងសត្តខាទិកប្រេត ទី៧

(៧) (ព្រះថេរៈទាំងឡាយសួរថា) នាងជាស្រីអាក្រាត មានរូបសម្បុរអាក្រក់ មានក្លិនអាក្រក់ ស្អុយ តែងបក់បញ្ចេញទៅ នាងមានហ្វូងរុយរោមរោមហើយ តើជាស្រីអ្វី បានជាមកឋិតនៅក្នុងទីនេះ ។

(ប្រេតស្រីតបថា) បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះ ហើយបានទៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ ក្នុងវេលាព្រឹក ខ្ញុំសម្រាលកូន ៧នាក់ ក្នុងវេលាល្ងាច សម្រាលកូន ៧ នាក់ទៀត ហើយទំពាស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំ ក្តៅក្រហាយ ហុយផ្សែង ព្រោះសេចក្តីស្រេកឃ្លាន ខ្ញុំមិនបានសេចក្តីស្ងប់ទុក្ខ តែងក្តៅក្រហាយ ដូចជាបុគ្គលត្រូវភ្លើងឆេះ ។

កិន្នុ កាយេន វាចាយ    មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន    បុត្តមំសានិ ខាទសិ ។
អហុ មយ្ហំ ទុវេ បុត្តា    ឧភោ សម្បត្តយោព្វនា
សាហំ បុត្តពលូបេតា    សាមិកំ អតិមញ្ញិស្សំ ។
តតោ មេ សាមិកោ កុទ្ធោ    សបត្តឹ មយ្ហមានយិ (១)
សា ច គព្ភំ អលភិត្ថ    តស្សា បាបំ អចេតយឹ
សាហំ បទុដ្ឋមនសា    អករឹ គព្ភបាតនំ ។
តស្សា តេមាសិកោ គព្ភោ    បុព្វលោហិតកោ បតិ
តទស្សា មាតា កុបិតា    មយ្ហំ ញាតី សមានយិ
សបថញ្ច មំ អការេសិ    បរិភាសាបយិ (២) ច មំ ។
សាហំ ឃោរញ្ច សបថំ    មុសាវាទំ អភាសិស្សំ
បុត្តមំសានិ ខាទាមិ    សចេ តំ បកតំ មយា
តស្ស កម្មវិបាកេន    មុសាវាទស្ស ចូភយំ
បុត្តមំសានិ ខាទាមិ    បុព្វលោហិតមក្ខិតា ។

សត្តបុត្តខាទកបេតវត្ថុ សត្តមំ

---

១ ម. សបត្តឹ មយ្ហមានយិ ។ ២ ម. បរិភាសាបយិ ។



(ព្រះថេរៈពោលសួរថា) អំពើអាក្រក់ដែលនាងធ្វើហើយដោយកាយ វាចា ចិត្ត ដូចម្តេចខ្លះ នាងទើបស៊ីសាច់កូនព្រោះផលកម្មអ្វី ។

(នាងប្រេតតបថា) ខ្ញុំមានកូន ២ នាក់ កូនទាំង ២ នាក់នោះពេញវ័យហើយ ខ្ញុំនោះអាស្រ័យកំឡាំងកូនទាំងនោះក៏មើលងាយប្តី ៖ តអំពីនោះមក ប្តីរបស់ខ្ញុំ ក្រេវក្រោធនឹងខ្ញុំ ដើម្បីបាននាំយកស្រីរួមប្តីដទៃទៀត ស្រីរួមប្តីបានកើតគភ៌ហើយ ខ្ញុំបានគិតខ្វល់នូវអំពើអាក្រក់ដល់ស្រីនោះ ខ្ញុំនោះមានចិត្តប្រទូស្ត បានធ្វើនូវការញុំាងគភ៌ឲ្យធ្លាក់ចុះ គភ៌នៃស្រីរួមប្តី បានតែ ៣ ខែ មានខ្ទុះនិងឈាមធ្លាក់ចុះ មាតានៃស្រីរួមប្តីនោះ ក្រេវក្រោធនឹងខ្ញុំ បានប្រជុំពួកញាតិមក ឲ្យខ្ញុំធ្វើសម្បថផង ឲ្យគេជេរប្រទេចខ្ញុំផង ។ ខ្ញុំនោះបានពោល នូវសម្បថដ៏គួរខ្លាចផង នូវពាក្យមុសាវាទផង ថាបើខ្ញុំ បានធ្វើអំពើអាក្រក់នេះហើយ សូមឲ្យខ្ញុំស៊ីសាច់កូន ដោយផលកម្មនោះផង ដោយផលមុសាវាទផង ទាំង ២ នេះ ទើបខ្ញុំស៊ីសាច់កូន ប្រឡាក់ដោយខ្ទុះនិងឈាមដូច្នេះ ។

ចប់ រឿងសត្តបុត្តខាទកប្រេត ទី ៧ ។

# អដ្ឋមំ គោណបេតវត្ថុំ

(៨) កិន្នុ ឧម្មត្តរូបោវ  លាយិត្វា ហរិតំ តិណំ
ខាទ ខាទាតិ លបសិ  គតសត្តំ ជរគ្គវំ ។
ន ហិ អន្នេន បានេន  មតោ គោណោ សមុដ្ឋហេ
ត្វំបិ[១] ពាលោ ច ទុម្មេធោ  យថា តញ្ញោវ ទុម្មតិ ។
ឥមេ បាទា ឥទំ សីសំ  អយំ កាយោ សវាលធិ
នេត្តា តថេវ តិដ្ឋន្តិ  អយំ គោណោ សមុដ្ឋហេ
នាយ្យកស្ស ហត្ថបាទា  កាយោ សីសញ្ច ទិស្សតិ
រុទំ មត្តិកថូបស្មឹ  ននុ ត្វញ្ញេវ ទុម្មតិ ។
អាទិត្តំ វត មំ សន្តំ  ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ[២]  សព្វំ និព្វាបយេ ទរំ ។
អព្វូឡ្ហំ វត មេ សល្លំ  សោកំ ហទយនិស្សិតំ
យោ មេ សោកបរេតស្ស  បិតុសោកំ អបានុទិ
ស្វាហំ អព្វូឡ្ហសល្លោស្មិ  សីតិភូតោស្មិ និព្វុតោ

១ ឱ. ម. ត្វំសិ ។ ២ ឱ. ម. ឱសិញ្ចិ ។



# រឿងគោណប្រេត ទី ៨

(៨) (បិតាសួរថា) អ្នកមានសភាពជាបុគ្គលឆ្កួតទេដឹង បានជាអ្នកច្រូតស្មៅខ្ចី យកមកនិយាយនឹងគោចាស់ ដែលផុតសត្វប្រាសចាកជីវិតថា ចូរស៊ីចុះៗ ផឹកចុះ ។ ធម្មតាគោដែលស្លាប់ហើយមិនដែលក្រោកឡើងបាន ដោយស្មៅនឹងទឹកទេ អ្នកជាបុគ្គលពាលអប្បបញ្ញា ប្រហែលនឹងបុគ្គលល្ងង់ឯទៀតៗដែរ ។

(កូនតបថា) នេះជាជើង នេះជាក្បាល នេះជាខ្លួនព្រមទាំងកន្ទុយ នេះជាភ្នែករបស់គោ ឋិតនៅគង់ដូចដែល គោនេះគប្បីក្រោកឡើងបាន ដៃជើងខ្លួននឹងក្បាលរបស់ជីតា ប្រាកដ ក្រែងអ្នកដែលយំលើគំនរដីនោះ ជាបុគ្គលល្ងង់ ។

(បិតាពោលថា) អ្នកស្រោចស្រប់យើងដែលក្តៅនេះហើយ ញុំាំងសេចក្តីក្តៅក្រហាយទាំងពួងឲ្យរម្ងាប់ ដូចបុគ្គលយកទឹកស្រោចលត់ភ្លើងដែលឆេះនាំងខ្លាញ់ សរគឺសេចក្តីសោក ដែលអាស្រ័យនៅក្នុងហឫទ័យយើង អ្នកបានដកចោលហើយ កាលយើងត្រូវសេចក្តីសោកចំពោះបិតា គ្របសង្កត់ អ្នកដែលបន្ទោបង់សេចក្តីសោកបាន យើងនោះ ឈ្មោះថា មានសរគឺសេចក្តីសោក ដែលអ្នកដកចោលហើយ មានសេចក្តីត្រជាក់កើតហើយ មានទុក្ខរលត់ហើយ

ន សោចាមិ ន រោទាមិ តវ[១] សុត្វាន មាណវ
ឯវំ ករោន្តិ សប្បញ្ញា យេ ហោន្តិ អនុកម្បកា
វិនិវត្តយន្តិ[២] សោកម្ហា សុជាតោ បិតរំ យថាតិ ។

គោណបេតវត្ថុ អដ្ឋមំ ។

## នវមំ មហាបេសការបេតវត្ថុ

(៩) គូថញ្ច មុត្តំ រុហិរញ្ច[៣] បុព្វំ
បរិភុញ្ជតិ កិស្ស អយំ វិបាកោ
អយំ នុ[៤] កិំ កម្មមកាសិ នារី
យា[៥] សព្វទា លោហិតបុព្វភក្ខា
នវានិ វត្ថានិ សុភានិ ចេវ
មុទូនិ សុទ្ធានិ ច លោមសានិ
ទិន្នានិមិស្សា កិដកា ភវន្តិ
អយំ នុ កិំ កម្មមកាសិ នារីតិ ។
ភរិយា មមេសា អហុ ភទន្តេ
អទាយិកា មច្ឆរិនី កទរិយា
សា មំ ទទន្តំ សមណព្រាហ្មណានំ
អក្កោសតិ បរិភាសតិ ច

១ ម. តវ ។ ២ ម. វិនិវត្តយន្តិ ។ ម. វិនិវត្តយិ ។ ៣ ម. ម. រុហិរញ្ច ។
៤ ម. នុក ។ ៥ ម. សា ។



ម្នាលមាណព យើងលែងសោយសោក លែងយំហើយ ព្រោះបានស្តាប់ពាក្យរបស់អ្នក ជនទាំងឡាយណា ប្រកបដោយបញ្ញា ជាអ្នកអនុគ្រោះ ជនទាំងនោះ តែងធ្វើយ៉ាងនេះ ដូចជាសុជាតមាណព បានញុំាងបិតាឲ្យត្រឡប់ចាកសេចក្តីសោកដូច្នោះ ។

ចប់ រឿងគោណប្រេត ទី ៨ ។

## រឿងមហាបេសការប្រេត ទី ៩

(៩) (ភិក្ខុសួរថា) នារីណា មានខ្ទុះនិងឈាមជាអាហារ សព្វកាល នារីនេះតែងបរិភោគលាមកផង មូត្រផង ឈាមផង ខ្ទុះផង នេះជាផលនៃកម្មអ្វី នារីនេះ បានធ្វើអំពើដូចម្តេចហ្ន៎ សំពត់ទាំងឡាយថ្មីផង ល្អផង មានសាច់ទន់ផង បរិសុទ្ធផង ប្រកបដោយរោមផង គេបានឲ្យដល់នារីនេះហើយ ក៏ប្រែក្លាយដូចជាលោហៈទៅវិញ ចុះនារីនេះបានធ្វើអំពើដូចម្តេច ។ (ប្រេតប្រាប់ថា) បពិត្រលោកដ៏ចំរើន នារីនេះ ជាភរិយារបស់ខ្ញុំ ជាស្រីមិនដែលឲ្យវត្ថុអ្វី ដល់អ្នកណាមួយឡើយ ជាស្រីកំណាញ់ស្វិតស្វាញ តែងជេរប្រទេចផ្តាសាខ្ញុំ ដែលកំពុងឲ្យទានដល់សមណព្រាហ្មណ៍ទាំងឡាយ ជា

ភុញ្ជ មុត្តំ រុធិរញ្ច បុព្វំ
បរិកុញ្ច តំ អសុចិ សព្វកាលំ ។
ឯតំ តេ បរលោកស្មឹ ហោតុ
វត្ថា ច តេ កណ្ឌកា ភវន្តុ[១]
ឯតាទិសំ ទុក្ករំ ចរិត្វា
ឥធាគតា ចិររត្តាយ ខាទតីតិ ។

មហាបេសការបេតវត្ថុ នវមំ ។

## ទសមំ ខល្លាដិយបេតវត្ថុ

(១០) កា នុ អន្តោវិមានស្មឹ តិដ្ឋន្តី នូបនិក្ខមិ
ឧបនិក្ខមស្សុ ភទ្ទេ[២] បស្សាម[៣] តំ ពហិទ្ធិកា[៤] ។
អដ្ដីយាមិ ហរាយាមិ នគ្គា និក្ខមិតុំ ពហិ
កេសេហម្ហិ បដិច្ឆន្នា បុញ្ញំ មេ អប្បកំ កតន្តិ ។
ហន្ទុត្តរីយំ ទទាមិ តេ ឥទំ ទុស្សំ និវាសយ

---

១ ឱ. តិណិកា ភវន្តុ ។ ម. កិដិកសមា ភវន្តុ ។ ២ ឱ. ឧក្កុដ្ឋបេ ចុត្តិ ឥទ្ធំ ។ ៣ ឱ. ម. បស្សាម ។ ៤ ម. ពហិទ្ធិតា



អ្នកចូរស៊ីលាមកផង មូត្រផង ឈាមផង ខ្ទុះផង ដែលជារបស់មិនស្អាត សព្វកាលចុះ ផលនេះចូរកើតមានដល់អ្នកក្នុងបរលោកចុះ សំពត់មានផែនដូចលោហៈ ចូរមានដល់អ្នកចុះ លុះនារីនោះ ប្រព្រឹត្តអំពើទុច្ចរិតក្រៃលែងដូច្នេះហើយ មកកាន់ទីនេះ ទើបបានទទួលផល (ជាក្រហល់ក្រហាយ) អស់កាលដ៏យូរអង្វែង ។

ចប់ រឿងមហាបេសការប្រេត ទី ៩ ។

## រឿងខល្លាដប្រេត ទី ១០

(១០) (ឧបាសកពោលសួរថា) នាងជាស្រីអ្វីហ្ន៎ ឋិតនៅខាងក្នុងវិមាន មិនចេញអំពីវិមាន ម្នាលនាងដ៏ចំរើន ចូរនាងចេញមក យើងនឹងឃើញនាង ដែលមានឫទ្ធិច្រើន ។

(នាងប្រេតតបថា) ខ្ញុំជាស្រីអាក្រាត មានសេចក្តីអៀនខ្មាស ដល់នូវសេចក្តីខ្មាសលំបាក មិនអាចចេញមក ខាងក្រៅបានទេ ខ្ញុំជាស្រី មានសរីរៈបិទបាំងដោយសក់ទាំងឡាយ (ព្រោះថា) កុសលកម្ម មានប្រមាណតិច ខ្ញុំបានធ្វើមកហើយ ។

(ឧបាសកពោលថា) បើដូច្នោះ យើងនឹងឲ្យសំពត់សាដក សម្រាប់ដណ្តប់ ដល់នាង ចូរនាងស្លៀកសំពត់សាដកនេះចុះ

ឥមំ ទុស្សំ និវាសេត្វា   ឯហិ[1] និក្ខម សោភណេ
ឧបនិក្ខមស្សុ ភទ្ទេ   បស្សាមិ តំ ពហិដ្ឋិតន្តិ ។
ហត្ថេន ហត្ថេ តេ ទិន្នំ   ន មយ្ហំ ឧបកប្បតិ
ឯសេត្ថុបាសកោ សទ្ធោ   សម្មាសម្ពុទ្ធសាវកោ
ឯតំ អច្ឆាទយិត្វាន   មម ទក្ខិណមាទិស
តថាហំ សុខិតា ហេស្សំ   សព្វកាមសមិទ្ធិនី ។
តញ្ច តេ ន្ហាបយិត្វាន   វិលិម្បេត្វាន វាណិជា
វត្ថេហច្ឆាទយិត្វាន   តស្សា ទក្ខិណមាទិសុំ
សមនន្តរានុទ្ទិដ្ឋេ[2]   វិបាកោ ឧទបជ្ជថ
ភោជនច្ឆាទនបានីយំ   ទក្ខិណាយ ឥទំ ផលំ ។
តតោ សុទ្ធា សុចិវសនា   កាសិកុត្តមធារិនី
ហសន្តី វិមានា និក្ខមិ   ទក្ខិណាយ ឥទំ ផលន្តិ ។
សុចិត្តរូបំ រុចិរំ   វិមានំ តេ ច កាសតិ[3]
ទេវតេ បុច្ឆិតាចិក្ខ   កិស្ស កម្មស្សិទំ ផលន្តិ ។

---

១ ម. ឯហិ ។ ២ ម. សមនន្តរានុទ្ទិដ្ឋេ ។ ៣ ម. បភាសតិ ។





ម្នាលនាងមានភក្ត្រដ៏ល្អ លុះនាងស្លៀកពាក់សំពត់សាដកនេះរួចហើយ ចូរចេញមកខាងក្រៅ ម្នាលនាងដ៏ចំរើន នាងចូរចេញមក យើងនឹងឃើញនាង ដែលឋិតនៅខាងក្រៅ ។

(នាងប្រេតតបថា) ទានដែលអ្នកឲ្យផ្ទាល់ដៃ មិនបានសម្រេចដល់ខ្ញុំទេ គឺបុរសនេះជាឧបាសក អ្នកមានសទ្ធា ជាសាវ័កនៃព្រះសម្មាសម្ពុទ្ធ អ្នកចូរញុំាងឧបាសកនេះឲ្យស្លៀកពាក់ ហើយឧទ្ទិសទក្ខិណាទានដល់ខ្ញុំ ទើបខ្ញុំនឹងបានសេចក្ដីសុខ សម្រេចនូវសេចក្ដីប្រាថ្នាទាំងពួង ។

ពួកពាណិជទាំងនោះ ក៏ឲ្យឧបាសកនោះងូតទឹក ប្រឡាប់ពាក់តែងដោយគ្រឿងក្រអូប ឲ្យស្លៀកពាក់សំពត់ទាំងឡាយរួចហើយ ទើបឧទ្ទិសទក្ខិណាទានដល់ប្រេតនោះថា ផលនេះកើតឡើង ក្នុងលំដាប់ដែលយើងឧទ្ទិសហើយ ភោជនាហារនិងសំពត់ស្លៀកពាក់និងទឹក ក៏កើតឡើង នេះជាផលនៃទក្ខិណាទាន ។

លំដាប់នោះ ស្រីប្រេតនោះជាស្រីបរិសុទ្ធ មានសំពត់ស្លៀកស្អាត ជាស្រីទ្រទ្រង់សំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសី ហើយក៏សើចចេញអំពីវិមានមក នេះជាផលនៃទក្ខិណាទាន ។

(ពួកពាណិជសួរថា) ម្នាលទេវតា វិមានរបស់នាង វិចិត្រដោយរូបល្អ ស្អាតរុងរឿងក្រៃ នាងដែលយើងសួរហើយ ចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ភិក្ខុនោ ចរមានស្ស ទោណិនិម្មជ្ជនី អហំ[១]
អទាសឹ ឧជុភូតស្ស វិប្បសន្នេន ចេតសា
តស្ស កម្មស្ស កុសលស្ស វិបាកំ ទីឃមន្តរំ
អនុភោមិ វិមានស្មឹ តញ្ចទានិ បរិត្តកំ ។
ឧទ្ធំ ចតូហិ មាសេហិ កាលកិរិយា ភវិស្សតិ
ឯកន្តំ កដុកំ ឃោរំ និរយំ បបតិស្សហំ
ចតុក្កណ្ណំ ចតុទ្វារំ វិភត្តំ ភាគសោ មិតំ
អយោបាការបរិយន្តំ អយសា[២] បដិកុជ្ជិតំ ។
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទា
តត្ថាហំ ទីឃមទ្ធានំ ទុក្ខំ វេទិស្សំ វេទនំ
ផលញ្ច បាបកម្មស្ស តស្មា សោចាមិទំ ភុសន្តិ[៣] ។

ខល្លាដិយបេតវត្ថុ ទសមំ ។

## ឯកាទសមំ នាគបេតវត្ថុ

(១១) បុរតោ ច សេតេន បលេតិ ហត្ថិនា
មជ្ឈេ បន អស្សតរីរថេន

---

១ ម. ទោណិនិម្មុជ្ជនំ អហំ ។ ម. ទោណី និម្មជ្ជនំ អហំ ។ អដ្ឋកថាយំ ទោណិ- និម្មជ្ជនិំ ណាហោ ទិស្សតិ ។ ២ ម. អយន្តំ អសា ។ ៣ ម. សោចាមហំ ភុសន្តិ ។



(ភរិយាប្រេតនោះថា) ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនម្សៅល្អិតប្រមាណ ១ តោក ដល់ភិក្ខុដែលកំពុងត្រាច់ទៅ មានចិត្តត្រង់ ខ្ញុំក៏បានទទួលវិបាកនៃកុសលកម្មនោះក្នុងវិមាន អស់មួយរយៈកាលដ៏យូរ តែឥឡូវនេះ កុសលនោះតិចពេកណាស់ ។ កាលកិរិយា នឹងមានក្នុងកាលលើសពី ៤ ខែ ខ្ញុំនឹងធ្លាក់ទៅកាន់នរកដ៏ខ្លាំងក្លា ខ្មោចផ្សា ដោយពិត នរកមានជ្រុង ៤ មានទ្វារ ៤ ចែកដោយចំណែក ដែលចែកហើយ មានកំផែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផែនដីនៃមហានរកនោះ សុទ្ធតែដែក មានភ្លើងឆេះប្រោលរន្ទាល ផ្សាយទៅបានមួយរយយោជន៍ ដោយជុំវិញ តាំងនៅសព្វកាល ខ្ញុំនឹងសោយទុក្ខវេទនាអស់កាលជាអង្វែងក្នុងនរកនោះ ព្រោះហេតុនោះ ខ្ញុំទើបទទួលផលនៃបាបកម្ម ដែលក្តៅក្រហាយក្រៃពេកណាស់ ។

ចប់ រឿងខល្លាដិយប្រេត ទី ១០ ។

## រឿងនាគប្រេត ទី ១១ ។

(១១) (សាមណេរសួរថា) អ្នកទៅមុខគេបររដំរីស
ឯអ្នកទៅកណ្ដាលគេ ជិះរថ ទឹមសេះកាត់អស្សតរ

បច្ឆា ច កញ្ញា សិវិកាយំ និយ្យាតិ
ឱភាសយន្តី ទស សព្វតោ ទិសា ។
តុម្ហេ បន មុគ្គរហត្ថបាណិនោ
រុទម្មុខា ភិន្នបភិន្នគត្តា[1]
មនុស្សភូតា កិមកត្ថ បាបំ
យេនញ្ញមញ្ញស្ស បិវាថ[2] លោហិតំ (តិ) ។
បុរតោ វ យោ គច្ឆតិ កុញ្ជរេន
សេតេន នាគេន ចតុក្កមេន
អម្ហាកំ បុត្តោ អហុ សោ បជេដ្ឋកោ[3]
ទានានិ ទត្វាន សុខី បមោទតិ ។
យោ សោ មជ្ឈេ អស្សតរីរថេន
ចតុព្ភិ យុត្តេន សុវគ្គិតេន
អម្ហាកំ បុត្តោ អហុ មជ្ឈិមោ សោ
អមច្ឆរី ទានបតិ វិរោចតិ ។
យា សា បច្ឆា សិវិកាយ និយ្យាតិ
នារី[4] សបញ្ញា មិគមន្ទលោចនា

១ ម. ជិន្នបភិន្នគត្តា ។ ២ ម. បិវាម ។ ៣ ឥ. សោ វជេដ្ឋកោ ។ ៤ ម. សោរ ... ។ ៥ ឧ. ការី ។



ចំណែកកញ្ញាមកខាងក្រោយគេ ទៅដោយវិកាស្ពានរុងរឿង

សព្វទិសទាំង ១០ ។ ឯអ្នកទាំងឡាយ (ដែលមកក្រោយគេបង្អស់)

មានដៃកាន់ដំបង មានមុខដោតដោយទឹកភ្នែកមានខ្លួនបែក

ធ្លាយ ហើយផឹកនូវរុធិរឈាម នៃគ្នានឹងគ្នាជាអាហារ អ្នក

ទាំងឡាយកាលកើតជាមនុស្ស តើបានធ្វើអំពើដូចម្ដេចខ្លះ ។

(នាងប្រេតតបថា) បុគ្គលណាទៅដោយដំរីសដ៏ប្រសើរមាន

ជើង៤មុខគេ បុគ្គលនោះជាបុត្រច្បងរបស់ខ្ញុំ បានឲ្យទានហើយ

ក៏បានដល់សេចក្ដីសុខ ។ បុគ្គលណាទៅដោយរថទឹមសេះ៤

មានគ្រឿងល្អនៅកណ្ដាល បុគ្គលនោះជាបុត្រកណ្ដាលរបស់

ខ្ញុំ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទានរុងរឿង ។ នារីណា

ប្រកបដោយបញ្ញា មានភ្នែកដូចម្រឹគទៅដោយវិការក្រោយគេ

បច្ឆាតំ ធីតា អហុ សា កនិដ្ឋា(១)
ភាគឌ្ឍភាគេន សុខំ បមោទតិ ។
ឯតេ ច ទានានិ អទំសុ បុព្វេ
បសន្នចិត្តា សមណព្រាហ្មណានំ
មយំ បន មច្ឆរិនោ អហុម្ហា
បរិភាសកា សមណព្រាហ្មណានំ
ឯតេ ច ទត្វា បរិចារយន្តិ
មយញ្ច សុស្សាម នឡោវ ឆិន្នោ(២)
កឹ តុម្ហាកំ ភោជនំ កឹ សយនំ(៣)
កថញ្ច(៤) យាបេថ សុបាបធម្មិនោ
បហូតភោគេសុ អនប្បកេសុ
សុខំ វិរាធាយ ទុក្ខជ្ជ បត្តា ។
អញ្ញមញ្ញំ វធិត្វាន បិវាម បុព្វលោហិតំ
ពហុំ បិត្វា ន ធាតា ហោម នច្ឆាទិម្ហសេ(៥) មយំ ។

១ ម. កនិដ្ឋិកា ។ ២ ម. ឆិន្នោតិ ។ ៣ ឱ. កិស្សយនំ ។ ៤ ឱ. កថំសុ ។
៥ ម. នច្ឆាទិម្ហសេ ។



នារីនោះ ជាធីតាពៅបង្អស់របស់ខ្ញុំ ជាអ្នកមានសេចក្តីសុខ ក្នុងត្រកូល តាមចំណែកផលបានពាក់កណ្តាល ។ អំពីជាតិមុន ជនទាំងនុ៎ះជាអ្នកមានចិត្តជ្រះថ្លា បានឲ្យទានដល់ពួកសមណៈនិងព្រាហ្មណ៍ ចំណែកយើងខ្ញុំទាំងឡាយវិញ ជាអ្នកកំណាញ់ ជេរប្រទេចផ្តាសាសមណព្រាហ្មណ៍ទាំងឡាយ ឯជនទាំងនេះ លុះឲ្យហើយទើបគេបម្រើ (ដោយកាមគុណ) ចំណែកពួកយើង ទើបស្រៀមស្គម ដូចដើមបបុស ដែលហាលថ្ងៃថ្ងា ។

(សាមណេរសួរថា) ភោជនាហារ របស់អ្នកទាំងឡាយដូចម្តេចទៅ ទីដេក របស់អ្នកដូចម្តេចទៅ ចុះអ្នកទាំងឡាយមានបាបធម៌ដ៏ក្រៃលែង ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដូចម្តេច ភោគធនាហារទាំងឡាយដ៏ច្រើន មិនមែនជារបស់តិចតួចឡើយ ឥឡូវនេះ អ្នកដល់នូវសេចក្តីទុក្ខ ព្រោះប្រាសចាកសេចក្តីសុខ ។

(នាងប្រេតតបថា) យើងខ្ញុំទាំងឡាយ សម្លាប់នូវគ្នានឹងគ្នា ហើយក្រេបផឹកនូវខ្ទុះនិងឈាម ទុកជាផឹកច្រើន ក៏មិនបាត់ស្រេកឃ្លាន យើងខ្ញុំទាំងឡាយ ក៏នៅតែស្រេកឃ្លានដដែល ។

ជេតវនេ វិហរន្តោ ... ឯកាទសមំ គាថាវត្ថុ

ឥតោ ចុតា បរិតាបយន្តិ
អនាថិកា បេត្វា[1] យមស្ស ឋាយិនោ
យេ តេ វិត្វា អធិគម្ម ភោគេ
ន ភុញ្ជរេ នាបិ ករោន្តិ បុញ្ញំ ។
តេ ខុប្បិបាសូបគតា បរត្ថ
បច្ឆា[2] ចិរំ ឈាយិរេ[3] ទយ្ហមានា
កម្មានិ កត្វាន ទុក្ខុទ្រយានិ[4]
អនុភោន្តិ ទុក្ខំ កដុកប្ផលានិ ។
ឥត្តរំ ហិ ធនធញ្ញំ ឥត្តរំ ឥធ ជីវិតំ
ឥត្តរំ ឥត្តរតោ ញត្វា ទីបំ កយិរាថ បណ្ឌិតោ ។
យេ តេ ឯវំ បជានន្តិ នរា ធម្មស្ស កោវិទា
តេ ទានេ នប្បមជ្ជន្តិ សុត្វា អរហតំ វចោ ។

គាថាវត្ថុ ឯកាទសមំ ។

---

១ ម. អនាថិកា ឧទ្ធិតា ។ ២ ម. បេតា ។ ៣ ម. ឈាយរេ ។ ៤ ម. ទុក្ខុទ្រិយានិ ។ ម. ទុក្ខុទ្រយានិ ។





ជនទាំងឡាយណា ជាអ្នកមិនកែកាយឡើយទេ ជនទាំងនោះ លុះលោកនេះទៅហើយ រមែងទៅកើត ក្នុងឋានយមលោក តែងខ្សឹកខ្សួល ដូចយើងទាំងឡាយ ជនទាំងឡាយណា បានទ្រព្យសម្បត្តិទាំងឡាយហើយ តែជាអ្នកកំណាញ់ មិនបរិភោគផង មិនធ្វើបុណ្យផង ។ ជនទាំងនោះ ជាអ្នកមានសេចក្ដីប្រែកឃ្លានស្រេកទឹក ក្នុងលោកខាងមុខ ក្នុងកាលជាខាងក្រោយមក ជនទាំងនោះ រមែងនេះពេលកាលក្ដៅក្រហាយ អស់កាលជាយូរអង្វែង ព្រោះបានធ្វើនូវកម្មមានផលជាទុក្ខ តែងទទួលផលជាទុក្ខ មានផលក្ដៅក្រហាយ ។ ទ្រព្យសម្បត្តិជារបស់មិនទៀង ជីវិតក្នុងលោកនេះ ជារបស់មិនទៀង បណ្ឌិតដឹងនូវរបស់មិនទៀង កាមសភាពជារបស់មិនទៀងហើយ គប្បីធ្វើនូវទានផង ។ ជនទាំងឡាយណា អ្នកណាស់ក្នុងព្រះសទ្ធម្ម ចិន្តប្រាសយហើយនេះ ជនទាំងនោះឈ្មោះថាជាអ្នកមិនធ្លុះប្រហែសក្នុងទាន ព្រោះបានស្ដាប់ពាក្យនៃព្រះអរហន្តទាំងឡាយ ។

ចប់រឿងគាថាប្រែ ទី ១១ ។

## ទ្វាទសមំ ឧរគបេតវត្ថុ

(១២) ឧរគោវ តចំ ជិណ្ណំ ហិត្វា គច្ឆតិ សន្តុំ
ឯវំ សរីរេ និព្ភោគេ បេតេ កាលកតេ សតិ
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ(១) ន សោចាមិ គតោ សោ តស្ស យា គតិ ។
អនព្ភិតោ តតោ អាគា នានុញ្ញាតោ ឥតោ គតោ
យថាគតោ តថា គតោ តត្ថ កា បរិទេវនា
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មា ឯតំ ន រោទាមិ គតោ សោ តស្ស យា គតិ ។
សចេ រោទេ កិសា អស្សំ តត្ថ មេ កឹ ផលំ សិយា
ញាតិមិត្តសុហជ្ជានំ ភិយ្យោ នោ អរតី សិយា
ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ

១ ម, ឯវំ ។



## រឿងឧរគប្រេត ទី ១២

(៥៦) (ពោធិសត្វនិយាយថា) ពស់តែងសកសំណកចាស់របស់ខ្លួនចោលហើយលូនទៅ យ៉ាងណាមិញ (សត្វ) កាលបើសរីរៈប្រើការមិនកើតហើយ ធ្វើមរណកាលទៅកាន់បរលោក ក៏យ៉ាងនោះ (ឯសរីរៈដែលនៅសល់ខាងក្រោយនោះ) កាលគេដុត ក៏មិនបានដឹង (ធ្វើម្តេចនឹងដឹង) នូវសេចក្តីខ្សឹកខ្សួល របស់ញាតិទាំងឡាយបាន ហេតុនោះ ខ្ញុំមិនសោកស្តាយសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

(មាតានិយាយថា) បុត្ររបស់ខ្ញុំនេះ ខ្ញុំមិនបានហៅគេមកអំពីលោកនោះ ខ្ញុំមិនបានអនុញ្ញាត គេក៏ទៅអំពីមនុស្សលោកនេះ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការទួញយំធ្វើអ្វី ព្រោះកាយនៅនោះ(ឯសរីរៈដែលនៅសល់ខាងក្រោយនោះ)គេដុតក៏មិនបានដឹង (ធ្វើម្តេចនឹងដឹង) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំទួញនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

(ប្អូនស្រីនិយាយថា) បើខ្ញុំយំ ខ្ញុំនឹងទៅជាស្គម ក្នុងការយំនោះ នឹងគប្បីមានផលដូចម្តេចដល់ខ្ញុំ សេចក្តីមិនត្រេកអរដ៏លើសលុប នឹងគប្បីមានដល់ពួកញាតិមិត្ត នឹងអ្នកមានចិត្តល្អ របស់យើងទាំងឡាយ (ឯសរីរៈដែលសល់នៅខាងក្រោយនោះ) កាលគេដុតក៏មិនបានដឹង(ធ្វើម្តេចនឹងដឹង) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ

តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

យថាបិ ទារកោ ចន្ទំ គច្ឆន្តំ អនុរោទតិ

ឯវំ សម្បទមេវេតំ យោ បេតំ អនុសោចតិ

ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ

តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតិ ។

យថាបិ ព្រហ្មេ ឧទកុម្ភោ ភិន្នោ អប្បដិសន្ធិយោ

ឯវំ សម្បទមេវេតំ យោ បេតំ អនុសោចតិ

ឌយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ

តស្មា ឯតំ ន សោចាមិ គតោ សោ តស្ស យា គតីតិ ។

ឧរគបេតវត្ថុ ទ្វាទសមំ ។



ហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

(ភរិយានិយាយថា) បុគ្គលណាសោកស្ដាយ នូវបុគ្គលដែលធ្វើមរណកាលទៅកាន់បរលោកហើយ បុគ្គលនោះប្រៀបដូចជាទារកយំទារនូវព្រះចន្ទ្រដែលកំពុងចរទៅ (ឯសរីរៈដែលសល់នៅខាងអាយនោះ) កាលគេដុតក៏មិនបានដឹង (ធ្វើម្ដេចនឹងដឹង) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

(កូនស្រីនិយាយថា) បពិត្រព្រាហ្មណ៍ ក្អមទឹកដែលបែកហើយតភ្ជាប់វិញមិនបាន យ៉ាងណា សរីរៈអ្នកស្លាប់នេះក៏យ៉ាងនោះដែរ បុគ្គលណាសោកស្ដាយនូវបុគ្គលដែលទៅកាន់បរលោកហើយ (បុគ្គលនោះក៏ដូចជាមនុស្សសោកស្ដាយនូវក្អមទឹកដែលបែកហើយ) (ឯសរីរៈដែលសល់នៅខាងអាយនោះ) កាលគេដុត ក៏មិនបានដឹង (ធ្វើម្ដេចនឹងដឹង) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

ចប់រឿងឧរគប្រេត ទី១២ ។

## ឧទ្ទានំ

ខេត្តូបមា សូករា បូតិ

បិដ្ឋធីតលិកំ តិរោកុឌ្ឌំ

បុត្តខាទិកា គោណាកូដំ

មហាបេសំ ណាគោ ឧរគេនសា

តេ វគ្គោ វគ្គោ បឋមេ ឧទ្ទានំ(១) ។

ឧរគវគ្គោ បឋមោ ។

---

១ ម. ខេត្តំ ច សូករំ បូតិ វិដ្ឋាបិ តិរោកុឌ្ឌំ បញ្ចបុត្តំ សត្តបុត្តំ ច គោណបេសការកញ្ញ តថា ខល្លាដិយំ នាគំ ទ្វេ ចសំ ឧរគញ្ចេវាតិ ទិស្សន្តិ ។





## ឧទ្ទាន

រឿងខេត្តូបមាប្រេត (ព្រះអរហន្តប្រៀបដូចស្រែ) ១ រឿង(សូករប្រេត) ប្រេតមានសម្បុរកាយល្អ ១ ជា ២ លើក រឿង(បូតិមុខប្រេត) ១ រឿងបិដ្ឋធីតលិកប្រេត ១ រឿងតិរោកុឌ្ឌប្រេត ១ រឿងបុត្តខាទិកប្រេត (ស្រីប្រេតស៊ីកូនឯង) ២ លើក រឿងគោណប្រេត ១ រឿងមហាបេសការប្រេត ស៊ីខ្ទុះឈាម ១ រឿងខល្លាដប្រេតនៅក្នុងនាវា ១ រឿងនាគប្រេត ១ រឿងឧរគប្រេត ១ ទាំងនេះ ក្នុងវគ្គជាបឋម មានរឿង ១២ យ៉ាងនេះឯង ។

ចប់ឧរគវគ្គ ទី ១ ។

# ទុតិយោ ឧព្វរីវគ្គោ

## បឋមំ សំសារមោចកបេតិវត្ថុ

(១៣) នគ្គា ទុព្វណ្ណរូបាសិ កិសា ធមនិសន្ថតា
ឧប្ផាសុឡិកេ[1] កិសិកេ កា នុ ត្វំ ឥធ តិដ្ឋសីតិ ។
អហំ ភទន្តេ បេតីម្ហិ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតាតិ ។
កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បេតលោកំ ឥតោ គតាតិ ។

អនុកម្បកា មយ្ហំ នាហេសុំ ភន្តេ
បិតា មាតា ច អថ វាបិ ញាតកា
យេ មំ និយោជេយ្យុំ ទទាហិ ទានំ
បសន្នចិត្តា សមណព្រាហ្មណានំ ។
ឥតោ អហំ វស្សសតានិ បញ្ច
យំ ឯវរូបា វិចរាមិ នគ្គា
ខុទាយ តណ្ហាយ ច ខជ្ជមានា
បាបស្ស កម្មស្ស ផលំ មមេទំ ។

---

១ ម. ឧប្បាសុឡិកេ ។



# ឧព្វរីវគ្គ ទី ២

## រឿងសំសារមោចកប្រេត ទី ១

(១៣) (ព្រះសារីបុត្តសួរថា) នាងស្រីស្គម មានខ្លួនជំរិតតាម នាងជាស្រីអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាម ដោយសរសៃ នាងជាអ្វី មកឈរនៅទីនេះ ។

(នាងប្រេតតបថា) បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំជាស្រីប្រេតដល់នូវសេចក្ដីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ។

ទុច្ចរិតអាក្រក់ ដែលនាងបានធ្វើ ដោយកាយ វាចា ចិត្ត តើដូចម្ដេច នាងទៅកាន់បេតលោក អំពីមនុស្សលោកនេះ ព្រោះវិបាកនៃកម្មដូចម្ដេច ។

បពិត្រលោកដ៏ចំរើន បិតាមាតា ឬពួកញាតិ ជាអ្នកអនុគ្រោះ
ដល់ខ្ញុំ គប្បីដឹកនាំខ្ញុំថា នាងចូរមានចិត្តជ្រះថ្លាឲ្យទានដល់
ពួកសមណព្រាហ្មណ៍ (ដូច្នេះ) ពុំមានឡើយ ។ ខ្ញុំទើបបាន
ជាស្រីអាក្រាតមានសភាពយ៉ាងនេះ តែងត្រាច់ទៅអស់ ៥០០
ឆ្នាំ ចាប់ដើមអំពីឆ្នាំនេះទៅ ទំពាស៊ីដោយសេចក្ដីស្រេក
ឃ្លានផង ដោយចំណង់ផង នេះជាផលនៃបាបកម្មរបស់ខ្ញុំ ។

ទទាមិ តេ អយ្យ បសន្នចិត្តា
អនុកម្ប មំ វីរ[1] មហានុភាវ
ទត្វា ច មេ អាទិស យំ ហិ កិញ្ចិ
មោចេហិ មំ ទុគ្គតិយា ភទន្តេ ។

សាធូតិ សោ តស្សា បដិស្សុណិត្វា សារីបុត្តោ អនុកម្បកោ

ភិក្ខូនំ អាលោបំ ទត្វា / បាណិមត្តញ្ច ចោឡកំ
ថាលកស្ស ច បានីយំ / តស្សា ទក្ខិណមាទិសិ
សមនន្តរានុទ្ទិដ្ឋេ / វិបាកោ ឧទបជ្ជថ ។
ភោជនច្ឆាទនំ បានីយំ / ទក្ខិណាយ ឥទំ ផលំ
តតោ សុទ្ធា សុចិវសនា / កាសិកុត្តមធារិនី
វិចិត្តវត្ថាភរណា / សារីបុត្តំ ឧបសង្កមិ ។
អភិក្កន្តេន វណ្ណេន / យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា / ឱសធី វិយ តារកា ។
កេន តេ តាទិសោ វណ្ណោ / កេន តេ ឥធ មិជ្ឈតិ

[1] ឱ. ធីរ ។



បពិត្រលោកម្ចាស់ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយចំពោះ
លោកម្ចាស់ បពិត្រលោកម្ចាស់ អ្នកមានព្យាយាម មាន
អានុភាពធំ សូមលោកអនុគ្រោះខ្ញុំ សូមលោកឧទ្ទិសឲ្យ
នូវទានណាមួយ ចំពោះខ្ញុំផង បពិត្រលោកម្ចាស់
ដ៏ចំរើន សូមលោកម្ចាស់ដោះខ្ញុំឲ្យរួចអំពីទុគ្គតិផងចុះ ។

ព្រះសារីបុត្តនោះ ជាអ្នកអនុគ្រោះ ទទួលស្តាប់ពាក្យស្រីប្រេតនោះ ថាសាធុដូច្នេះហើយ បានប្រគេននូវពំនូតបាយ នូវសំពត់ប្រមាណប៉ុនបាតដៃផង នឹងទឹកដែលគួរក្រេបផឹកមួយផ្តិលដល់ភិក្ខុទាំងឡាយរួចហើយ ទើបឧទ្ទិសទក្ខិណាទានដល់ស្រីប្រេតនោះ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ គឺភោជនាហារ នឹងសំពត់ស្លៀកពាក់ នឹងទឹកដែលគួរក្រេបផឹក ក៏កើតឡើង នេះជាផលនៃទក្ខិណា លំដាប់នោះ ស្រីប្រេតនោះ ជាស្រីស្អាត ស្លៀកពាក់សំពត់ស្អាត ប្រសើរជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងអលង្ការណៈវិចិត្រ ចូលទៅរកព្រះសារីបុត្ត ។

(ព្រះសារីបុត្តសួរថា) ម្នាលទេវតា នាងមានសម្បុរល្អ ភ្លឺស្វាងទិស ដូចជាផ្កាយព្រឹក ។ សម្បុររបស់នាងប្រាកដដូច្នេះដោយហេតុអ្វី

ឧប្បជ្ជន្តិ ច តេ ភោគា   យេ កេចិ មនសោ បិយា

បុញ្ញានិ តំ ទេវិ មហានុភាវេ

មនុស្សភូតា កិមកាសិ បុញ្ញំ

កេនាសិ ឯវំ ជលិតានុភាវា

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

ឧប្បណ្ឌុកឹ[១] កិសំ ឆាតំ   អគ្ឃដ្ដិតច្ឆវឹ[២]

មុនិ ការុណិកោ លោកេ តំ មំ អទក្ខិ ទុគ្គតំ[៣]

ភិក្ខូនំ អាលោបំ ទត្វា   បាណិមត្តញ្ច ចោឡកំ

ថាលកស្ស ច បានីយំ   មម ទត្វាន មាទិសិ ។

អាលោបស្ស ផលំ បស្ស   ភត្តំ វស្សសតំ ទស

ភុញ្ជាមិ កាមកាមិនី   អនេកសព្យញ្ជនំ ។

---

១ ម. ឧប្បណ្ឌុកំ ។ ២ ម. ឧគ្ឃដ្ដ កច្ឆវិំ ។ ម. ឧគ្ឃដ្ដិ សង្ឃាដិ កច្ឆវី ។ ៣ ម. ទុក្ខិតំ ទុគ្គតំ ។ ម. អទក្ខិ ទុគ្គតំ ។



ផលនៃសេចក្ដីសុចរិត សម្រេចដល់នាងក្នុងលោកនេះ ដោយហេតុអ្វី បាន ជាភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលទេវតា   ដ៏មានអានុភាពច្រើន   យើងសួរ

សួរនាង នាងកាលកើតជាមនុស្ស  បានធ្វើបុណ្យដូច

ម្ដេច នាងមានអានុភាពភ្លឺថ្កុំ ទាំងសម្បុរ របស់នាង

ក៏ភ្លឺសព្វទិស យ៉ាងនេះ ដោយបុញ្ញកម្ម ដូចម្ដេច ។

(ប្រេតតបថា) ព្រះអគ្គសាវក ជាអ្នកប្រាជ្ញក្នុងលោក ប្រកប ដោយសេចក្ដីករុណា បានឃើញខ្ញុំជាស្រីស្គម មានសម្បុរលឿង មានសេចក្ដីស្រេកឃ្លាន ជាស្រីកម្រោក មានសម្បុរស្បែកគ្រោត គ្រាត ដល់នូវសេចក្ដីទុក្ខលំបាក ហើយបានប្រគេនដុំនំបាយផង សំពត់ប្រមាណប៉ុនបាតដៃផង ទឹកមួយផឹកប្រមាណមួយផ្តិលផង ដល់ ភិក្ខុទាំងឡាយ ហើយបានឧទ្ទិស(នូវទក្ខិណាទានដល់ខ្ញុំ) ។ សូម លោកឃើញផល ដំនួតបាយចុះ ខ្ញុំជាស្រីបាននូវកាមតាមចំណង់ បរិភោគនូវភត្តអស់មួយពាន់ឆ្នាំ ប្រកបដោយម្ហូបមានរសជាអនេក

បាណិមត្តស្ស ចោឡស្ស   វិបាកំ បស្ស យាទិសំ
យាវតា នន្ទរាជស្ស   វិជិតស្មិំ បដិច្ឆទា
តតោ ពហុតរា ភន្តេ   វត្ថានច្ឆាទនានិ មេ
កោសេយ្យកម្ពលីយានិ   ខោមកប្បាសិកានិ ច
វិបុលា ច មហគ្ឃា ច   តេបាកាសេវ[១] លម្ពរេ
សាហំ តំ បរិទហាមិ   យំ យំ ហិ មនសោ បិយំ
ថាលកស្ស ច បានីយំ   វិបាកំ បស្ស យាទិសំ ។
គម្ភីរា ចតុរស្សា ច   បោក្ខរញ្ញោ[២] សុនិម្មិតា
សេតោទកា សុប្បតិត្ថា   សីតា អប្បដិគន្ធិយា[៣]
បទុមុប្បលសញ្ឆន្នា   វារិកិញ្ជក្ខបូរិតា ។
សាហំ រមាមិ កីឡាមិ   មោទាមិ អកុតោភយា ។
មុនឹ ការុណិកំ លោកេ[៤]   ភន្តេ វន្ទិតុមាគតា ។

សំសារមោចកបេតវត្ថុ បឋមំ ។

១ ម. តេ អាកាសេ ។ ២ ម. បោក្ខរញ្ញា ។ ៣ ម. អប្បដិគន្ធិកា ។ ៤ ម. លោកំ ។



សូមលោកឃើញនូវវិបាកនៃសំពត់ប្រមាណប៉ុនបាតដៃ ប្រាកដដូចម្ដេច បពិត្រលោកម្ចាស់ដ៏ចំរើន សំពត់សម្រាប់ស្លៀកពាក់ ក្នុងដែនដៃនៃស្ដេចនន្ទរាជប្រមាណណា សំពត់ស្លៀកទាំងសំពត់ដណ្ដប់ផង សំពត់កោសេយ្យៈ ទាំងសំពត់កម្ពលផង សំពត់ត្បាញអំពីសម្បកឈើ ទាំងសំពត់ដែលត្បាញអំពីកប្បាសផង ដ៏ទូលាយ មានដំឡៃច្រើន របស់ខ្ញុំ ច្រើនជាងសំពត់ ក្នុងដែននន្ទរាជនោះ សំពត់ទាំងអស់នោះ តែងសំយុងចុះមកអំពីអាកាស សំពត់ណាដែលជាទីពេញចិត្ត ខ្ញុំក៏ស្លៀកពាក់នូវសំពត់នោះ សូមលោកឃើញនូវវិបាកនៃទឹកផឹកប្រមាណមួយក្អម ប្រាកដដូចម្ដេច ។ ស្រះបោក្ខរណីដ៏ជ្រៅ មានជ្រុង៤ ដែលគេធ្វើល្អ និម្មិតល្អហើយ មានទឹកថ្លា មានកំពង់រាបស្មើ មានទឹកត្រជាក់ មានក្លិនក្រអូប ដេរដាសដោយផ្កាឈូក និងឧប្បល ពេញដោយទឹកដ៏ដេរដាសដោយកេសរ ។ ខ្ញុំនោះរីករាយ សេពសប្បាយ ឥតមានភ័យអំពីណាៗឡើយ បពិត្រលោកដ៏ចំរើន ខ្ញុំមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណា ក្នុងលោក ។

ចប់ រឿងសំសារមោចកប្រេត ទី ១ ។

## ទុតិយំ សារីបុត្តត្ថេរស្ស មាតុបេតវត្ថុ

(១៤) នគ្គា ទុព្វណ្ណរូបាសិ កិសា ធមនិសន្ថតា

ឧប្ផាសុលិកេ កិសិកេ កា នុ ត្វំ ឥធ តិដ្ឋសិ ។

អហន្តេ សកិយា(១) មាតា បុព្វេ អញ្ញាសុ ជាតិសុ

ឧបបន្នា បេត្តិវិសយំ ខុប្បិបាសា សមប្បិតា

ឆឌ្ឌិតំ ខិបិតំ ខេឡំ សិង្ឃាណិកំ សិលេសុមំ

វសញ្ច ឌយ្ហមានានំ វិជាតានញ្ច លោហិតំ

វណិកានញ្ច(២) យំ ឃានំ សីសច្ឆិន្នញ្ច(៣) លោហិតំ

ខុធាបរេតា ភុញ្ជាមិ(៤) ឥត្ថិបុរិសនិស្សិតំ

បុព្វលោហិតំ ភក្ខាមិ បសូនំ មានុសានញ្ច

អលេណា អនគារា ច នីលមញ្ចបរាយណា

ទេហិ បុត្តក មេ ទានំ ទត្វា អនុទិសាហិ(៥) មេ

អប្បេវ នាម មុញ្ចេយ្យំ បុព្វលោហិតភោជនា ។

មាតុយា វចនំ សុត្វា ឧបតិស្សោនុកម្បកោ

អាមន្តយិ មោគ្គល្លានំ អនុរុទ្ធញ្ច កប្បិនំ

---

១ ម. សកិយា ។ ២ ម. វណិកានញ្ច ។ ៣ ម. សីសច្ឆិន្នាន ។ ៤ ម. ភុញ្ជិស្សំ ។ ៥ ម. អនុទិសាហិ ។



## រឿងប្រេត ជាមាតានៃព្រះសារីបុត្ត ទី ២

(១៤) (ព្រះសារីបុត្តសួរថា) ម្នាលស្រីស្គម មានឆ្អឹងជំនីរគគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរោមពាសដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ។

(នាងប្រេតតបថា) អំពីមុន ខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន បរិភោគទឹកមាត់ ដែលគេស្តោះចោល ទឹកសម្បោរ ស្លេស្ម ខ្លាញ់កៅ (នៃសាកសព) ដែលគេដុត នឹងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន នឹងឈាមនៃដំបៅនឹងប្រមុះនឹងក្បាលដាច់ មានសេចក្តីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគខ្ទុះនឹងឈាមដែលជាប់នឹងសរីរៈនៃស្រីនឹងបុរស ខ្ទុះនឹងឈាមនៃបសុសត្វនឹងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសាន ដូចគ្រែ លោកម្ចាស់ជាបុត្រ សូមលោកម្ចាស់ឱ្យទាន ដើម្បីខ្ញុំ លុះឱ្យហើយ ចូរឧទ្ទិសផលដល់ខ្ញុំ តើធ្វើដូចម្តេចហ្ន៎ ឱ្យខ្ញុំគប្បីបានរួចអំពីការបរិភោគខ្ទុះនឹងឈាម ។

ព្រះអគ្គសាវ័ក មាននាមថា ឧបតិស្សៈ លុះបានស្តាប់ពាក្យនៃនាងប្រេត ជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅ ព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១

ចតស្សោ កុដិយោ កត្វា   សង្ឃេ ចាតុទ្ទិសេ អទា
កុដិយោ អន្នបានញ្ច   មាតុ ទក្ខិណមាទិសិ ។
សមនន្តរានុទ្ទិដ្ឋេ   វិបាកោ ឧទបជ្ជថ
ភោជនំ បានីយំ វត្ថំ   ទក្ខិណាយ ឥទំ ផលំ
តតោ សុទ្ធា សុចិវសនា   កាសិកុត្តមធារិនី
វិចិត្តវត្ថាភរណា   កោលិតំ ឧបសង្កមិ ។
អភិក្កន្តេន វណ្ណេន   យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា   ឱសធី វិយ តារកា
កេន តេតាទិសោ វណ្ណោ   កេន តេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា   យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

សារីបុត្តស្សាហំ មាតា[១]   បុព្វេ អញ្ញាសុ ជាតិសុ
ឧប្បន្នា បេត្តិវិសយំ   ខុប្បិបាសា សមប្បិតា

១ ម. សារិបុត្តស្ស មេ មាតា ។



ឲ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយប្រគេនកុដិផង បាយនិងទឹកផង ចំពោះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើង ក្នុងលំដាប់ដែលឧទ្ទិសហើយ គឺភោជនាហារ ទឹកផឹក និងសំពត់ (ក៏កើតឡើង) នេះជាផលនៃទក្ខិណាទាន លំដាប់នោះ (ស្រីនោះ) ស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ប្រដាប់នូវសំពត់ដ៏ឧត្តមជាសំពត់ ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ បានចូលទៅរកព្រះកោលិត ។

(ព្រះកោលិតសួរថា) ម្នាលនាងទេវតា នាងមានសម្បុរល្អ មកឈរនៅ (ទីនេះ) ភ្លឺស្វាងខ្វាត់សព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះ កើតឡើងដល់នាង ដោយហេតុដូចម្តេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគៈណាមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវតា មានអានុភាពច្រើន យើងសូមសួរ
នាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យ ដូចម្តេច
នាងជាទេវតា មានអានុភាពរុងរឿងយ៉ាងនេះ ទាំង
សម្បុរនាង ក៏ភ្លឺសព្វទិស ដោយបុញ្ញកម្មដូចម្តេច ។

(ប្រេតតបថា) អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន

ឆឌ្ឌិតំ ខិបិតំ ខេឡំ   សិង្ឃាណិកំ សិលេសុមំ
វសញ្ច ឌយ្ហមានានំ   វិជាតានញ្ច លោហិតំ
វណិតានញ្ច យំ ឃានំ   សីសច្ឆិន្នញ្ច លោហិតំ
ខុទាបរេតា ភុញ្ជាមិ   ឥត្ថីបុរិសនិស្សិតំ
បុព្វលោហិតំ ភក្ខាមិ   បសូនំ មនុស្សានញ្ច
អលេណា អនគារា ច   នីលមញ្ចបរាយណា ។
សារីបុត្តស្ស ទានេន   មោទាមិ អកុតោភយា
មុនឹ ការុណិកំ លោកេ   តំ ភន្តេ វន្ទិតុមាគតា ។

សារីបុត្តត្ថេរស្ស មាតុបេតវត្ថុ ទុតិយំ ។

## តតិយំ មត្តាបេតវត្ថុ

(១៨) នគ្គា ទុព្វណ្ណរូបាសិ   កិសា ធមនិសន្ថតា
ឧប្ផាសុឡិកេ កិសិកេ   កា នុ ត្វំ ឥធ តិដ្ឋសិ ។
សាហំ(១) មត្តា តុវំ តិស្សា   សបត្តី តេ បុរេ អហុំ
បាបកម្មំ ករិត្វាន   បេតលោកំ ឥតោ គតា ។

១ ម. យ. អហំ ។





បរិភោគតែទឹកមាត់ ដែលគេស្ដោះចោល ទឹកសម្បោរ ស្លេស្ម និង ខ្លាញ់ពក (នៃសាកសព) ដែលគេដុត ទឹកឈាមនៃស្រីកំពុងឆ្លាយ ដែលសម្រាលកូន ទឹកឈាមនៃដំបៅនិងច្រមុះ និងក្បាលដាច់ ខ្ញុំមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ បរិភោគខ្ទុះទឹកឈាមដែលជាប់នឹងសរីរៈនៃស្ត្រីនិងបុរស ខ្ទុះទឹកឈាមនៃបសុសត្វ និងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីពំនាក់អាស្រ័យ ដេកនៅលើទីស្មសានដូចនៃគ្រែ ។ ខ្ញុំត្រេកអរដោយទាននៃព្រះសារីបុត្រ ទើបមិនមានភ័យ អំពីទីណា ។ បពិត្រលោកដ៏ចំរើន ខ្ញុំមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណា ក្នុងលោក ។

ចប់ រឿងប្រេត ជាមាតានៃព្រះសារីបុត្រ ទី ២ ។

## រឿងនាងមត្តាប្រេត ទី ៣

(១៨) (នាងតិស្សាសួរថា) ម្នាលស្រីស្គម មានផ្គើរដំណើរតាមនាងជាស្រីមានកាយអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរឹងរៃដោយសរសៃ នាងជាអ្វី បានជាមកឈរនៅក្នុងទីនេះ ។

(នាងមត្តាប្រេតប្រាប់ថា) កាលអំពីមុន នាងឯង ឈ្មោះតិស្សា ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្ដី របស់នាង បានធ្វើអំពើបាប ទើបបានឃ្លាត អំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

កិន្នុ កាយេន វាចាយ    មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន    បេតលោកំ ឥតោ គតាតិ ។
ចណ្ឌី ច ផរុសា ចាសឹ    ឥស្សុកី មច្ឆរី សឋា[1]
តាហំ ទុរុត្តំ វត្វាន    បេតលោកំ ឥតោ គតាតិ ។
សច្ចំ[2] អហំបិ ជានាមិ    យថា ត្វំ ចណ្ឌិកា អហុ
អញ្ញញ្ច ខោ តំ បុច្ឆាមិ    កេនាសិ បំសុកុន្ថិតា[3] ។
សីសំ នហាតា ត្វំ អាសិ    សុចិវត្ថា អលង្កតា
អហញ្ច ខោ អធិមត្តំ    សមលង្កតរា តយា
តស្សា មេ បេក្ខមានាយ    សាមិកេន សមន្តយិ
តតោ មេ ឥស្សា វិបុលា    កោធោ មេ សមជាយថ
តតោ បំសុំ គហេត្វាន    បំសុនា តំ វិកិរឹហំ[4]
តស្ស កម្មវិបាកេន    តេនម្ហិ បំសុកុន្ថិតា ។
សច្ចំ អហំបិ ជានាមិ    បំសុនា មំ ត្វំ ឱកិរិ
អញ្ញញ្ច ខោ តំ បុច្ឆាមិ    កេន ខជ្ជសិ កច្ឆុយាតិ ។

១ ម. សឋី ។ ២ ម. សព្វំ ។ ៣ ម. បំសុកុន្ថិតា ។ ៤ ម. ធំ បិ ឱកិរឹ ។



ចុះអំពើអាក្រក់ ដែលនាងបានធ្វើហើយ ដោយកាយ វាចា ចិត្តនោះ តើដូចម្តេច នាងឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះវិបាកនៃកម្ម ដូចម្តេច ។

ខ្ញុំជាស្រីកាច (ឆ្នាស) បានពោលផរុសវាចា ជាស្រីឫស្យា កំណាញ់ អួតអាង ខ្ញុំនោះបានពោលពាក្យអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

ពិតមែនហើយ យើងបានដឹងថា នាងជាស្រីឆ្នាស យើងសូមសួរនាង អំពីហេតុដទៃទៀត ចុះនាងមានខ្លួនប្រឡាក់ដោយអាចម៍ដី ព្រោះកម្ម ដូចម្តេច ។

នាងបានលុបលាងក្បាលរួចហើយ មានសំពត់ដ៏ស្អាត ប្រដាប់ហើយ ខ្លួនយើងសោត ក៏ប្រដាប់តាក់តែងដោយគ្រឿងអលង្ការដ៏ក្រៃលែងជាងនាង កាលខ្ញុំនោះ កំពុងសម្លឹងមើល នាងក៏ពោលបបោចនឹងស្វាមី ក្នុងលំដាប់នោះ ខ្ញុំមានសេចក្តីឫស្យាពេកណាស់ ខ្ញុំមានសេចក្តីក្រោធកើតឡើង តអំពីនោះ ខ្ញុំក៏ប្រវ៉ៃយកអាចម៍ដីទៅរោយដាក់នាង ដោយអាចម៍ដី ព្រោះហេតុនោះ ខ្ញុំទើបមានខ្លួនប្រឡាក់ ដោយអាចម៍ដី ព្រោះវិបាកនៃកម្មនោះឯង ។

កេសជ្ជហារី ទុតោយោ    វណ្ណិ អគមិច្ឆ សេ

ត្វំ ច កេសជ្ជមាហារី[១]    អហញ្ញ[២] ការិតច្ឆលោ

តស្សា ត្យាជានមានាយ[៣]    សេយ្យំ តយាហំ សមោតរិំ

តស្ស កម្មវិបាកេន    តេន ទ្វាដ្ឋមំ កច្ឆយាតិ ។

សក្ខិំ អហំបិ ជាតាមិ    សេយ្យំ មេ ត្វំ សមោតរិ

អញ្ញញ្ញ តោ កំ បុច្ឆាមិ    តេលាសិ ឆត្តិយា ទុវ្ដិ ។

សហាយានិ សមយោ អាសិ    ញាតីនំ សមិតី អហុ

តវញ្ញ[៤] អាមន្តិតា អាសិ    សសាមី ពោ ច តោ អហំ

តស្សា ត្យាជានមានាយ    ទុស្សំ ត្យាហំ អទាទុនី

តស្ស កម្មវិបាកេន    តេនម្ហិ ឆត្តិយា អហាន្តិ ។

សក្ខិំ អហំបិ ជាតាមិ    ទុស្សំ មេ ត្វំ អទាទុទិ

អញ្ញញ្ញ តោ ត បុច្ឆាមិ    តេលាសិ ក្ខជកង្ខិនីតិ ។

---

១ ម. កេសជ្ជមហាសិ ។ ២ ម. ព្ទោ ។ ៣ ម. គេអាជានមានាយ ។ ៤ ម. តញ្ញ ។





ពិតមែនហើយ យើងដឹងថា នាងបានកេយកាចម៍ជំពាក់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងត្រូវកេនគមមោស់ បៀតបៀន ដោយកម្មអ្វី ។

យើងទាំងពីរនាក់ បានចូលទៅកាន់ព្រៃ ដើម្បីកេញ្ចាំ ចំណែកនាងបានយកក្រម៉ុក ឯខ្ញុំបាននាំយកទៅមកវិញ កាលបើនាងមិនដឹង ខ្ញុំក៏កេយទៅខ្វះជាថ្នាំណែករបស់នាង ព្រោះហេតុនោះ ឥឡូវរបស់ ខ្ញុំ ទើបត្រូវគេគមមោស់បៀតបៀន ព្រោះវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងបានដឹងថា នាងបានកេយ (ខ្ញុំ) ហើ ចំណែករបស់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះ នាងមានកាយគគ្រោត ដោយកម្មអ្វី ។

—មានការប្រជុំមិត្តសំឡាញ់ និងជួបជុំពួកញាតិ គេបានហៅនាងព្រមទាំងស្វាមី តែខ្ញុំគេមិនហៅ កាលបើនាងមិនបានដឹង ខ្ញុំក៏លួចយកសំពត់នាងទៅលាក់ ហេតុនោះ ខ្ញុំទើបមានកាយគគ្រោត ព្រោះវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងដឹងថា នាងបានលួចសំពត់របស់យើង ទៅលាក់ យើងសួរនាងអំពីហេតុដទៃទៀត ចុះរាងកាយរបស់នាង មានក្លិនស្អុយដូចក្លិនលាមក ព្រោះកម្មអ្វី ។

តវ គន្ធញ្ច មាលញ្ច          បណ្ណញ្ច វិលេបនំ
ថូបក្ខេ អហារេសឹ          តំ បាបំ បកតំ មយា
តស្ស កម្មវិបាកេន          វេទម្ហិ គូថគន្ធិនី ។
សច្ចំ អហំបិ ជានាមិ          តំ បាបំ បកតំ តយា
អញ្ញញ្ច ខោ តំ បុច្ឆាមិ          កេនាសិ ទុគ្គតា តុវំ ។
ឧភិន្នំ សមកំ អាសិ          យំ គេហេ វិជ្ជតេ ធនំ
សន្តេសុ ទេយ្យធម្មេសុ          ទីបំ នាកាសិមត្តនោ
តស្មា កម្មវិបាកេន          តេនម្ហិ ទុគ្គតា អហន្តិ ។
តទេវ មំ ត្វំ អវច          បាបកម្មំ និសេវសិ
ន ហិ បាបេហិ កម្មេហិ          សុលភា ហោសិ សុគ្គតី[1] ។
វាមតោ មំ ត្វំ បច្ចេសិ          អថោបិ មំ ឧស្សុយ្យសិ
បស្ស បាបានំ កម្មានំ          វិបាកោ ហោតិ យាទិសោ ។
តេ ឃរទាសិយោ អាសុំ          តានេវាភរណានិ មេ
តេ អញ្ញេ បរិចារេន្តិ          ន ភោគា ហោន្តិ សស្សតា
ឥទានិ ភូតស្ស បិតា          អាបណា គេហមេហិតិ

១ ម. សុគ្គតិ ។



ខ្ញុំបានលួចយកនូវគ្រឿងក្រអូប ផ្កាប្រដាប់និងគ្រឿងលាប ជាទានដ៏ខ្ពស់របស់នាង នៅវេលាគន់ណេញលាមក ខ្ញុំបានធ្វើអំពើអាក្រក់នោះ ហេតុនោះ បានជាខ្ញុំមានក្លិនស្អុយផ្សាយក្លិនលាមក ព្រោះហេតុវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងបានដឹងហើយថា នាងបានធ្វើអំពើអាក្រក់នោះ យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងជាស្រីទុគ៌ត ព្រោះវិបាកនៃកម្មអ្វី ។

កាលយើងទាំងពីរនាក់ មានទ្រព្យសម្បត្តិ ក្នុងផ្ទះស្មើគ្នា កាលទេយ្យធម៌មាន ខ្ញុំក៏មិនបានធ្វើទីពឹងដើម្បីខ្លួន ព្រោះហេតុនោះ បានជាខ្ញុំជាស្រីទុគ៌ត ដោយវិបាកនៃកម្មនោះឯង ។

នាងឯងបានស្ដីឲ្យខ្ញុំថា នាងកុំសេពអំពើអាក្រក់ ព្រោះថា សុគតិ មិនមែនបានដោយងាយ ព្រោះបាបកម្មឡើយ ។ នាងបានកំហែងយើងដោយផ្លូវខុស ទាំងបានមួលបង្កាច់យើង នាងចូរមើលចុះ វិបាកនៃអំពើអាក្រក់ ប្រាកដយ៉ាងណា (អំពីមុន) ខ្ញុំស្រីទាំងឡាយក្នុងផ្ទះនោះ និងគ្រឿងប្រដាប់ប្រដានោះឯង ជារបស់ខ្ញុំក៏មាន (ឥឡូវនេះ) របស់អស់នោះ ក៏បានទៅអ្នកដទៃប្រើប្រាស់ ទ្រព្យទាំងឡាយ ក៏ជារបស់មិនទៀង ឥឡូវនេះ (កុដុម្ពិក) ប្ដីរបស់ខ្ញុំ ត្រឡប់អំពីផ្សារមកផ្ទះ

អប្បំ តេ ទទេ កិញ្ចិ មា សុ តាវ អទោ តតោ(១) ។
នគ្គា ទុព្វណ្ណរូបាម្ហិ កិសា ធមនិសណ្ឋិតា
កោបីនំ បតិ(២) នត្ថិ មា មំ ក្ខតបិតាធុស ។
ហន្ទ កិំ ត្យាហំ(៣) ទម្មិ កិំ វា តេ ករោមហំ
យេន ត្វំ សុខិតា អស្ស សព្វកាមសមិទ្ធិនី ។
ចត្តារោ ភិក្ខូ សង្ឃតោ ចត្តារោ បន បុគ្គលា(៤)
អដ្ឋ ភិក្ខូ ភោជយិត្វា មម ទក្ខិណមាទិសិ
តទាហំ សុខិតា ហេស្សំ សព្វកាមសមិទ្ធិនី ។
សាធូតិ សា បដិស្សុត្វា ភោជយិត្វា អដ្ឋ ភិក្ខវោ
វត្ថេហច្ឆាទយិត្វាន(៥) តស្សា ទក្ខិណមាទិសិ ។
សមនន្តរានុទ្ទិដ្ឋេ វិបាកោ ឧទបជ្ជថ
ភោជនច្ឆាទនំ បានីយំ ទក្ខិណាយ ឥទំ ផលំ
តតោ សុទ្ធា សុចិវសនា កាសិកុត្តមធារិនី

---

១ ឱ. ម. អទា ។ ២ ឱ. កោបិនមេត្ថ ។ ៣ ម. ហន្ទ កិំ វា ត្យាហំ ។ ៤ ម. បុគ្គលេ ។
៥ ឱ. វត្ថេហច្ឆាទយិត្វាន ។ ម. វត្ថេ អច្ឆាទយិត្វាន ។



ធ្វើខ្លួនខ្លួច កុំឲ្យម្ចាស់នឹងវត្រូវរលាយផលខ្លួនដល់នាង នាងកុំអាល ទៅអំពីទីនេះឡើយ ។

ខ្លួនខ្ញុំជាស្រីអាក្រាត មានរូបរាងអាក្រក់ក្រៃពេក ជាស្រីស្គម មានខ្លួនពេញទៅដោយសរសៃ នេះជាគ្រឿងខ្មាសរបស់ស្រីទាំងឡាយ កុំឲ្យក្រដម៉ក់ ជាបិតានាងមកឃើញខ្ញុំឡើយ ។

បើដូច្នោះ ខ្ញុំគួរឲ្យអ្វីដល់នាង ម្យ៉ាងទៀត ខ្ញុំនឹងធ្វើឧបការៈ អ្វីដល់នាង ដែលជាហេតុឲ្យនាងសម្រេចដោយសេចក្តីប្រាថ្នាទាំងពួង ដល់នូវសេចក្តីសុខ ។

នាងចូរនិមន្តភិក្ខុ ៨ រូបគឺ ភិក្ខុ ៤ រូបអំពីសង្ឃ ភិក្ខុ ៤ រូបទៀត អំពីបុគ្គល ឲ្យឆាន់ ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំនោះ ជាហេតុឲ្យខ្ញុំសម្រេចសេចក្តីប្រាថ្នាទាំងពួង ដល់នូវសេចក្តីសុខ ។

នាងតិស្សា បានទទួលពាក្យនាងមត្តាប្រេតថា សាធុ ហើយទើប និមន្តភិក្ខុ ៨ រូបឲ្យឆាន់ ហើយឲ្យស្លៀកដណ្តប់ ដោយសំពត់ ទាំងឡាយ ហើយឧទ្ទិសទក្ខិណាទាន ដល់នាងមត្តាប្រេតនោះ ។ វិបាកក៏កើតឡើង តាមលំដាប់ដែលឧទ្ទិសហើយ ភោជនាហារ សំពត់ ស្លៀកដណ្តប់ និងទឹកផឹក ក៏កើតឡើង នេះជាផលនៃទក្ខិណាទាន លំដាប់នោះ នាងប្រេត ជាស្រីស្អាត មានគ្រឿងស្លៀកពាក់ ស្អាត ប្រស្រស់ ស្លៀកសំពត់ដ៏ឧត្តម ជាគឺសំពត់ដែលកើតក្នុងដែនកាសី

វិចិត្តវត្ថាភរណា សព្វត្ថី ឧបសោភសិ ។

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ

ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា

កេន តេ តាទិសោ វណ្ណោ កេន តេ ឥធ មិជ្ឈតិ

ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ

មនុស្សភូតា កិមកាសិ បុញ្ញំ

កេនាសិ ឯវំ ជលិតានុភាវា

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

អហំ មត្តា តុវំ តិស្សា សបត្តី តេ បុរេ អហុំ

បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា

ត្វំ ទានេន ទិន្នេន មោទាមិ អកុតោភយា ។

ចិរំ ទីឃាយុ ភវតិ សហ សព្វេហិ ញាតិភិ

អសោកំ វិរជំ ឋានំ អាវាសំ វសវត្តិនំ

ឥធ ធម្មំ ចរិត្វាន ទានំ ទត្វាន សោភណេ ។



មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ទើបបានចូលទៅកាន់នាងតិស្សាជា ស្រីរួមប្តី ។

(នាងតិស្សាសួរថា) ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿង ដោយរស្មី មកឋិតនៅ ភ្លឺស្វាងចូរទៅសព្វទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ ដោយហេតុដូចម្តេច ផលនៃសុចរិតសំរេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេចបានជា ភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកើតជាមនុស្ស បានធ្វើបុញ្ញកម្មដូចម្តេច នាងជាទេវធីតាមាន អានុភាពភ្លឺថ្លៃយ៉ាងនេះ ដោយបុញ្ញកម្មដូចម្តេច បានជានាង មានអានុភាពដ៏រុងរឿង ទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស ។

(នាងមត្តាប្រកាសថា) កាលពីមុន នាងឈ្មោះតិស្សា ខ្ញុំឈ្មោះ មត្តាជាស្រីរួមប្តីរបស់នាង បានធ្វើនូវអំពើអាក្រក់ ទើបបានឃ្លាតអំពី មនុស្សលោកនេះទៅកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់នាង ដែលបានឲ្យហើយ ទើបមិនមានភ័យក្នុងទីណាឡើយ ។ ម្នាលប្អូន ចូរនាងរស់នៅ អស់កាលយូរ ព្រមដោយពួកញាតិទាំងអស់ចុះ ម្នាលនាងល្អ ចូរនាងប្រព្រឹត្តធម៌ ទំឲ្យទានក្នុងលោកនេះ ទីនឹង (ចូលទៅកាន់ឋានសួគ៌) ដែលមិនមានសោក មិនមានធូលី ជាទីនៅនៃសេវត្តីទេវតាទាំងឡាយ ។

វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេតិ ឋានន្តិ ។

មត្តាបេតវត្ថុ តតិយំ ។

## ចតុត្ថំ នន្ទាបេតវត្ថុ

(១៦) កាឡី[១] ទុព្ពណ្ណរូបាសិ ផរុសា ភីរុទស្សនា[២]
បិង្គលាសិ កឡារាសិ ន តំ មញ្ញាមិ មានុសិន្តិ ។
អហំ នន្ទា នន្ទិសេន ភរិយា តេ បុរេ អហុំ
ទាសកម្មំ ករិត្វាន បេតលោកំ ឥតោ គតាតិ ។
កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បេតលោកំ[៣] ឥតោ គតាតិ ។
ចណ្ឌី ច ផរុសា ចាសឹ តយិ ចាសឹ[៤] អគារវា
តាហំ ទុរុត្តំ វត្វាន បេតលោកំ ឥតោ គតាតិ ។
ហន្ទុត្តរីយំ ទទាមិ តេ ឥមំ ទុស្សំ និវាសយ
ឥមំ ទុស្សំ និវាសេត្វា ឯហិ នេស្សាមិ តំ ឃរំ

១ ម. កាឡី ។ ២ ម. ផរុសា ភីរុកទស្សនា ។ ៣ ម. បេតលោកា ។ ៤ ម. តយិ ។



នាងចូរបន្ទោបង់នូវមន្ទិលគឺសេចក្តីកំណាញ់ ព្រមទាំងឫស
គល់ចេញ ដែលគេនិន្ទាមិនបាន ចូរទៅកាន់ស្ថានសួគ៌ ។

ចប់រឿងនាងមត្តាប្រេតទី ៣ ។

## រឿងនន្ទាប្រេតទី ៤

(១៦) (នន្ទិសេនជាស្វាមីសួរថា) នាងជាស្រីមានខ្លួនខ្មៅ មានរូបអាក្រក់គ្រោតគ្រោតមើលគួរខ្លាច មានភ្នែកលឿង មានធ្មេញក្រញើល យើងមិនសំគាល់ថា នាងជាស្រីមនុស្សទេ ។

(នាងប្រេតតបថា) ម្នាលនន្ទិសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះកាន់បេតលោក ។

ចុះអំពើអាក្រក់ ដែលនាងបានធ្វើដោយកាយ វាចា ចិត្តនោះ តើដូចម្តេចខ្លះ នាងទៅអំពីមនុស្សលោកនេះ កាន់បេតលោក ដោយវិបាកនៃកម្មដូចម្តេចខ្លះ ។

ខ្ញុំជាស្រីកំណាចផង មានវាចាអាក្រក់ផង ឥតមានសេចក្តីគោរពចំពោះអ្នកផង ខ្ញុំពោលពាក្យអាក្រក់ចំពោះអ្នក ទើបបានទៅអំពីមនុស្សលោកនេះកាន់បេតលោក ។

បើដូច្នោះ យើងនឹងឲ្យសំពត់បង់កដល់នាង ចូរនាងស្លៀកសំពត់នេះចុះ លុះនាងស្លៀកសំពត់នេះហើយ ចូរចូលមក យើងនឹងនាំនាងទៅផ្ទះ

វត្ថញ្ច អន្នបានញ្ច លទ្ធាសិ ត្វំ យតំ គតា
បុត្តេ ច តេ បស្សិស្សសិ សុណិសាយោ(១) ច នត្តាសិ ។
ហាស្វេច ហាត្វេ(២) តេ និន្ទំ ន មយ្ហំ ឧបកប្បតិ
ភិក្ខូ ច សីលសម្បន្នេ វីតរាគេ ពហុស្សុតេ
តប្បេហិ អន្នបានេន មមំ ទក្ខិណមាទិសិ
តថាហំ សុខិតា ហេស្សំ សព្វកាមសមិទ្ធិនី ។
តតោ សាធូតិ សោ បដិស្សុណិត្វា ទានំ វិបុលមាករិ
អន្នបានំ ខាទនីយំ វត្ថំ សេនាសនានិ ច
ឆត្តំ គន្ធញ្ច មាលញ្ច វិវិធា ច ឧបាហនា ។
ភិក្ខូ ច សីលសម្បន្នេ វីតរាគេ ពហុស្សុតេ
តប្បេត្វា អន្នបានេន តស្សា ទក្ខិណមាទិសិ ។
សមនន្តរានុទិដ្ឋេ វិបាកោ ឧទបជ្ជថ
ភោជនច្ឆាទនំ បានីយំ ទក្ខិណាយ ឥទំ ផលំ
តតោ សុទ្ធា សុចិវសនា កាសិកុត្តមធារិនី
វិចិត្តវត្ថាភរណា សាមិកំ ឧបសង្កមិ ។

---

១ ម. សុនិសាយោ ។ ២ ម. ហាត្វ ហាត្វេន ។



នាងទៅដល់ផ្ទះហើយ នឹងបានសំពត់ បាយទឹក បានឃើញនូវបុត្រទាំងឡាយរបស់នាងផង បានឃើញកូនប្រសាស្រីរបស់នាងផង ។

ក្តីដែលអ្នកបានឲ្យគាស់ដៃដោយដៃ មិនសម្រេចដល់ខ្ញុំទេ អ្នកចូរញុំាងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ជាអ្នកប្រាសចាករាគៈ ជាពហុស្សូត ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំ គ្រានោះ ទើបខ្ញុំនឹងដល់នូវសេចក្តីសុខ សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងបាន ។

លំដាប់នោះ នន្ទសេន ឧបាសកនោះ ទទួលថា សាធុដូច្នេះហើយ បានតាក់តែងនូវទានដ៏បរិបូណ៌ គឺ បាយ ទឹក បង្អែម សំពត់ សេនាសនៈ ឆ័ត្រ គ្រឿងក្រអូប ផ្កាកម្រង ស្បែកជើងផ្សេងៗ ។ នន្ទសេនឧបាសកក៏បានញុំាងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយឧទ្ទិសទក្ខិណាទាន ដល់នាងនន្ទាប្រេត ។

វិបាកក៏កើតឡើងក្នុងលំដាប់ដែលបានឧទ្ទិស ភោជនាហារ សំពត់ស្លៀក ទាំងទឹកផឹកក៏កើត នេះជាផលនៃទក្ខិណាទាន

លំដាប់នោះ នាងនន្ទាប្រេតនោះ ជាស្រីស្អាតមានសំពត់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ ដែលកើតក្នុងដែនកាសី មានគ្រឿងតាក់តែងដ៏វិចិត្រ ចូលទៅរកស្វាមី ។

ខុទ្ទកនិកាយេ បេតវត្ថុស្ស ឧព្ពរិវគ្គស្ស ចតុត្ថំ នន្ទាបេតវត្ថុ

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ កេន តេ ឥធ មិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវំ ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។

អហំ នន្ទា នន្ទសេន ភរិយា តេ បុរេ អហុំ
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា
តវ ទិន្នេន ទានេន មោទាមិ អកុតោភយា ។
ចិរំ ជីវ គហបតិ សហ សព្វេហិ ញាតិភិ
អសោកំ វិរជំ ឋានំ អាវាសំ វសវត្តិនំ
ឥធ ធម្មំ ចរិត្វាន ទានំ ទត្វា គហបតិ

វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ។

នន្ទាបេតវត្ថុ ចតុត្ថំ ។



បេតវត្ថុ ឧព្ពរិវគ្គ ទី ២ រឿងនាងនន្ទាប្រេត ទី ៤

(នន្ទសេន ឧបាសកសួរថា) ម្នាលនាងទេវតា នាងមានសម្បុរដ៏រុងរឿង ភ្លឺស្វាងទួទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ ដោយហេតុដូចម្តេច ផលនៃសុចរិតសំរេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច ភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលនាងទេវតា មានអានុភាពច្រើន យើងសូមសួរ
នាង នាងកាលកើតជាមនុស្សបានធ្វើបុញ្ញកម្មដូចម្តេច
នាងជាទេវតាមានអានុភាពរុងរឿងយ៉ាងនេះ ដោយ
បុញ្ញកម្មដូចម្តេច ទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស ។

(នាងប្រេតតបថា) ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់អ្នកដែលបានឲ្យ ហើយទើបឥតមានភ័យក្នុងទីណាៗឡើយ ។ ម្នាលគហបតី អ្នកព្រមទាំងពួកញាតិទាំងអស់គ្នា ចូររស់នៅអស់កាលយូរ ម្នាលគហបតី អ្នកប្រព្រឹត្តធម៌ ឲ្យទានក្នុងលោកនេះ នឹងចូលទៅកាន់ទីស្ថានដែលមិនមានសោក មិនមានធូលីជាទីនៅនៃវសវត្តីទេវតាទាំងឡាយ ។

អ្នកចូរបន្ទោបង់នូវមន្ទិល គឺសេចក្តីកំណាញ់ព្រមទាំងឫស
គល់ចេញ ប្រាសចាកនិន្ទា ចូលទៅកាន់ឋានសួគ៌ ។

ចប់រឿងនន្ទាប្រេត ទី ៤ ។

## បញ្ចមំ មដ្ឋកុណ្ឌលិប្បេតវត្ថុ

(១៧) អលង្កតោ មដ្ឋកុណ្ឌលី

ៗ បេ ៗ

(វិមានវត្ថុស្មឹ សត្តមស្ស សុនិក្ខិត្តវគ្គស្ស នវមវត្ថុស្មឹ ទដ្ឋព្វំ)

មដ្ឋកុណ្ឌលិប្បេតវត្ថុ បញ្ចមំ ។

## ឆដ្ឋំ កណ្ហប្បេតវត្ថុ

(១៨) ឧដ្ឋេហិ កណ្ហ កឹ[១] សេសិ កោ អត្ថោ សុបនេន តេ
យោ ច តុយ្ហំ សកោ ភាតា ហទយំ ចក្ខុ ច ទក្ខិណំ
តស្ស វាតា ពលីយន្តិ[២] ឃដោ ជប្បតិ កេសវ ។
តស្ស តំ វចនំ សុត្វា រោហិណេយ្យស្ស កេសវោ
តរមានរូបោ វុដ្ឋាសិ[៣] ភាតុ សោកេន អដ្ដិតោ[៤] ។
កឹ នុ ឧម្មត្តរូបោវ កេវលំ ទ្វារកំ ឥមំ
សសោ សសោតិ លបសិ កីទិសំ សសមិច្ឆសិ
សោវណ្ណមយំ មណិមយំ លោហមយំ អថ រូបិយមយំ
សង្ខសិលាបវាឡមយំ ការយិស្សាមិ តេ សសំ[៥]

---
១ ម. កណ្ហេ តិ ។ ២ ម. ផលិយន្តិ ។ ៣ ម. វុដ្ឋាយ ។ ៤ ម. អដ្ដិតោ ។ ៥ ម. សសំ ។





## រឿងមដ្ឋកុណ្ឌលិប្រេត ទី ៥

*(១៧) អ្នកមានគ្រឿងប្រដាប់ហើយ មានកុណ្ឌលដ៏រលើង*

*ៗ បេ ៗ*

*(គួរមើលក្នុងរឿងទី ៩ នៃសុនិក្ខិត្តវគ្គទី ៧ ក្នុងវិមានវត្ថុ)*

ចប់ រឿងមដ្ឋកុណ្ឌលិប្រេត ទី ៥ ។

## រឿងកណ្ហប្រេត ទី ៦

*(១៨) (រោហិណេយ្យអាមាត្យក្រាបទូលថា) បពិត្រព្រះកណ្ហៈ ព្រះអង្គផ្ទំធ្វើអ្វី សូមព្រះអង្គក្រោកឡើង ប្រយោជន៍អ្វីដល់ព្រះអង្គដោយការផ្ទំលក់នេះ ខ្យល់កំពុងតែកំរើកឡើង ដល់ព្រះរាជកនិដ្ឋ ដែលដូចជាហឫទ័យនឹងចក្ខុខាងស្តាំរបស់ព្រះអង្គ បពិត្រព្រះអង្គមានព្រះកេសាល្អ ឃដបណ្ឌិតកំពុងតែរវើរវាយ ។*

*ព្រះបាទកេសវៈ ទ្រង់បានស្តាប់ពាក្យនោះ របស់រោហិណេយ្យអាមាត្យនោះហើយ ក៏ស្លុតព្រះហឫទ័យ ទ្រង់ក្រោកចាកក្រឡាព្រះបន្ទំហើយទ្រង់ទន្ទឹងរៀកខ្លួន ព្រោះសេចក្តីសោកចំពោះព្រះកនិដ្ឋ។*

*អ្នកមានសភាពជាមនុស្សឆ្កួតទេដឹង បានជាត្រាច់ទៅសព្វស្រុកទ្វារកៈនេះ ហើយស្រែកថា ទន្សាយៗ ដូច្នេះ អ្នកចង់បានទន្សាយអ្វី ទន្សាយមាស ទន្សាយកែវមណី ទន្សាយទង់ដែង ឬមួយទន្សាយប្រាក់ ទន្សាយស័ង្ខ សិលា កែវប្រពាឡ យើងនឹងប្រើគេឲ្យធ្វើទន្សាយឲ្យអ្នក*

សន្តិ អញ្ញេបិ សសកា   អរញ្ញេ វនគោចរា
តេបិ តេ អានយិស្សាមិ   កីទិសំ សសមិច្ឆសិ ។
នាហំ មេតេ សសេ ឥច្ឆេ   យេ សសា បឋវិស្សិតា[១]
ចន្ទតោ សសមិច្ឆាមិ   តំ មេ ឱហរ កេសវ ។
សោ នូន[២] មធុរំ ញាតិ   ជីវិតំ វិជហិស្សសិ
អបត្ថិយំ បត្ថយសិ   ចន្ទតោ សសមិច្ឆសិ ។
ឯវញ្ចេ កណ្ហ ជានាសិ   យថញ្ញមនុសាសសិ
កស្មា បុរេ មតំ បុត្តំ   អជ្ជាបិ មនុសោចសិ
ន តំ[៣] លព្ភា មនុស្សេន   អមនុស្សេន វា បន
ជាតោ មេ មា មរី បុត្តោ   កុតោ លព្ភា អលព្ភិយំ
ន មន្តា មូលភេសជ្ជា   ឱសធេហិ ធនេន វា
សក្កា អានយិតុំ កណ្ហ   យំ បេតមនុសោចសិ ។

---

១ ម. បឋវិសិតា ។ ២ ម. នូន ។ ៣ ម. យេ ។ ៤ ម. ន យំ ។



កុំពោរសោកទេ ពួកទន្សាយដទៃ ដែលត្រាច់ស៊ីស្មៅក្នុងព្រៃក៏មាន យើងនឹងនាំយកទន្សាយទាំងនោះមកឲ្យអ្នក តើអ្នកចង់បានទន្សាយដូចម្តេច ។

ទន្សាយទាំងឡាយណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំព្រះអង្គមិនប្រាថ្នាចង់បានទន្សាយទាំងនុ៎ះទេ ខ្ញុំព្រះអង្គប្រាថ្នាចង់បានតែទន្សាយអំពីដួងព្រះចន្ទ្រ បពិត្រព្រះអង្គមានព្រះកេសាខ្មៅ សូមព្រះអង្គនាំយកទន្សាយនោះមកឲ្យខ្ញុំ ។

ម្នាលកនិដ្ឋញាតិ អ្នកនោះនឹងក្ស័យជីវិតដ៏ថ្លៃថ្លា អ្នកប្រាថ្នារបស់ដែលមិនគួរប្រាថ្នា ព្រោះអ្នកប្រាថ្នាទន្សាយអំពីដួងព្រះចន្ទ្រ ។

បពិត្រព្រះអង្គមានព្រះកេសាខ្មៅ បើព្រះអង្គទ្រង់ជ្រាបយ៉ាងនេះហើយ គួរតែព្រះអង្គប្រៀនប្រដៅអ្នកដទៃបាន ចុះក្នុងថ្ងៃនេះ ហេតុដូចម្តេច បានជាព្រះអង្គ ទ្រង់ព្រះកន្សែងនឹងបុត្តដែលធ្វើមរណកាលក្នុងកាលមុន ។ (ពាក្យថា) បុត្តរបស់យើងកើតមកហើយកុំស្លាប់ទៅវិញ ពាក្យនោះ មនុស្សនឹងទេវតាមិនដែលបានឮបានស្តាប់ឡើយ ព្រះអង្គគប្បីបានខ្លួនរបស់ដែលមិនគួរបានអំពីទីណា បពិត្រព្រះអង្គមានព្រះកេសាខ្មៅ ព្រះអង្គទ្រង់សោយសោកចំពោះបុគ្គលដែលទៅកាន់បរលោកហើយនោះ ព្រះអង្គមិនអាច ដើម្បីនឹងនាំយកមកវិញបាន ដោយមន្ត ដោយមូលភេសជ្ជៈ ដោយឱសថ ឬដោយទ្រព្យឡើយ ។

មហទ្ធនា មហាភោគា    រដ្ឋវន្តាបិ ខត្តិយា
បហូតធនធញ្ញាសេ    តេបិ នោ អជរាមរា ។
ខត្តិយា ព្រាហ្មណា វេស្សា    សុទ្ទា ចណ្ឌាលបុក្កុសា
ឯតេ ចញ្ញេ[១] ច ជាតិយា    តេបិ នោ អជរាមរា ។
យេ មន្តំ បរិវត្តេន្តិ    ឆឡង្គំ ព្រហ្មចិន្តិតំ
ឯតេ ចញ្ញេ[២] ច វិជ្ជាយ    តេបិ នោ អជរាមរា ។
ឥសយោ ចាបិ យេ សន្តា    សញ្ញតត្តា តបស្សិនោ
សរីរំ តេបិ កាលេន    វិជហន្តិ តបស្សិនោ ។
ភាវិតត្តា អរហន្តោ    កតកិច្ចា អនាសវា
និក្ខិបន្តិ ឥមំ ទេហំ    បុញ្ញបាបបរិក្ខយា ។
អាទិត្តំ វត មំ សន្តំ    ឃតសិត្តំវ បាវកំ
វារិនា វិយ ឱសិញ្ចំ[៣]    សព្វំ និព្វាបយេ ទរំ ។
អព្ពហី[៤] វត មេ សល្លំ    សោកំ ហទយនិស្សិតំ
យោ មេ សោកបរេតស្ស    បុត្តសោកំ អបានុទិ

---

១.២ ឱ. មញ្ញេ ។ ៣ ឱ. ម. ឱសិញ្ចំ ។ ៤ ឱ. ម. អព្ពុឡ្ហំ ។



ពួកជនអ្នកមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើនក្តី ពួកក្សត្រិយ៍ដែលនៅក្នុងរដ្ឋមណ្ឌល មានទ្រព្យនិងស្រូវដ៏ច្រើនក្តី ជនទាំងនោះក៏នៅមិនរួចអំពីជរានិងមរណៈឡើយ ។ ក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រៈក្តី ចណ្ឌាលក្តី បុក្កុសៈក្តី ជនទាំងនុ៎ះផ្សេងគ្នាដោយជាតិ ជនទាំងនោះឯង ក៏មិនរួចអំពីជរានិងមរណៈ ។ ជនទាំងឡាយណាប្រព្រឹត្តនូវព្យាយមន្ត ប្រកបដោយអង្គ ៦ ដែលព្រហ្មបានគិតហើយ ជនទាំងនុ៎ះផ្សេងគ្នាដោយវិជ្ជា ជនទាំងនោះឯង ក៏មិនរួចអំពីមរណៈដែរ ។ ម្យ៉ាងទៀត ពួកឥសីណា ជាអ្នករម្ងាប់ជាអ្នកសង្រួមកាយនិងចិត្ត មានព្យាយាមដុតកំដៅកិលេស ពួកឥសីដែលមានព្យាយាម ដុតកំដៅកិលេសនោះឯង ក៏រមែងលះបង់សរីរៈទៅតាមកាល ។ ព្រះអរហន្តទាំងឡាយ អ្នកមានខ្លួនចំរើនហើយ មានកិច្ចបានធ្វើស្រេចហើយ មានអាសវៈអស់ហើយ រមែងដាក់ចុះនូវកាយនេះ ព្រោះអស់បុណ្យនិងបាប ។

ប្អូនញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួងរបស់យើងដែលក្តៅដោយភ្លើងគឺសេចក្តីសោកឱ្យរលត់ ដូចបុគ្គលយកទឹកទៅស្រោចស្រង់ភ្លើងដែលឆេះនឹងខ្លាញ់ ។ សរគឺសេចក្តីសោកដែលអាស្រ័យនៅក្នុងហឫទ័យរបស់យើង អ្នកក៏បានដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្តីសោកព្រោះកូនរបស់យើងដែលមានសេចក្តីសោកគ្របសង្កត់ហើយ

ស្វាហំ អព្វុឡ្ហសល្លោស្មិ សីតិភូតោស្មិ និព្វុតោ ។
ន សោចាមិ(១) ន រោទាមិ តវ សុត្វាន ភាសិតំ
ឯវំ ករោន្តិ សប្បញ្ញា យេ ហោន្តិ អនុកម្បកា
និវត្តយន្តិ(២) សោកម្ហា ឃដោ ជេដ្ឋំ ភាតរំ
យស្ស ឯតាទិសា ហោន្តិ អមច្ចា បរិចារកា
សុភាសិតេន អន្វេន្តិ(៣) ឃដោ ជេដ្ឋំវ ភាតរន្តិ ។

កណ្ហប្បេតវត្ថុ ឆដ្ឋំ ។

## សត្តមំ ធនបាលប្បេតវត្ថុ

(១៩) នគ្គោ ទុព្វណ្ណរូបាសិ កិសោ ធមនិសន្ថតោ
ឧប្ផាសុលិកោ កិសិកោ កោ នុ ត្វំ អសិ មារិសាតិ ។
អហំ ភទន្តេ បេតោម្ហិ ទុគ្គតោ យមលោកិកោ
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតោតិ ។
កឹ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បេតលោកំ ឥតោ គតោតិ ។

១ ម. នោ សោចាមិ ។ ២ ម. វិនិវត្តយតិ ។ ៣ ម. អន្វេសិ ។



យើងនោះមានសរគឺសេចក្ដីសោកបានដកចេញហើយ ជាអ្នកត្រជាក់ ហើយមានទុក្ខរលត់ហើយ ។ យើងលែងសោក លែងយំហើយ ព្រោះបានស្ដាប់ភាសិតរបស់អ្នក ជនទាំងឡាយណា ប្រកបដោយបញ្ញា ជាអ្នកអនុគ្រោះ ជនទាំងនោះធ្វើយ៉ាងនេះ ឃដបណ្ឌិត បានញុំាងបងឲ្យត្រឡប់ចាកសេចក្ដីសោក អាមាត្យទាំងឡាយ ដែលជាអ្នកបំរើរបស់ព្រះរាជាអង្គណា ក៏រមែងប្រាកដដូច្នោះ ដូចជា ឃដបណ្ឌិត បានញុំាងបងឲ្យប្រព្រឹត្តទៅតាមសុភាសិត ។

ចប់ រឿងកណ្ហប្រេត ទី ៦ ។

## រឿងធនបាលប្រេត ទី ៧

(១៩) (ពួកពាណិជសួរថា) អ្នកជាបុគ្គលអាក្រាត មានរូបមានសម្បុរអាក្រក់ ស្គាំងស្គម រេមរោមដោយសរសៃ មានឆ្អឹងជំនីរតាមស្គម ម្នាលអ្នកនិទ្ទុក្ខ ចុះអ្នកជាអ្វី ។

(ប្រេតតបថា) បពិត្រអ្នកទាំងឡាយដ៏ចំរើន ខ្ញុំជាប្រេតដល់នូវសេចក្ដីទុក្ខ ជាយមលោកសត្វ ព្រោះធ្វើអំពើអាក្រក់ ទើបទៅអំពីមនុស្សលោកនេះ កាន់បេតលោក ។

ចុះអំពើអាក្រក់ ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត ដូចម្ដេច អ្នកទៅ អំពីមនុស្សលោកនេះ កាន់បេតលោក ព្រោះវិបាកនៃកម្មដូចម្ដេច ។

នគរំ អត្ថិ ទសណ្ណានំ[១] ឯរកច្ឆន្តិ វិស្សុតំ
តត្ថ សេដ្ឋី បុរេ អាសឹ ធនបាលោតិ មំ វិទូ ។
អសីតិ សកដវាហានំ ហិរញ្ញស្ស អហោសិ មេ
បហូតំ មេ ជាតរូបំ មុត្តាវេឡុរិយា ពហូ ។
តាវ មហទ្ធនស្សាបិ ន មេ ទាតុំ បិយំ អហុ
បិទហិត្វា ទ្វារំ ភុញ្ជាមិ មា មំ យាចនកាទ្ទសុំ ។
អស្សទ្ធោ មច្ឆរី ចាសឹ កទរិយោ បរិភាសកោ
ទទន្តានំ ករោន្តានំ វារយិស្សំ ពហុជ្ជនំ[២] ។
វិបាកោ នត្ថិ ទានស្ស សំយមស្ស កុតោ ផលំ
បោក្ខរញ្ញោទបានានិ អារាមានិ ច រោបិតេ
បបាយោ ច វិនាសេសឹ ទុគ្គេ សង្កមនានិ ច ។
ស្វាហំ អកតកល្យាណោ កតបាបោ តតោ ចុតោ
ឧប្បន្នោ បេត្តិវិសយំ[៣] ខុប្បិបាសសមប្បិតោ
បញ្ចបញ្ញាសវស្សានិ តតោ កាលកតោ អហំ ។
នាភិជានាមិ ភុត្តំ វា បីតំ វា បន បានិយំ
យោ សំយមោ សោ វិនាសោ យោ វិនាសោ សោ សំយមោ
បេតា ហិ កិរ ជានន្តិ យោ[៤] សំយមោ សោ វិនាសោ ។

១ ម. អត្ថិ បណ្ណានំ ។ ២ ម. ពហុជ្ជនេ ។ ៣ ម. បេត្តិវិសយំ ។ ៤ ម. សោ ។



មាននគរមួយ ឈ្មោះឯរកច្ឆៈ ក្នុងដែនទសណ្ណៈ ក្នុងកាលមុន ខ្ញុំកើតជាសេដ្ឋី ក្នុងនគរនោះ គេស្គាល់ខ្ញុំថាធនបាល ។ ខ្ញុំមានប្រាក់ ៨០ រទេះ មានមាសច្រើន មានកែវមុក្តា និងកែវពិទូរ្យច្រើន ។ ការឲ្យទានមិនជាទីពេញចិត្តរបស់ខ្ញុំ អ្នកមានទ្រព្យច្រើនដល់ម្លោះ ខ្ញុំក៏បិទទ្វារផ្ទះបរិភោគ មិនឲ្យពួកយាចកឃើញខ្ញុំឡើយ ។ ខ្ញុំជាអ្នកមិនមានសទ្ធា កំណាញ់ស្វិតស្វាញ ជេរប្រទេចពួកជនអ្នកឲ្យ អ្នកធ្វើ បានឃាត់ឃាំងពួកជនដ៏ច្រើន ។ ផលនៃទានមិនមាន ផលនៃការសង្រួមនឹងមានមកអំពីណា ខ្ញុំបានបំផ្លាញស្រះបោក្ខរណីនិងអណ្តូងទឹកផង របស់ដែលគេដាំក្នុងអារាមផង រោងទឹកផង ស្ពានក្នុងទីទៅបានដោយលំបាកផង ។ ខ្ញុំនោះមិនបានធ្វើល្អ ធ្វើតែការអាក្រក់ ច្យុតអំពីមនុស្សលោកនោះទៅកើតក្នុងកំណើតប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លានអស់ ៥៥ ឆ្នាំ តាំងពីខ្ញុំធ្វើមរណកាលអំពីអត្តភាពនោះ ។ ខ្ញុំមិនបានបរិភោគបាយ ឬផឹកទឹកឡើយ សេចក្តីសំចៃ (មិនឲ្យទាន) ណា នោះជាសេចក្តីវិនាស សេចក្តីវិនាសណា នោះជាសេចក្តីសំចៃ បានឮថា ប្រេតទាំងឡាយរមែងដឹងថា សេចក្តីសំចៃណា នោះជាសេចក្តីវិនាស ។

អហំ បុរេ សំយមិស្សំ  នាទាសិំ ពហុកេ ធនេ
សន្តេសុ ទេយ្យធម្មេសុ  ទីបំ នាកាសិមត្តនោ[១] ។
សោហំ បច្ឆានុតប្បាមិ  អត្តកម្មផលូបគោ
ឧទ្ធំ ចតូហិ មាសេហិ  កាលកិរិយា ភវិស្សតិ ។
ឯកន្តកដុកំ ឃោរំ  និរយំ បបតិស្សហំ
ចតុក្កណ្ណំ ចតុទ្វារំ  វិភត្តំ ភាគសោ មិតំ
អយោបាការបរិយន្តំ  អយសា បដិកុជ្ជិតំ ។
តស្ស អយោមយា ភូមិ  ជលិតា តេជសា យុត្តា
សមន្តា យោជនសតំ  ផរិត្វា តិដ្ឋតិ សព្វទា ។
តត្ថាហំ ទីឃមទ្ធានំ  ទុក្ខំ វេទិស្ស វេទនំ
ផលំ បាបស្ស កម្មស្ស  តស្មា សោចាមហំ ភុសំ ។
តំ វោ វទាមិ ភទ្ទំ វោ  យាវន្តេត្ថ សមាគតា
មាកត្ថ បាបកំ កម្មំ  អាវី វា យទិ វា រហោ ។
សចេ តំ បាបកំ កម្មំ  ករិស្សថ ករោថ វា
ន វោ[២] ទុក្ខា បមុត្តត្ថិ  ឧបច្ចាបិ[៣] បលាយតំ
មត្តេយ្យា[៤] ហោថ បេត្តេយ្យា  កុលេ ជេដ្ឋាបចាយិកា
សាមញ្ញា ហោថ ព្រហ្មញ្ញា  ឯវំ សគ្គំ គមិស្សថាតិ ។

---

១ ឱ. ម. តាកាសិមត្តនោ ។ ២ ម. តេ ។ ៣ ឱ. ឧបច្ចាបិ ។ ៤ ម. មេត្តេយ្យា ។



អំពីជាតិមុន ខ្ញុំបានសំចៃ តែមិនបានឲ្យទ្រព្យទាំងឡាយដ៏ច្រើន កាលទេយ្យធម៌ទាំងឡាយមាននៅ ខ្ញុំមិនបានធ្វើទីពឹងដល់ខ្លួនឡើយ ។ ខ្ញុំនោះក្ដៅក្រហាយក្នុងកាលជាន់ក្រោយ អន្ទោលទៅតាមផលកម្មរបស់ខ្លួន កាលកិរិយាក៏មានដោយការកន្លងទៅនៃខែ ៤ ។ ខ្ញុំធ្លាក់ទៅលើក្នុងនរកដ៏ខ្លាំងក្លា ក្ដៅផ្សា ជានរកមានជ្រុង ៤ មានទ្វារ ៤ ចែកដោយចំណែកដែលគេចែកស្មើគ្នា មានរបងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ផ្ទៃផែនដីជាន់ក្រោមនៃមហានរកនោះ សុទ្ធតែដែក មានភ្លើងឆេះភ្លឺព្រោងព្រាត ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វកាល ។ ខ្ញុំបានសោយទុក្ខវេទនា អស់កាលយូរអង្វែង ក្នុងនរកនោះ ដោយផលនៃបាបកម្ម ព្រោះហេតុនោះ ខ្ញុំទើបសោកស្ដាយក្រៃពេកណាស់ ។ ខ្ញុំប្រាប់សេចក្ដីនោះដល់អ្នកទាំងឡាយ អ្នកទាំងឡាយមកកាន់ទីប្រជុំនេះមានប្រមាណប៉ុន្មាន សេចក្ដីចំរើនចូរមានដល់អ្នកទាំងឡាយ អ្នកទាំងឡាយកុំធ្វើកម្មលាមក ទោះក្នុងទីកំបាំងក្ដី ក្នុងទីស្ងាត់ឡើយ ។ បើអ្នកទាំងឡាយ នឹងធ្វើ ឬធ្វើនូវបាបកម្មលាមកនោះ ទោះបីអ្នកទាំងឡាយ ហោះទៅលើអាកាស ក៏មិនផុតអំពីសេចក្ដីទុក្ខ អ្នកទាំងឡាយគប្បីប្រតិបត្តិមាតាបិតា គោរពក្រែងដល់បុគ្គលចាស់ទុំក្នុងត្រកូល គប្បីធ្វើការបូជា ដល់សមណព្រាហ្មណ៍ អ្នកទាំងឡាយនឹងទៅឋានសួគ៌ដោយបុញ្ញកម្មយ៉ាងនេះ ។

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតិ សោ ជគតិប្បទេសោ
យត្ថដ្ឋិតោ មុញ្ចេយ្យ បាបកម្មា ។

ធនបាលបេតវត្ថុ សត្តមំ ។

## អដ្ឋមំ ចូឡសេដ្ឋិបេតវត្ថុ

(២០) នគ្គោ កិសោ បព្វជិតោសិ ភន្តេ
រត្តិំ កុហិំ គច្ឆសិ កិស្ស ហេតុ
អាចិក្ខ មេ តំ[1] អបិ សក្កុណេមុ
សព្វេន វិត្តំ បដិបាទយេ តុវំ ។
ពារាណសី នគរំ ទូរឃុដ្ឋំ
តត្ថាហំ គហបតិ អឌ្ឍកោ អហុ[2] ទីនោ[3]
អទាតា គេធិតមនោ អាមិសស្មិំ
ទុស្សីល្យេន[4] យមវិសយម្ហិ បត្តោ ។
សោ សូចិកាយ កិលមិតោ តេហិ តេនេវ
ញាតីសុ យាមិ អាមិសកិញ្ចិក្ខហេតុ
អទានសីលា ន ច សទ្ទហន្តិ

១ ម. តុំ ។ ២ ឱ. អឌ្ឍកោ ឥទ្ធិ ។ ៣ ឱ. ទីនោ ។ ៤ ឱ. ម. ទុស្សីល្យេន ។



ទោះទៅក្នុងអាកាស ក៏មិនរួច (អំពីបាបកម្ម) ចូលទៅក្នុងកណ្តាលសមុទ្រ ក៏មិនរួច ចូលទៅក្នុងចន្លោះភ្នំ ក៏មិនរួច បុគ្គលឋិតនៅ ក្នុងប្រទេសនៃផែនដីណា ហើយរួចចាកបាបកម្មបាន ប្រទេសនៃផែនដីនោះ មិនមានឡើយ ។

ចប់ រឿងធនបាលប្រេត ទី ៧ ។

## រឿងចូឡសេដ្ឋីប្រេត ទី ៨

(២០) (ព្រះបាទអជាតសត្រូវទ្រង់សួរថា) បពិត្រលោកដ៏ចំរើន លោកជាបព្វជិត[1] មានកាយគគ្រោក ស្គាំងស្គម ហេតុអ្វីបានជាលោកទៅកាន់ទីណាក្នុងវេលារាត្រី សូមលោកប្រាប់ហេតុនោះដល់ខ្ញុំ ខ្ញុំនឹងអាចចាត់ចែងទ្រព្យទាំងពួង តាមអធ្យាស្រ័យនៃលោក ។

(ប្រេតតបថា) ក្រុងពារាណសី មានកិត្តិសព្ទល្បីទៅក្នុងទីឆ្ងាយ ខ្ញុំជាគហបតី មានទ្រព្យច្រើន ក្នុងក្រុងពារាណសីនោះ ជាអ្នកកំណាញ់មិនឲ្យទាន មានចិត្តជាប់នៅក្នុងអាមិសៈ ដល់នូវយមវិស័យ (បេតលោក) ដោយការទ្រុស្តសីល ។ ខ្ញុំជាបុគ្គលលំបាកដោយសេចក្តីស្រេកឃ្លាន ប្រាកដដូចជាម្ជុលចាក់នៅជាប់ ព្រោះអំពើអាក្រក់នោះ ទើបទៅកាន់ញាតិ ជាហេតុនឹងបានអាមិសៈតិចតួច (ពួកមនុស្សណា) មិនឲ្យទាន មិនជឿថា

១ បានជាព្រះបាទអជាតសត្រូវ ទ្រង់សួរប្រេតនោះយ៉ាងនេះ ព្រោះទ្រង់ឃើញក្បាលប្រេតនោះប្រាកដដូចអ្នកបួស (អដ្ឋកថា) ។

ទានំ ផលំ ហោតិ បរម្ហិ លោកេ ។
ធីតា ច មយ្ហំ លបតេ អភិក្ខណំ
ទស្សាមិ ទានំ បិតុនំ បិតាមហានំ
ឧបក្ខដំ បរិវិសយន្តិ ព្រាហ្មណា
យាមហំ អន្ធកវិន្ទំ ភុត្តុំ ។
តមព្រវិ រាជា ត្វមនុភវិយាន តម្បិ
ឯយ្យាសិ ខិប្បំ អហម្បិ ការិស្សំ បូជំ
អាចិក្ខ មេ តំ យទិ អត្ថិ ហេតុ
សទ្ធាយិតំ ហេតុវចោ[1] សុណោម ។
តថាតិ វត្វា អគមាសិ តត្ថ
ភុញ្ជីសុ ភត្តំ ន ច ទក្ខិណារហា[2]
បច្ចាគមី[3] រាជគហំ បុនាបរំ
បាតុរហោសិ បុរតោ ជនាធិបស្ស ។
ទិស្វាន បេតំ បុនទេវ[4] អាគតំ
រាជា អវោច អហម្បិ កឹ ទទាមិ
អាចិក្ខ មេ តំ យទិ អត្ថិ ហេតុ
យេន តុវំ ចិរតរំ បីណិតោ សិយា ។

១ ម. ហេតុវចោ ។ ២ ម. ន ចន ទក្ខិណារហា ។ ឱ. ន ច ទក្ខិណារហា ។
៣ អដ្ឋកថាយំ បច្ចាគមីតិ ទិស្សតិ ។ ៤ ម. បុនរេ ។



ផលទានមានក្នុងបរលោក (មនុស្សទាំងនោះតែងនាំទៅកើតជាប្រេត រឺទុក្ខច្រើនដូចជាខ្ញុំ) ។ ធីតារបស់ខ្ញុំ តែងនិយាយរឿយៗថា អាត្មាអញនឹងឲ្យទានដល់បិតា ដល់ជីតា ក៏បានឲ្យព្រាហ្មណ៍ទាំងឡាយបរិភោគភោជនដែលខ្ញុំតាក់តែង ខ្ញុំទៅកាន់អន្ធកវិន្ទនគរ ដើម្បីបរិភោគនូវផលទាននោះ ។

ព្រះបាទអជាតសត្រូវ បានត្រាស់សួរទៅប្រេតនោះថា អ្នកបានទទួលផលទាន (ដែលធីតារបស់អ្នកបានតាក់តែងឲ្យហើយ) នោះ គប្បីត្រឡប់វិលមកវិញឆាប់ យើងនឹងធ្វើការបូជា (ដល់អ្នក) បើមានហេតុ អ្នកចូរប្រាប់ហេតុនោះដល់យើង យើងនឹងស្ដាប់ពាក្យប្រកបដោយហេតុដែលគួរជឿ ។

ប្រេតនោះពោលថា ល្អហើយ បានទៅកាន់អន្ធកវិន្ទនគរ នោះ ពួកព្រាហ្មណ៍បរិភោគភត្ត តែជាអ្នកមិនគួរដល់ទក្ខិណា (ព្រោះជាព្រាហ្មណ៍ទុស្សីល) ខាងក្រោយមក ប្រេតនោះក៏ទៅនគររាជគ្រឹះវិញ ក៏ប្រាកដចំពោះព្រះភក្ត្រ ព្រះបាទអជាតសត្រូវជាធំជាងជន ។

ព្រះរាជាបានទតឃើញប្រេតមកហើយ ត្រាស់សួរថា យើងនឹងឲ្យនូវអ្វី អ្នកជាបុគ្គលឆ្អែតអស់កាលយូរ ដោយហេតុណា បើហេតុនោះមាន អ្នកចូរប្រាប់ដល់យើង ។

តុវញ្ច សង្ឃំ អភិសិយាន កដ
អន្នេន បានេនបិ ចីវរេន
តំ ទក្ខិណំ អាទិស មេ ហិតាយ
យំ អហំ ចិររត្តំ បីណិតោ សិយា ។
តតោ ច រាជា និបតិត្វា[១] តាវទេ
ទានំ សហត្ថា អតុលញ្ច ទត្វា[២]
សង្ឃេ ច អារោចយិ បកតឹ[៣] តថាគតស្ស
[៤]បេតស្ស ទក្ខិណំ អាទិសិត្ថ ។
សោ បូជិតោ អតិវិយ[៥] សោភមានោ
បាតុរហោសិ បុរតោ ជនាធិបស្ស
យក្ខោហមស្មិ បរមិទ្ធិបត្តោ
ន មយ្ហំ ឥទ្ធិសមសទិសា មានុសា ។
បស្សានុភាវំ អបរិមិតំ មមយិទំ
តយានុទិដ្ឋំ អតុលំ ទត្វា សង្ឃេ
សន្តប្បិតោ សតតំ សទា ពហូហិ
យាមិ អហំ សុខិតោ មនុស្សទេវាតិ ។

ចូឡសេដ្ឋិបេតវត្ថុ អដ្ឋមំ ។

---

១ ម. បរិវិសិត្វា ។ ២ ម. ទទិត្វា ។ ៣ ម. សង្ឃេ អារោចេសិ បកតឹ ។
៤ ម. តំ បហេ តស្ស ទានំ អន្នំ ។ ៥ ម. អតីវ ។



បពិត្រមហារាជ សូមព្រះអង្គអង្គាសព្រះពុទ្ធផង ព្រះសង្ឃផង ដោយបាយ ទឹក និងចីវរ ហើយសូមឧទ្ទិសនូវទក្ខិណាទាននោះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ខ្ញុំគប្បីជាបុគ្គលឆ្អែតឆ្អន់អស់កាលយូរ ដោយប្រការយ៉ាងនេះ ។

ក្នុងកាលនោះ ព្រះរាជាស្ដេចចុះចាកប្រាសាទនោះ ហើយថ្វាយនូវទាន មានឧបមាគេប្រមាណមិនបាន ដោយព្រះហស្តព្រះអង្គឯង ដល់ព្រះសង្ឃ ហើយក្រាបទូលនូវពិធីទានដែលបានធ្វើចំពោះព្រះតថាគត ហើយឧទ្ទិសនូវទក្ខិណាទានដល់ប្រេត ។

ប្រេតនោះ ដែលព្រះរាជាបូជាហើយ ក៏រុងរឿងក្រៃពេក ប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជាជាធំជាងជន ពោលថា ខ្ញុំព្រះអង្គជាយក្ស សម្រេចនូវឫទ្ធិដ៏ឧត្តម ពួកមនុស្សមានឫទ្ធិប្រាកដស្មើនឹងខ្ញុំគ្មាន ។ សូមព្រះអង្គទ្រង់ទតមើល នូវអានុភាពរបស់ខ្ញុំ គេប្រមាណមិនបាននេះ ទានដ៏ឧត្តមដែលព្រះអង្គឧទ្ទិសហើយឲ្យចំពោះសង្ឃ បពិត្រមនុស្សទេព ខ្ញុំព្រះអង្គ ជាបុគ្គលឆ្អែតស្កប់ស្កល់ ដោយវត្ថុទាំងឡាយច្រើនរឿយៗ សព្វកាល ក៏បាននូវសេចក្ដីសុខ ឥឡូវសូមលាទៅ ។

ចប់រឿងចូឡសេដ្ឋិប្រេតទី ៨ ។

## នវមំ អង្កុរបេតវត្ថុ

(៦១)យស្ស អត្ថាយ គច្ឆាម កម្ពោជំ ធនហារកា
អយំ កាមទទោ យក្ខោ ឥមំ យក្ខំ នយាមសេ
ឥមំ យក្ខំ គហេត្វាន សាធុកេន បសយ្ហ វា
យានំ អារោបយិត្វាន ខិប្បំ គច្ឆាម ទ្វារកំ ។
យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។
យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ខន្ធម្បិ តស្ស ឆិន្ទេយ្យ អត្ថោ ចេ តាទិសោ សិយា ។
យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស បត្តំ ភិន្ទេយ្យ[១] មិត្តទុព្ភោ ហិ បាបកោ ។
យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
សមូលម្បិ តំ អព្ពុយ្ហ[២] អត្ថោ បេ[៣] តាទិសោ សិយា ។
យស្សេករត្តឹ ហិ ឃរេ វសេយ្យ
យត្ថន្នបានំ[៤] បុរិសោ លភេថ
ន តស្ស បាបំ មនសាបិ ចេតយេ[៥]
កតញ្ញុតា សប្បុរិសេហិ វណ្ណិតា ។

១ ម. ហិំសេយ្យ ។ ២ ឱ. អព្ពុហេ ។ ៣ ម. ចេ ។ ៤ ម. យស្សន្នបានំ ។ ៥ ម. ចិន្តយេ ។





## រឿងអង្កុរប្រេត ទី ៩

(៦១) (ព្រាហ្មណ៍និយាយថា) យើងទាំងឡាយ ជាអ្នកស្វែងរកទ្រព្យ ទៅកាន់ដែនកម្ពុជៈ ព្រោះហេតុនៃទ្រព្យណា យក្សនេះជាអ្នកឲ្យទ្រព្យតាមប្រាថ្នា យើងនឹងនាំយកយក្សនេះទៅ ឬថា យើងចាប់យកយក្សនេះ ហើយនឹងអង្វរឲ្យបានដោយពីរោះ លើកឡើងកាន់យាន ហើយទៅកាន់ទ្វារកនគរ ដោយឆាប់រហ័ស ។

(អង្កុរៈតបថា) បុគ្គលអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគួរកាប់មែកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមក ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា គប្បីកាត់ឈើនោះបានខ្លះ បើមានប្រយោជន៍ត្រូវដោយការកាត់នោះ ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគប្បីគួចស្លឹកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមក ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា គប្បីដកឈើនោះព្រមទាំងឫសបានខ្លះ បើមានប្រយោជន៍ត្រូវដោយការដកនោះ ។

បុរសគប្បីនៅក្នុងផ្ទះ នៃបុគ្គលណា សូម្បីអស់មួយរាត្រី
បុរសគប្បីបានបាយទឹកក្នុងទីណាក់ នៃបុគ្គលណា មិនគប្បីគិតនូវគំនិតអាក្រក់ ដល់បុគ្គលនោះ សូម្បីដោយចិត្តឡើយ
ពួកសប្បុរស តែងសរសើរនូវការនៃបុគ្គលកតញ្ញូ ។

យស្សេករត្តិម្បិ ឃរេ វសេយ្យ
អន្នេន បានេន ឧបដ្ឋិតោ សិយា
ន តស្ស បាបំ មនសាបិ ចេតយេ[១]
អទុព្ភបាណី ទហតេ មិត្តទុព្ភី ។

យោ បុព្វេ កតកល្យាណោ បច្ឆា បាបេន ហឹសតិ
អល្លបាណិហតោ[២] បោសោ ន សោ ភទ្រានិ បស្សតិ ។

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។

នាហំ ទេវេន វា មនុស្សេន វា
ឥស្សរិយេន វាហំ សុប្បសយ្ហោ[៣]
យក្ខោហមស្មិ បរមិទ្ធិបត្តោ
ទូរង្គមោ វណ្ណពលូបបន្នោ ។

បាណិ តេ សព្វសោវណ្ណោ បញ្ចធារោ មធុស្សវោ
នានារសា បគ្ឃរន្តិ មញ្ញេហំ តំ បុរិន្ទទំ ។

១ ម. ចិន្តយេ ។ ២ ម. អល្លបាណិំហតោ ។ ៣ ម. ទុប្បសយ្ហោ ។



បុរសគប្បីនៅក្នុងផ្ទះនៃបុគ្គលណា សូម្បីអស់មួយរាត្រី ដែលគេទំនុកបម្រុងដោយបាយនិងទឹក មិនគប្បីគិតអំពើអាក្រក់ដល់បុគ្គលនោះ សូម្បីដោយចិត្តឡើយ បុគ្គលមានដៃមិនប្រទូស្ត តែងដុតកំដៅនូវបុគ្គលដែលប្រទូស្តមិត្ត ។

សត្វណាបៀតបៀន នូវបុគ្គលដែលធ្វើឧបការៈមុន ដោយអំពើអាក្រក់ ក្នុងកាលជាខាងក្រោយ សត្វនោះជាអ្នកបៀតបៀន នូវបុគ្គលជាអ្នកមានបាតដៃទទឹក[១] រមែងមិនឃើញ នូវសេចក្ដីចំរើនទេ ។

បុគ្គលណា ប្រទូស្តដល់នរជន ដែលមិនបានប្រទូស្ត ជាបុគ្គលស្អាត មិនមានទីទួលគឺកិលេស បាបរមែងត្រឡប់ទៅរកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។ ខ្ញុំនោះបើទេវតាក្ដី មនុស្សក្ដី កំចាត់កំចាយដោយឥស្សរិយយសមិនបានឡើយ ខ្ញុំនេះជាយក្សសម្រេចនូវឫទ្ធិដ៏ឧត្ដម ទៅក្នុងទីឆ្ងាយបាន ប្រកបដោយរូបសម្បត្តិនិងកំឡាំង ។

ដៃទាំងអស់របស់អ្នក មានសម្បុរដូចជាមាស ទ្រទ្រង់នូវតែជាទីច្រាប់ដោយអង្គុលីទាំង ៥ បញ្ចេញនូវរសផ្អែម រសទាំងឡាយផ្សេងៗរមែងហូរចេញ ខ្ញុំសំគាល់ថាជាសក្កទេវរាជ ឈ្មោះបុរិន្ទទៈ ។

១ មានបាតដៃទទឹក សំដៅយកអ្នកធ្វើឧបការៈ ។

នាហំ ទេវោ ន គន្ធព្វោ នាបិ(១) សក្កោ បុរិន្ទទោ
ពេតំ អង្កុរ ជានាហិ រោរុវម្ហា(២) ឥធាគតំ ។
កឹសីលោ កឹសមាចារោ រោរុវម្ហិ(៣) បុរេ តុវំ
កេន តេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។
តន្តវាយោ បុរេ អាសឹ រោរុវស្មឹ(៤) តទា អហំ
សុកិច្ឆវុត្តិ កបណោ ន មេ វិជ្ជតិ ទាតវេ ។
និវេសនញ្ច(៥) មេ អាសិ អសយ្ហស្ស ឧបន្តិកេ
សទ្ធស្ស ទានបតិនោ កតបុញ្ញស្ស លជ្ជិនោ ។
តត្ថ យាចនកា យន្តិ នានាគោត្តា វណិព្វកា
តេ ច មំ តត្ថ បុច្ឆន្តិ អសយ្ហស្ស និវេសនំ ។
កត្ថ គច្ឆាម(៦) ភទ្ទំ វោ កត្ថ ទានំ បទីយតិ
តេសាហំ(៧) បុដ្ឋោ អក្ខាមិ(៨) អសយ្ហស្ស និវេសនំ ។

១ ម. នម្ហិ ។ ២ ឱ. រោរុវម្ហា ។ ៣-៤ ឱ. រោរុវស្មឹ ។ ម. រោរុវស្មឹ ។ ៥ ឱ. អាវេសនញ្ច ។ ៦ ឱ. គច្ឆាមិ ។ ៧ ឱ. តេសាហំ ។ ៨ ឱ. វក្ខាមិ ។



ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រឈ្មោះបុរិន្ទទះទេ ម្នាលអង្កុរៈ អ្នកចូរដឹងនូវខ្លួនខ្ញុំថាជាប្រេត[១] ច្យុតអំពីរោរុវនរក (មកកើត) ក្នុងទីនេះវិញ ។

អំពីជាតិមុន កាលអ្នកនៅក្នុងរោរុវនគរ មានសីលដូចម្តេច មានសមាចារដូចម្តេច ផលបុណ្យសម្រេចក្នុងដៃរបស់អ្នក ដោយការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូចម្តេច ។

អំពីជាតិមុន កាលនោះខ្លួនខ្ញុំជាអ្នកតម្បាញ នៅក្នុងរោរុវនគរ ជាអ្នកប្រព្រឹត្តចិញ្ចឹមជីវិតដោយលំបាក ជាមនុស្សកំព្រា វត្ថុដែលគួរឲ្យទានមិនមានដល់ខ្ញុំទេ តែទីលំនៅរបស់ខ្ញុំនៅជិត (ផ្ទះ) នៃអសយ្ហមហាសេដ្ឋី ដែលជាអ្នកប្រកបដោយសទ្ធា ជាម្ចាស់នៃទាន ធ្វើបុណ្យ ជាអ្នកខ្មាសបាប ។ ពួកយាចក និងពួកវណិព្វកៈ មានគោត្រផ្សេងៗគ្នា តែងទៅក្នុងទីនោះ ជនទាំងនោះតែងសួររកទីលំនៅនៃអសយ្ហមហាសេដ្ឋី នឹងខ្ញុំ ក្នុងទីនោះ ។ សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយ ពួកយើងទៅក្នុងទីណា អសយ្ហមហាសេដ្ឋី តែងឲ្យទានក្នុងទីណា ខ្ញុំកាលដែលជនទាំងនោះសួរហើយ បានប្រាប់នូវលំនៅ នៃអសយ្ហមហាសេដ្ឋី ដល់ជនទាំងនោះ ។

១ សំដៅយកនរកឈ្មោះ ។

បគ្គយ្ហ ទក្ខិណំ ពាហុំ   បត្ថ គច្ឆេ កត្ថំ ភោ
បត្ត ទានំ បទីយតិ   [1] តេន បាណិ កាមទទោ
តេន បាណិ មធុស្សវោ   តេន មេ ព្រហ្មចរិយេន
បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។

ន កិរ ត្វំ អទា ទានំ   សកបាណីហិ កស្សចិ
បរស្ស ទានំ អនុមោទមានោ   បាណឹ បគ្គយ្ហ បាវទិ ។
តេន បាណិ កាមទោ   តេន បាណិ មធុស្សវោ
តេន មេ ព្រហ្មចរិយេន   បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។

យោ សោ ទានមទា ភត្តេ   បសន្នោ សកបាណីហិ
សោ ហិត្វា មានុសំ ទេហំ   កិន្នុ សោ ទិសតំ គតោ ។

នាហំ ជានាមិ អសយ្ហសាហិនោ
អង្គីរសស្ស គតឹ អាគតឹ វា
សុតំ ច មេ វេស្សវណស្ស សន្តិកេ
សក្កស្ស សហព្យតំ គតោ អសយ្ហោ ។

---

១ ម. ឯត្ថ ឋានេ អសយ្ហស្ស ធិរេសោ ទេនិ នត្ថិ ។



ខ្ញុំបានលើកដៃខាងស្តាំ (បង្ហាញលំនៅនៃអសយ្ហមហាសេដ្ឋី ដល់ជនទាំងនោះ) ថា សេចក្តីចំរើន ចូរមានដល់អ្នកទាំងឡាយចុះ អ្នកទាំងឡាយចូរនាំគ្នាទៅក្នុងទីនុ៎ះចុះ អសយ្ហមហាសេដ្ឋី ក៏ឲ្យទានក្នុងទីនុ៎ះ ដៃរបស់ខ្ញុំ អាចឲ្យសម្រេចសេចក្តីប្រាថ្នាបានដោយហេតុនោះ ដៃរបស់ខ្ញុំទើបបញ្ចេញនូវរសផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តដ៏ប្រសើរនោះ ។

បានឮថា អ្នកមិនដែលឲ្យទាន ដល់ជនណាមួយ ដោយដៃទាំងឡាយរបស់ខ្លួនទេ គ្រាន់តែអនុមោទនាទាន របស់បុគ្គលដទៃ ហើយលើកដៃចង្អុលប្រាប់ផ្លូវប៉ុណ្ណោះ ។

ដៃរបស់ខ្ញុំ អាចឲ្យសម្រេចសេចក្តីប្រាថ្នា ដោយហេតុនោះ ដៃរបស់ខ្ញុំទើបបញ្ចេញនូវរសផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តដ៏ប្រសើរនោះ ។

បពិត្រលោកដ៏ចំរើន អសយ្ហមហាសេដ្ឋីនោះ ជាអ្នកមានចិត្តជ្រះថ្លា ហើយបានឲ្យនូវទាន ដោយដៃខ្លួនឯង លុះសេដ្ឋីនោះលះបង់នូវអត្តភាពជាមនុស្ស ហើយទៅទិសណា ។

ខ្ញុំក៏មិនដឹង នូវដំណើរទៅ ឬមក នៃអសយ្ហមហាសេដ្ឋី
ជាអ្នកអត់ធន់ ដែលមានរស្មីផ្សាយចេញអំពីកាយឡើយ
តែខ្ញុំឮថា អសយ្ហមហាសេដ្ឋី ទៅកើតជាមួយនឹងព្រះឥន្ទ្រ
ក្នុងសំណាក់នៃស្តេចវេស្សវណ ។

អលមេវ កាតុំ កល្យាណំ   ទានំ ទាតុំ យថារហំ
បាណឹ កាមទទំ ទិស្វា   កោ បុញ្ញំ ន ករិស្សតិ ។
សោ ហិ នូន ឥតោ គន្ត្វា   អនុប្បត្វាន ទ្វារកំ
ទានំ បដ្ឋបយិស្សាមិ   យំ មមស្ស សុខាវហំ ។
ទស្សាមិ អន្នបានញ្ច   វត្ថសេនាសនានិ ច
បបញ្ច ឧទបានញ្ច   ទុគ្គេ សង្កមនានិ ចាតិ ។
កេន តេ អង្គុលី កុណា[១]   មុខញ្ច កុណលីកតំ[២]
អក្ខីនិ ច បគ្ឃរន្តិ   កឹ បាបំ បកតំ តយាតិ ។
អង្គីរសស្ស គហបតិនោ   សទ្ធស្ស ឃរមេសិនោ
តស្សាហំ ទានវិស្សគ្គេ   ទានេ អធិកតោ អហុ[៣] ។
តត្ថ យាចនកេ ទិស្វា   អាគតេ ភោជនត្ថិកេ
ឯកមន្តំ អបក្កម្ម   អកាសឹ កុណលឹ មុខំ ។
តេន មេ អង្គុលី កុណា   មុខញ្ច កុណលីកតំ
អក្ខីនិ ច បគ្ឃរន្តិ   តំ បាបំ បកតំ មយាតិ ។
ធម្មេន តេ កាបុរិស   មុខញ្ច កុណលី កតំ
អក្ខីនិ ច បគ្ឃរន្តិ   យំ តំ បរស្ស ទានស្ស
អកាសិ កុណលឹ មុខន្តិ ។

---

១ ម. កុណា ។ ២ ម. កុណលីកតំ ។ ៣ ឱ. ទានេ អធិកតោ អហុំ ។





បុគ្គលនឹងធ្វើកុសល គួរឲ្យទានតាមសមគួរ បុគ្គលណាឃើញដៃ ដែលឲ្យតាមចំណង់ហើយ នឹងមិនធ្វើបុណ្យកើត ។ ខ្ញុំទៅអំពីទីនេះ ដល់ទៅក្រុងទ្វារកនគរ នឹងតម្កល់ទុកនូវទាន ជាទីនាំមកនូវសេចក្តីសុខ ដល់ខ្ញុំជាពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្តូងទឹក រោងទឹកសម្រាប់ផឹក នឹងស្ពានក្នុងផ្លូវដែលលំបាកទៅ ។

ម្រាមដៃម្រាមជើងរបស់អ្នកក្ងិកក្ងក់ មុខរបស់អ្នកក្រញៅក្រញូវ ភ្នែករបស់អ្នក ចេះតែហូរចេញនូវទឹកភ្នែក ព្រោះហេតុអ្វី បាបកម្មដូចម្តេច ដែលអ្នកបានធ្វើហើយ ។

កាលអង្គីរសគហបតី ដែលមានរស្មីចេញអំពីកាយ មានសទ្ធា គ្រប់គ្រងផ្ទះ ខ្ញុំជាអ្នកចាត់ចែងក្នុងទានទាំងឡាយ ក្នុងរោងទានរបស់គហបតីនោះ ។ ខ្ញុំបានឃើញពួកស្មូមដែលត្រូវការភោជន មកក្នុងទីនោះ ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយបានធ្វើមុខក្រញៅក្រញូវ ។ ព្រោះហេតុនោះបានជា ម្រាមដៃម្រាមជើងរបស់ខ្ញុំក្ងិកក្ងក់ មុខរបស់ខ្ញុំក្រញៅក្រញូវ ភ្នែកទាំងឡាយរបស់ខ្ញុំ ចេះតែហូរចេញនូវទឹកភ្នែក មានក្លិនស្អុយ បាបកម្មនោះ ខ្ញុំបានធ្វើហើយ ។

ម្នាលបុរសលាមក មុខរបស់អ្នកក្រញៅក្រញូវផង ភ្នែករបស់អ្នក ចេះតែហូរចេញនូវ(ទឹកភ្នែកមានក្លិនស្អុយ) ផង (សមគួរ)តាមហេតុ ព្រោះអ្នកបានធ្វើមុខក្រញៅក្រញូវចំពោះទានបុគ្គលដទៃ ។

ការំ ហិ ទានំ ជននាទោ　　ការេយ្យំ បរបត្តិយំ
អន្នបានំ ខាទនីយំ　　វត្ថសេនាសនានិ ច ។
សោ ហិ នូន ឥតោ គន្ត្វា　　អនុប្បត្វាន ទ្វារកំ
ទានំ តំ បដ្ឋបយិស្សាមិ　　យំ មមស្ស សុខាវហំ ។
ទស្សាមន្នញ្ច បានញ្ច　　វត្ថសេនាសនានិ ច
បបញ្ច ឧទបានញ្ច　　ទុគ្គេ សង្កមនានិ ច ។
តតោ ហិ សោ និវត្តិត្វា　　អនុប្បត្វាន ទ្វារកំ
ទានំ បដ្ឋយិ អង្កុរោ[១]　　យន្តំ អស្ស សុខាវហំ ។
អទា អន្នញ្ច បានញ្ច　　វត្ថសេនាសនានិ ច
បបញ្ច ឧទបានញ្ច　　វិប្បសន្នេន ចេតសា ។
កោ ឆាតោ កោ ច តសិតោ　　កោ វត្ថំ បរិទហិស្សតិ[២]
កស្ស សន្តានិ យោគ្គានិ　　ឥតោ យោជេន្តុ វាហនំ ។
កោ ឆត្តិច្ឆតិ គន្ធញ្ច　　កោ មាលំ កោ ឧបាហនំ
ឥតិ សុ តត្ថ[៣] ឃោសេន្តិ　　កប្បកា សូទមាគធា[៤]
សទា សាយញ្ច បាតោ ច　　អង្កុរស្ស និវេសនេ ។
សុខំ សុបតិ អង្កុរោ　　ឥតិ ជានាតិ មំ ជនោ
ទុក្ខំ សុបាមិ សិន្ធក　　យំ ន បស្សាមិ យាចកេ ។

១ ឧ. បដ្ឋបយង្កុរោ ។ ២ ឧ. បរិវស្សតិ ។ ម. បរិធស្សតិ ។ ៣ ម. សុត្តញ្ច ។ ៤ ម. សុតមាគធា ។



ព្រះសកាលវិញ្ញាន បាយ ទឹក ភាជន៍យៈសំពត់ នឹងសេនាសនៈ កើតឡើងដ៏ (ទាននោះ) ឲ្យសម្រេចដល់បុគ្គលដទៃ ដូចម្តេច ។

ខ្ញុំទៅអំពីទីនេះដល់ទ្វារកនគរហើយ នឹងដំកល់នូវទាន ជាទីនាំមកនូវសេចក្ដីសុខដល់ខ្ញុំដោយពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹក ទឹកសម្រាប់ផឹក នឹងស្ពានក្នុងផ្លូវលំបាកទៅ ។

លំដាប់នោះ ព្រះអង្កុរៈនោះ ត្រឡប់អំពីទីនោះមកដល់ទ្វារកនគរហើយ ក៏បានដំកល់នូវទាននោះ ជាទីនាំមកនូវសេចក្ដីសុខ ។ បានឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹកនិងរានទឹកសម្រាប់ផឹក ដោយចិត្តជ្រះថ្លា ។ អ្នកណាឃ្លាន អ្នកណាស្រេក អ្នកណានឹងស្លៀកដណ្ដប់សំពត់ អ្នកណាលំបាកដោយយាន ចូរទឹមពាហនៈ បរអំពីទីនេះទៅចុះ ។ អ្នកណាចង់បានឆ័ត្រ ចង់បានគ្រឿងក្រអូប ចង់បានកម្រងផ្កា ចង់បានស្បែកជើង ចូរយកទៅចុះ ពួកជាងកាត់សក់ ពួកអ្នកធ្វើបាយ នឹងពួកអ្នកក្រងផ្កា តែងស្រែកឃោសនាក្នុងលំនៅនៃអង្កុរៈ ទាំងពេលព្រឹក ទាំងពេលល្ងាច សព្វៗកាល ក្នុងទីនោះដូច្នេះ ។

ជនតែងដឹងនូវខ្ញុំថា អង្កុរៈដេកជាសុខ ម្នាលសិន្ធកមាណព តែខ្ញុំ ដេកជាទុក្ខ ព្រោះមិនឃើញ ពួកយាចក ។

សុខំ សុបតិ អន្ធកោ ឥតិ ជានាតិ មំ ជនោ
ឧត្តំ សិទ្ធកា[1] សុជាបិ អប្បកោ សុវណ្ណិកោ ។
សក្កោ ចេ មេ វរំ ទជ្ជា តាវត្តិំសានមិស្សរោ
កិស្ស សព្វស្ស លោកស្ស វរមានោ វរំ វរេតិ ។
សក្កោ ចេ មេ វរំ ទជ្ជា តាវត្តិំសានមិស្សរោ
កាលុដ្ឋិតស្ស មេ សតោ សុរិយុគ្គមនំ[2] បតិ
ទិព្វា ភក្ខា បាតុភវេយ្យុំ សីលវន្តោ ច យាចកា
ទទតោ មេ ន ខីយេថ ទត្វា នានុតប្បេយ្យាហំ
ទទំ ចិត្តំ បសាទេយ្យំ ឯតំ សក្ក វរំ វរេ ។

ន សព្វវិត្តានិ បរេ បវេច្ឆេ
ទទេយ្យ ទានញ្ច ធនញ្ច រក្ខេ
តស្មា ហិ ទានា ធនមេវ សេយ្យោ
អតិប្បទានេន កុលា ន ហោន្តិ ។
អទានមតិទានញ្ច នប្បសំសន្តិ បណ្ឌិតា
តស្មា ហិ ទានា ធនមេវ សេយ្យោ
សមេន វត្តេយ្យ ស ធីរធម្មោតិ ។

---

១ ម. សិទ្ធក ។ ២ ម. សុរិយសុគ្គមនំ ។



ដល់កើតនឹងខ្ញុំថា អគ្គីរដែលដេកលក់ជាសុខ ម្ចាស់សិទ្ធកមាណព
តែខ្ញុំដេកជាទុក្ខ ព្រោះឃើញនូវពួកកណ្ដកផងតិច ។ ប្រសិនបើ
ព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យពរដល់អ្នក តើ
អ្នកគប្បីប្រាថ្នានូវពរ ដល់លោកទាំងពួងដូចម្ដេច ។
បើព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យនូវពរដល់ខ្ញុំ
កាលខ្ញុំក្រោកឡើងអំពីព្រឹក ក្នុងវេលាជាទីរះឡើងនៃព្រះអាទិត្យ
ភិក្ខាទាំងឡាយដ៏ជាទិព្វ គប្បីកើតប្រាកដ ពួកអ្នកមានសីលនិង
យាចក គប្បីមានប្រាកដ កាលខ្ញុំឲ្យនូវទាន ក៏គប្បីអស់ទៅឡើយ
លុះខ្ញុំឲ្យរួចហើយ ក៏គប្បីក្ដៅក្រហាយ កាលខ្ញុំកំពុងឲ្យ គប្បី
ញ៉ាំងចិត្តឲ្យជ្រះថ្លា បពិត្រសក្កៈ ខ្ញុំចង់បាននូវពរយ៉ាងនេះ ។
បុគ្គលក៏គប្បីឲ្យនូវទ្រព្យតាមចិត្តទាំងអស់ ដល់បុគ្គលដទៃ
ឡើយ បុគ្គលគប្បីឲ្យនូវទានផង គប្បីរក្សានូវទ្រព្យផង
ព្រោះថា ទ្រព្យនោះឯងប្រសើរជាងទាន ត្រកូលទាំងឡាយ
មិនចំរើន ព្រោះឲ្យទានហួសពេក ។ អ្នកប្រាជ្ញ
ទាំងឡាយ តែងមិនសរសើរ នូវការមិនឲ្យទានផង នូវការ
ឲ្យទានច្រើនពេកផង ព្រោះថា ទ្រព្យនោះឯងប្រសើរជាងទាន
បុគ្គលគួរប្រព្រឹត្តឲ្យស្មើ នោះជាធម៌របស់អ្នកប្រាជ្ញ ។

អហោ វតារេ អហមេវ ទជ្ជំ
សន្តោ ហិ មំ សប្បុរិសា ភជេយ្យុំ
មេឃោវ និន្នានិ ហិ បូរយន្តោ
សន្តប្បយេ សព្វវណិព្វកានំ ។

យស្ស យាចនកេ ទិស្វា មុខវណ្ណោ បសីទតិ
ទត្វា អត្តមនោ ហោតិ តំ ឃរំ វសតោ សុខំ ។
យស្ស យាចនកេ ទិស្វា មុខវណ្ណោ បសីទតិ
ទត្វា អត្តមនោ ហោតិ ឯសា យញ្ញស្ស[១] សម្បទា ។
បុព្វេវ ទានា សុមនោ ទទំ ចិត្តំ បសាទយេ
ទត្វា អត្តមនោ ហោតិ ឯសា យញ្ញស្ស សម្បទា ។
សដ្ឋិវាហសហស្សានិ អង្គីរសស្ស និវេសនេ
ភោជនំ ទីយតេ និច្ចំ បុញ្ញបេក្ខស្ស ជន្តុនោ ។
តិសហស្សានិ សូទានិ[២] អាមុត្តមណិកុណ្ឌលា
អង្គីរំ ឧបជីវន្តិ ទានេ យញ្ញស្ស វាវដា ។
សដ្ឋិបុរិសសហស្សានិ អាមុត្តមណិកុណ្ឌលា
អង្គីរសស្ស មហាទានេ កដ្ឋំ ផាលេន្តិ មាណវា ។

១ ម. បុញ្ញស្ស ។ ២ ម. តិសហស្សា សូទា ។



ឱហ្ន៎ អាត្មាអញគប្បីឲ្យនូវទាន ព្រោះថា សប្បុរសទាំងឡាយអ្នកមានចិត្តស្ងប់ស្ងាត់ហើយ គប្បីគប់រកនូវអាត្មាអញ អាត្មាអញ ញ៉ាំងពួកវណិព្វកៈទាំងពួង ឲ្យឆ្អែតស្កប់ស្កល់ ដូចមហាមេឃញ៉ាំងទីទាបឲ្យពេញដូច្នោះ ។

សម្បុរមុខរបស់បុគ្គលណាជ្រះថ្លា ព្រោះឃើញពួកយាចកទាំងឡាយ បុគ្គលនោះលុះឲ្យហើយ រមែងមានចិត្តត្រេកអរ នោះជាសុខរបស់បុគ្គលអ្នកគ្រប់គ្រងផ្ទះ ។ សម្បុរមុខរបស់បុគ្គលណា ជ្រះថ្លា ព្រោះឃើញពួកយាចកទាំងឡាយ បុគ្គលនោះលុះឲ្យរួចហើយ រមែងមានចិត្តត្រេកអរ នេះជាការបរិបូណ៌នៃយញ្ញ ។ បុគ្គលមុននឹងឲ្យទាន ក៏មានចិត្តស្អាត កំពុងឲ្យ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា លុះឲ្យរួចហើយមានចិត្តត្រេកអរ នេះជាការបរិបូណ៌នៃយញ្ញ ។ បុគ្គលតែងឲ្យភោជនជានិច្ចដល់ជន អ្នកប្រាថ្នាបុណ្យ ក្នុងលំនៅនៃអង្គីរៈ អស់ ៦ ហ្មឺនរទេះ ។ ពួកអ្នកធ្វើបាយចំនួនបីពាន់ (៣០០០) នាក់ ប្រដាប់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណី ជាអ្នកខ្វល់ខ្វាយនូវបុណ្យក្នុងការឲ្យទាន តែងអាស្រ័យ ចិញ្ចឹមជីវិតនឹងអង្គីរៈ ។ ពួកបុរសចំនួនប្រាំមួយហ្មឺន (៦០.០០០) នាក់ ប្រដាប់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណី ជាមាណពតែងពុះឧស ក្នុងមហាទាននៃអង្គីរៈ ។

សោឡសិត្ថិសហស្សានិ សព្វាលង្ការភូសិតា
អង្កុរស្ស មហាទានេ វិជា បគ្គណ្ហន្តិ នារិយោ
សោឡសិត្ថិសហស្សានិ សព្វាលង្ការភូសិតា
អង្កុរស្ស មហាទានេ ឆត្តគ្គាហា ឧបដ្ឋិតា ។
ពហុំ ពហូនំ បាទាសិ ចិរំ បាទាសិ ខត្តិយេ(១)
សក្កច្ចញ្ច សហត្ថា ច ចិត្តិំ កត្វា បុនប្បុនំ ។
ពហូ មាសេ ច បក្ខេ ច ឧតុសំវច្ឆរានិ ច
មហាទានំ បវត្តេសិ អង្កុរ ទីឃមន្តរំ(២) ។
ឯវំ ទត្វា យជិត្វា ច អង្កុរ ទីឃមន្តរំ
សោ ហិត្វា មានុសំ ទេហំ តាវតឹសូបគោ អហុតិ ។
កដច្ឆុភិក្ខំ ទត្វាន អនុរុទ្ធស្ស ឥន្ទកោ
សោ ហិត្វា មានុសំ ទេហំ តាវតឹសូបគោ អហុ ។
ទសហិ ឋានេហិ អង្កុរំ ឥន្ទកោ អតិរោចតិ
រូបេ សទ្ទេ រសេ គន្ធេ ផោដ្ឋព្វេ ច មនោរមេ
អាយុនា យសសា ចេវ វណ្ណេន ច សុខេន ច
អាធិបច្ចេន អង្កុរំ ឥន្ទកោ អតិរោចតីតិ ។

១ ម. ខត្តិយោ ។ ២ ម. ទីឃមន្តរ ។



ពួកស្រ្តីចំនួនមួយម៉ឺនប្រាំមួយពាន់(១៦០០០)នាក់ ប្រដាប់ខ្លួនដោយគ្រឿងអលង្ការទាំងពួង ជានារីកាន់ផ្លិតប្រមូលខ្យល់ក្នុងមហាទាននៃអង្កុរៈ ។ ពួកស្រ្តីចំនួនមួយម៉ឺនប្រាំមួយពាន់ (១៦០០០) នាក់ ប្រដាប់ខ្លួនដោយគ្រឿងអលង្ការទាំងពួង ជាអ្នកកាន់ឆ្នូវវែក ហើយចូលទៅឈរនៅ (ខាងបរិវេណ) ក្នុងមហាទាននៃអង្កុរៈ ។ អ្នកបានឲ្យទានច្រើនដល់ជនច្រើន ម្នាលនាងក្សត្រី នាងបានឲ្យទានអស់កាលដ៏យូរចុះ ធ្វើនូវសេចក្តីកោតក្រែងដោយគោរពផង ដោយដៃផង ឲ្យរឿយៗចុះ ។ អង្កុរៈបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ អស់ខែទាំងឡាយជាច្រើនផង អស់បក្ខទាំងឡាយជាច្រើនផង អស់រដូវនិងឆ្នាំទាំងឡាយជាច្រើនផង ក្នុងចន្លោះនៃកាលដ៏វែងឆ្ងាយ ។ អង្កុរៈបានឲ្យទានយ៉ាងនេះផង បូជាយ៉ាងនេះផង អស់ចន្លោះនៃកាលដ៏វែង អង្កុរៈនោះ លុះលះបង់នូវកាយជាមនុស្សនេះទៅ ក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្ស ។ ឥន្ទកៈបានឲ្យនូវចង្ហាន់មួយវែកដល់ព្រះអនុរុទ្ធ ឥន្ទកៈនោះលុះលះបង់នូវកាយជាមនុស្សនេះទៅ ក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្សដែរ ។ ឥន្ទកៈជាអ្នករុងរឿងជាងអង្កុរៈដោយឋានៈ ១០ យ៉ាង គឺរូប ១ សំឡេង ១ រស ១ ក្លិន ១ ផោដ្ឋព្វៈដ៏ជាទីត្រេកអរនៃចិត្ត ១ អាយុ ១ យស ១ សម្បុរ ១ សេចក្តីសុខ ១ ភាពជាធំ ១ ឥន្ទកទេវបុត្រ រុងរឿងជាងអង្កុរទេវបុត្រ ដោយភាពដូច្នេះ (យ៉ាងនេះ) ។

មហានាគំ តយា ទិន្និ   អនុរុទ្ធ និយមន្តិ
អវិទូរេ និសិន្នោសិ   អាគច្ឆ មម សន្តិកេ ។
តាវត្តិំសេ យថា ពុទ្ធោ   សិលាយំ បណ្ឌុកម្ពលេ
បារិច្ឆត្តកមូលម្ហិ   វិហាសិ បុរិសុត្តមោ ។
ទសសុ លោកធាតូសុ   សន្និបតិត្វាន ទេវតា
បយិរុបាសន្តិ សម្ពុទ្ធំ   វសន្តំ នគមុទ្ធនិ ។
ន កោចិ ទេវោ វណ្ណេន   សម្ពុទ្ធំ អតិរោចតិ
សព្ពេ ទេវេ អតិក្កម្ម[១]   សម្ពុទ្ធោវ វិរោចតិ ។
យោជនានិ ទសា ទ្វេ ច   អត្តភេយំ តទា អហុ
អវិទូរេ ច ពុទ្ធស្ស   វត្តតោ អតិរោចតិ ។
វិលោកេត្វាន សម្ពុទ្ធោ   អនុរុទ្ធាបិ វទ្ធតិ
ទក្ខិណេយ្យំ សម្ភាវេត្វា[២]   វទិ វេទមព្រវិ
មហានាគំ តយា ទិន្និ   អនុរុទ្ធ និយមន្តិ
អតិទូរេ និសិន្នោសិ   អាគច្ឆ មម សន្តិកំ(កេ) ។
ចោទិតោ ភាវិតត្តេន   អនុរុទ្ធេ វទមព្រវិ[៣]
តំ មយ្ហំ ទេវ នាមេន   ទក្ខិណេយ្យេន សុញ្ញតំ ។

---

១ ឱ. អតិក្កម្ម ។ ២ ឱ. បកាវេត្វា ។ ៣ ម. ភិទមព្រវិ ។ ម. ភិទមព្រវិ ។





(ព្រះមានព្រះភាគត្រាស់ថា) ម្នាលអនុរុទ្ធៈ មហានាគដែលអ្នកបានឲ្យហើយ គឺបន្ទោះនៃកាលដ៏វែង ឥឡូវអ្នកទៅអង្គុយនៅក្នុងទីឆ្ងាយ ចូរអ្នកមកក្នុងទីជិតនៃតថាគត ។

កាលណា ព្រះពុទ្ធ ឧត្តមជាងបុរស គង់នៅលើថ្មបណ្ឌុកម្ពលជិតគល់នៃបារិច្ឆត្តកព្រឹក្ស ក្នុងឋានត្រៃត្រិង្ស ។ ទេវតាទាំងឡាយ ក្នុងលោកធាតុទាំង ១០ បានប្រជុំគ្នាចូលទៅអង្គុយជិតព្រះសម្ពុទ្ធ ដែលគង់នៅលើកំពូលភ្នំ (សុមេរុ) ។ ទេវតាណាមួយ រុងរឿងជាងព្រះសម្ពុទ្ធដោយវណ្ណៈមិនមានឡើយ មានតែព្រះសម្ពុទ្ធមួយព្រះអង្គឯងប៉ុណ្ណោះរុងរឿងកន្លងនូវទេវតាទាំងអស់ ។ ក្នុងកាលនោះ អនុរុទ្ធទេវបុត្រនៅក្នុងទីប្រមាណ ១៦ យោជន៍ ឥន្ទកទេវបុត្ររុងរឿងក្រៃពេក ក្នុងទីជិតនៃព្រះសម្ពុទ្ធ ។ ព្រះសម្ពុទ្ធ ទ្រង់មើលមើលនូវអនុរុទ្ធទេវបុត្រនិងឥន្ទកទេវបុត្រ កាលទ្រង់សរសើរនូវទក្ខិណេយ្យបុគ្គល បានត្រាស់សំដែងនូវពាក្យនេះថា ម្នាលអនុរុទ្ធៈ មហាទានដែលអ្នកឲ្យហើយអស់បន្ទោះនៃកាលដ៏វែង អ្នកអង្គុយក្នុងទីឆ្ងាយពេកណាស់ ចូរមកជិតតថាគតមក ។

អនុរុទ្ធទេវបុត្រដែលព្រះសម្ពុទ្ធមានព្រះអង្គអប់រំហើយ ទ្រង់ដាស់តឿនហើយ ក៏បានក្រាបបង្គំទូលថ្វាយថា ប្រយោជន៍អ្វីដោយទាននោះរបស់ខ្ញុំព្រះអង្គ ព្រោះ(ទាននោះ) សូន្យចាកទក្ខិណេយ្យបុគ្គល ។

អយំ សោ ឥន្ទកោ យក្ខោ ទជ្ជា ទានំ បរិត្តកំ
អតិរោចតិ អម្ហេហិ ចន្ទោ តារគណេ យថា (ឥតិ) ។
ឧជ្ជង្គលេ យថា ខេត្តេ ពីជំ ពហុំបិ រោបិតំ
ន ផលំ វិបុលំ ហោតិ ន បិ តោសេតិ កស្សកំ ។
តថេវ ទានំ ពហុកំ ទុស្សីលេសុ បតិដ្ឋិតំ
ន ផលំ វិបុលំ ហោតិ ន បិ តោសេតិ ទាយកំ ។
យថាបិ ភទ្ទកេ ខេត្តេ ពីជំ អប្បម្បិ រោបិតំ
សម្មាធារំ បវេច្ឆន្តេ ផលំ តោសេតិ កស្សកំ
តថេវ សីលវន្តេសុ គុណវន្តេសុ តាទិសុ
អប្បកំបិ កតំ ការំ បុញ្ញំ ហោតិ មហប្ផលំ ។
វិចេយ្យ ទានំ ទាតព្វំ យត្ថ ទិន្នំ មហប្ផលំ
វិចេយ្យ ទានំ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា
វិចេយ្យ ទានំ សុគតប្បសត្ថំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
ពីជានិ វុត្តានិ យថា សុខេត្តេ ។

អង្កុរបេតវត្ថុ នវមំ ។



ឥន្ទកយក្សនេះឯង ឲ្យទានតិចតួច រុងរឿងជាងពួកខ្ញុំព្រះអង្គ ដូចជាព្រះចន្ទក្នុងពួកផ្កាយ ។

(ព្រះសម្ពុទ្ធត្រាស់ថា) ពូជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើន ក្នុងស្រែខ្ទួល ផលរមែងមិនបរិបូណ៌ ទាំងមិនញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្ដេចមិញ ទានដែលបុគ្គលដំកល់ទុកហើយមានប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផលរមែងមិនបរិបូណ៌ ទាំងមិនបានញ៉ាំងទាយកឲ្យត្រេកអរបាន ក៏ដូច្នោះឯង ។ ពូជដែលបុគ្គលព្រោះហើយ សូម្បីតិច ក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញ៉ាំងអ្នកស្រែឲ្យត្រេកអរបាន ដូចម្ដេចមិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បីតិចតួច ក្នុងពួកបុគ្គលទាំងឡាយ មានសីល មានគុណ បុណ្យរមែងមានផលច្រើន ក៏ដូច្នោះឯង ។ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលណា រមែងមានផលច្រើន បុគ្គលគួរពិចារណាហើយសឹមឲ្យទាន ទាយកទាំងឡាយពិចារណាហើយឲ្យនូវទាន តែងទៅកាន់ឋានសួគ៌

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ។

ចប់ រឿងអង្កុរប្រេត ទី ៩ ។

## ទសមំ ឧត្តរមាតុបេតវត្ថុ

(៦៦) ទិវាវិហារគតំ ភិក្ខុំ គង្គាតីរេ និសិន្នកំ
តំ បេតី ឧបសង្កម្ម ទុព្វណ្ណា ភីរុទស្សនា
កេសា ចស្សា អតិទីឃា យាវ ភូមាវលម្ពរេ
កេសេហិ សា បដិច្ឆន្នា សមណំ ឯតទព្រវិ[1] ។
បញ្ចបណ្ណាសវស្សានិ យតោ កាលកតា អហំ
នាភិជានាមិ ភុត្តំ វា បីតំ វា បន បានីយំ
ទេហិ ត្វំ បានីយំ ភន្តេ តសិតា បានីយាយ មេតិ ។
អយំ សីតោទកា គង្គា ហិមវន្តតោ សន្ទតិ
បិវ ឯត្តោ គហេត្វាន កឹ មំ យាចសិ បានីយំ (ឥតិ) ។
សចាហំ ភន្តេ គង្គាយ សយំ គណ្ហាមិ បានីយំ
លោហិតំ មេ បរិវត្តតិ តស្មា យាចាមិ បានីយំ (ឥតិ) ។
កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន គង្គា តេ ហោតិ លោហិតំ (ឥតិ) ។

[1] ម. ឯតទព្រវិ ។





## រឿងនាងឧត្តរមាតុប្រេត ទី ១០

(៦៦) ស្រីប្រេតដែលមានសម្បុរអាក្រក់ គួរខ្លាច បានចូលទៅរកភិក្ខុនោះ[1] ដែលកំពុងសម្រាកនៅក្នុងវេលាថ្ងៃ អង្គុយនៅទៀបឆ្នេរទន្លេគង្គា សក់ទាំងឡាយនៃស្រីប្រេតនោះ វែងសឹងធ្លាក់ចុះដល់ដី ស្រីប្រេតនោះ បិទបាំងខ្លួនប្រាណដោយសក់ទាំងឡាយ ហើយនិយាយទៅនឹងសមណៈដូច្នេះថា ចាប់ដើមតាំងពីខ្ញុំ ធ្វើមរណកាលមកបាន ៥៥ ឆ្នាំហើយ មិនដែលបានបរិភោគ ឬក្រេបផឹកនូវទឹកឡើយ បពិត្រលោកដ៏ចំរើន សូមលោកឲ្យនូវទឹកដល់ខ្ញុំ ដើម្បីបានក្រេបផឹក ព្រោះសេចក្តីស្រេក ។

(ព្រះកច្ចាយនត្ថេរពោល) ទន្លេគង្គានេះ មានទឹកត្រជាក់ហូរមកពីភ្នំហិមវន្ត នាងចូរកាន់យកនូវទឹកអំពីទន្លេគង្គានេះ ហើយក្រេបផឹកចុះ ហេតុអ្វីបានជានាងសូមទឹកនឹងយើងដូច្នេះ ។

បពិត្រលោកដ៏ចំរើន បើខ្ញុំកាន់យកទឹក អំពីទន្លេគង្គាដោយខ្លួនឯង ទឹកនោះក៏ប្រែទៅជាឈាមដល់ខ្ញុំវិញ ព្រោះហេតុនោះបានជា ខ្ញុំសូមទឹកអំពីលោកម្ចាស់វិញ ។

ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត ដូចម្តេចខ្លះ បានជាទឹកទន្លេគង្គា ប្រែទៅជាឈាមដល់នាង ព្រោះវិបាកនៃកម្មដូចម្តេច ។

[1] ក្នុងអដ្ឋកថា សំដៅយកព្រះកច្ចាយនត្ថេរ ។

បុត្តោ មេ ឧត្តរោ នាម(១) សទ្ធោ អាសិ ឧបាសកោ
សោ ច មយ្ហំ អកាមាយ សមណានំ បវេច្ឆតិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ ។
តមហំ បរិភាសាមិ មច្ឆេរេន ឧបទ្ទុតា
យញ្ច(២) មយ្ហំ អកាមាយ សមណានំ បវេច្ឆសិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ ។
ឯតំ តេ បរលោកស្មិំ លោហិតំ ហោតុ ឧត្តរ
តស្ស កម្មវិបាកេន គង្គា មេ ហោតិ លោហិតន្តិ ។

ឧត្តរមាតុប្បេតវត្ថុ ទសមំ ។

## ឯកាទសមំ សុត្តប្បេតវត្ថុ

(៦៣) អហំ បុរេ បព្វជិតស្ស ភិក្ខុនោ សុត្តំ
អទាសិ ឧបគម្ម យាចិតា តស្ស
វិបាកោ វិបុលំ ផលូបលព្ភតិ
ពហុ(៣) ច មេ ឧប្បជ្ជរេ វត្ថកោដិយោ ។
បុប្ផាភិកិណ្ណំ រមិតំ(៤) វិមានំ
អនេកចិត្តំ នរនារិសេវិតំ
សាហំ ភុញ្ជាមិ ច បារុបាមិ ច

១ ឱ. ៤. [illegible] ២ ម. [illegible] ៣ ម. [illegible] ៤ ឱ. [illegible] ។



បុត្ររបស់ខ្ញុំឈ្មោះឧត្តរៈ ជាឧបាសកអ្នកមានសទ្ធា កាលខ្ញុំមិនប្រាថ្នា (មិនឲ្យទាន) បុត្ររបស់ខ្ញុំនោះឲ្យនូវចីវរ បិណ្ឌបាត គិលានប្បច្ច័យ និងសេនាសនប្បច្ច័យ ដល់សមណៈទាំងឡាយ ។ ខ្ញុំនោះត្រូវសេចក្ដីកំណាញ់បៀតបៀន ក៏ជេរប្រទេចកូននោះថា កាលអញមិនប្រាថ្នានឹងឲ្យ ឯងបានឲ្យនូវចីវរ បិណ្ឌបាត គិលានប្បច្ច័យ និងសេនាសនប្បច្ច័យណា ដល់សមណៈទាំងឡាយ ។ ម្នាលឧត្តរៈ បច្ច័យមានចីវរជាដើមនុ៎ះ ចូរកើតទៅជាឈាម ដល់អ្នកឯង ក្នុងបរលោកចុះ ព្រោះវិបាកនៃកម្មនោះ បានជាទឹកក្នុងស្ទឹងគង្គាក្លាយទៅជាឈាមដល់ខ្ញុំ ។

ចប់ រឿងឧត្តរមាតុប្រេត ទី ១០ ។

## រឿងសុត្តប្រេត ទី ១១

(៦៣) (ស្រីដែលនៅជាមួយនឹងវិមានប្រេត មានសេចក្ដីអផ្សុក បាននោលថា) ក្នុងកាលមុន បព្វជិតភិក្ខុ ក្នុងព្រះបរមពុទ្ធ បានចូលមកសុំអំបោះ ខ្ញុំក៏បានប្រគេន (អំបោះនេះ) ខ្ញុំបានផលនៃការប្រគេនអំបោះនោះ ជាផលចំរើនលើសលុប ទាំងសំពត់ច្រើនកោដិក៏កើតឡើងដល់ខ្ញុំ ។ ខ្ញុំនោះបានប្រើប្រាស់នូវវិមានជាទីត្រេកអរ ដេរដាសដោយផ្កា វិចិត្រដោយកែវច្រើនយ៉ាង ដែលជនប្រុសស្រីសេពហើយផង បានស្លៀកដណ្ដប់ (សំពត់តាមចំណង់)ផង

បញ្ចវីស្តិ ច[១] ច តាវ ទិយតិ ។
តស្សេវ កម្មស្ស វិបាកមន្វយា
សុខញ្ច សាតញ្ច ឥធូបលព្ភតិ
សាហំ គន្ត្វា បុនទេវ មានុសំ
កាហាមិ បុញ្ញានិ នយេយ្យបុត្ត មន្តិ[២] ។
សត្តតុរី វស្សសតា ឥធាគតា
ជិណ្ណា ច វុឌ្ឍា ច តហឹ ភវិស្សសិ
សព្វេវ តេ កាលកតា ច ញាតកា
កឹ[៣] តត្ថ គន្ត្វាន ឥតោ ករិស្សសិ ។
សត្តេវ វស្សានិ ឥធាគតាយ មេ
ទិព្វញ្ច សុខញ្ច សមប្បិតាយ
សាហំ គន្ត្វា បុនរេវ មានុសំ
កាហាមិ បុញ្ញានិ នយេយ្យបុត្ត មន្តិ ។
តេ តំ គហេត្វាន បសយ្ហ ពាហាយំ
បច្ចានយិត្វាន បុនរេវ ថេរី សុទុព្វលិ
វទេសិ អញ្ញំបិ ជនំ ឥធាគតំ
ករោថ បុញ្ញានិ សុខូបលព្ភតិ ។

១ ម. បញ្ចវីសតិ ។ ២ ម. បុញ្ញានិ ការោមិ នយយ្យបុត្តំ ។ ៣ ម. កឹ ។



ទាំងទ្រព្យដ៏ច្រើន ក៏មិនដែលអស់ផង ។ ខ្ញុំបានសេចក្តីសុខ និងសេចក្តីស្រួល ក្នុងវិមាននេះ ព្រោះតែផលនៃកម្មនោះឯង ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្រ សូមអ្នកនាំខ្ញុំទៅ(ឯមនុស្សលោកចុះ) ។

(វិមានប្រេតនិយាយថា) នាងមកក្នុងវិមាននេះ បាន៧០០ ឆ្នាំហើយ (បើនាងទៅអំពីវិមាននេះវិញទៅទៀត) ក្នុងមនុស្សលោកនោះ នឹងគ្រាំគ្រាចាស់ ញាតិរបស់នាងទាំងអស់ ស្លាប់អស់ហើយ (ព្រោះហេតុនោះ) នាងនឹងទៅអំពីទេវលោកនេះ ធ្វើអ្វី ក្នុងមនុស្សលោកនោះ ។

(ស្រីនោះនិយាយថា) ខ្ញុំបានមកក្នុងវិមាននេះ ជាស្រីបរិបូណ៌ ដោយនូវទិព្វ នឹងសេចក្តីសុខអស់ត្រឹម ៧ ឆ្នាំ ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្រ សូមអ្នកនាំខ្ញុំទៅចុះ ។

វិមានប្រេតនោះ ក៏នាំយកនាងចាប់ស្រីនោះ ត្រង់ដើមដៃ នាំមក (កាន់ស្រុកដើមកំណើត) វិញ ហើយនិយាយនឹងស្រីចាស់ មានកំឡាំងខ្សោយនោះថា នាងត្រូវប្រាប់ ដល់ជនដទៃទៀត ដែលមកក្នុងទីនេះថា អ្នកទាំងឡាយ ចូរធ្វើបុណ្យទាំងឡាយ អ្នកទាំងឡាយ នឹងបានសេចក្តីសុខ ។

ទិន្នា មយា អកតេន សាធុនា
បេតា វិហញ្ញន្តិ គតេវ មានុសា ។
កាមញ្ច កត្វា សុខវេទនីយំ
នេក មនុស្សា ច សុខេ ឋិតា បជាតិ ។

សុត្តបេតវត្ថុ ឯកាទសមំ ។

## ទ្វាទសមំ កណ្ណមុណ្ឌបេតវត្ថុ

(៦៦) សោវណ្ណសោបានផលកា សោវណ្ណវាលុកសន្ថតា

តត្ថ សោគន្ធិយា វគ្គូ    សុចិគន្ធា មនោរមា
នានារុក្ខេហិ សញ្ឆន្នា    នានាគន្ធសមេរិតា
នានាបទុមសញ្ឆន្នា    បុណ្ឌរីកសមោហតា ។
សុរភី សម្បវាយន្តិ    មនុញ្ញា មាលុតេរិតា
ហំសកោញ្ចាភិរុទា ច    ចក្កវាកាភិកូជិតា
នានាទិជគណាកិណ្ណា    នានាសរគណាយុតា
នានាផលធរា រុក្ខា    នានាមាលធរា[1] វនា ។

---
១ ម. ម. នានាផលធរា ។



ស្រីនោះ ឲ្យទានដល់ពួកជនដែលមកកាន់សំណាក់ខ្លួន ហ៎ ពួកប្រេតដែលខ្ញុំបានឃើញហើយ ជាអ្នកមានអំពើល្អមិនបានធ្វើ តែងលំបាក យ៉ាងណាមិញ ពួកមនុស្ស ក៏យ៉ាងនោះដែរ ពួកសត្វទាំងទៅគតិនៃមនុស្ស ដែលបានធ្វើកម្មមានសេចក្ដីសុខជាផលហើយ តែងតាំងនៅក្នុងសេចក្ដីសុខ ។

ចប់រឿងសុត្តប្រេត ទី ១១ ។

## រឿងកណ្ណមុណ្ឌប្រេតទី ១២

(៦៦) (ព្រះរាជាសួរស្រីប្រេតថា) ស្រះបោក្ខរណី មានកាំជណ្ដើរជាវិការៈនៃមាស ក្រាលខ្សាច់ជាវិការៈនៃមាស (ដោយជុំវិញ) ពួកផ្កាឧប្បលណី ក្នុងស្រះបោក្ខរណីនោះល្អ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត (ស្រះបោក្ខរណីនោះ) ដេរដាស ដោយឈើផ្សេងៗ ផ្សាយទៅដោយក្លិនផ្សេងៗ ដេរដាស ដោយឈូកក្រហមផ្សេងៗ គ្របដាស់ដោយឈូកសផ្សេងៗ ។ (ស្រះបោក្ខរណីទាំងឡាយនោះ) ក្រហឹមអឹងកង ដោយហង្សនឹងក្រៀល មានសត្វចាក្រពាក ស្រែកក្រលួច កុះករ ដោយហ្វូងសត្វស្លាបផ្សេងៗ ប្រកបដោយពួកបក្សី មានសំឡេងផ្សេងៗ ផង ឈើទាំងឡាយ ទ្រទ្រង់នូវផ្លែផ្សេងៗ ផង ព្រៃទាំងឡាយ ទ្រទ្រង់នូវកម្រងផ្កាផ្សេងៗ ផង មានក្លិនក្រអូបជាទីគាប់ចិត្ត ដែលខ្យល់បក់មកត្រូវ ក៏ផ្សាយទៅ ។

ន មនុស្សេសុ ឦទិសំ   ឧឡារំ យកទិសំ តវំ
បាសាទា ច ពហុកា តុយ្ហំ   សោវណ្ណរូបិយមយា
ទទ្ទល្លមានា អាភេន្តិ   សមន្តា ចតុរោ ទិសា ។
បញ្ច ទាសីសតា តុយ្ហំ   យា តេមា បរិចារិកា
តា[1] កម្ពុកាយូរធរា   កញ្ចនាវេឡភូសិតា[2] ។
បល្លង្កា ពហុកា តុយ្ហំ   សោវណ្ណរូបិយមយា
កទលីមិគសញ្ឆន្នា   សជ្ជា[3] គោណកសន្ថតា
យត្ថ តុំ វាសូបគតា   សព្វកាមសមិទ្ធិនី ។
សម្បត្តាយ អឌ្ឍរត្តាយ[4]   តតោ ឧដ្ឋាយ គច្ឆសិ
ឧយ្យានភូមឹ គន្ត្វាន   បោក្ខរញ្ញា សមន្តតោ ។
តស្សា តីរេ តុវំ ឋាសិ[5]   ហរិតេ សទ្ទលេ សុភេ
តតោ តេ កណ្ណមុណ្ឌោ ច   សុនខោ អង្គមង្គានិ ខាទតិ ។
យទា ច ខាយិតា អាសិ   អដ្ឋិសង្ខលិកា កតា
ឱគាហសិ បោក្ខរណឹ   ហោតិ កាយោ យថា បុរេ ។
តតោ ត្វំ អង្គបច្ចង្គី   សុចារុ បិយទស្សនា
វត្ថេន បារុបិត្វាន   អាយាសិ មម សន្តិកំ ។

---

១ ម. កា ។ ២ ម. កញ្ចនាវេឡុភូសិតា ។ ៣ ឱ. សំវិតោ ។ ៤ ម. សម្បត្តា អឌ្ឍរត្តាយ ។ ៥ ម. ឋិតាសិ ។



ឧឡារ (របស់នាង) នេះ ប្រាកដយ៉ាងណា ឧឡារប្រាកដយ៉ាងនេះ មិនមាន ក្នុងពួកមនុស្សទេ ពួកប្រាសាទ របស់នាង ក៏ច្រើន សុទ្ធសុទ្ធតែមាសនិងប្រាក់ រុងរឿងញ៉ាំងទិសទាំង ៤ ឲ្យភ្លឺជុំវិញ ។ ទាសី ៥០០ នាក់ ជាស្រីបម្រើរបស់នាង ពួកទាសីទាំងនោះ ក៏ប្រដាប់នូវស័ង្ខ និងកងកនិងកងត្រុំ ស្អិតស្អាងដោយសំពត់មាស ។ បល្ល័ង្ករបស់នាង ក៏ច្រើន សុទ្ធសុទ្ធតែមាសនិងប្រាក់ ក្រាលកម្រាលស្បែកឈ្លូស ដែលបុគ្គលតាក់តែងហើយ ក្រាលសំពត់រោមណកៈ ជាទីចូលដេកនៅនាស្រ័យ របស់នាងអ្នកសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ លុះដល់ពាក់កណ្ដាលអធ្រាត្រ នាងតែងក្រោកអំពីបល្ល័ង្កនោះ ទៅកាន់ឧទ្យានភូមិ ដើរជុំវិញស្រះបោក្ខរណី ។ (ម្នាលនាងដ៏ចំរើន នាងទៅ) ឈរលើច្រាំងស្រះបោក្ខរណីនោះ ជាទីមានស្មៅខៀវខ្ចីស្អាត លំដាប់នោះ ស្រាប់តែមានឆ្កែកំបុកត្រចៀកមកខាំស៊ីអវយវៈតូច-ធំរបស់នាង ។ នាង ក្នុងកាលដែលឆ្កែខាំស៊ី ធ្វើឲ្យនៅសល់តែឆ្អឹងហើយ នាងចុះទៅកាន់ស្រះបោក្ខរណី កាយ (របស់នាង) ក៏គង់នៅដូចក្នុងកាលមុន ។ លំដាប់នោះ នាងមានអវយវៈតូច-ធំពេញលេញល្អល្អះ គួរឲ្យរមិលមើល ស្លៀកដណ្ដប់សំពត់ ហើយមកកាន់សំណាក់នៃអាត្មា ។

កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន កណ្ណមុណ្ឌោ ច សុនខោ
អង្គមង្គានិ ខាទតិ ។
កិម្ពិលាយំ គហបតិ សទ្ធោ អាសិ ឧបាសកោ
តស្សាហំ ភរិយា អាសិំ ទុស្សីលា អតិចារិនី ។
ឯវំ អតិចរមានាយ[១] សាមិកោ ឯតទព្រវិ[២]
នេតំ ឆន្នំ[៣] បតិរូបំ យំ ត្វំ អតិចរាសិ មំ ។
សាហំ ឃោរញ្ច សបថំ មុសាវាទំ អភាសិស្សំ
នាហំ តំ អតិចរាមិ កាយេន ឧទ ចេតសា
សចាហំ តំ អតិចរាមិ កាយេន ឧទ ចេតសា
អយំ[៤] កណ្ណមុណ្ឌោ សុនខោ អង្គមង្គានិ ខាទតុ ។
តស្ស កម្មស្ស វិបាកំ មុសាវាទស្ស ចូភយំ
សត្តវស្សសតានិ ច[៥] អនុភូតំ យតោ ហិ មេ[៦]
កណ្ណមុណ្ឌោ ច សុនខោ អង្គមង្គានិ ខាទតិ ។
ត្វញ្ច ទេវ ពហុការោ អត្ថាយ មេ ឥធាគតោ
សុមុត្តាហំ កណ្ណមុណ្ឌស្ស អសោកា អកុតោភយា

---

១ ឧ. សោហំ អតិចរមានាយ ។ ២ ម. ឯតទព្រវី ។ ៣ ម. ឯតន្តុយ ទេខន្តិ អត្ថិ ។ ៤ ម. ឯតន្តុយ ទេត អត្ថិ ។ ៥ ឧ. សត្តេវ វស្សសតានិ ។ ៦ ម. ហិមេ ។



អំពើអាក្រក់ដូចម្ដេច ដែលនាងបានធ្វើដោយកាយ វាចា ចិត្ត ដោយផលនៃកម្មដូចម្ដេច បានជាឆ្កែកំបុតត្រចៀក ទាំសុីនូវអវយវៈតូចធំ។

(ស្រីប្រេតនោះ ក្រាបទូលថា) ក្នុងនគរកិម្ពិលា មានគហបតីជាឧបាសកអ្នកមានសទ្ធា ខ្ញុំជាប្រពន្ធរបស់គាត់ ជាស្រីទ្រុស្តសីល បានប្រព្រឹត្តកន្លងចិត្តប្ដី ។ កាលខ្ញុំប្រព្រឹត្តកន្លងចិត្តប្ដីយ៉ាងនេះហើយ ប្ដីបាននិយាយយ៉ាងនេះថា អំពើនេះមិនប្រពៃ មិនសមគួរទេ ព្រោះនាងប្រព្រឹត្តកន្លងអញ ។ ខ្ញុំនោះ បាននិយាយស្បថយ៉ាងអាក្រក់ផង និយាយពាក្យកុហកផងថា ខ្ញុំមិនប្រព្រឹត្តកន្លងអ្នកដោយកាយ ឬដោយចិត្តទេ ប្រសិនបើខ្ញុំប្រព្រឹត្តកន្លងអ្នក ដោយកាយ ឬដោយចិត្ត សូមឲ្យឆ្កែកំបុតត្រចៀកនេះទាំសុីអវយវៈតូចធំចុះ ។ ឆ្កែកំបុតត្រចៀក ទាំសុីអវយវៈតូចធំរបស់ខ្ញុំ ព្រោះបាបកម្មណា ខ្ញុំបានទទួលនូវផលនៃបាបកម្មនោះតាំងពីយូរអង្វែង ទុស្សីលកម្ម១ មុសាវាទកម្ម១ អស់ ៧០០ ឆ្នាំ ។

(ស្រីប្រេតនោះពោលថា) បពិត្រព្រះសម្មតិទេព ព្រះអង្គជាអ្នកមានឧបការៈច្រើន បានយាងមក ក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ឥឡូវខ្ញុំក៏បានរួចស្រឡះ ចាកឆ្កែកំបុតត្រចៀក ជាស្រីលែងមានសេចក្ដីសោក លែងមានភ័យ អំពីអារម្មណ៍ណាមួយ

តាហំ ទេវ នមស្សាមិ   យាចាមិ បញ្ជលីកតា
ភុញ្ជ អមានុសេ កាមេ   រម ទេវ មយា សហាតិ ។
ភុត្តា[១] អមានុសា កាមា   រមិតោម្ហិ តយា សហ
តាហំ សុភគេ យាចាមិ   ខិប្បំ បដិនយាហិ មន្តិ ។

កណ្ណមុណ្ឌបេតវត្ថុ ទ្វាទសមំ ។

## តេរសមំ ឧព្ពរីបេតវត្ថុ

(៦៩) អហុ រាជា ព្រហ្មទត្តោ   បញ្ចាលានំ រថេសភោ
អហោរត្តានមច្ចយោ   រាជា កាលមក្រុព្វថ[២] ។
តស្ស អាឡាហនំ គន្ត្វា   ភរិយា កន្ទតិ ឧព្ពរី
ព្រហ្មទត្តំ អបស្សន្តី   ព្រហ្មទត្តាតិ កន្ទតិ ។
ឥសិ ច តត្ថ អាគច្ឆិ   សម្បន្នចរណោ មុនិ
សោ[៣] ច តត្ថ អបុច្ឆិត្ថ   យេ តត្ថ សុសមាគតា
កស្ស ឥទំ[៤] អាឡាហនំ   នានាគន្ធសមេរិតំ
កស្សាយំ កន្ទតិ ភរិយា   ឥតោ ទូរគតំ បតឹ

១ ម. ភុត្វា ។ ២ ម. កាលំ ករិ ភវា ។ ៣ ឱ. តេ ។ ៤ ម. កស្សិទំ ។



បពិត្រព្រះសម្មតិទេព ខ្ញុំសូមធ្វើអញ្ជលី ថ្វាយបង្គំ អង្វរព្រះអង្គ សូមព្រះអង្គសោយកាមគុណទិព្វ ដែលមិនមែនជារបស់មនុស្ស បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរជាមួយនឹងខ្ញុំ ។

(ស្តេចពោលថា) កាមគុណទិព្វមិនមែនជារបស់មនុស្ស អញបាន បរិភោគហើយ អញជាអ្នកត្រេកអរជាមួយនឹងនាងហើយ ម្នាលនាងមានភាគល្អ អញសូមអង្វរនាង នាងចូរនាំអញទៅ(នគរ)វិញឲ្យឆាប់ ។

ចប់ រឿងកណ្ណមុណ្ឌប្រេត ទី ១២ ។

## រឿងឧព្វរីប្រេត ទី ១៣

(៦៩) (ព្រះសង្គីតិកាចារ្យទាំងឡាយ ពោលថា) ស្តេចរបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ទ្រង់ព្រះនាមព្រហ្មទត្ត ព្រះអង្គប្រសើរក្នុងរថសម្បត្តិ លុះដល់ថ្ងៃនិងយប់កន្លងទៅ ស្តេចក៏ទ្រង់សោយទិវង្គត ។ អគ្គមហេសីរបស់ស្តេចនោះ ឈ្មោះនាងឧព្វរី បានទៅកាន់ទីសុសាន ហើយទ្រង់ព្រះកន្សែង កាលមិនឃើញស្តេចព្រហ្មទត្ត ក៏ទ្រង់ព្រះកន្សែងថា ឱព្រះបាទព្រហ្មទត្ត ។ ឥសី ជាអ្នកប្រាជ្ញ បរិបូណ៌ដោយចរណៈ បានមកក្នុងទី ដែលនាងឧព្វរីយំនោះ ឥសីនោះបាន សួរពួកជនដែលមកជួបជុំក្នុងទីនោះថា ចុះទីសុសាននេះដែលផ្សាយទៅដោយក្លិនក្រអូបផ្សេងៗ តើរបស់នរណា ស្រីនេះជាភរិយារបស់នរណា កំពុងតែកន្ទក់កន្ទេញរកប្តី ដែលទៅឆ្ងាយអំពីមនុស្សលោកនេះ

ព្រហ្មទត្តំ អបស្សន្តី ព្រហ្មទត្តាតិ កន្ទតិ ។
តេ ច តត្ថ វិយាកំសុ យេ តត្ថ សុសមាគតា
ព្រហ្មទត្តស្ស ភទ្ទន្តេ ព្រហ្មទត្តស្ស មារិស
តស្ស ឥទំ អាឡាហនំ នានាគន្ធសមេរិតំ
តស្សាយំ កន្ទតិ ភរិយា ឥតោ ទូរគតំ បតី
ព្រហ្មទត្តំ អបស្សន្តី ព្រហ្មទត្តាតិ កន្ទតីតិ ។
ឆឡាសីតិសហស្សានិ ព្រហ្មទត្តស្ស នាមកា
ឥមស្មឹ អាឡាហនេ ទឌ្ឍា តេសំ កំ អនុសោចសីតិ ។
យោ រាជា ចូឡនីបុត្តោ បញ្ចាលានំ រថេសភោ
តំ ភន្តេ អនុសោចាមិ ភត្តារំ សព្វកាមទន្តិ[១] ។
សព្វេវហេសុំ រាជានោ ព្រហ្មទត្តស្ស នាមកា
សព្វេវ ចូឡនីបុត្តា បញ្ចាលានំ រថេសភា

១ ឱ. សព្វកាមទំ ។



កាលមិនឃើញព្រះបាទព្រហ្មទត្ត ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ។

ពួកជនដែលមកជួបជុំគ្នាក្នុងទីនោះ ក៏បានឆ្លើយថា បពិត្រមហាឥសីដ៏ចំរើន (ទីសុសាននេះ) របស់ព្រះបាទព្រហ្មទត្ត បពិត្រមហាឥសីអ្នកនិរទុក្ខ (ស្រីនេះជាភរិយា) របស់ព្រះបាទព្រហ្មទត្ត ទីសុសាននេះ របស់ព្រះបាទព្រហ្មទត្តនោះ ដែលផ្សាយទៅ ដោយក្លិនគ្រឿងក្រអូបផ្សេង ៗ ស្រីនេះជាភរិយា របស់ព្រះបាទព្រហ្មទត្តនោះ កន្ទក់កន្ទេញរកប្ដី ដែលទៅឆ្ងាយ អំពីមនុស្សលោកនេះហើយ កាលមិនឃើញព្រះបាទព្រហ្មទត្ត ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ។

(តាបសសួរនាងឧព្វរីថា) ស្តេចទាំងឡាយ ៨៦.០០០ ព្រះអង្គ សុទ្ធតែឈ្មោះព្រះបាទព្រហ្មទត្ត ត្រូវគេដុតក្នុងទីសុសាននេះដែរ បណ្តាស្តេចព្រហ្មទត្តទាំងនោះ តើនាងសោកស្តាយរកស្តេចព្រហ្មទត្តអង្គណា ។

(នាងឧព្វរីឆ្លើយថា) បពិត្រលោកដ៏ចំរើន ស្តេចអង្គណារបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ជាកូនប្រុសនៃព្រះបាទចូឡនី ព្រះអង្គប្រសើរក្នុងរថសម្បត្តិ ខ្ញុំសោកស្តាយរកស្តេចអង្គនោះ ជាភស្តា (របស់ខ្ញុំ) ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ។

(តាបសសួរថា) ពួកស្តេចទាំងអស់ សុទ្ធតែឈ្មោះព្រហ្មទត្ត ពួកស្តេចទាំងអស់ របស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល សុទ្ធតែជាកូនប្រុសនៃព្រះបាទចូឡនី ព្រះអង្គប្រសើរ ក្នុងរថសម្បត្តិ

សត្ថេសិ អនុបុព្វេន  មហេសិត្តំ អការយិ

កស្មា បុរិមកេ ហិត្វា  បច្ឆិមំ អនុសោចសិ ។

អាតុមេ ឥត្ថីភូតាយ  ទីឃរត្តាយ មារិស

យស្សា មេ ឥត្ថីភូតាយ  សំសារេ ពហុ កាសសីតិ ។

អហុ ឥត្ថី អហុ បុរិសោ  បសុយោនិម្បិ អាគមា[១]

ឯវមេតំ អតីតានំ[២]  បរិយន្តោ ន ទិស្សតីតិ ។

អាទិត្តំ វត មំ សន្តំ  ឃតសិត្តំវ បាវកំ

វារិនា វិយ ឱសិញ្ចំ[៣]  សព្វំ និព្វាបយេ ទរំ

អព្វហិ[៤] វត មេ សល្លំ  សោកំ ហទយនិស្សិតំ

យោ មេ សោកបរេតាយ  បតិសោកំ អបានុទិ ។

---

១ ឱ. បសុយោនិម្បិ អគមា ។ ២ ម. អតីតានំ ។ ៣ ឱ. ម. ឱសិញ្ចំ ។ ៤ ឱ. ម. អព្វូឡ្ហំ ។



នាងបានជាមហេសី របស់ព្រះស្តេចទាំងអស់តាមលំដាប់មក ហេតុអ្វីបានជានាងលះចោលព្រះស្តេចជាន់មុន ហើយមកសោកស្តាយតែស្តេចជាន់ក្រោយវិញ ។

(នាងឧព្វិរីតបថា) បពិត្រលោកម្ចាស់អ្នកនិរទុក្ខ លោកពោលជាច្រើនដងហើយថា នាងឯងជាមហេសីនៃស្តេច (ទាំងពួង) ក្នុងសង្សារ ចំពោះខ្ញុំ ដែលកើតជាស្រីណា ខ្លួនរបស់ខ្ញុំ ដែលកើតជាស្រីនោះ (ធ្លាប់កើតជាស្រី) អស់កាលដ៏យូរ (ឬក៏ធ្លាប់កើតជាប្រុសដែរ) ។

(តាបសពោលថា)នាងឯង ជួនកាលកើតជាស្រី ជួនកាលកើតជាប្រុស មិនតែប៉ុណ្ណោះ ជួនកាលបានទៅកាន់កំណើតបសុសត្វ កាលបើយ៉ាងនេះ ទីបំផុត(នៃអត្តភាពទាំងឡាយ) ដែលកន្លងទៅ ឥត្ថីភាព និងបុរិសភាពនុ៎ះ រមែងមិនប្រាកដឡើយ ។

(នាងឧព្វិរីពោលថា)លោកបានស្រោចស្រប់ខ្ញុំដែលភ្លើងគឺសេចក្តីសោកកំពុងឆេះហើយ ឲ្យស្ងប់រម្ងាប់បាន ហើយញុំាងសេចក្តីក្រវល់ក្រវាយទាំងពួងឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចពន្លត់ភ្លើងដែលកំពុងឆេះនូវផ្តាំនឹងខ្លាញ់ លោកណា បានបន្ទោបង់នូវសេចក្តីសោកព្រោះប្តីចំពោះខ្ញុំ ដែលមានសេចក្តីសោកកំពុងគ្របសង្កត់ លោកនោះ ឈ្មោះថាបានដកនូវសរគឺសេចក្តីសោក ដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ។

សាហំ អព្វុឡ្ហសល្លាស្មិ សីតិភូតាស្មិ និព្វុតា
ន សោចាមិ ន រោទាមិ តវ សុត្វា មហាមុនិ ។
តស្ស តំ វចនំ សុត្វា សមណស្ស សុភាសិតំ
បត្តចីវរមាទាយ បព្វជិ អនគារិយំ
សា ច បព្វជិតា សន្តា អគារស្មា អនគារិយំ
មេត្តំ ចិត្តំ អភាវេសិ ព្រហ្មលោកូបបត្តិយា
គាមា គាមំ វិចរន្តី និគមេ រាជធានិយោ ។
ឧរុវេលំ នាម សោ គាមោ យត្ថ កាលមកុព្វថ
មេត្តចិត្តំ អាភាវេត្វា ព្រហ្មលោកូបបត្តិយា
ឥត្ថិចិត្តំ វិរាជេត្វា ព្រហ្មលោកូបគា អហូតិ ។

ឧព្វរិបេតវត្ថុ តេរសមំ ។

## ឧទ្ទានំ

បណ្ឌុ មាតា មត្តា ច នន្ទា កុណ្ឌលិនា ឃដោ[១]
ទ្វេសេដ្ឋី តុន្នវាយោ[២] វិហារសុត្តសោណបេតុព្វរីតិ[៣][៤] ។

ឧព្វរិវគ្គោ ទុតិយោ ។

១ ឱ. បណ្ឌុ មាតា ច មិតា ច នន្ទា កុណ្ឌលិយេ ឃដោ ។ ២ ឱ. តុន្នវាយោ ច ។ ៣ ឱ. វិហារសុត្តសោណបេតុព្វរីតិ ។ ៤ ម. ឥតិ វគ្គោ ច វគ្គោតិ ។



ខ្ញុំនោះ ជាអ្នកមានសរគឺសេចក្តីសោកដកចោលហើយ ជាអ្នកមានចិត្តត្រជាក់ត្រជុំហើយ មានទុក្ខរលត់ហើយ បពិត្រព្រះមហាមុនី ខ្ញុំលែងសោកស្តាយ លែងយំខ្សឹកហើយ ព្រោះស្តាប់ពាក្យរបស់លោក ។

នាងឧព្វរីបានស្តាប់ពាក្យ សុភាសិតនោះ របស់តាបសជាសមណៈនោះហើយ ក៏ប្រដាប់បាត្រនិងចីវរ ចូលកាន់ផ្នួស លុះនាងឧព្វរីនោះចេញចាកផ្ទះចូលកាន់ផ្នួសហើយ ក៏ចេញពីស្រុក ដើរទៅកាន់ស្រុក កាន់និគម និងរាជធានីទាំងឡាយ បានចំរើនមេត្តាចិត្ត ដើម្បីកើតក្នុងព្រហ្មលោក ។ នាងឧព្វរីបានធ្វើមរណកាល ក្នុងស្រុកឈ្មោះឧរុវេលៈ នាងឧព្វរីនោះ បានចំរើនមេត្តាចិត្ត ដើម្បីកើតក្នុងព្រហ្មលោក ហើយញុំាងចិត្តឲ្យនឿយណាយក្នុងឥត្ថីភាព ក៏បានទៅកើតក្នុងព្រហ្មលោក ។

ចប់ រឿងឧព្វរីប្រេត ទី ១៣ ។

## ឧទ្ទាន

រឿងសំសារមោចកប្រេត (ប្រេតស្គមកើតកេតរលៀង) ១ រឿងស្រីប្រេតជាមាតានៃព្រះសារីបុត្តត្ថេរ ១ រឿងនាងមត្តាប្រេត (ដែលនៅរួមប្តីនៃនាងតិស្សា) ១ រឿងនន្ទាប្រេត ១ រឿងមដ្ឋកុណ្ឌលីប្រេត ១ រឿងកណ្ហប្រេត ១ រឿងធនបាលប្រេត ១ រឿងចូឡសេដ្ឋីប្រេត ១ រឿងអង្កុរប្រេត ១ រឿងនាងឧត្តរមាតុប្រេត ១ រឿងសុត្តប្រេត ១ រឿងកណ្ណមុណ្ឌប្រេត ១ រឿងឧព្វរីប្រេត ១ ។

ចប់ ឧព្វរីវគ្គ ទី ២ ។

## តតិយោ ចូឡវគ្គោ

### បឋមំ អភិជ្ជមានបេតវត្ថុ

(២៦) អភិជ្ជមានេ វារិម្ហិ  គង្គាយ ឥធ គច្ឆសិ
នគ្គោ បុព្វឌ្ឍបេតោវ  មាលាធារី អលង្កតោ
កុហឹ គមិស្សសិ បេត[១]  កត្ថ វាសោ ភវិស្សតិ ។
ចុន្ទដ្ឋិលំ[២] គមិស្សាមិ  បេតោ សោ ឥតិ ភាសតិ[៣]
អន្តរេ វាសភគាមំ  ពារាណសិយា[៤] សន្តិកេ ។
តញ្ច ទិស្វា មហាមត្តោ  កោលិយោ ឥតិ វិស្សុតោ
សត្តុភត្តញ្ច បេតស្ស  បីតកញ្ច យុគំ អទា ។
នាវាយ តិដ្ឋមានាយ  កប្បកស្ស អទាបយិ
កប្បកស្ស បទិន្នម្ហិ  ឋានេ បេតស្ស ទិស្សថ ។
តតោ សុវត្ថវសនោ  មាលាធារី អលង្កតោ
ឋានេ ឋិតស្ស បេតស្ស  ទក្ខិណា ឧបកប្បថ
តស្មា ទជ្ជេថ បេតានំ  អនុកម្បាយ បុនប្បុនំ ។

១ ឱ. បេតិ ។ ម. បេត ។ ២ ឱ. ចុន្ទដ្ឋិយំ ។ ៣ ឱ. ភាសសិ ។ ៤ ម. ពារាណស្យា ច ។





## ចូឡវគ្គ ទី ៣

### រឿងអភិជ្ជមានប្រេត ទី ១

(៦៦) (កោលិយមហាមាត្យ សួរថា) អ្នកឯងជាប្រេតអាក្រាត តែពាក់កណ្ដាលកាយខាងលើ ជាអ្នកទ្រទ្រង់នូវកម្រងផ្កា តាក់តែងក្បាល ដើរលើទឹកទន្លេគង្គា មិនបែកខ្ញែក ក្នុងទីនេះ ម្នាលប្រេត អ្នកនឹងទៅក្នុងស្រុកណា ទីនៅរបស់អ្នកនឹងមានក្នុងទីណា ។

ប្រេតនោះ បាននិយាយថា ខ្ញុំនឹងទៅស្រុកចុន្ទដ្ឋិលៈ ត្រង់ចន្លោះផងស្រុកវាសភៈ និងក្រុងពារាណសី ។

មហាមាត្យ ដែលល្បីឈ្មោះថា កោលិយៈ បានឃើញប្រេតនោះហើយ ក៏ឲ្យសត្តុនិងបាយផង ឲ្យសំពត់លឿងមួយគូផង ដល់ប្រេត ។ កាលដែលទូកឈប់ (កោលិយមហាមាត្យ) បានប្រើឲ្យឲ្យព្រះកេសឡ្យ (សំពត់មួយគូដល់សម) កាលដែលសំពត់មួយគូ ដែលឲ្យទៅព្រះកេសឡ្យហើយ សំពត់នោះ ក៏ប្រាកដ ដល់ប្រេតមួយរំពេច ។ លំដាប់នោះ ប្រេតក៏ស្លៀកពាក់សំពត់ដ៏ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងខ្លួន ទក្ខិណាទានក៏សម្រេចដល់ប្រេត ដែលឋិតនៅក្នុងទីគួរសំរេច ព្រោះហេតុនោះ បុគ្គលគួរឲ្យទក្ខិណាទានរឿយៗ ដើម្បីអនុគ្រោះដល់ប្រេតទាំងឡាយ ។

សាហុន្នវាសិនោ(១) ឯកេ អញ្ញេ(២) កេសនិវាសិនោ
បេតា ភត្តាយ គច្ឆន្តិ បក្កមន្តិ ទិសោទិសំ ។
ទូរេ ឯកេ(៣) បធាវិត្វា អលទ្ធា ច និវត្តរេ
ឆាតា បមុច្ឆិតា ភន្តា(៤) ភូមិយំ បដិសម្ភិតា(៥)
កេចិ តត្ថ ច បតិតា(៦) ភូមិយំ បដិសម្ភិតា
បុព្វេ អកតកល្យាណា អគ្គិទឌ្ឍាវ អាតបេ ។
មយំ បុព្វេ បាបធម្មា ឃរណិកុលមាតរោ(៧)
សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ(៨)
បហូតំ អន្នបានំ ហិ អបិស្សុ អវកិរិយតិ(៩)
សម្មគ្គតេ បព្វជិតេ ន ច កិញ្ចិ អទម្ហសេ ។
អកម្មកាមា អលសា សាទុកាមា មហគ្ឃសា
អាលោបបិណ្ឌទាតារោ(១០) បដិគ្គហេ បរិភាសិតា(១១) ។
តេ ឃរា តា ច ទាសិយោ តានេវាភរណានិ នោ
តេ អញ្ញេ(១២) បរិចារេន្តិ(១៣) មយំ ទុក្ខស្ស ភាគិនោ

---

១ ម. សាហុន្នវាសិនោ ។ ២ ម. អញ្ញា ។ ៣ ម. ទូរេ ឯកេ ។ ម. ទូរេ ឯកា ។ ៤ ម. បមុច្ឆិតា ភន្តា ។ ម. សម្មុច្ឆិតា ភន្តា ។ ៥ ម. បដិសុម្ភិតា ។ ៦ ម. តេ ច បតិតា ។ ៧ ម. ឃរណិយោ កុលមាតរោ ។ ៨ ម. នាកម្ហត្តនោ ។ ៩ ម. អវកិរិម្ហសេ ។ ១០ ម. អាលោបបិណ្ឌទាតារោ ។ ១១ ម. បរិភាសិម្ហសេ ។ ១២ ម. អញ្ញេ ។ ១៣ ម. បរិចារេន្តិ ។



(ព្រះសង្គីតិកាចារ្យទាំងឡាយ ពោលថា) ពួកប្រេតខ្លះស្លៀកពាក់កំណាត់សំពត់ចាស់ ដាច់ដាចខ្ទុះខ្ទាយ ពួកប្រេតដទៃទៀតបាំង (កេរ្តិ៍ខ្មាស) ដោយសក់ ពួកប្រេតទាំងនោះដើរដើម្បីបាយ ចៀសចេញទៅអំពីទិសទៅកាន់ទិស ។ ពួកប្រេតខ្លះ ក៏ទៅក្នុងទីឆ្ងាយ (ដើម្បីស៊ី) លុះមិនបាន ក៏ត្រឡប់មកវិញ ស្រេកឃ្លាន ដើរទៅដួលដេក ដួលស្រុសលើផែនដី ពួកសត្វមិនបានធ្វើអំពើល្អ ក្នុងកាលមុន (រមែងក្តៅក្រហាយ) ដូចជាត្រូវភ្លើងឆេះ ក្នុងទីដ៏ក្តៅថា ក្នុងកាលពីដើម ពួកយើងមានធម៌ដ៏លាមក ជាម្ចាស់ផ្ទះ ជាមាតានៃទារកក្នុងត្រកូល ទេយ្យធម៌ទាំងឡាយមានគ្រប់គ្រាន់ តែពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ព្រោះថា ពួកយើងបានកោលគ្រឿងស៊ីនិងគ្រឿងផឹកដ៏ច្រើន កាលដែលមានបព្វជិត ប្រតិបត្តិត្រឹមត្រូវ ពួកយើងមិនបានប្រគេនតែបន្តិចបន្តួចសោះឡើយ ។ ពួកយើងស្រឡាញ់តែអកុសលកម្ម ជាអ្នកខ្ជិលច្រអូស ចំណូលតែនំឆ្ងាញ់ ជាអ្នកស៊ីច្រើន ឲ្យដុំបាយទទួលត្រឹមតែមួយពំនូត តែនិតិះដៀលចំពោះពួកជនអ្នកទទួល ។ ផ្ទះទាំងនោះ ពួកស្រីទាំងនោះ គ្រឿងអាភរណៈទាំងនោះ ជារបស់យើង (សព្វថ្ងៃនេះ) បានទៅពួកអ្នកដទៃប្រើប្រាស់របស់នោះ ឯពួកយើងបានតែចំណែកនៃសេចក្តីទុក្ខម្យ៉ាង

វេណី វា អវញ្ញា ហោន្តិ រថការី[១] ច ទុក្ខិតា
ចណ្ឌាលី កបណា ហោន្តិ កប្បកា[២] ច បុនប្បុនំ ។
យាសុ យាសុ ជាតីសុ កុលេសុ កបណេសុ ច
តេសុ តេស្វេវ ជាយន្តិ ឯសា មច្ឆរិនោ គតិ ។
បុព្វេ ច កតកល្យាណា ទាយកា វីតមច្ឆរា
សគ្គន្តេ បរិបូរេន្តិ ឱភាសេន្តិ ច នន្ទនំ ។
វេជយន្តេ ច បាសាទេ រមិត្វា កាមកាមិនោ
ឧច្ចាកុលេសុ ជាយន្តិ សភោគេសុ តតោ ចុតា ។
កូដាគារេ ច បាសាទេ បល្លង្កេ គោណត្ថតេ[៣]
វីជិតង្គា មោរហត្ថេហិ កុលេ ជាតា យសស្សិនោ ។
អង្កតោ អង្កំ គច្ឆន្តិ មាលាធារី អលង្កតា
ធាតិយោ ឧបតិដ្ឋន្តិ សាយំ បាតំ សុខេសិនោ ។
នយិទំ អកតបុញ្ញានំ[៤] កតបុញ្ញានមេវិទំ
អសោកំ នន្ទនំ រម្មំ តិទសានំ មហាវនំ

---

១ ម. រថិការ ។ ២ ម. នហាបិនី ។ ៣ ម. គោណសន្ថតេ ។ ម. គោណកត្ថតេ ។
៤ ម. អកតបុញ្ញានំ ។



ពួកជនដែលត្រូវគេមើលងាយរឿយ ៗ គឺជាងវែង ១ ជាងរថ ១ អ្នកក្រសួមក្រខ ចណ្ឌាលទុគ៌តកំព្រា ១ អ្នកកាត់សក់ ១ ក្នុងត្រកូលទាំងឡាយណា ៗ ជាកពារជន កំព្រាជន (ពួកសត្វមិនបានធ្វើបុណ្យ) កើតនៅក្នុងត្រកូលទាំងឡាយនោះ ៗ នេះជាគតិនៃជនអ្នកកំណាញ់ ។ ពួកជន បានធ្វើអំពើល្អក្នុងកាលមុន ជាទាយកអ្នកប្រាសចាកសេចក្តីកំណាញ់ ពួកជននោះ ឈ្មោះថា ញុំាងឋានសួគ៌ឲ្យពេញលេញផង ឈ្មោះថា ញុំាងនន្ទនវ័នឲ្យរុងរឿងផង ។ ពួកជនទាំងនោះ ជាអ្នកបរិភោគកាមតាមប្រាថ្នា ត្រេកអរក្នុងប្រាសាទឈ្មោះវេជយន្ត លុះច្យុតចាកទេវលោកនោះហើយ ក៏បានមកកើតក្នុងត្រកូលខ្ពង់ខ្ពស់ទាំងឡាយដែលមានភោគៈ ។ ពួកជនទាំងនោះបានកើតក្នុងត្រកូលមានយស មានខ្លួនគេបក់ដោយផ្លិតស្លាបក្ងោកទាំងឡាយ លើបល្ល័ង្កដែលគេក្រាលដោយសំពត់គោណកៈ ក្នុងផ្ទះមានកំពូលនិងប្រាសាទ ។ ជាអ្នកទ្រទ្រង់នូវកម្រងផ្កា មានខ្លួនប្រដាប់ហើយ ទៅអំពីខ្លួនមួយទៅកាន់ខ្លួនមួយ (នៃញាតិ ឬពីលៀងទាំងឡាយ) ពីលៀងទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខឲ្យ តែងបម្រើទាំងល្ងាចទាំងព្រឹក ។ នន្ទនវ័នរបស់ពួកទេវតានៅក្នុងឋាននៃត្រៃត្រឹង្ស មិនមានសោក ជាទីត្រេកអរ នេះមិនមែនរបស់ពួកជនមិនបានធ្វើបុណ្យទេ នេះជារបស់ពួកជនដែលបានធ្វើបុណ្យ

---

១ កាលនោះក្នុងខ្លួនតែងទៅលើចង្កេះរបស់ញាតិនិងមេដោះ មិនដែលដើរផ្ទាល់នឹងដី ។ អដ្ឋកថា ។

សុខំ អកតបុញ្ញានំ  ឥធ នត្ថិ បរត្ថ ច
សុខញ្ច កតបុញ្ញានំ  ឥធ ចេវ បរត្ថ ច ។
តេសំ សហព្យកាមានំ  កត្តព្វំ កុសលំ ពហុំ
កតបុញ្ញា ហិ មោទន្តិ  សគ្គេ ភោគសមង្គិនោតិ ។

អភិជ្ជមានបេតវត្ថុ បឋមំ ។

## ទុតិយំ សានុវាសិប្បេតវត្ថុ

[៤៧] កុណ្ឌិនគរិយោ[១] ថេរោ  សានុវាសិនិវាសិកោ[២]
ពោដ្ឋបាទោតិ នាមេន  សមណោ ភាវិតិន្ទ្រិយោ ។
តស្ស មាតា បិតា ភាតា  ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន  បេតលោកំ ឥតោ គតា ។
តេ ទុគ្គតា សូចិកដ្ឋា  កិលន្តា នគ្គិនោ កិសា
ឧត្តសន្តា[៣] មហត្តាសា[៤]  ន ទស្សេន្តិ កុរូរិនោ[៥] ។
តស្ស ភាតា វិតរិត្វា  នគ្គោ ឯកបថេ ឯកោ
ចតុកុណ្ឌិកោ ភវិត្វាន  ថេរស្ស ទស្សយីតុមំ ។

---

១ ម. កុណ្ឌិនាគរិយោ ។ ២ ម. សានុវាសិនិវាសិកោ ។ ៣ ម. ម. ឧត្តសន្តា ។ ៤ ម. មហាតាសា ។ ៥ ម. ន ទស្សេន្តិ កុរូរិនោ ។ ម. ន ទស្សន្តិ កុរុរិនោ ។



ពួកជនដែលមិនបានធ្វើបុណ្យ មិនមានសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខឡើយ ឯពួកជនដែលបានធ្វើបុណ្យ រមែងមានសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខពិតប្រាកដ ។ ពួកជនដែលចង់កើតជាមួយនឹងពួកទេវតានោះ គួរធ្វើបុណ្យឲ្យច្រើន ព្រោះពួកជនដែលបានធ្វើបុណ្យហើយ តែងបរិបូណ៌ដោយភោគៈ រមែងរីករាយ ក្នុងឋានសួគ៌ ។

ចប់ រឿងអភិជ្ជមានប្រេត ទី ១ ។

## រឿងសានុវាសិប្រេត ទី ២

(៤៧) (ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ពោលថា) ព្រះថេរៈឈ្មោះពោដ្ឋបាទ អ្នកកើតក្នុងក្រុងកុណ្ឌី បាននៅអាស្រ័យលើភូមិឈ្មោះសានុវាសី ជាអ្នកស្ងប់បាប មានឥន្ទ្រិយចំរើនហើយ (ដោយអរិយមគ្គភាវនា) ។ មាតា បិតា និងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្តីលំបាក បានកើតក្នុងយមលោក (នរក) លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ពួកប្រេតទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាក មានមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្ញែងខ្លាច ភ័យញ័រខ្លួន ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកអាក្រាត តែម្នាក់ឯងក្នុងផ្លូវចុះតែដើរមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដៃជើងបួន ក៏ប្រញាប់ប្រញាល់ទៅបង្ហាញខ្លួនដល់ព្រះថេរៈ ។

ថេរោ អមនសិកត្វា តុណ្ហីភូតោ អតិក្កមិ[១]
សោ ច វិញ្ញាបយិ ថេរំ ភាតា បេតំ[២] គតោ អហំ ។
មាតា បិតា ច តេ ភន្តេ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា
តេ ទុគ្គតា សូចិកដ្ឋា កិលន្តា នគ្គិនោ កិសា
ឧត្តសន្តា មហត្តាសា ន ទេស្សន្តិ ករូរិនោ ។
អនុកម្បស្សុ ការុណិកោ ទត្វា អន្វាទិសាហិ នោ
តវ ទិន្នេន ទានេន យាបេស្សន្តិ ករូរិនោ ។
ថេរោ ចរិត្វា បិណ្ឌាយ ភិក្ខូ អញ្ញេ ច ទ្វាទស
ឯកជ្ឈំ សន្និបតិំសុ ភត្តវិស្សគ្គការណា ។
ថេរោ សព្វេវ តេ អាហ យថាលទ្ធំ ទទាថ មេ
សង្ឃភត្តំ ករិស្សាមិ អនុកម្បាយ ញាតិនំ ។

១ ឱ. អចក្ខិ ។ ២ ឱ. បេតា គតោ ។ ម. បេតគតោ ។



ព្រះថេរៈមិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះឈ្មោះនេះ ហើយក៏នៅស្ងៀមដើរហួសទៅ ឯប្រេតនោះបានទូលព្រះថេរៈឲ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណាត្រូវជាបង បានទៅកាន់បេតលោកហើយ ។ បពិត្រលោកដ៏ចំរើន មាតានិងបិតារបស់លោក ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើកម្មដ៏លាមក មាតានិងបិតាទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្លុតខ្លាំង ភ័យខ្លាំងឡើង ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ លោកជាអ្នកមានសេចក្តីករុណាអាសូរ សូមអនុគ្រោះឲ្យទានឧទ្ទិសទៅឲ្យយើងទាំងឡាយផង មាតានិងបិតាទាំងនោះ ដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលលោកម្ចាស់ឲ្យហើយ ។

ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១២ អង្គផង ដើរទៅបិណ្ឌបាត ហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។ ព្រះថេរៈបាននិយាយនឹងពួកភិក្ខុទាំងអស់នោះថា លោកទាំងឡាយ សូមឲ្យនូវភត្តដែលលោកទាំងឡាយបានហើយយ៉ាងណាដល់ខ្ញុំ ខ្ញុំនឹងធ្វើសង្ឃភត្ត ដើម្បីអនុគ្រោះ ដល់ពួកញាតិ ។

និយ្យាទយឹសុ ថេរស្ស     ថេរោ សង្ឃំ និមន្តយិ
ទត្វា អន្វាទិសិ ថេរោ     បិតុ មាតុ ច ភាតុនោ
ឥទំ មេ ញាតីនំ ហោតុ     សុខិតា ហោន្តុ ញាតយោ ។
សមនន្តរានុទិដ្ឋេ     ភោជនំ ឧទបជ្ជថ[១]
សុចឹ បណីតំ សម្បន្នំ     អនេករសព្យញ្ជនំ
តតោ ឧទ្ទិស្សតិ ភាតា     វណ្ណវា ពលវា សុខី ។
បហូតំ ភោជនំ ភន្តេ     បស្ស នគ្គាម្ហសេ មយំ
តថា ភន្តេ បរក្កម     យថា វត្ថំ លភាម្ហសេ ។
ថេរោ សង្ការកូដតោ     ឧច្ចិនិត្វាន នន្តកេ
បិលោតិកំ បដំ កត្វា     សង្ឃេ ចាតុទ្ទិសេ អទា ។
ទត្វា អន្វាទិសិ ថេរោ     បិតុ មាតុ ច ភាតុនោ
ឥទំ មេ ញាតីនំ ហោតុ     សុខិតា ហោន្តុ ញាតយោ ។

១ ម. ឧទបជ្ជិ ។





ភិក្ខុទាំងនោះ បានប្រគេន (កន្ទាំងនោះ) ដល់ព្រះថេរៈ ព្រះថេរៈបាននិមន្តសង្ឃ លុះព្រះថេរៈ បានឲ្យទានហើយ ក៏ឧទ្ទិសចំពោះបិតាមាតានឹងបងថា សូមឲ្យទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមឲ្យពួកញាតិ បានដល់នូវសេចក្តីសុខ ។

ភោជនក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស (ភោជននោះ) ជាភោជនដ៏ស្អាត ថ្លៃថ្លា ឆ្ងាញ់ ជាម្ហូបមានរសជាច្រើន ក្នុងកាលខាងក្រោយ តពីកាលជាទីបាននូវភោជននោះមក ប្រេតជាបង មានសម្បុរល្អ មានកំឡាំង មានសេចក្តីសុខ បានបង្ហាញខ្លួន (ដល់ព្រះថេរៈហើយពោលថា) បពិត្រលោកដ៏ចំរើន សូមលោកមើលមើលនូវភោជនដ៏ច្រើន (ដែលពួកយើងបានហើយដោយគុណ នៃទានរបស់លោក) ប៉ុន្តែពួកយើងនៅអាក្រាតនៅឡើយ បពិត្រលោកដ៏ចំរើន ពួកយើងគួរបាននូវសំពត់ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសកំណាត់សំពត់ចោលដោយទាំងឡាយអំពីគំនរនៃសម្រាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំងបួន ។ ព្រះថេរៈ បានឲ្យទានហើយឧទ្ទិសដល់បិតាមាតា នឹងបងថា ទាននេះចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។

សមនន្តរានុទ្ទិដ្ឋេ វត្ថានិ ឧបបជ្ជិសុ[១]
តតោ សុវត្ថវសនោ ថេរស្ស ទស្សយីតុមំ ។
វណ្ណវា ពលវា សុខី យាវតា នន្ទរាជស្ស
វិជិតស្មិំ បដិច្ឆទា តតោ ពហុតរា ភន្តេ ។
វត្ថានិច្ឆាទនានិ នោ កោសេយ្យកម្ពលីយានិ
ខោមកប្បាសិកានិ ច វិបុលា ច មហគ្ឃា ច
តេ អាកាសេវលម្ពរេ តេ មយំ បរិទហាម
យំ យំ ហិ មនសោ បិយំ
តថា ភន្តេ បរក្កម យថា គេហំ លភាមសេ ។
ថេរោ បណ្ណកុដឹ កត្វា សង្ឃេ ចាតុទ្ទិសេ អទា
ទត្វា ច ឧទ្ទិសំ[២] ថេរោ បិតុ មាតុ ច ភាតុនោ
ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។
សមនន្តរានុទ្ទិដ្ឋេ ឃរានិ ឧបបជ្ជិសុ[៣]
កូដាគារនិវេសនា វិភត្តា ភាគសោ មិតា ។

១ ម. ឧបបជ្ជិសុ ។ ២ ម. អាទិសិ ។ ៣ ម. ឧបបជ្ជិថ ។



សំពត់ទាំងឡាយ ក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ (ប្រេតជាបទី) ក៏ស្លៀកដណ្ដប់សំពត់ដ៏ល្អបានបង្ហាញខ្លួនដល់ព្រះថេរៈ ។ (ប្រេតនោះ) មានសម្បុរល្អ មានកំឡាំងមានសេចក្ដីសុខ (បាននិយាយថា) បពិត្រលោកដ៏ចំរើន សំពត់ជាគ្រឿងបិទបាំងកាយក្នុងដែនរបស់ព្រះបាទនន្ទៈ ទាំងប៉ុន្មាន (សំពត់ជាគ្រឿងបិទបាំង របស់ពួកយើង) ច្រើនលើសជាងសំពត់ជាគ្រឿងបិទបាំងកាយទាំងនោះ ។

សំពត់ទាំងឡាយជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺកោសេយ្យពស្ត្រ កម្ពលីយពស្ត្រ ខោមពស្ត្រ កប្បាសិកពស្ត្រ ជាសំពត់ធំទូលាយមានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះ ពីអាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំងនោះ តាមចិត្តស្រឡាញ់ បពិត្រលោកដ៏ចំរើន ពួកយើងគួរបានផ្ទះដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានធ្វើកុដិប្រក់ដោយស្លឹកហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំងបួន លុះព្រះថេរៈ បានប្រគេនហើយឧទ្ទិសដល់បិតា មាតានឹងបងថា សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅ ដែលញែកចែក ដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច (ដល់ពួកប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស ។

ន មនុស្សេសុ ឦទិសា   យាទិសា នោ ឃរា ឥធ
អបិ ទិព្វេសុ យាទិសា   តាទិសា នោ ឃរា ឥធ
ទទ្ទល្លមានា អាភេន្តិ   សមន្តា ចតុរោ ទិសា ។
តថា ភន្តេ បរក្កាម   យថា ទានំ លភាមសេ ។
ថេរោ ករកំ បូរេត្វា   សង្ឃេ ចាតុទ្ទិសេ អទា ។
ទត្វា អន្វាទិសី ថេរោ   បិតុ មាតុ ច ភាតុនោ
ឥទំ មេ ញាតីនំ ហោតុ   សុខិតា ហោន្តុ ញាតយោ ។
សមនន្តរានុទ្ទិដ្ឋេ   បានីយំ ឧទបជ្ជថ(១)
គម្ភីរា ចតុរស្សា ច   បោក្ខរញ្ញោ សុនិម្មិតា(២)
សីតោទកា សុប្បតិត្ថា ច   សីតា អប្បដិគន្ធិយា
បទុមុប្បលសញ្ឆន្នា   វារិកិញ្ជក្ខបូរិតា ។
តត្ថ ន្ហាត្វា បិវិត្វា   ថេរស្ស បដិទស្សយុំ
បហូតំ បានីយំ ភន្តេ   បាទា ទុក្ខា ផលន្តិ(៣) នោ
អាហិណ្ឌមានា ខញ្ជាម   សក្ខរេ កុសកណ្ដកេ

១ ម. ឧទបជ្ជិសុ ។ ២ ម. សុមាបិតា ។ ៣ ម. ពាទ ទុក្ខា ផលន្តិ ។



(ប្រេតទាំងនោះពោលថា) ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះ យ៉ាងណា ផ្ទះទាំងឡាយ ក្នុងមនុស្សលោកមិនដូច្នោះទេ តែផ្ទះទាំងឡាយ ក្នុងឋានទិព្វទាំងឡាយ យ៉ាងណា ផ្ទះទាំងឡាយ របស់ពួកយើងក្នុងបេតលោកនេះ យ៉ាងនោះដែរ ជាផ្ទះដ៏រុងរឿង តាមញ៉ាំងទិសទាំង ៤ ឲ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចំរើន ពួកយើងគួរបានទឹកផឹក ដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានដាក់ទឹកបំពេញធម្មក្រក ហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតា មាតានិងបងថា សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខ ។

ទឹកក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស ស្រះបោក្ខរណីទាំងឡាយ ដែលបុគ្គលនិម្មិតល្អហើយ ជ្រៅ មានជ្រុងបួន មានទឹកដ៏ត្រជាក់ មានកំពង់ល្អ ជាស្រះត្រជាក់ មានក្លិនក្រអូបប្រៀបមិនបាន ដេរដាស ដោយផ្កាឈូកនិងផ្កាឧប្បល ពេញដោយលំអងលើទឹក ។ ប្រេតទាំងនោះងូតផឹក ក្នុងស្រះបោក្ខរណីនោះហើយ បង្ហាញខ្លួនដល់ព្រះថេរៈថា បពិត្រលោកដ៏ចំរើន (ពួកយើងបាន) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើង ឈឺ ពុះពង ពួកយើងកាលដើរជាន់លើក្រួសរវេង លើស្បូវភ្លាំងនិងបន្លា វៀនវើចៗ

តថា ភន្តេ បរក្កម    យថា យានំ លភាមសេ ។
ថេរោ សិបាជិតំ លទ្ធា    សង្ឃេ ចាតុទ្ទិសេ អទា ។
ទត្វា អន្វាទិសិ ថេរោ    បិតុ មាតុ ច ភាតុនោ
ឥទំ មេ ញាតីនំ ហោតុ    សុខិតា ហោន្តុ ញាតយោ ។
សមនន្តរានុទ្ទិដ្ឋេ    បេតា រថេន មាគមុំ
អនុកម្បិតម្ហ ភទន្តេ    ភត្តេន ឆាទនេន ច
ឃរេន បានីយទានេន    យានទានេន ចូភយំ
មុនឹ ការុណិកំ លោកេ    តំ ភន្តេ វន្ទិតុមាគតាតិ ។

សានុវាសិបេតវត្ថុ ទុតិយំ ។

# តតិយំ រថការិបេតវត្ថុ

(២៨) វេឡុរិយថម្ភំ រុចិរំ បភស្សរំ
វិមានមារុយ្ហ អនេកចិត្តំ
តត្ថច្ឆសិ ទេវិ មហានុភាវេ
បថទ្ធនិ បណ្ណរសេវ ចន្ទិមា
វណ្ណោ ច តេ កនកស្ស សន្និភោ





បពិត្រលោកដ៏ចំរើន ពួកយើងនឹងបាននូវយាន ដោយប្រការណា សូមលោកចំព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានស្បែកជើងមានជាន់មួយ ហើយបានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយក៏ឧទ្ទិស ចំពោះបិតាមាតានិងបងថា សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខ ។

ពួកប្រេតបានមកដោយរថ ក្នុងលំដាប់ដែលឧទ្ទិសហើយ (ទើបពោលថា) បពិត្រលោកដ៏ចំរើន ពួកយើងលោកបានអនុគ្រោះហើយ ដោយបាយផង ដោយគ្រឿងស្លៀកដណ្ដប់ផង ដោយផ្ទះផង ដោយទានទាំងពីរគឺ បានីយទាននិងយានទានផង បពិត្រលោកដ៏ចំរើន ពួកយើងមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណាក្នុងលោក ។

ចប់ រឿងសានុវាសីប្រេតទី ២ ។

# រឿងរថការីប្រេត ទី ៣

(២៨) (មាណពនិយាយនឹងស្រីប្រេតថា) បពិត្រនាងទេវី មានអានុភាពច្រើន នាងឡើងកាន់វិមាន មានសសរកែវពិទូរ្យ ភ្លឺរុងរឿងគួរជាទីរីករាយ វិចិត្រដោយគ្រឿងច្រើនយ៉ាង ហើយនៅក្នុងវិមាននោះដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត នៅក្នុងផ្លូវជាគន្លង (របស់ខ្លួន) ពណ៌សម្បុររបស់នាងល្អប្រាកដស្មើដោយមាស

ឧត្តមរូបោ[១] ភុសទស្សនេយ្យោ
បល្លង្កសេដ្ឋេ អតុលេ និសិន្នា
ឯកា តុវំ នត្ថិ ច តុយ្ហំ សាមិកោ ។
ឥមា ច តេ បោក្ខរញ្ញោ សមន្តតោ[២]
បហូតមាល្យា[៣] ពហុបុណ្ឌរីកា
សោវណ្ណចុណ្ណេហិ សមន្តមោត្ថតា[៤]
ន តត្ថ បង្កោ បណកោ ច វិជ្ជតិ ។
ហំសា ចិមេ ទស្សនិយា មនោរមា
ឧទកស្មិំ អនុបរិយន្តិ សព្វទា
សមយ្យ វគ្គុ មុបនទន្តិ សព្វេ
ពិន្ទុស្សរា ទុន្ទុភីនំវ ឃោសោ ។
ទទ្ទល្លមានា យសសា យសស្សិនី
នាវាយ ច ត្វំ អវលម្ព តិដ្ឋសិ
អាឡារបម្ហេ[៥] ហសិតេ បិយំវទេ
សព្វង្គកល្យាណិ ភុសំ វិរោចសិ ។
ឥទំ វិមានំ វិរជំ សមេ ឋិតំ

១ ម. ឧត្តរូបោ ។ ម. ឧត្តត្តរូបោ ។ ២ ម. បោក្ខរញ្ញា សមន្តតោ ។ ម. បោក្ខរណី សមន្តា ។ ៣ ម. បហុតមល្យា ។ ៤ ម. សមន្តមោត្ថតា ។ ៥ ម. អាឡារបម្ហ ។





*មានសភាពខ្ពង់ខ្ពស់ គួរឲ្យរមិលមើលក្រៃពេក បពិត្រនាង មិនមានអ្នកផ្ទឹមបាន នាងគង់លើបល្ល័ង្កដ៏ប្រសើរបំផុត នាងនៅតែម្នាក់ឯង នាងមិនមានប្ដីសោះ ។ ឯស្រះបោក្ខរណីទាំងឡាយ របស់នាងនេះ មានកម្រងផ្កាច្រើនយ៉ាង មានផ្កាឈូកសច្រើនដោយជុំវិញ រោយរាយជុំវិញ ដោយកំទេចនៃមាសទាំងឡាយ ភក់ និងចក ក៏មិនមានក្នុងស្រះបោក្ខរណីទាំងនោះ ។ សត្វហង្សទាំងនេះ គួររមិលមើល គួររីករាយនៃចិត្ត ក៏ហែលត្រឡប់លើទឹកសព្វ ៗ កាល ហង្សទាំងអស់មានសំឡេងមូល ដូចជាសំឡេងគឹកកង នៃស្គរទាំងឡាយប្រជុំគ្នាបន្លឺឡើងនូវសំឡេងដ៏ពីរោះ ។ នាងជាអ្នកមានយសរុងរឿងដោយយស ឈរផ្អែកលើទូក បពិត្រនាងមានរោមភ្នែកខ្មៅ វែង នាងសើច នាងពោល នូវពាក្យជាទីស្រឡាញ់ មានលំអសព្វអវយវៈ រុងរឿងក្រៃពេក ។ វិមាននេះ ប្រាសចាកធូលី តាំងនៅលើផែនដីរាប*

ទុយ្យាចវធិ(១) ភេជ្ជន្ទុំវប្បធិ
ឥច្ឆាមិ តេ នារិ អនោមទស្សនេ
តយា សហ ឧទ្ទេ ឥធ មោទិតុន្តិ ។
ករោហិ កម្មំ ឥធ វេទនីយំ
ចិត្តញ្ច តេ ឥធ និតញ្ច ហោតុ(២)
កត្វាន កម្មំ ឥធ មោទនីយំ
ឯវំ មមំ លច្ឆសិ កាមកាមិនិន្តិ ។
សាធូតិ សោ តស្សា បដិស្សុណិត្វា
អកាសិ កម្មំ តហិំ វេទនីយំ
កត្វាន កម្មំ តហិំ វេទនីយំ
ឧបបជ្ជិ មាណវោ តស្សា សហព្យតន្តិ ។

រថការីបេតវត្ថុ តតិយំ ។

ភាណវារំ ទុតិយំ ។

## ចតុត្ថំ ភុសប្បេតវត្ថុ

(៦៩) ភុសានិ ឯកោ សាលី បុនាបរេ(៣)
អយញ្ច(៤) នារី សកមំសលោហិតំ

---

១. ឱ. ទុយ្យាចវិធិ ។ ២ ឱ. ចិត្តំ ភវតុ ។ ឱ. និតញ្ច ហោតុ ។ ៣ ឱ. ឯកោ សាលី បុនាបរោ ។ ៤ ឱ. អញ្ញា ។



ជាខ្ញុំទៀត ញុំាងនាងប្រេតនីសេចក្តីរីករាយឲ្យចំរើន បពិត្រនារី គួរមើលមើល មិនចេះឆ្អែត ខ្ញុំប្រាថ្នា ដើម្បីរីករាយក្នុងវិមានជាទីរីករាយនេះរបស់នាង ជាមួយនឹងនាង ។

(នាងវិមានប្រេតពោលថា) អ្នកចូរធ្វើនូវកម្មដែលឲ្យផលក្នុងឋានទេវតានេះ ទាំងចិត្តរបស់អ្នកសោត ក៏ចូរឱនទៅក្នុងឋានទេវតានេះ លុះអ្នកធ្វើនូវកម្មដែលគួររីករាយក្នុងឋានទេវតានេះហើយ ទើបអ្នកបាននូវខ្ញុំជាស្រីមានកាមតាមប្រាថ្នា ដោយប្រការយ៉ាងនេះ ។

មាណពនោះ បានទទួលស្តាប់ពាក្យនាងវិមានប្រេតនោះថា អើនាង ស្រួលហើយ ហើយក៏បានធ្វើកម្មដែលឲ្យផលក្នុងឋានទេវតានោះ លុះមាណពបានធ្វើកម្មដែលឲ្យផលក្នុងឋានទេវតានោះហើយ ក៏បានទៅកើតជាមួយនឹងនាងវិមានប្រេតនោះ ។

ចប់ រឿងរថការីប្រេត ទី ៣ ។

ចប់ ភាណវារៈ ទី ២ ។

## រឿងភុសប្រេត ទី ៤

(៦៩) (ព្រះមោគ្គល្លានសួរថា) ប្រេតម្នាក់ (រោយរាយ) អង្កាមនៃស្រូវសាលី (លើក្បាលខ្លួន) ប្រេតម្នាក់ទៀត (សំពងចំបែកក្បាល របស់ខ្លួន ដោយដំបងដែក) ឯស្រីនេះ (ស៊ី) សាច់និងឈាម របស់ខ្លួន

បេតវត្ថុស្មឹ តតិយស្ស ចូឡវគ្គស្ស ចតុត្ថំ កុសលបេតវត្ថុ

គូថញ្ច ភុជិ អសុចិំ អកន្តំ[១]
បរិភុញ្ជសិ កិស្ស អយំ វិបាកោ ។

អយំ បុរេ មាតរំ ហិំសតិ    អយំ បន កូដវាណិជោ
អយំ មំសានិ ខាទិត្វា    មុសាវាទេន វញ្ចេតិ ។

អហំ មនុស្សេសុ មនុស្សភូតា
អគារិនី សព្វកុលស្ស ឥស្សរា ។

សន្តេសុ បរិគុយ្ហាមិ[២]    មា ច កិញ្ចិ ឥតោ អទំ
មុសាវាទេន ឆាទេមិ    នត្ថិ ឯតំ មម គេហេ
សចេ សន្តំ និគុយ្ហាមិ    គូថំ[៣] មេ ហោតុ ភោជនំ ។
តស្ស កម្មវិបាកេន    មុសាវាទស្ស ចូភយំ
សុគន្ធសាលិនោ ភត្តំ    គូថំ មេ បរិវត្តតិ ។
អវញ្ឈានិ[៤] ច កម្មានិ    ន ហិ កម្មំ វិនស្សតិ
ទុគ្គន្ធំ កិមិនំ មីឡ្ហំ    ភុញ្ជាមិ ច បិវាមិ ចាតិ ។

កុសលបេតវត្ថុ ចតុត្ថំ ។

---

១ ម. អសុចិ អកន្តិកំ ។ ឱ. អសុចិកន្តំ ។ ២ ម. បរិគូហាមិ ។ ឱ. បរិគុហាមិ ។ ៣ ម. និគូហាមិ គូថោ ។ ឱ. និគុហាមិ គូថោ ។ ៤ អញ្ញកថាយំ អវញ្ឈានីតិ ទិស្សតិ ។ ឯតំ យុត្តតរំ



បេតវត្ថុ ចូឡវគ្គ ទី ៣ រឿងកុសលប្រេត ទី ៤

ភិក្ខុនីអ្នកសោក គឺស៊ីលាមក មិនស្អាត មិនគួរឲ្យ
ប្រាថ្នា នេះតើ ជាផលនៃកម្ម ដូចម្តេច ។

(ភរិយារបស់ពាណិជ បានទូលថា) ក្នុងកាលមុន ប្រេតម្នាក់នេះ បានប្រហារមាតា (ដោយព្រនង់) ឯប្រេតម្នាក់នេះ ជាពាណិជ បោកប្រាស ប្រេតនេះ រមែងស៊ីសាច់ពីដំបូង ហើយបញ្ឆោត ដោយពាក្យមុសាវាទ ។

ខ្ញុំបានកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នក
គ្រប់គ្រងផ្ទះ ជាឥស្សរៈនៃត្រកូលទាំងពួង ។

កាលដែលគ្រឿងឧបករណ៍មានគ្រប់គ្រាន់ ខ្ញុំក៏បានលាក់លៀមទុក មិនបានឲ្យវត្ថុតិចតួច អំពីគ្រឿងឧបករណ៍នេះ (ដល់អ្នកដទៃ) ខ្ញុំបិទបាំងដោយពាក្យមុសាវាទថា វត្ថុនេះក្នុងផ្ទះខ្ញុំមិនមានទេ ប្រសិនបើ ខ្ញុំលាក់វត្ថុដែលមាន សូមឲ្យលាមកមកជាភោជនរបស់ខ្ញុំចុះ ។ បាយនៃស្រូវសាលី មានក្លិនក្រអូបឈ្ងុយ ក៏ក្លាយទៅជាលាមកវិញខ្ញុំ ដោយវិបាកនៃកម្មទាំងពីរនេះ (ការលាក់លៀមទុកវត្ថុដែលមាន១) និងមុសាវាទ១ ។ ឯកម្មទាំងឡាយ មិនមែនឥតសោះសូន្យឡើយ ព្រោះថា កម្មមិនដែលវិនាសទៅ ខ្ញុំស៊ីផឹកនូវលាមក មានក្លិនអាក្រក់ (ជាលំនៅ) នៃពួកដង្កូវ ។

ចប់ រឿងកុសលប្រេត ទី ៤ ។

## បញ្ចមំ កុមារបេតវត្ថុ

(៣០) អច្ឆេរូបំ សុគតស្ស ញាណំ
សត្ថា យថា បុគ្គលំ ព្យាកាសិ
ឧស្សន្នបុញ្ញាបិ ភវន្តិ ហេកេ
បរិត្តបុញ្ញាបិ ភវន្តិ ហេកេ ។
អយំ កុមារោ សីវថិកាយ ឆឌ្ឌិតោ
អង្គុដ្ឋស្នេហេន យាបេសិ រត្តិំ ។
ន យក្ខភូតា ន សរីសបា វា
វិហេឋយេយ្យុំ[១] កតបុញ្ញកុមារំ
សុនខាបិមស្ស បលិហិំសុ បាទេ
ធង្កា សិង្គាលា បរិវត្តយន្តិ ។
គព្ភាសយំ បក្ខិគណា ហរន្តិ
កាកា បន អក្ខិមលំ ហរន្តិ
ន ឥមស្ស រក្ខំ វិទហិំសុ កេចិ
ន ឱសធំ សាសបធូបនំ វា ។
នក្ខត្តយោគំបិ ន អគ្គហេសុំ
ន សព្វធញ្ញានិបិ អាកិរិំសុ

១ ម. ន ហេឋយុំ ។



## រឿងកុមារប្រេត ទី ៥

(៣០) (ព្រះសង្គីតិកាចារ្យទាំងឡាយ ពោលថា) ញាណរបស់ព្រះសុគត មានសភាពអស្ចារ្យ ដូចព្រះសាស្តាទ្រង់ព្យាករនូវបុគ្គលថា បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យស្តើង ។ កុមារនេះ ដែលគេបោះបង់ក្នុងព្រៃស្មសាន បានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះ ដែលហូរចេញអំពីមេដៃ (នៃទេវតា) អស់មួយរាត្រី ។ យក្ស និងភូតទាំងឡាយក្តី ពស់ទាំងឡាយក្តី មិនបៀតបៀនកុមារ អ្នកមានបុណ្យធ្វើហើយទេ សូម្បីតែពួកឆ្កែ ក៏មកលិទ្ធជើងទាំងគូ របស់កុមារនេះដែរ ពួកក្អែកព្រៃ ពួកចចក ក៏មកដើរជុំវិញ (កុមារនោះ) ។ ហ្វូងសត្វស្លាបទាំងឡាយ ក៏នាំយកមន្ទិលគភ៌ចេញ ឯក្អែកទាំងឡាយ ក៏នាំយកអាចម៍ភ្នែកចេញ មនុស្សនឹងអមនុស្សពួកខ្លះ មិនបានចាត់ចែងការរក្សានូវកុមារនេះទេ មិនបានចាត់ចែងនូវឱសថ និងការអប់ ដោយគ្រាប់ស្ពៃ (ដល់កុមារនេះទេ) ។ សូម្បីតែពួកមនុស្ស ក៏មិនរៀននូវការប្រកបនូវនក្ខត្តឫក្ស ទាំងមិនបានរោយរាយ នូវធញ្ញជាតិគ្រប់មុខ

ឯតាទិសំ ឧត្តមកិច្ឆបត្តំ
រត្តាភតំ សីវថិកាយ ឆឌ្ឌិតំ ។
នវនីតបិណ្ឌំ[១] វិយ បវេធមានំ
សសំសយំ ជីវិតសាវសេសំ
តមទ្ទស ទេវមនុស្សបូជិតោ
ទិស្វា បន ព្យាករិ ភូរិបញ្ញោ
អយំ កុមារោ នគរស្សិមស្ស
អគ្គកុលិកោ ភវិស្សតិ ភោគតោ ច[២]
កិស្ស វតំ កិំ បន ព្រហ្មចរិយំ
កិស្ស សុចិណ្ណស្ស អយំ វិបាកោ
ឯតាទិសំ ព្យសនំ បាបុណិត្វា
តំ តាទិសំ បច្ចនុភោស្សតិទ្ធិំ ។
ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស
បូជំ អកាសិ ជនតា ឧឡារំ
តត្រស្ស ចិត្តស្ស អហុ អញ្ញថត្តំ
វាចំ អភាសិ ផរុសំ អសព្ភំ[៣]
សោ តំ វិតក្កំ បវិនោទយិត្វា

---

១ ឱ. ម. នោនីតបិណ្ឌំ ។ ២ ឱ. ភោគតោ ច ។ ៣ ម. អសព្ភិ ។





លើកុមារដែលមានសភាពដូច្នោះ ដែលដល់នូវសេចក្តីលំបាកយ៉ាងក្រៃលែង គេនាំមកក្នុងវេលាយប់ ហើយបោះចោលក្នុងព្រៃស្មសាន ព្រះពុទ្ធដែលទេវតានិងមនុស្សបូជា បានឃើញកុមារនោះ ដូចជាដុំខ្លាញ់ទឹកដោះខាប់ កំពុងតែញាប់ញ័រប្រកបដោយសេចក្តីសង្ស័យ នៅសល់តែជីវិត លុះព្រះពុទ្ធមានប្រាជ្ញាស្មើដោយផែនដីបានឃើញហើយ ទើបទ្រង់ព្យាករថា កុមារនេះ នឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផង ក្នុងនគរនេះ ។

(ពួកភិក្ខុបានសួរថា) តើវតដូចម្តេច ព្រហ្មចរិយៈដូចម្តេច នេះជាផលនៃវត ឬព្រហ្មចរិយៈដូចម្តេច ដែលកុមារនេះបានសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្តីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវឫទ្ធិ និងសម្បត្តិដល់ម្ល៉េះនោះវិញ ។

(ព្រះសម្ពុទ្ធកាលទ្រង់ព្យាករថា) ពួកជនបានធ្វើនូវការបូជា ដ៏ទូលាយចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន តាកេនោះមានចិត្តប្រែក្នុងការបូជានោះ តាកេនោះបាននិយាយពាក្យអាក្រក់ ជាពាក្យមិនគួរចាប់ចិត្ត ក្នុងទីប្រជុំនៃសប្បុរស តាកេនោះ បន្ទោបង់សេចក្តីត្រិះរិះនោះចេញហើយ

បីតិបសាទំ បដិលទ្ធា បញ្ញា
តថាគតំ ជេតវនេ វសន្តំ
យាគុយា ឧបដ្ឋាសិ សោ សត្តរត្តំ ។
តស្ស វតំ តំ បន ព្រហ្មចរិយំ
តស្ស សុចិណ្ណស្ស អយំ វិបាកោ
ឯតាទិសំ ព្យសនំ បាបុណិត្វា
តំ តាទិសំ បច្ចុបោសស្សុរត្តិំ ។
ឋត្វាន សោ វស្សសតំ ឥធេវ
សព្វេហិ កាមេហិ សមង្គិភូតោ
កាយស្ស ភេទា អភិសម្បរាយំ
សហព្យតំ គច្ឆតិ វាសវស្ស ។

កុមារបេតវត្ថុ បញ្ចមំ ។

## ឆដ្ឋមំ សេរិណីបេតវត្ថុ

(៣១)នគ្គា ទុព្វណ្ណរូបាសិ កិសា ធមនិសន្ថតា
ឧប្ផាសុលិកេ កិសិកេ កា នុ ត្វំ ឥធ តិដ្ឋសីតិ ។
អហំ ភទ្ទន្តេ បេតីម្ហិ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា(តិ)។



គឺត្រឡប់បាននូវសេចក្តីត្រេកអរនិងសេចក្តីជ្រះថ្លា ក្នុងកាលជាខាងក្រោយ ពាក្យនោះ បានបម្រើព្រះតថាគត ព្រះអង្គគង់នៅក្នុងវត្តជេតពន ដោយយាគូអស់ ៧ ថ្ងៃ ។ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់កុមារនោះ នេះជាផលនៃវត្ត ឬព្រហ្មចរិយៈនោះ ដែលកុមារនេះសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្តីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវថ្ងៃនិងពួកសម្បត្តិដល់ម្ល៉ោះនោះវិញ ។ លុះកុមារនោះ ឋិតនៅក្នុងមនុស្សលោកនេះ អស់មួយរយឆ្នាំ ជាអ្នកបរិបូណ៌ដោយកាមគុណទាំងពួង លុះបែកធ្លាយរាងកាយទៅខាងមុខ ក៏បានជាគូន នៃសក្កទេវរាជ ។

ចប់ រឿងកុមារប្រេត ទី ៥ ។

## រឿងសេរិណីប្រេត ទី ៦

(៣១) (ឧបាសកបានសួរស្រីប្រេតថា) ម្នាលនាងស្គម មានផ្ទៃនិងជំនីរគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ ជាស្រីស្គមរីងរៃដោយសរសៃ នាងជាអ្វី មកឈរក្នុងទីនេះ ។

(ស្រីប្រេតឆ្លើយថា) បពិត្រអ្នកដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក (លុះច្យុត) អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ។

កិំ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បេតលោកំ ឥតោ គតា(តិ) ។
អនវជ្ជេសុ[១] តិត្ថេសុ វិចិនំ អឌ្ឍមាសកំ
សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកាសិមត្តនោ ។
នទឹ ឧបេមិ តសិតា រិត្តកា បរិវត្តតិ
ឆាយំ ឧបេមិ ឧណ្ហេសុ អាតបោ បរិវត្តតិ ។
អគ្គិវណ្ណោ ច មេ វាតោ ឌហន្តោ ឧបវាយតិ
ឯតញ្ច ភន្តេ អរហាមិ អញ្ញញ្ច បាបកំ តតោ ។
គន្ត្វាន ហត្ថិនិំ បុរំ[២] វជ្ជេសិ មយ្ហំ មាតរំ
ធីតា ច តេ មយា ទិដ្ឋា ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា ។
អត្ថិ ច មេ ឯត្ថ និក្ខិត្តំ អនក្ខាតញ្ច តំ មយា
ចត្តារិ សតសហស្សានិ បល្លង្កស្ស ច ហេដ្ឋតោ ។
តតោ មេ ទានំ ទទាតុ តស្សា ច ហោតុ ជីវិកា
ទានំ ទត្វា ច[៣] មេ មាតា ទក្ខិណំ អនុទិស្សតុ មេ[៤]

១ ម. អនាវដេសុ ។ ២ ម. ហត្ថិនិបុរំ ។ ៣ ម. ច ។ ៤ ម. ទក្ខិណំ ទុទិស្ស តុម្ហេ ។





(១ ព្រះសង្ឃសួរថា) អំពើអាក្រក់ដូចម្តេច ដែលនាងបានធ្វើហើយ ដោយកាយ វាចា ចិត្ត នាង (ច្យុត) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ដោយផលនៃកម្មដូចម្តេច ។

(ស្រីប្រេតឆ្លើយថា) ខ្ញុំបានរើសទ្រព្យកន្លះមាសក ត្រង់កំពង់ទាំងឡាយ ដែលមិនមានទោស គឺមិនមានអ្នកណាមួយហាត់ហាំង កាលដែលទេយ្យធម៌ទាំងឡាយ កំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើខ្លួនឲ្យជាទីពឹងនៃខ្លួនសោះ ។ ខ្ញុំស្រេកទឹក ចូលទៅកាន់ស្ទឹង ស្ទឹងក៏ប្រែទៅជាទទេ ខ្ញុំចូលទៅជ្រកម្លប់ ក្នុងកាលកំពុងក្តៅ ស្រមោលក៏ប្រែទៅជាក្តៅ ។ ខ្យល់ដែលដូចភ្លើងសោត ក៏ក្តៅសាយមកដល់ខ្ញុំ បពិត្រអ្នកដ៏ចំរើន ខ្ញុំគួរ (នឹង) ទុក្ខមានបរម្រែកជាដើមនេះ និងបាបកម្មដទៃដ៏លាមកលើសលុបជាងសេចក្តីទុក្ខមានសម្រេកជាដើមនោះ ។ អ្នកគួរទៅកាន់ហត្ថិនីបុរី ហើយជំរាបមាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក (ច្យុត) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុះមាន តែខ្ញុំមិនបានប្រាប់ទ្រព្យនោះ (ឯទ្រព្យទាំងនោះ) ចំនួន ៤ សែនកហាបណៈ ក្រោមបល្ល័ង្ក(របស់ខ្ញុំ) ។ មាតារបស់ខ្ញុំនោះ ចូរឲ្យទានអំពីទ្រព្យនោះផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឲ្យទានហើយ ចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំផង

តទាហំ សុខិតា ហេស្សំ សព្វកាមសមិទ្ធិនី ។
សាធូតិ សោ តស្សា បដិស្សុណិត្វា គន្ត្វាន ហត្ថិនីបុរំ
តស្សា អវោច មាតរំ ធីតា ច តេ មយា ទិដ្ឋា
ទុគ្គតា យមលោកិកា ពាបកម្មំ ករិត្វាន
បេតលោកំ ឥតោ គតា សា មំ តត្ថ សមាទបេសិ
គន្ត្វាន ហត្ថិនីបុរំ វជ្ជេសិ មយ្ហំ មាតរំ
ធីតា ច តេ មយា ទិដ្ឋា ទុគ្គតា យមលោកិកា
ពាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា ។
អត្ថិ ច មេ ឯត្ថ និក្ខិត្តំ អនក្ខាតញ្ច តំ មយា[១]
ចត្តារិ សតសហស្សានិ បល្លង្កស្ស ច ហេដ្ឋតោ
តតោ មេ ទានំ ទទាតុ[២] តស្សា ច ហោតុ ជីវិកា
ទានំ ទត្វា ច មេ មាតា ទក្ខិណំ អនុទិស្សតុ មេ
តទាហំ សុខិតា ហេស្សំ សព្វកាមសមិទ្ធិនី ។

១ ម. ឥ ។ ២ ម. តតោ ភុំ ទានំ ទេហិ ។



ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។

ចំណែកបុរសនោះ ទទួលស្តាប់ពាក្យប្រេតនោះថា ប្រពៃហើយ រួចក៏ទៅកាន់ហត្ថិនីបុរី បានប្រាប់ដល់មាតារបស់ស្រីប្រេតនោះថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក (បាប) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក កូនស្រីរបស់នាងនោះ បានផ្តាំនឹងខ្ញុំក្នុងបេតលោកនោះថា អ្នកអញ្ជើញទៅកាន់ហត្ថិនីបុរី ហើយប្រាប់ដល់មាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើកម្មដ៏លាមក (បាប) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុះមាន តែខ្ញុំមិនបានប្រាប់នូវទ្រព្យនោះ (ឯទ្រព្យនោះ) ចំនួន ៤ សែនកហាបណៈនៅទីក្រោមបល្ល័ង្ក(របស់ខ្ញុំ) ។ សូមមាតាឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំ លុះឲ្យទានហើយសូមឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។

តតោ ហិ សា ទានមទាសិ ឧច្ចាវចសុលក្ខណមានសិ
បេតី ច សុខិតា អហោសិ តស្សា បាបំ សុជីវិតាតិ ។

សេរិណីបេតវត្ថុ ឆដ្ឋំ ។

## សត្តមំ មិគលុទ្ទបេតវត្ថុ

(៣៦) នរោ នារីបុរក្ខតោ យុវា រជនីយេហិ កាមគុណេហិ[១] សោភសិ
ទិវសំ អនុភោសិ ការណិកំ អកាសិ បុរិមាយ ជាតិយា ។
អហំ រាជគហេ រម្មេ រមណីយេ គិរិព្វជេ
មិគលុទ្ទោ បុរេ អាសឹ[២] លោហិតបាណី ទារុណោ ។
អវិរោធករេសុ បាណិសុ បុថុសត្តេសុ បទុដ្ឋមានសោ
វិចរឹ អតិទារុណោ សទា បរហឹសាយ រតោ អសញ្ញតោ ។
តស្ស មេ សហាយោ សុហទយោ សទ្ធោ អាសិ ឧបាសកោ
សោបិ[៣] មំ អនុកម្បន្តោ និវារេសិ បុនប្បុនំ
មាកាសិ បាបកំ កម្មំ មា តាត ទុគ្គតឹ អគា
សចេ ឥច្ឆសិ បេច្ច សុខំ វិរម បាណវធា អសំយមា ។

១ ម. រតិរមេហិ ការេហិ ។ ២ ម. ឯត្ថ ឃាតេ លុទ្ទោតិ អត្ថោ ។ ៣ ម. ប ។



ក៏ក្នុងលំដាប់នោះ មាតានោះបានឲ្យទាន លុះឲ្យហើយ បាន ឧទ្ទិសនូវចំណែកបុណ្យទានដល់ស្រីប្រេតនោះ ស្រីប្រេតក៏បានដល់នូវ សេចក្តីសុខផង មាតានោះក៏ភ្ញាក់ដឹង ដោយឥរិយាបថ ។

ចប់ រឿងសេរិណីប្រេត ទី ៦ ។

## រឿងមិគលុទ្ទប្រេត ទី ៧

(៣៦) (ព្រះនារទត្ថេរសួរប្រេតថា) អ្នកជាមនុស្ស មានស្រីជាបរិវារ ត្រេកត្រអាលដោយកាមគុណទាំងឡាយ គួរឲ្យត្រេកត្រអាល (ក្នុងវេលាយប់ ផ្សេងៗ) ក្នុងវេលាថ្ងៃ អ្នកបានសោយទុក្ខ អ្នកធ្វើកម្មអ្វី ក្នុងជាតិមុន ។

(ប្រេតបានឆ្លើយថា) កាលពីដើមខ្ញុំជាព្រានម្រឹគ មានដៃប្រឡាក់ដោយឈាម ជាអ្នកសាហាវ នៅក្នុងក្រុងរាជគ្រឹះ មានភ្នំជុំវិញជាកំពែង ជាទីគួរត្រេកអររីករាយ ។ ខ្ញុំមានចិត្តប្រទូស្តចំពោះពួកសត្វច្រើន ជាសត្វមិនធ្វើកំហុស (ទីទីណាមួយ) សាហាវក្រៃពេក ត្រេកអរតែក្នុងការបៀតបៀនចំពោះសត្វដទៃ មិនសង្រួម គ្រប់កាលទាំងពួង ។ សំឡាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា គាត់អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែកូន អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នា សេចក្តីសុខ ក្នុងបរលោក អ្នកចូរវៀរចេញនូវការមិនសង្រួមគឺការសម្លាប់សត្វ ។

តស្សាហំ វចនំ សុត្វា សុខកាមស្ស ហិតានុកម្បិនោ

នាកាសឹ សកលានុសាសនឹ ចិរបាបាភិរតោ អវិទ្ទសុ ។

សោ មំ បុន ភូរិសុមេធសោ អនុកម្បាយ សំយមេ និវេសយិ

សចេ ទិវា ហនសិ បាណិនោ អថ តេ រត្តឹ ភវតុ សំយមោ ។

ស្វាហំ ទិវា ហនិត្វាន បាណិនោ វិរតោ រត្តឹ អហោសិ សំយតោ

រត្តាហំ បរិចារេមិ[១] ទិវា ខជ្ជាមិ ទុគ្គតោ ។

តស្ស កម្មស្ស កុសលស្ស អនុភោមិ រត្តឹ អមានុសឹ

ទិវា បដិហតា វ កុក្កុរា ឧបធាវន្តិ សមន្តា ខាទិតុំ

យេ ច តេ សតតានុយោគិនោ[២] ធុវំ បយុត្តា សុគតស្ស សាសនេ

មញ្ញាមិ តេ អមតមេវ កេវលំ អធិគច្ឆន្តិ

បទំ អសង្ខតន្តិ ។

មិគលុទ្ទកបេតវត្ថុ សត្តមំ ។

១ ម. បរិចារេមិ ។ ២ អដ្ឋកថាយំ បន យេ ច សតតានុយោគិនោតិ ទិស្សតិ



ខ្ញុំបានស្តាប់ពាក្យសំឡាញ់នោះ ជាអ្នកប្រាថ្នានូវសេចក្តីសុខ អ្នកអនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ(របស់គាត់)ទាំងអស់ ។ សំឡាញ់នោះ ជាអ្នកមានប្រាជ្ញាល្អ ស្មើដោយផែនដី បានដឹកនាំខ្ញុំក្នុងសេចក្តីសង្រួមខ្លួនទៀត ដោយសេចក្តីអនុគ្រោះថា បើអ្នកសំឡាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសំឡាប់ពួកសត្វ តែក្នុងវេលាថ្ងៃ ជាអ្នកសង្រួមវៀរចាកការសំឡាប់សត្វក្នុងវេលាយប់ ខ្ញុំក្សាន្តបានតែក្នុងវេលាយប់ វេលាថ្ងៃ ទៅកាន់ទុគ្គតិ (ឆ្កែទាំងឡាយ) ខាំស៊ី ។ ខ្ញុំបានសោយសម្បត្តិ មិនមែនជារបស់មនុស្សក្នុងវេលាយប់ (ដោយអំណាច) កុសលកម្មនោះ វេលាថ្ងៃ ពួកឆ្កែមានចិត្តខាញ់ស្ទុះមកដោយខាំ ដោយជុំវិញ ។ ពួកសត្វណា មានការប្រកបរឿយៗ ប្រកបជានិច្ច ក្នុងសាសនារបស់ព្រះសុគត ខ្ញុំសំគាល់ថា ពួកសត្វនោះតែងបាននូវព្រះនិព្វានឈ្មោះអមតៈ ជាធម្មជាតសុខ គឺមិនលាយឡំ ដោយលោកិយសុខ ជាបទមិនមានបច្ច័យ ប្រជុំតាក់តែងបានឡើយ ។

ចប់ រឿងមិគលុទ្ទកប្រេត ទី ៧ ។

# អដ្ឋមំ ទុតិយមិគលុទ្ទប្បេតវត្ថុ

(៣៣) កូដាគារេ ច បាសាទេ　　បល្លង្កេ បោណាភិសន្ថតេ[១]
បញ្ចង្គិកេន តុរិយេន　　រមសិ សុប្បវាទិតេ ។
តតោ រត្យា វិវសានេ　　សុរិយុគ្គមនំ បតិ
អបវិទ្ធោ សុសានស្មឹ　　ពហុំ ទុក្ខំ និគច្ឆសិ ។
កឹ នុ កាយេន វាចាយ　　មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន[២]　　ឥទំ ទុក្ខំ និគច្ឆសិ ។
អហំ រាជគហេ រម្មេ　　រមណីយេ គិរិព្វជេ
មិគលុទ្ទោ បុរេ អាសឹ　　លុទ្ទោ អាសឹ អសញ្ញតោ ។
តស្ស មេ សហាយោ សុមនោ　សទ្ធោ អាសិ ឧបាសកោ
តស្ស កុលុបកោ ភិក្ខុ　　អាសិ គោតមសាវកោ ។
សោបិ មំ អនុកម្បន្តោ　　និវារេសិ បុនប្បុនំ
មាកាសិ បាបកំ កម្មំ　　មា តាត[៣] ទុគ្គតឹ អគា
សចេ ឥច្ឆសិ បេច្ច សុខំ　　វិរម បាណវធំ អសំយមំ ។
តស្សាហំ វចនំ សុត្វា　　សុខកាមស្ស ហិតានុកម្បិនោ
នាកាសឹ សកលានុសាសនឹ　ចិរបាបាភិរតោ អពុទ្ធិមា ។

១ ម. បោណកត្ថតេ ។ ២ ម. កម្មស្ស វិបាកេន ។ ៣ ម. តាត ។



# រឿងទុតិយមិគលុទ្ទប្រេត ទី ៨

(៣៣) (ព្រះនារទត្ថេរសួរប្រេតថា) អ្នកត្រេកអរលើបល្ល័ង្ក ដែលក្រាលដោយសំពត់រោមលោកៈ ក្នុងប្រាសាទ ដែលជាផ្ទះកំពូល គេប្រគំហើយ ដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។ កាលផុតរាត្រី ព្រះអាទិត្យរះឡើង ក្នុងទីបំផុតនៃរាត្រីនោះ អ្នកត្រូវគេបោះបង់ចោលក្នុងព្រៃស្មសាន ដល់នូវសេចក្ដីទុក្ខច្រើន ។ អំពើអាក្រក់ ដូចម្ដេច ដែលអ្នកបានធ្វើហើយ ដោយកាយ វាចា ចិត្ត អ្នកដល់នូវសេចក្ដីទុក្ខនេះ តើដោយផលនៃកម្ម ដូចម្ដេច ។

(ប្រេតនោះឆ្លើយថា) កាលពីដើម ខ្ញុំជាព្រានម្រឹគ ជាអ្នកអាក្រក់ មិនសង្រួម នៅក្នុងក្រុងរាជគ្រឹះ មានភ្នំជុំជាក្រោល គួរត្រេកអរ រីករាយ ។ សំឡាញ់របស់ខ្ញុំនោះ អ្នកមានចិត្តល្អ ជាឧបាសកមានសទ្ធា មានភិក្ខុមួយអង្គជាជីតុនរបស់សំឡាញ់ខ្ញុំនោះ ជាសាវ័ក របស់ព្រះគោតម ។ ភិក្ខុនោះ អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្ដីសុខក្នុងបរលោក អ្នកចូរវៀរចាកនូវការមិនសង្រួម គឺការសម្លាប់សត្វ ។ ខ្ញុំបានស្ដាប់ពាក្យរបស់ភិក្ខុនោះ លោកប្រាថ្នាសេចក្ដីសុខ អនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរហើយមិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ (របស់លោក) ទាំងអស់ ។

សោហំ បន ភូរិសុមេធសោ[១] អនុកម្បាយ សំយមេ និវេសយិ
សចេ ទិវា ហនសិ បាណិនោ អថ តេ រត្តិ ភវតុ សំយមោ ។
ស្វាហំ ទិវា ហនិត្វា បាណិនោ[២] វិរតោ រត្តិ អហោសិ សំយតោ
រត្តាហំ បរិចារេមិ[៣] ទិវា ខជ្ជាមិ ទុក្ខិតោ ។
តស្ស កម្មស្ស កុសលស្ស អនុភោមិ រត្តិ អមានុសឹ
ទិវា បដិហតាវ កុក្កុរា ឧបធាវន្តិ សមន្តា ខាទិតុំ
យេ ច តេ សតតានុយោគិនោ ធុវំ បយុត្តា សុគតស្ស សាសនេ
មញ្ញាមិ តេ អមតមេវ កេវលំ អធិគច្ឆន្តិ បទំ អសង្ខតន្តិ ។

ទុតិយមិគលុទ្ទប្បេតវត្ថុ អដ្ឋមំ ។

## នវមំ កូដវិនិច្ឆយកប្បេតវត្ថុ

(៣៦) មាលី កិរីដី[៤] កាយូរី គត្តា តេ ចន្ទនុស្សទា
បសន្នមុខវណ្ណោសិ សុរិយវណ្ណោវ[៥] សោភសិ ។
អមានុសា បារិសជ្ជា យេ តេ មេ បរិចារកា[៦]
ទស កញ្ញាសហស្សានិ យា តេ មា បរិចារិកា ។

១ ម. ភូរិមេធសោ ។ ២ ម. បាណិនំ ។ ៣ ម. បរិចារេមិ ។ ៤ ម. តិរីដី ។ ៥ ម. សុរិយវណ្ណី ។ ៦ ម. បរិចារិកា ។



ភិក្ខុនោះ លោកមានប្រាជ្ញាល្អ ស្មើដោយផែនដី បានដឹកនាំខ្ញុំក្នុងសេចក្ដីសង្រួមម្ដងទៀត ដោយសេចក្ដីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះ សម្លាប់ពួកសត្វតែក្នុងវេលាថ្ងៃ ជាអ្នកសង្រួម វៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃ ទៅកាន់ទុក្ខ (ឆ្កែទាំងឡាយ) ខាំស៊ី ។ ខ្ញុំសោយសម្បត្តិទិព្វ (ដោយអំណាច) នៃកុសលកម្មនោះ ក្នុងវេលាយប់ វេលាថ្ងៃ ពួកឆ្កែមានចិត្តខ្ញាញ់ ស្ទុះមកដេញខាំដោយជុំវិញ ពួកសត្វណា មានការប្រកបរឿយ ៗ ប្រកបជានិច្ច ក្នុងសាសនារបស់ព្រះសុគត ខ្ញុំសំគាល់ថា ពួកសត្វនោះ តែងបាននូវព្រះនិព្វានឈ្មោះអមតៈ ជាធម្មជាតសុទ្ធ គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ។

ចប់ រឿងទុតិយមិគលុទ្ទប្រេត ទី ៨ ។

## រឿងកូដវិនិច្ឆយកប្រេត ទី ៩ ។

(៣៦) (ព្រះនារទត្ថេរសួរប្រេតថា) អ្នកពាក់នូវកម្រងផ្កា ជួតក្បាល ពាក់សង្វារ ខ្លួនរបស់អ្នកប្រស់ព្រំ ដោយខ្លឹមចន្ទន៍ អ្នកមានសម្បុរមុខថ្លា ល្អ ដូចជាសម្បុរនៃព្រះអាទិត្យ ។ បរិវារទាំងឡាយរបស់អ្នក ដែលកបំពាល់ក្នុងបរិស័ទ មិនមែនជាមនុស្ស គឺនាងកញ្ញាមួយម៉ឺន ជាស្រីបំរើរបស់អ្នក ។

តា កម្ពុកាយុរធរា  កញ្ចនាវេលភូសិតា[១]
មហានុភាវោសិ តុវំ  លោមហំសនរូបវា ។
បិដ្ឋិមំសានិ អត្តនោ  សាមំ ឧក្កច្ច[២] ខាទសិ
កិន្នុ កាយេន វាចាយ  មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន  បិដ្ឋិមំសានិ អត្តនោ
សាមំ ឧក្កច្ច[៣] ខាទសិ ។

អត្តនោហំ អនត្ថាយ  ជីវលោកេ អចារិស្សំ
បេសុញ្ញមុសាវាទេន  និកតិវញ្ចនាយ ច ។
តត្ថាហំ បរិសំ គន្ត្វា  សច្ចកាលេ ឧបដ្ឋិតេ
អត្ថំ ធម្មំ និរាកត្វា  អធម្មមនុវត្តិស្សំ ។
ឯវំ សោ ខាទតត្តានំ  យោ ហោតិ បិដ្ឋិមំសិកោ
យថាហំ អជ្ជ ខាទាមិ  បិដ្ឋិមំសានិ អត្តនោ ។
តយិទំ តយា នារទ សាមំ ទិដ្ឋំ
អនុកម្បកា យេ កុសលា វទេយ្យុំ
មា បេសុណំ មា ច មុសា អភណិ
មា ខោសិ បិដ្ឋិមំសិកោ តុវំ ។

កូដវិនិច្ឆយកប្បេតវត្ថុ ឆដ្ឋំ ។

១ ម. កញ្ចនវេឡុភូសិតា ។ ២-៣ ឱ. ឧក្កន្ត្វា ។



ពាន់កញ្ញាទាំងនោះ ទ្រទ្រង់នូវសង្វារមាស ស្អិតស្អាងដោយសំពត់មាស អ្នកជាបុគ្គលមានអានុភាពច្រើន មានរូបអាចញ៉ាំងពួកជនអ្នកមើលឲ្យព្រឺរោម ។ អ្នកខ្វារសាច់ខ្នងរបស់ខ្លួន ស៊ីដោយខ្លួនឯង តើអំពើអាក្រក់ដូចម្តេច ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នកខ្វារសាច់ខ្នងរបស់ខ្លួនស៊ីដោយខ្លួនឯង តើដោយផលនៃកម្មដូចម្តេច ។

(ប្រេតនោះបានឆ្លើយថា) ខ្ញុំបានប្រព្រឹត្ត ដើម្បីសេចក្តីវិនាសខ្លួន ដោយការញុះញង់នឹងមុសាវាទផង ដោយការបន្លំ នឹងបោកប្រាស់ផង ក្នុងជីវលោក ។ ខ្ញុំបានទៅកាន់បរិស័ទ មិនធ្វើនូវហេតុមានប្រយោជន៍ ក្នុងកាលពិតដែលតាំងឡើងប្រាកដ តែជាប្រព្រឹត្តតាមនូវហេតុ ដែលមិនមានប្រយោជន៍វិញ ក្នុងជីវលោកនោះ ។ ប្រេតណា ស៊ីសាច់ខ្នង ប្រេតនោះឈ្មោះថាស៊ីខ្លួនឯង ដូចជាខ្ញុំស៊ីសាច់ខ្នងរបស់ខ្លួន ក្នុងថ្ងៃនេះដែរ ។

បពិត្រព្រះនារទ រឿងនេះ លោកម្ចាស់ បានឃើញ
ដោយព្រះអង្គឯងស្រាប់ហើយ ជនទាំងឡាយណា ជាអ្នក
អនុគ្រោះ ជនទាំងនោះ ជាអ្នកឈ្លាសវៃ គប្បីពោលថា
អ្នកកុំនិយាយពាក្យញុះញង់ផង កុំនិយាយពាក្យកុហកផង
អ្នកកុំស៊ីនូវសាច់ខ្នងឡើយ ។

ចប់ រឿងកូដវិនិច្ឆយកប្រេត ទី ៦ ។

## ទសមំ ធាតុវិវណ្ណបេតវត្ថុ

(៣៩) អន្តលិក្ខស្មឹ តិដ្ឋន្តោ ទុគ្គន្ធោ បូតិ វាយសិ
មុខញ្ច តេ កិមយោ បូតិគន្ធំ ខាទន្តិ កឹ កម្មមកាសិ បុព្វេ ។

តតោ សត្ថំ គហេត្វាន ឱក្កន្តន្តិ បុនប្បុនំ
ខារេន បរិប្ផោសិត្វា ឱក្កន្តន្តិ បុនប្បុនំ ។
កឹ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន ឥទំ ទុក្ខំ និគច្ឆសិ ។
អហំ រាជគហេ រម្មេ រមណីយេ គិរិព្វជេ
ឥស្សរោ ធនធញ្ញស្ស សុបហូតស្ស មារិស ។
តស្សាយំ មេ ភរិយា ច ធីតា ច សុណិសា ច មេ
តា មាលំ ឧប្បលញ្ចាបិ បច្ចគ្ឃញ្ច វិលេបនំ
ថូបំ ហរន្តិយោ វារេសឹ តំ បាបំ បកតំ មយា ។
ឆឡាសីតិសហស្សានិ មយំ បច្ចត្តវេទនា
ថូបបូជំ វិវណ្ណេត្វា បចាម[1] និរយេ ភុសំ

[1] ឱ. បច្ចាម ។



## រឿងធាតុវិវណ្ណប្រេត ទី ១០

(៣៩) (ព្រះមហាកស្សបសួរធាតុវិវណ្ណប្រេតថា) អ្នកឋិតនៅក្នុងអាកាស មានក្លិនអាក្រក់ ស្អុយផ្សាយទៅផង ពួកដង្កូវកស៊ីមាត់របស់អ្នក ដែលមានក្លិនស្អុយផង តើអ្នកបានធ្វើអំពើដូចម្តេច ក្នុងកាលមុន ។ ព្រោះតែផ្សាយក្លិនអាក្រក់ និងមាត់ដែលដង្កូវកស៊ីនោះ (បានជាពួកសត្វដែលកម្មដាស់តឿន) កាន់គ្រឿងសស្ត្រាមកវះ (មាត់អ្នក) រឿយ ៗ ហើយស្រោចដោយទឹកខារ (ទឹកក្រូច) វះញយ ៗ ថែមទៀត ។ អំពើអាក្រក់ដូចម្តេច ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នកដល់ទុក្ខនេះ តើដោយផលនៃកម្ម ដូចម្តេច ។

(ធាតុវិវណ្ណប្រេតនោះឆ្លើយថា) បពិត្រលោកអ្នកនិរទុក្ខ ខ្ញុំជាឥស្សរៈលើទ្រព្យនិងធញ្ញជាតិ ដ៏ច្រើនក្រៃលែង (នៅ) ក្នុងក្រុងរាជគ្រឹះ មានភ្នំជុំជាក្រោល គួរត្រេកអររីករាយ ។ (កាលពីជាតិមុន) ស្រីនេះជាប្រពន្ធរបស់ខ្ញុំផង ស្រីនេះជាធីតារបស់ខ្ញុំផង ស្រីនេះជាកូនប្រសាររបស់ខ្ញុំផង ខ្ញុំបានឃាត់ (ស្រីនោះ) ដែលនាំផ្កាកុំសែន ផ្កាឧប្បល និងគ្រឿងលាបមានតម្លៃ ទៅកាន់ព្រះស្តូប បាបនោះឯង ដែលខ្ញុំបានធ្វើហើយ ។ ពួកយើងចំនួន ៨៦.០០០ នាក់ រងទុក្ខវេទនាចំពោះខ្លួន ។ ឆេះនៅក្នុងនរកយ៉ាងខ្លាំង ព្រោះតិះដៀល នូវការបូជាចំពោះព្រះស្តូប

យេ ច ខោ ថូបបូជាយ វត្តន្តេ អរហតោ មហេ

អាទីនវំ បកាសេន្តិ វិវេចយេថ នេ តតោ

ឥមា ច បស្ស អាយន្តិយោ មាលធារី អលង្កតា ។

មាលាវិភូតិំ អនុភោន្តិយោ សមិទ្ធា តា យសស្សិយោ[1]

តញ្ច ទិស្វាន អច្ឆេរំ អព្ភុតំ លោមហំសនំ ។

នមោ ករោន្តិ សប្បញ្ញា វន្ទន្តិ តំ មហាមុនិំ

សោហំ នូន ឥតោ គន្ត្វា យោនិំ លទ្ធាន មានុសិំ

ថូបបូជំ ករិស្សាមិ អប្បមត្តោ បុនប្បុនន្តិ ។

ធាតុវិវណ្ណបេតវត្ថុ ទសមំ ។

## ឧទ្ទានំ

អភិជ្ជមានោ កោណ្ឌញ្ញោ រថការី ភុសេន ច

កុមារោ គណិកា[2] ចេវ ទ្វេ លុទ្ធា បិដ្ឋិបូជយោ

វគ្គោ តេន បវុច្ចតីតិ[3] ។

ចូឡវគ្គោ តតិយោ

១ ម. យសស្សិនិយោ ។ ២ ម. គណិកា ។ ៣ ម. តេទំ ចុទ្ទសំ ឧ វិស្សតិ ។



ពួកជនណាប្រកាសនូវទោសក្នុងការបូជា ចំពោះព្រះអរហន្តសម្មា-សម្ពុទ្ធ ដែលប្រព្រឹត្តទៅដោយការបូជានូវព្រះស្តូប (ដូចជាខ្ញុំ) សូមលោកគប្បីឃាត់ពួកជននោះ កុំឲ្យនិយាយបញ្ចេញពាក្យនោះឡើយ សូមលោកគប្បីមើលពួកស្រីទាំងនេះ ដែលទ្រទ្រង់កម្រងផ្កា មានខ្លួនប្រដាប់ហើយ កំពុងមកតាមអាកាសផង ។ ពួកស្រីទាំងនោះ បានសម្រេច (សម្បត្តិទិព្វ) មានយសបរិវារ កំពុងសោយផលនៃការបូជាដោយកម្រងផ្កា សេចក្តីក្រើនរោមក៏កើតឡើង ព្រោះឃើញហេតុជាអស្ចារ្យចំឡែកនោះ ។ ពួកអ្នកមានប្រាជ្ញា តែងធ្វើនមស្ការថ្វាយបង្គំសរសើរព្រះមហាមុនីនោះ ខ្ញុំនោះ លុះទៅអំពីបេតលោកនេះ ហើយបាននូវកំណើតជាមនុស្ស ជាអ្នកមិនធ្វេសប្រហែស នឹងធ្វើការបូជាចំពោះព្រះស្តូបរឿយ ៗ ដោយពិត ។

ចប់ រឿងធាតុវិវណ្ណប្រេត ទី ១០ ។

## ឧទ្ទាន

និយាយអំពីរឿងអភិជ្ជមានប្រេត ១ រឿងសាណវាសីប្រេត ១ រឿងរថការីប្រេត ១ រឿងភុសប្រេត ១ រឿងកុមារប្រេត ១ រឿងសេរិនីប្រេត ១ រឿងមិគលុទ្ទប្រេត ២ លើក រឿងកូដ-វិនិច្ឆយកប្រេតដែលស៊ីសាច់ខ្នងរបស់ខ្លួន ១ រឿងធាតុវិវណ្ណប្រេត ឃាត់ការបូជា ១ ព្រោះហេតុនោះទើបពោលថាវគ្គ ។

ចប់ ចូឡវគ្គ ទី ៣ ។

# ចតុត្ថោ មហាវគ្គោ

## បឋមំ អម្ពសក្ករបេតវត្ថុ

(៣៦) វេសាលី នាម នគរត្ថិ វជ្ជីនំ
តត្ថ អហុ លិច្ឆវិ អម្ពសក្ករោ
ទិស្វាន បេតំ នគរស្ស ពាហិរំ
តត្ថេវ បុច្ឆិត្ថ តំ ការណត្ថិកោ ។
សេយ្យា[១] និសជ្ជា នយិមស្ស អត្ថិ
អភិក្កមោ នត្ថិ បដិក្កមោ ច[២]
អសិតបីតខាយិតវត្ថភោគា
បរិចារិកា សាបិ ឥមស្ស[៣] នត្ថិ ។
យេ ញាតកា ទិដ្ឋសុតា សុហជ្ជា
អនុកម្បកា យស្ស អហេសុំ បុព្វេ
ទដ្ឋុំបិ ទានិ ន លភន្តិ[៤] តំបិ
វិរាជិតត្តោ ហិ ជនេន តេន ។
ន ទុគ្គតស្ស[៥] ភវន្តិ មិត្តា
ជហន្តិ មិត្តា វិកលំ វិទិត្វា

១ ឱ. សេយ្យា ។ ២ ឱ. ភិ ។ ៣ ឱ. សាបិ ឥមស្ស ។ ៤ ឱ. ទដ្ឋុំបិ តានិ ន លភន្តិ ។ ម. ទដ្ឋុំបិ តេ ទានិ ន តំ លភន្តិ ។ ៥ ម. នទុគ្គតស្ស ។



# មហាវគ្គ ទី ៤

## រឿងអម្ពសក្ករប្រេត ទី ១

(៣៦) (ព្រះសង្គីតិកាចារ្យពោលថា) មាននគរ ១ ឈ្មោះវេសាលី របស់អ្នកដែនវជ្ជី ក្នុងក្រុងវេសាលីនោះ មានស្តេចលិច្ឆវី ព្រះនាមអម្ពសក្ករៈ បានទតឃើញប្រេតនៅខាងក្រៅក្រុង ស្តេចមានព្រះហឫទ័យចង់ដឹងហេតុ បានត្រាស់សួរប្រេតនោះ ក្នុងទីនោះឯង ថា បុគ្គល (ដែលគេដាក់ស្លុយឡើង លើដែកអណ្តោត) នេះ ដេក ឬអង្គុយ ក៏មិនបាន ការឈានទៅមុខ នឹងការឈានថយក្រោយ ក៏មិនបាន ការស៊ីផឹក លិទ្ធភក្ស សំពត់ភោគៈ ទាំងស្រីជាអ្នកបំរើរបស់បុគ្គលនេះ ក៏មិនមានទៀត ។ ពួកជនណា ដែលជាញាតិសំឡាញ់ ដែលឃើញហើយ ឮហើយ ជាអ្នកមានចិត្តល្អ អនុគ្រោះ នៃបុគ្គលណា ដែលមានក្នុងកាលពីដើម សូម្បីនេះ ពួកញាតិជាដើមនោះ ក៏មិនបានឃើញបុគ្គលនោះដែរ ព្រោះខ្លួនឃ្លាតឆ្ងាយពីបុគ្គលនោះ បុគ្គលទុគ៌ត រមែងមិនមានពួកមិត្ត ពួកមិត្តតែងលះបង់ចោល ព្រោះដឹងថាខ្វះខាត

អត្ថញ្ច ធម្មំ បរិកាយន្តិ
បាបា ច មិត្តា ឧត្តមស្ស[១] ហោន្តិ ។
និហីនត្តោ សត្តោកាមបាតិ តាវទេវ
សម្មត្តិតោ សំបរិកិឡិដ្ឋគត្តោ
ឧស្សន្នតិត្ថំ បលិប្បមានោ
អជ្ជ សុវេ ជីវិតស្សុបរោធោ[២] ។
ឯតាទិសំ ឧត្តមកិច្ចបត្តំ
ឧត្តាសិតំ បិចុមន្ទស្ស សូលេ
អថ ត្វំ កេន វណ្ណេន វទេសិ
យក្ខ ជីវតោ ជីវិតមេវ សេយ្យោតិ ។
សាលោហិតោ ឯសោ អហោសិ មយ្ហំ
អហំ សកាសេ បុរិមាយ ជាតិយា
ទិស្វា ច មេ ការុញ្ញំ អហោសិ
រាជ មា បាបធម្មោ និរយំ បតាយំ ។
ឥតោ ចុតោ លិច្ឆវិ ឯស បោសោ
សត្តុស្សទំ និរយំ ឃោររូបំ
ឧបបជ្ជតិ ទុក្កដកម្មការី

១ ម. ឧត្តមត្តស្ស ។ ២ ម. ជីវិតស្សុបរោធោ ។



ពួកមិត្តរមែងរាយរាប់ ព្រោះឃើញប្រយោជន៍ ជាបុគ្គលខ្ពង់ខ្ពស់ (ដោយភោគសម្បត្តិ) តែងមានមិត្តច្រើន ។ បុគ្គលសាមញ្ញខ្សត់ប្រយោជន៍ លំបាកដោយភោគៈអំពីអស់ មានខ្លួនប្រឡាក់ដោយឈាម មានខ្លួនដុះធ្លាយ លេងជីវិតទៅក្នុងថ្ងៃនេះ ឬថ្ងៃស្អែក ដូចដំណក់ទឹកសន្សើម (ដែលធ្លាក់ទៅលើចុងស្មៅ) ។ សរីរៈប្រាកដដូច្នេះ ដល់នូវសេចក្ដីលំបាកដ៏ក្រៃលែង គេដោតស្នួយឡើងលើឈើតាណ្ឌាត ដែលគេធ្វើដោយមែកស្ដៅ កាលបើយ៉ាងនេះហើយ ម្នាលយក្ស ចុះហេតុអ្វីបានជាអ្នកពោលថា នែអ្នកដ៏ចំរើន អ្នកចូររស់នៅចុះ (ព្រោះ) ការរស់នៅជាការប្រសើរ ។

(ប្រេតឆ្លើយថា) បុរសនុ៎ះ(កាលពីជាតិមុន)ជាសាលោហិតរបស់ខ្ញុំ ខ្ញុំរលឹកឃើញជាតិក្នុងកាលមុន បពិត្រព្រះរាជា លុះខ្ញុំឃើញហើយ ក៏មានសេចក្ដីករុណាដូច្នេះថា បុរសមានធម៌ដ៏លាមកនេះ កុំធ្លាក់ចុះក្នុងនរកឡើយ ។ បពិត្រលិច្ឆវី បុរសនោះជាអ្នកធ្វើអំពើអាក្រក់ កាលច្យុតចាកអត្តភាពនេះហើយ នឹងកើតក្នុងនរក ដែលសម្បូរដោយសត្វ មានសភាពគួរខ្លាចស្ញប់

មហាកិតាបំ កាដុកំ ផលានំ ។
អនេកកាលេន គុណេន សេយ្យោ
អយមេវ ស្សេណោ ចិរាយេន តេន
មា ឯកគ្គទុក្ខំ កាដុកំ ផលានំ
ឯកគ្គតិប្បំ(១) ចរយំ បតាយំ
ឥទញ្ច សុត្វា វចនំ មមេសោ
ទុក្ខូបនីតោ វិជហេយ្យ បាណំ(២)
តស្មា អហំ សន្តិកេ ន គណាមិ
មា មេ តតោ(៣) ជីវិតស្សុបរោធោតិ ។
អញ្ញាតោ ឯសោ បុរិសស្ស អត្ថោ
អញ្ញំ បិ(៤) ឥច្ឆាមសេ បុច្ឆិតុំ តុំ
ទុំកាសកម្មំ(៥) មម នោ សចេ តកោសិ(៦)
បុច្ឆាមិហំ ន ច នោ កុជ្ឈិតព្វំ ។
អទ្ធា បដិញ្ញា មេ តទា អហុ(៧)
អចិក្ខិតា អប្បសន្នស្ស ហោតិ

១ ម. ឯកគ្គតិប្បំ ។ ២ ឱ. ម. បាណំ ។ ៣ ឱ. មេ តតោ ។ ៤ ឱ. អញ្ញម្បិ ។
៥ ឱ. កាសកម្មំ ។ ៦ ម. សចេ នោ ករោតិ ។ ៧ ម. តវេតំ តទាហុ ។



មានគំរោងក្នុងដីល្អ ទំហំ មហាទុក្ខផ្លែផ្កា ជាគ្រឿងធ្វើកាមឲ្យកើត ។ ដែលអណ្តាតខាងឯនី ប្រសើរជាងឈើនោះ ដោយគុណមាន ចំណែកដ៏ច្រើន បុរសនេះ ក៏ធ្លាក់ក្នុងនោះ មានទុក្ខថែមទៀត មានទុក្ខដ៏ក្តៅក្រហាយ ជាគ្រឿងធ្វើកាមឲ្យកើត មានទុក្ខដ៏ក្រៀមក្រំ ថែមទៀត បុរសអ្នកដល់នូវសេចក្តីទុក្ខនោះ ស្តាប់ពាក្យខ្ញុំនេះបាន ហើយ គប្បីនឿយនូវតើលាមកចេញ ហេតុដូច្នោះបានជាខ្ញុំ មិននិយាយក្នុងស៊ីណាក់ទៃ (បុគ្គលនេះ) ថា ការរលត់ទៅនៃជីវិត នេះ ចូរកុំមានដល់ខ្ញុំ ក្នុងទីជាមួយគ្នាឡើយ ។

(ព្រះបាទសេដ្ឋីសួរថា) ប្រយោជន៍របស់បុរសនេះ ខ្ញុំដឹង ហើយ យើងទាំងសួរប្រយោជន៍ដទៃទៀត ចំពោះអ្នក បើអ្នកមិន បើកឱកាសឲ្យយើងទេ យើងក៏មិនហាមសួរអ្នកដែរ អ្នកកុំ គប្បីទឹងនឹងយើង ។

(ព្រេតតបថា) សេចក្តីប្តេជ្ញារបស់យើង មានហើយក្នុងកាល នោះដោយពិតថា មិនប្រាប់ដល់បុគ្គលដែលមិនជ្រះថ្លា (ទីនក្នា)

អកាមា សហេយ្យាហោតិ កត្វា
បុច្ឆស្សុ មំ ការំ យថា វិសយ្ហន្តិ[១] ។
យំ កិញ្ចាហំ ចក្ខុនា បស្សិស្សាមិ[២]
សព្វម្បិ តាហំ អភិសទ្ទហេយ្យំ
ទិស្វាន តំ នោបិ ចេ សទ្ទហេយ្យំ
ករេយ្យាសិ មេ យក្ខ និយស្សកម្មន្តិ[៣] ។
សច្ចប្បដិញ្ញា តវ មេសា ហោតុ
សុត្វាន ធម្មំ លភស្សុ បសាទំ
អញ្ញត្ថិកោ នោ ច បទុដ្ឋចិត្តោ
យន្តេ សុតំ អសុតំ ចាបិ ធម្មំ ។
សព្វំ អក្ខិស្សំ យថា បជានំ ។
សេតេន អស្សេន អលង្កតេន
ឧបយាសិ សូលាវុតកស្ស សន្តិកេ
យានំ ឥទំ អព្ភុតំ ទស្សនេយ្យំ
កិស្សេតំ កម្មស្ស អយំ វិបាកោ ។
វេសាលិយា នគរស្ស មជ្ឈេ
ចិក្ខល្លមគ្គេ នរកំ[៤] អហោសិ

---

១ ម. វិសយ្ហំ ។ ២ ម. បស្សាមិ ។ ៣ ម. និយស្សកម្មំ ។ ៤ ឱ. ចិក្ខល្លមគ្គេ នរកំ ។





អ្នកចូរសួរខ្ញុំតាមតែចិត្តចុះ យើងនឹងខំប្រាប់ទៅ តែជាមនុស្សមានពាក្យគួរជឿបាន ចុះ ហើយសួរខ្ញុំចុះ តាមសេចក្តីពិតដែលអាច (នឹងប្រាប់បាន) ។

(ស្តេចលិច្ឆវីត្រាស់ថា) យើងឃើញនូវហេតុណាមួយដោយចក្ខុ យើងត្រូវជឿហេតុនោះទាំងអស់ ប្រសិនបើយើងឃើញហើយ យើងមិនជឿហេតុនោះទេ ម្នាលយក្ខ អ្នកត្រូវធ្វើនិយស្សកម្ម (ការបន្ទាបយស) ដល់យើងចុះ ។

(ប្រេតតបថា) ពាក្យប្តេជ្ញានុ៎ះ ជាពាក្យប្តេជ្ញាដ៏ពិតរបស់ព្រះ-អង្គចុះ បើព្រះអង្គត្រូវការចង់ដឹង មានហឫទ័យមិនប្រទូស្ត ស្តាប់ធម៌ណា ជាធម៌ដែលព្រះអង្គធ្លាប់ស្តាប់ហើយក្តី មិនធ្លាប់ស្តាប់ហើយក្តី លុះព្រះអង្គស្តាប់ធម៌នោះហើយ ចូរបាននូវសេចក្តីជ្រះថ្លា កាលបើខ្ញុំដឹងយ៉ាងណា នឹងក្រាបទូលនូវហេតុនោះទាំងអស់ ។

(ស្តេចលិច្ឆវីសួរថា) អ្នកមានសេះសប្រដាប់ហើយ ហើយចូលទៅក្បែរជិតនៃបុរសដែលគេដាក់ដោយឈើអណ្តាន ឯយានជំនិះនេះ ជារបស់អស្ចារ្យគួរមើល នេះជាផលនៃកម្មអ្វី ។

(ប្រេតតបថា) មានថ្លុកភក់ជ្រាំនៅកណ្តាលក្រុងវេសាលីនោះ

គោសីសមេកាហំ បសន្នចិត្តោ
សេតុំ គហេត្វា ឧកាស្មិំ និក្ខិបិំ ។
ឯតស្មិំ ចារេតិ បតិដ្ឋបេត្វា
មយញ្ច អញ្ញេ ច អតិក្កមិម្ហា[១]
យានំ ឥធំ អគ្គិំ ឥសប្បេយ្យំ
តស្សេវ កម្មស្ស អយំ វិបាកោ ។
វណ្ណោ ច តេ សព្វទិសា បភាសតិ
គន្ធោ ច តេ សព្វទិសា បវាយតិ
យក្ខិទ្ធិបត្តោសិ មហានុភាវោ
នគ្គោ ចាសិ កិស្ស អយំ វិបាកោ ។
អក្កោធនោ និច្ចបសន្នចិត្តោ
សណ្ហាហិ វាចាហិ ជនំ ឧបេមិ
តស្សេវ កម្មស្ស អយំ វិបាកោ
ទិព្វោ មេ វណ្ណោ សតតំ បភាសតិ ។
យសញ្ច កិត្តិញ្ច ធម្មេ ឋិតានំ
ទិស្វាន មន្តេមិ បសន្នចិត្តោ[២]
តស្សេវ កម្មស្ស អយំ វិបាកោ

១ ឱ. អញ្ញេ ច អតិក្កមេយ្យុំ ។ ២ ម. ទិស្វា [illegible] បសន្នចិត្តោ ។



ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បាននាំយកក្បាលគោព្ធិជាស្ពាន ដាក់ក្រង់ជង្ហុកនោះ ។ យើងក្តី ពួកមនុស្សដទៃទៀតក្តី បានជាន់ដើរលើស្ពាននោះហើយ ទើបដើរទៅបាន យានដ៏វិសេស ដ៏អស្ចារ្យ គួរមិលមើល នេះជាផលនៃកម្មនោះឯង ។

(ស្តេចលិច្ឆវីសួរថា) ចុះអ្នកមានសម្បុរភ្លឺទៅសព្វទិស អ្នកមានក្លិនផ្សព្វផ្សាយទៅសព្វទិសបាន អ្នកបានឫទ្ធិជាយក្ស មានអានុភាពច្រើន តែជាអ្នកអាក្រាត នេះជាវិបាកនៃកម្មអ្វី ។

(ប្រេតឆ្លើយថា) ខ្ញុំជាមនុស្សមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច និយាយទៅនឹងជនដោយពាក្យពីរោះផ្អែមល្ហែម នេះជាផលនៃកម្មនោះឯង បានជាសម្បុររបស់ខ្ញុំ ភ្លឺជាទិព្វដូចជានិច្ច ។ ខ្ញុំបានឃើញយសក្តី និងកេរ្តិ៍ឈ្មោះ របស់ពួកជនអ្នកតាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សា នេះជាផលនៃកម្មនោះឯង

និច្ចោ មេ តត្ថោ សុគតិំ បាបយតិ ។
សហាយានំ តិដ្ឋស្មិំ ឧហាយន្តានំ[១]
ថលេ គហេត្វា និធនស្ស ចុស្សំ
តាឡុគ្គិកោ[២] តោ ច មនុជ្ជចេត្តោ
តេនម្ហិ ឆត្តោ កសិរំ បវិដ្ឋោ ។
យោ គាឡ្ហមានោ ច ករោតិ បាបំ
តស្សីទិសំ កម្មវិបាកមាហុ
អគាឡ្ហមានោ បន យោ ករោតិ
គឹ តស្ស កម្មស្ស វិបាកមាហុ ។
យេ ទុដ្ឋសង្កប្បមនា មនុស្សា
កាយេន វាចាយ ច សង្កិលិដ្ឋា
កាយស្ស ភេទា អភិសម្បរាយំ
អសំសយំ តេ និរយំ ឧបេន្តិ ។
អបរេ បន សុគតិំ អាសិសមានា[៣]
ទានេ រតា សង្គហិតត្តភាវា
កាយស្ស ភេទា អភិសម្បរាយំ
អសំសយំ តេ សុគតិំ ឧបេន្តីតិ ។

១ ឱ. ឧហាយនានំ ។ ២ ម. ចណ្ឌិក្កោ ។ ៣ ឱ. សុគតិមាសមានា ។





បានជាខ្ញុំមានកំនើតដូចជាចិត្ត ផ្សព្វផ្សាយនៅជាទិញបាន ។ ខ្ញុំបានយកសំពត់ក្រហមសំឡាញ់ កំពុងទុកចិត្តគួរកំពង់ លាក់លើគោក ខ្ញុំស្រវឹងនឹងសេចលេង មិនមានចិត្តប្រុងស្មុគ ព្រោះតែកម្មនោះ បានជាខ្ញុំលំបាក ទាំងការចិញ្ចឹមជីវិតក៏លំបាកពន់ពេក ។

(ស្ដេចលិច្ឆវីក្រាស់សួរថា) បើបុគ្គលណា តែងធ្វើបាប អ្នកប្រាជ្ញទាំងឡាយបានសំដែង នូវផលនៃកម្មរបស់បុគ្គលនោះប្រាកដដូច្នេះ ចុះបើបុគ្គលណា មិនតែងធ្វើបាបទេ អ្នកប្រាជ្ញទាំងឡាយ បានសំដែងនូវផលនៃកម្មនោះដូចម្ដេច ។

(ប្រេតតបថា) បើពួកមនុស្សណា មានតម្រេះក្នុងចិត្តប្រទូស្ត ហើយ សៅហ្មងដោយកាយនឹងវាចា មនុស្សទាំងនោះ លុះបែកធ្លាយកនឹងកាយស្លាប់ទៅ ក្នុងបរលោក រមែងទៅកើតក្នុងនរកឥតមានសង្ស័យឡើយ ។ ចំណែកពួកមនុស្សដទៃ ប្រាថ្នានូវសុគតិ ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ មនុស្សទាំងនោះ លុះបែកធ្លាយកនឹងកាយស្លាប់ទៅក្នុងបរលោក រមែងទៅកើតក្នុងសុគតិ ឥតមានសង្ស័យឡើយ ។

កិំ ឯត្ថ ជានេយ្យំ អហំ អវេច្ច
កល្យាណបាបស្ស អយំ វិបាកោ
កិំ វាហំ ទិស្វា អភិសទ្ទហេយ្យំ
កោ វាបិ មំ សទ្ទហាបេយ្យ ឯតំ ។
ទិស្វា ច សុត្វា អភិសទ្ទហស្សុ
កល្យាណបាបស្ស អយំ វិបាកោ
កល្យាណបាបេ ឧភយេ អសន្តេ
សិយា នុ សត្តា សុគតា ទុគ្គតា វា ។
នោ ចេត្ថ កម្មានិ ករេយ្យុំ មច្ចា
កល្យាណបាបានិ មនុស្សលោកេ
នាហេសុំ សត្តា សុគតា ទុគ្គតា វា
ហីនា បណីតា ច មនុស្សលោកេ ។
យស្មា ច កម្មានិ ករោន្តិ មច្ចា
កល្យាណបាបានិ មនុស្សលោកេ
តស្មា[១] សត្តា សុគតា ទុគ្គតា វា
ហីនា បណីតា ច មនុស្សលោកេ ។
ទ្វយជ្ជ កម្មានំ វិបាកមាហុ
សុខស្ស ទុក្ខស្ស ច វេទនីយំ

១ ម. [illegible] ហោតិ អត្ថិ ។



(ស្តេចលិច្ឆវីត្រាស់ថា) យើងបានពិចារណាហើយ គប្បីដឹង ពាក្យនោះដូចម្តេច នេះជាផលនៃកល្យាណកម្ម និងបាបកម្ម ទេតើ យើងឃើញដូចម្តេច គប្បីជឿ ឬណា គប្បីធ្វើឲ្យជឿពាក្យនោះបាន ។

(ប្រេតតបថា) ព្រះអង្គទតឃើញហើយ ឮហើយ សូមជឿចុះ នេះជាផលនៃកល្យាណកម្ម និងបាបកម្ម កាលបើកល្យាណកម្មនិងបាបកម្ម ទាំងពីរមិនមានទេ ពួកសត្វគប្បីមានសុគតិ ឬទុគ្គតិ ដូចម្តេចបាន ។ ប្រសិនបើពួកសត្វមិនគប្បីធ្វើកល្យាណកម្ម និងបាបកម្ម ក្នុងមនុស្សលោកនេះទេ ពួកសត្វក៏មិនបានសុគតិ ឬទុគ្គតិ ទាំងមិនបានថោកទាប ឬខ្ពង់ខ្ពស់ក្នុងមនុស្សលោកឡើយ ។ ពួកសត្វធ្វើកល្យាណកម្មនិងបាបកម្ម ក្នុងមនុស្សលោកនេះ ព្រោះហេតុណា ហេតុនោះបានជា ពួកសត្វ ទៅសុគតិខ្លះ ទុគ្គតិខ្លះ ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ ក្នុងមនុស្សលោក ។ ពួកអ្នកប្រាជ្ញ បានសំដែងនូវផលទាំងពីរនៃកម្មទាំងឡាយ ដែលជាគ្រឿងសោយនូវសុខ និងទុក្ខ

តតោ ចុតោ បរិភាសយន្តិ
បត្តិ ពាលា ទុស្សតិ អបស្សិត្វាជាតិ ។
ន មត្តិ តាទ្ទានំ សយំ កតានំ
ទត្វាប មេ ទត្តំ សោ អាទិសេយ្យ
អច្ឆាទនំ សយនមថន្នបានំ
តេនម្ហិ នគ្គោ កសិរា ចវុត្តិ ។
សិយា នុ ខោ ការណំ កិញ្ចិ យក្ខ
អច្ឆាទនំ យេន តុវំ លភេថ
អាចិក្ខ មេ ត្វំ យទត្ថិ ហេតុ
សទ្ធាយិកំ ហេតុវចោ សុណោម ។
កប្បិតកោ នាម ឥធត្ថិ ភិក្ខុ
ឈាយី សុសីលោ អរហា វិមុត្តោ
គុត្តិន្ទ្រិយោ សំវុតបាតិមោក្ខោ
សីតិភូតោ ឧត្តមទិដ្ឋិបត្តោ
សខិលោ វទញ្ញូ សុវចោ សុមុខោ
ស្វាគមោ សុប្បដិមុត្តកោ ចាបិ
បុញ្ញស្ស ខេត្តំ អរណវិហារី
ទេវមនុស្សានញ្ច ទក្ខិណេយ្យោ





ក្នុងទេវលោកនេះឃោមរពេយនោះ យកិត ក្នុងកាលជាមួកមិនបាន ឃើញខ្ញុំនេះភាពទទឹងតែហើយ ថែមទឹងនេះទៀត (ក្នុងអបាយទាំងឡាយ មានខុរកជាដើម) ។ បុញ្ញកម្មដែលធ្វើដោយខ្លួនឯង មិនមានអ្នកឱ្យគ្រឿងស្លៀកពាក់ ទឹងផឹក ទីអង្គុយ ថ្នាំ និងទឹក ហើយខ្ញុំសំរាកខ្ញុំ ក៏មិនមានដែរ ហេតុនោះ បានជាខ្ញុំមានការអាក្រាតទាំងការប្រព្រឹត្តចិញ្ចឹមជីវិតក៏លំបាក ។

(ព្រះបាទលិច្ឆវីត្រាស់សួរថា) ម្នាលយក្ស ហេតុតិចតួចដែលអ្នកអាចបាន នូវគ្រឿងស្លៀកពាក់ មានដែរឬ អ្នកចូរប្រាប់ដល់យើង ហេតុណាដែលនាំឱ្យយើងជឿបាន យើងនឹងស្ដាប់នូវពាក្យ តាមហេតុនោះ ។

(ប្រេតតបថា) ក្នុងក្រុងវេសាលីនេះ មានភិក្ខុ ១ រូប ឈ្មោះកប្បិតកៈ មានឈាន មានសីលធម៌ល្អ ជាព្រះអរហន្ត មានចិត្តផុតស្រឡះចាកកុសល មានឥន្ទ្រិយស្រគត់ស្រគំ សង្រួមក្នុងបាតិមោក្ខ ត្រជាក់ត្រជំ សម្រេចនូវការយល់ដ៏ខ្ពង់ខ្ពស់ មានសំដីទន់ភ្លន់ ជំនួនូវពាក្យពេល មានសំដីផ្អែមល្ហែម មានព្រះភក្ត្រស្រស់ស្រាយ ដោយការឥតមិតាថិដោយប្រពៃផុតស្រឡះហើយជាបញ្ញាល្អ ជាបុញ្ញក្ខេត្ត សូម្បីស្ងប់ចាកកិលេស ជាទក្ខិណេយ្យបុគ្គល របស់ទេវតា និងមនុស្សទាំងឡាយ

សន្តោ វិទូ អនីឃោ និរាសោ
មុត្តោ វិសល្លោ អមមោ អវង្កោ
និរូបធិ សព្វបបញ្ចខីណោ
តិស្សោ វិជ្ជា អនុប្បត្តោ ជុតិមា ។
អប្បញ្ញាតោ ទិស្វាបិ ន សុជានោ
មុនីតិ នំ វជ្ជិសុ[១] វោហរន្តិ
ជានន្តិ តំ យក្ខភូតា អនេជំ
កល្យាណធម្មំ វិចរន្តំ[២] លោកេ ។
តស្ស តុវំ ឯកំ យុគំ ទុវេ វា
មមុទ្ទិសិត្វាន សចេ ទទេថ
បដិគ្គហីតានិ ច តានិ អស្សុ[៣]
មមញ្ច បស្សេថ សន្នទ្ធទុស្សន្តិ ។
កស្មឹ បទេសេ សមណំ វសន្តំ
គន្ត្វាន បស្សេមុ មយំ ឥទានិ
សោ[៤] មជ្ជ កង្ខំ វិចិកិច្ឆិតញ្ច
ទិដ្ឋីវិសូកានិ វិនោទយេ នោ[៥] ។

---

១ ម. មុនិំ វជ្ជិសុ ។ ឱ. មុនំ ហិ នំ វជ្ជិសុ ។ ២ ម. វិចរន្តិ ។ ៣ ម. បស្សុ ។ ឱ. ចស្សុ ។ ៤ ម. យោ ។ ៥ ម. វិនោទយេយ្យ មេ ។



ជាសប្បុរស ព្រោះបានកំផ្សងនូវ វិត្តៈ វិភាគៈ មិនមានទុក្ខ មិនមានសេចក្ដីប្រាថ្នា ផុតស្រឡះចាកភពទាំងពួង មានសរ គឺកិលេសទៅព្រួសហើយ មិនមានសេចក្ដីសំគាល់ថា អញ មិនវៀចវេរ មិនមានឧបធិក្កិលេស អស់ធម៌ជាគ្រឿងយឺតយូរ គ្រប់យ៉ាង បានសម្រេចវិជ្ជា ៣ មានសេចក្ដីរុងរឿង ។ លោកនោះ មិនល្បីតាមប្រាកដទេ ទុកជាឃើញក៏មិនងាយ នឹងស្គាល់ ពួកមនុស្សអ្នកនៅក្នុងដែនវជ្ជី តែងនាំគ្នាហៅថា មុនីដូច្នេះ ពួកយក្សដឹងថា លោកជាបុគ្គលស្ងប់ស្ងាត់ មិនមានសេចក្ដីញាប់ញ័រគឺកិលេស មានកល្យាណធម៌ ប្រព្រឹត្តនៅក្នុងលោក ។ បើព្រះអង្គ ឲ្យសំពត់ ១ គូ ២ គូ ដល់ព្រះថេរៈនោះឧទ្ទិសដល់ខ្ញុំ ខ្ញុំនឹងគប្បីបានសំពត់ ដែលលោកទទួលហើយនោះផង ព្រះអង្គនឹងទតឃើញខ្ញុំដែលស្លៀកសំពត់ហើយផង ។

(ព្រះបាទលិច្ឆវីត្រាស់សួរថា) ឥឡូវនេះ យើងនឹងទៅជួបព្រះសមណៈនៅក្នុងប្រទេសណា សមណៈនោះគប្បីបន្ទោបង់នូវសេចក្ដីសង្ស័យផង នូវសេចក្ដីងឿងឆ្ងល់ផង នូវសេចក្ដីយល់ខុស ដែលជាសត្រូវរបស់យើងផង ក្នុងថ្ងៃនេះបានឬទេ ។

ឯសោ និសិន្នោ កបិនច្ចនាយំ
បរិវារិតោ ទេវតាហិ ពហូហិ
ធម្មិកថំ ភាសតិ សច្ចនាមោ
សកស្មិំ អាចេរកេ[១] អប្បមត្តោ[២] ។
តថាហំ កស្សាមិ គន្ត្វា ឥទានិ
អច្ឆាទយិស្សំ សមណំ យុគេន
បដិគ្គហិតានិ ច តានិ អស្សុ
តុវញ្ច បស្សេមុ សន្នទ្ធទុស្សន្តិ ។
មា អក្ខណេ បព្វជិតំ ឧបាគមិ
សាធុ វោ លិច្ឆវិ នេស ធម្មោ
តតោ ច កាលេ ឧបសង្កមិត្វា
តត្ថេវ បស្សាហិ រហោ និសិន្នន្តិ ។
តថាតិ វត្វា អគមាសិ តត្ថ
បរិវារិតោ ទាសគណេន លិច្ឆវិ
សោ តំ នគរំ ឧបសង្កមិត្វា
វាសូបគច្ឆិត្ថ សកេ និវេសនេ ។

---

១ ម. អាចេរកេ ។ ២ ម. តិសត្តោ ឥតិ ។





(ប្រេតពោលថា) សមណៈនុះគង់នៅឯប្រទេសឈ្មោះកបិនច្ចនា មានពួកទេវតាច្រើនចោមរោម លោកមាននាមជាសច្ចៈ ជាអ្នកមិនប្រមាទក្នុងធម៌ជាគ្រឿងអស្ចារ្យរបស់ខ្លួន សំដែងធម្មីកថា ។

(ព្រះបាទលិច្ឆវីត្រាស់សួរថា) បើដូច្នោះ ឥឡូវនេះ យើងនឹងទៅធ្វើឲ្យសមណៈស្លៀកដណ្តប់ ដោយគូសំពត់ អ្នកចូរមើលសំពត់ទាំងនោះ ដែលលោកបានទទួលហើយ ឯយើងគប្បីមើលនូវអ្នកស្លៀកសំពត់ ។

(ប្រេតពោលថា) ព្រះអង្គកុំចូលទៅរកបព្វជិត ក្នុងកាលមិនគួរឡើយ ខ្ញុំសូមអង្វរ ធម៌នោះ មិនមែនជាធម៌របស់ព្រះអង្គ ជាស្តេចលិច្ឆវីទេ ទ្រង់ចូលទៅក្នុងកាលគួរនោះ ទើបឃើញលោកគង់នៅ ក្នុងទីស្ងាត់នោះឯង ។

ស្តេចលិច្ឆវីនោះពោលពាក្យថាដូច្នោះហើយ ក៏មានពួកទាសៈចោមរោម យាងចូលទៅក្នុងទីនោះ លុះចូលទៅក្រុងនោះហើយ ទ្រង់យាងចូលទៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គវិញ ។

តតោ ច កាលេ គិហិកិច្ចានិ កត្វា
ន្ហាត្វា បិវិត្វា ច ខណំ លភិត្វា
វិចេយ្យ បេយ្យោ ច យុគានិ អដ្ឋ
គាហាបយិំ ទាសគណេន សច្ចាំ ។
សោ តំ បទេសំ ឧបសង្កមិត្វា
តំ អទ្ទស សមណំ សន្តចិត្តំ
បដិក្កន្តំ គោចរតោ និវត្តំ
សីតិភូតំ រុក្ខមូលេ និសិន្នំ ។
តមេនំ អវោច ឧបសង្កមិត្វា
អប្បាពាធំ ផាសុវិហារញ្ច បុច្ឆិំ
វេសាលិយំ លិច្ឆវិ អហំ ភទន្តេ
ជានន្តិ មំ លិច្ឆវិ អម្ពសក្ខរោ ។
ឥមានិ មេ អដ្ឋ យុគានិ ភន្តេ[១]
បដិគ្គណ្ហ ភន្តេ ទទាមិ[២] តុយ្ហំ
តេនេវ អត្ថេន ឥធាគតោស្មិ
យថា អហំ អត្តមនោ ភវេយ្យំ ។
ទូរតោ វ សមណព្រាហ្មណា ច

១ ឱ. សុភន្តិ ។ ២ ឱ. បទាមិ ។



លំដាប់នោះ ស្តេចលិច្ឆវី ធ្វើនូវកិច្ចទាំងឡាយជារបស់គ្រហស្ថ ក្នុងវេលាព្រឹកហើយ ក៏ស្រង់ទឹក សោយនូវសុគន្ធរសផឹក រួចបាននូវឱកាស ក៏ជ្រើសរើសនូវសំពត់បាន៨គូ អំពីហិប ហើយក៏ឲ្យពួកទាសៈកាន់យកតាមទៅ ។ ស្តេចលិច្ឆវីនោះ ចូលទៅឯប្រទេសនោះ បានឃើញសមណៈនោះ អ្នកមានចិត្តស្ងប់រម្ងាប់ កំពុងវិលត្រឡប់ពីគោចរ ជាបុគ្គលត្រជាក់ត្រជុំ គង់នៅក្រោមម្លប់ឈើ ។ លុះស្តេចលិច្ឆវីចូលទៅដល់ហើយ ក៏ពោលទៅនឹងសមណៈនោះ រួចហើយក៏សួរនូវការមិនមានអាពាធ នឹងការនៅជាសុខសប្បាយ (ហើយទូល) ថា បពិត្រលោកដ៏ចំរើន ខ្ញុំជាស្តេចលិច្ឆវីក្នុងក្រុងវេសាលី អ្នកផងតែងស្គាល់ខ្ញុំថាជាស្តេចលិច្ឆវីឈ្មោះអម្ពសក្ខរៈ ។ បពិត្រលោកដ៏ចំរើន សូមលោកទទួលសំពត់ទាំង៨គូរបស់ខ្ញុំនេះចុះ បពិត្រលោកដ៏ចំរើន ខ្ញុំសូមប្រគេនដល់លោក ខ្ញុំមកក្នុងទីនេះ ព្រោះប្រយោជន៍នោះឯង គួរឲ្យខ្ញុំមានចិត្តត្រេកអរ ។

(ព្រះថេរៈតបថា) ពួកសមណៈព្រាហ្មណ៍ ដែលមកអំពីចំងាយ តែងតែវៀរចាកនូវនិវេសន៍ របស់ព្រះអង្គ

និវេសនន្តេ បរិវជ្ជយន្តិ

បត្តានិ ភិជ្ជន្តិ តវ និវេសនេ

សង្ឃាដិយោ ចាបិ វិទាលយន្តិ ។

អថាបរេ ទានកុណ្ឌិកាហិ

អហឹសកា សមណា ទាជយន្តិ

ឯតាទិសំ បព្វជិតំ វិហេសិ

តយា កតំ សមណា ចាបុណន្តិ ។

តិណេន តេលំបិ ន ត្វំ អទាសិ

មូឡ្ហស្ស មគ្គំបិ ន បាវទាសិ

អន្ធស្ស ទណ្ឌំ សយមាទិយាសិ

ឯតាទិសោ កទរិយោ អសំវុតោ ។

អថ ត្វំ កេន វណ្ណេន កិមេវ ទិស្វា

អម្ហេហិ សហ សំវិភាគំ ករោសិ ។

បច្ចេមិ ភន្តេ យំ ត្វំ វទេសិ ។

វិហេសយិំ សមណព្រាហ្មណេ ច

ខិឌ្ឌត្ថិកោ នោ ច បទុដ្ឋចិត្តោ

ឯតំបិ មេ ទុក្កដមេវ ភន្តេ



ទ្រុងកំពីងឡាយ តែងធ្លាក់បែក សង្ឃាដីទាំងឡាយ តែងតែរហែកដាច់ដាច ក្នុងនិវេសន៍របស់ព្រះអង្គ ។ មួយទៀតពួកសមណៈដទៃ មានក្បាលសំយុងចុះ រមែងធ្លាក់ចុះដោយជើងទាំងឡាយ ពោលគឺជើង (របស់ព្រះអង្គ) កាលបើព្រះអង្គបៀតបៀននូវបព្វជិតប្រាកដដូច្នោះហើយ ពួកសមណៈរមែងដល់នូវអំពើដែលព្រះអង្គធ្វើ ។ ព្រះអង្គមិនដែលឲ្យប្រេងសូម្បីដោយចុងស្បូវផង មិនប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវផង ព្រះអង្គសមាទាន កាន់យកឈើច្រត់ របស់មនុស្សអន្ធពាលដោយព្រះអង្គឯង បុគ្គលបែបហ្នឹងឈ្មោះថា កំណាញ់ស្អិតស្អាញ ជាអ្នកមិនសង្រួម ។ កាលបើយ៉ាងហ្នឹង តើព្រះអង្គឃើញនូវហេតុអ្វី តាមដោយហេតុអ្វី បានជាព្រះអង្គធ្វើនូវការចែករំលែកជាមួយនឹងអាត្មាភាព ។

(ស្តេចត្រាស់ថា) បពិត្រលោកដ៏ចំរើន លោកពោលពាក្យណា ខ្ញុំក៏ទទួលស្តាប់នូវពាក្យនោះ ។

(ព្រះថេរៈតបថា) ព្រះអង្គធ្វើពួកសមណព្រាហ្មណ៍ឲ្យវេទនាហើយ ។

(ស្តេចត្រាស់ថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាបុគ្គលត្រូវការទ័នលេង មិនមានចិត្តប្រទូស្តឡើយ ខ្ញុំធ្វើអំពើអាក្រក់នេះមែនហើយ

ចិន្នាយ តេ បសវិត្វាន[១] ធាមំ
វេទេតិ ទុក្ខំ អប្បមត្តកោតិ[២]
ឧមាកេ យុក ចត្តនីយស្ស ការី
តាសុ តតោ ទុក្ខតរស្ស ហោតិ ។
តំ និស្វា សំវេគមលត្ថំ ភន្តេ
តប្បច្ចយា ភិចំ[៣] ធនាមំ ធនំ
បដិគ្គណ្ហ ភន្តេ វត្ថយុគានិ អដ្ឋ
យក្ខស្សិមាគច្ឆន្តុ ទក្ខិណាយោ ។
អទ្ធា ហិ[៤] ធានំ ពហុធា បសដ្ឋំ
ទទតោ ច តេ អក្ខយធម្មត្ថុ
បដិគ្គណ្ហាមិ តេ វត្ថយុគានិ អដ្ឋ
យក្ខស្សិមាគច្ឆន្តុ ទក្ខិណាយោ ។
តតោ ហិ សោ អាចមយិត្វា លិច្ឆវិ
ថេរស្ស ទត្វាន យុគានិ អដ្ឋ
បដិគ្គហិតានិ ច តានិ ភស្ស[៥]
យក្ខញ្ច បស្សេថ សំនទ្ធទុស្សំ ។

១ ឱ. បសវិត្វា ។ ២ ឱ. អសមត្ថកោតិ ។ ៣ ឱ. ធាមំ ។ ៤ ឱ. ឧកហិ ។ ៥ ឱ. បត្តានិ ភស្ស ។ ម. ច តានិ បស្ស ។



បុគ្គលគ្មានក្តី កំរោះក្តី ដែលមានទ្រព្យតិច តែងទទួលទុក្ខ ព្រោះតែសេចក្តីបាប ដោយការលេង ជាបុគ្គលមានចំណែក នៃភាពជាអ្នកក្រោក អ្វីដែលដល់ខ្លួនក្តីហើយធំ ជានិភាព ក្រោកនោះ របស់ប្រុសនោះ ។ បពិត្រលោកដ៏ចំរើន ខ្ញុំ ឃើញប្រុសនោះគួរឲ្យកើតសង្វេគ ទើបឲ្យទាន ព្រោះសង្វេគ នោះជាបច្ច័យ បពិត្រលោកដ៏ចំរើន សូមលោកទទួលសំពត់ ទាំង៨គូចុះ ទក្ខិណាទាន (ដែលខ្ញុំប្រគេនហើយ) នេះ សូមឲ្យបានសម្រេចដល់យក្សចុះ ។

(ព្រះថេរៈតបថា) ការមិនរេចរេស់ ចូរមានដល់ព្រះអង្គ កាល ឲ្យទាន ដែលអ្នកប្រាជ្ញមានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ដោយប្រការដ៏ច្រើនដោយពិត ឯអាត្មានឹងទទួលសំពត់របស់ ព្រះអង្គទាំង៨គូ សូមទក្ខិណាទានសម្រេចដល់យក្សចុះ ។

លំដាប់នោះឯង ស្តេចលិច្ឆវីនោះក៏ជះសំអាត ហើយប្រគេន សំពត់ ៨ គូដល់ព្រះថេរៈ ព្រះថេរៈបានទទួលសំពត់៨គូនោះ ហើយ ស្តេចលិច្ឆវី បានឃើញនូវយក្សស្លៀកដណ្តប់សំពត់ ។

តមន្ទស ចន្ទនសារលិត្តំ [១]
អាជញ្ញមារុយ្ហ ឧឡារវណ្ណំ
អលង្កតំ សាធុនិវត្ថទុស្សំ
បរិវារិតំ យក្ខមហិទ្ធិបត្តំ ។
សោ តំ ទិស្វា អត្តមនោ ឧទគ្គោ
បហដ្ឋចិត្តោ សុកត្តុខោ
កម្មញ្ច ទិស្វាន មហាវិបាកំ
សន្ទិដ្ឋិកំ ចក្ខុនា សច្ចិកត្វា ។
តាមេវមាហេច ឧបសង្កមិត្វា
ទស្សាមិ ទានំ សមណព្រាហ្មណានំ
ន ចាបិ មេ កិញ្ចិ អទេយ្យមត្ថិ
តុវញ្ច មេ យក្ខ ពហុបការោ ។
តុវញ្ច មេ លិច្ឆវិ ឯកទេសំ
អទាសិ ទានានិ អមោឃមេតំ
ស្វាហំ ករិស្សាមិ តយា វ សក្ខឹ
អមានុសោ មានុសកេន សទ្ធឹ ។
គតិ ច ពន្ធុ ច បរាយណញ្ច

១ ម. ចន្ទនសារលិត្តំ ។





ស្តេចលិច្ឆវី បានទតឃើញប្រេតនោះ មានខ្លួនប្រស់ព្រំដោយខ្លឹមច័ន្ទន៍ ហើយឡើងជិះសេះអាជានេយ្យ មានរូបដ៏ប្រសើរ មានគ្រឿងប្រដាប់ត្រឹមត្រូវ មានសំពត់ស្លៀក ដណ្ដប់ ដ៏ស្អាត មានបរិវារចោមរោម ដល់នូវឫទ្ធិជាយក្សយ៉ាងធំ ។ លុះស្តេចលិច្ឆវីនោះ ទតឃើញប្រេតនោះហើយ ក៏មានព្រះហឫទ័យសោមនស្ស ខ្ពស់ស្តុកឡើង មានព្រះហឫទ័យត្រេកអរ មានបេកាកដ៏ប្រសើរល្អ មានចក្ខុ ព្រោះបានឃើញនូវកម្មមានផលដ៏ធំផង ធ្វើឲ្យជាក់ច្បាស់នូវប្រេតដែលខ្លួនបានឃើញដោយខ្លួនឯង ។ ស្តេចលិច្ឆវីបានចូលទៅរកប្រេតនោះ ហើយមានព្រះបន្ទូលថា យើងនឹងឲ្យទាន ដល់ពួកសមណៈព្រាហ្មណ៍ ឯវត្ថុបរិច្ចាគ ដែលយើងមិនត្រូវឲ្យ មិនមានទេ ម្នាលយក្ស អ្នកមានឧបការៈដល់យើងច្រើនណាស់ ។

(ប្រេតតបថា) បពិត្រស្តេចលិច្ឆវី ព្រះអង្គបានឲ្យទានចំនួនឡាយចំពោះខ្ញុំម្ចាស់ ការឲ្យទាននេះ មិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសាក្សីជាមួយព្រះអង្គជាមនុស្ស ។

(ស្តេចលិច្ឆវីតបថា) អ្នកជាគតិ ជាផៅពង្ស ជាទីទៅមុខ

មំ ត្វំ វទេសិ អថ ទេវតាសិ
យាចាមិ តំ[1] បញ្ជលិកោ កវិន្ទ
អក្ខាហិ តំ យក្ខ បុច្ឆាមិ ធម្មំ ។
សចេ តុវំ អស្សទ្ធោ[2] ភវិស្សសិ
កទរិយរូបោ វិប្បដិបន្នចិត្តោ
តេនេវ មំ លច្ឆសិ ទស្សនាយ
ទិស្វា ច តំ នោបិ[3] ច អាលបិស្សំ ។
សចេ តុវំ ភវិស្សសិ ធម្មគារវោ
ទានេ រតោ សង្គហិតត្តភាវោ
វទញ្ញូ តោ សមណព្រាហ្មណានំ
ឯវំ មមំ លច្ឆសិ ទស្សនាយ ។
ទិស្វា ច តំ អាលបិស្សំ ភទន្តេ
ឥមញ្ច សូលោ លហុំ បមុញ្ច
យតោ និទានំ អការម្ហ សក្ខឹ
មញ្ញាមិ[4] សូលាវុតកស្ស ការណា
តេ អញ្ញមញ្ញំ អការម្ហ សក្ខឹ ។

---

១ ម. យាចាមហំ ។ ២ ម. ភូមស្សទ្ធោ ។ ៣ ម. នាបិ ។
៤ ម. មញ្ញុ ។



មិនជាមិត្រស្និទ្ធស្នាញ់ មិនជាទេវតារបស់យើង យើងសូម ប្រណម្យអញ្ជលីចំពោះអ្នក ម្នាលយក្ស យើងចង់ឃើញ អ្នកម្ដងទៀត ។

(ទេវបុត្តតបថា) បើព្រះអង្គជាអ្នកមិនមានសទ្ធា ជាបុគ្គល កំណាញ់ មានចិត្តវិបត្តិហើយ ព្រះអង្គបានឃើញខ្ញុំដោយ ហេតុនោះឯង ទុកជាខ្ញុំឃើញ ក៏មិននិយាយរកចំពោះព្រះ អង្គដែរ ។ បើព្រះអង្គជាអ្នកគោរពក្នុងធម៌ ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ ជាអណ្ដូងរបស់ពួកសមណ- ព្រាហ្មណ៍ យ៉ាងនេះ ទើបព្រះអង្គបានឃើញខ្ញុំបាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំឃើញហើយនិយាយ ចំពោះព្រះអង្គ ជា ព្រះអង្គ ចូរដោះបុរសនេះ អំពីឈើអណ្ដោតឲ្យឆាប់ ទៅ យើងបានធ្វើជាសាក្សី ព្រោះហេតុតែបុរសណាយើង ក៏មិនដឹង ព្រោះហេតុតែបុរស ដែលគេដោតដោយឈើ អណ្ដោត យើងទាំងនោះបានធ្វើជាសាក្សីដល់គ្នានឹងគ្នា ។

អយញ្ច សូលាវុតោ លហុំ បមុត្តោ
សក្កច្ច ធម្មានិ[១] សមាចរន្តោ
មុញ្ចេយ្យ[២] សោ និរយា ច តម្ហា
កម្មំ សិយា អញ្ញត្រ វេទនីយំ ។
កប្បិតកញ្ច ឧបសង្កមិត្វា
តេន សហ សំវិភជិត្វាន កាលេ
សយំ មុខេន ឧបនិសជ្ជ បុច្ឆ
សោ តេ អក្ខិស្សតិ ឯតមត្ថំ ។
តមេវ ភិក្ខុំ ឧបសង្កមិត្វា បុច្ឆស្សុ
បុញ្ញត្ថិកោ នោ ច[៣] បទុដ្ឋចិត្តោ
សោ តេ សុតំ អសុតញ្ចាបិ[៤] ធម្មំ
សព្វំបិ អក្ខិស្សតិ យថា បជានំ
សុត្វា ច ធម្មំ សុគតិំ គមិស្ស[៥] ។
សោ តត្ថ រហស្សំ[៦] សមុល្លបិត្វា
សក្ខិំ ករិត្វាន អមានុសេន
បក្កាមិ សោ លិច្ឆវីនំ សកាសំ

---

១ ម. ធម្មានិ ។ ២ ម. មុច្ចេយ្យ ។ ៣ ម. នោ ។ ៤ ម. អសុតញ្ចាបិ ។ ៥ សុត្វាន ធម្មំ សុគតិំ គមិស្សសីតិ បាឋោ ទិស្សតិ ។ ៦ ម. រហស្សំ ។





បើបុរសដែលជាប់នៅលើឈើអណ្តោតនេះ ឆាប់រួចបាន គប្បីប្រព្រឹត្តធម៌ដោយគោរព បើបុរសនោះរួចអំពីនរកនោះបាន កម្មនោះនឹងទៅជាកម្មដែលបុរសនោះគប្បីទទួលផលក្នុងភពដទៃ ។ សូមព្រះអង្គ ស្តេចចូលទៅរកកប្បិតកភិក្ខុ ហើយចាត់ចែងភោជនាហារក្នុងកាលជាមួយនឹងលោក ហើយគង់ចំពោះមុខលោក ដោយព្រះអង្គឯង ហើយទូលសួរលោកចុះ លោកនឹងនិងប្រាប់សេចក្តីនោះដល់ព្រះអង្គ ។ សូមព្រះអង្គចូលទៅរកភិក្ខុនោះហើយសួរចុះ ព្រោះភិក្ខុនោះត្រូវការបុណ្យ មិនមានចិត្តប្រទូស្តទេ ភិក្ខុនោះដឹងយ៉ាងណា ក៏នឹងប្រាប់នូវធម៌ទាំងអស់យ៉ាងនោះ ដែលព្រះអង្គស្តាប់ហើយក្តី មិនដែលស្តាប់ហើយក្តី កាលបើព្រះអង្គស្តាប់ លោកនឹងសំដែងប្រាប់នូវធម៌ផង នូវសុគតិផង ។

ស្តេចលិច្ឆវីនោះ បានពិគ្រោះក្នុងទីស្ងាត់ ក្នុងទីនោះ ហើយធ្វើឲ្យជាសាក្សី ជាមួយនឹងអមនុស្ស ហើយចៀសចេញទៅ កាន់សំណាក់ នៃស្តេចលិច្ឆវីទាំងឡាយ

អថព្រវិ បរិសំ សន្និសិន្នំ ។
សុណន្តុ ភោន្តោ មម ឯកវាក្យំ
អហំ ករិស្សំ លភិស្សាមិ អត្ថំ
សូលាវុតោ បុរិសោ លុទ្ទកម្មោ
បណីតទណ្ឌោ អនុសត្តរូបោ[១] ។
ឯត្តាវតា វីសតិរត្តិមត្តា
យតោ អាវុតោ នេវ ជីវតិ ន មតោ
តាហំ មោចយិស្សាមិ ទានិ
យថាមតី អនុជានាតុ សង្ឃោ ។
ឯតញ្ច អញ្ញញ្ច លហុំ បមុញ្ច
តោ តំ វទេថ ន តថា ករេយ្យ
យថា បជានាសិ តថា ករោហិ
យថាមតី អនុជានាតិ សង្ឃោ ។
សោ តំ បទេសំ ឧបសង្កមិត្វា
សូលាវុតំ មោចយិ ខិប្បមេវ
មា ភាយិ សម្មាតិ ច[២] តំ អវោច
តិកិច្ឆកានញ្ច ឧបដ្ឋបេសិ ។

១ ម. អនុប្បត្តរូបោ ។ ២ ម. ឱ-ប សម្មា តិ ។



សំណាប់នោះ ស្ដេចបានពោលចំពោះបរិស័ទដែលមកប្រជុំគ្នា ។

(ស្ដេចសិវិរាជត្រាស់ថា) អ្នកដ៏ចំរើនទាំងឡាយ ចូរស្ដាប់ពាក្យយើងមួយម៉ាត់ យើងនឹងធ្វើនូវការ យើងនឹងបាននូវប្រយោជន៍ បុរសដែលត្រូវគេដោតដោយឈើអណ្ដោត ជាអ្នកមានកម្មអាក្រក់ មានគេដាក់ទោសទុកហើយ មានសភាពជាមនុស្សជាប់ដោយកាំ ។ បុរសដែលត្រូវឈើអណ្ដោតដោតហើយ មិនរស់ មិនស្លាប់ អស់ ២០ រាត្រីប៉ុណ្ណោះ ឥឡូវនេះយើងនឹងដោះបុរសនោះ[១] សូមសង្ឃយល់តាមសេចក្ដីគាប់ចិត្ត(របស់យើង)ចុះ ។

(ប្រជុំជនថា) សូមព្រះអង្គដោះលែងបុរសដែលជាប់ដោយឈើអណ្ដោតនោះផង បុរសដទៃផងឲ្យឆាប់ទៅ នរណាពោលនឹងព្រះអង្គដែលគិតនឹងធ្វើដូច្នោះ ព្រះអង្គយល់ឃើញណា ចូរធ្វើយ៉ាងនោះចុះ ឥឡូវសង្ឃយល់តាមសព្វព្រះទ័យហើយ ។

ស្ដេចនោះបានចូលទៅប្រទេសនោះ ហើយបានដោះលែងបុរសដែលគេដោត ដោយឈើអណ្ដោតមួយរំពេច ហើយត្រាស់ទៅបុរសនោះថា នែសំឡាញ់មានបុណ្យស្មើ ចូរអ្នកកុំភ័យឡើយ ហើយក៏ប្រគល់ឲ្យទៅពួកពេទ្យអ្នកថែរក្សា ។

១ សំដៅយកពួកក្រុមស្ដេចសិវិ ។

ការាបេត្វា ឧបសង្កមិត្វា
តេន សហ សិរិគព្ភដ្ឋានេ កាលេ
សយំ មុខេនេវ ឧបនិសជ្ជ[១] លិង្គំ
ការេត្វា ពុជ្ឈន្តំ[២] ការណាគ្គតោ
សុណាតុ តោ បុរិសោ លុទ្ទកម្មោ
បណ្ឌិតជនេហិ អនុសត្ថោ ។
ឯត្តាវតា វីសតិរត្តិមត្តា
យតោ អាវុតោ នេវ ជីវតិ ន មតោ ។
សោ មោចិតោ គន្ត្វា មយា ឥតោ
ឯតស្ស យក្ខស្ស វចោ[៣] ភន្តេ
សិយា នុ ខោ ការណំ កិញ្ចិទេវ
យេន សោ និរយំ នោ វជេយ្យ ។
អាចិក្ខ ភន្តេ យទិ អត្ថិ ហេតុ
សទ្ធាយិតំ ហេតុ វចោ[៤] សុណោម
ន តេសំ កម្មានំ វិនាសមត្ថិ
អវេទយិត្វា ឥធ ព្យន្តិភាវោ ។

១ ម. មុខេន នេវ ឧបនិសជ្ជ ។ ឧ. មុខេន ឧបនិសជ្ជ ។ ២ ម. ការេ ពុជ្ឈន្តំ គំ ការំ ។ ឧ. ការេ ពុជ្ឈន្តំ ។ ៣ ម. វចោ ។ ៤ ម, វចោ ។



ទើបស្តេចលិច្ឆវីនោះនឹងចូលទៅរកបុរសកកក្ករ ហើយចាត់ចែង រាជការនោះ ក្នុងកាលជិតរួច មួយអន្លើនឹងបុរសកកក្ករនោះ ស្តេចលិច្ឆវីនៃក្រុងវេសាលីដោយហេតុ ទើបចូលទៅគន់ជិតហើយ សួរបុរសកកក្ករនោះ ដែលអង្គុយនៅទីនោះ ដោយព្រះនុស្ស ព្រះអង្គឯងថា បុរសដែលគេដោតដោយឈើអណ្តូក(ហ្នឹង) ជាអ្នកធ្វើកម្មអាក្រក់ ត្រូវគេដាក់គាំងហើយ មានសភាពជា អ្នកជាប់ដោយគាំង បុរសដែលត្រូវឈើអណ្តូកដោតហើយ មិនរស់ មិនស្លាប់ អស់២០រាត្រីប៉ុណ្ណោះ ។ បពិត្រលោក ដ៏ចំរើន ឥឡូវនេះ បុរសនោះ ខ្ញុំបានដោះលែងតាមពាក្យ អ្នកទាំងហើយ ហេតុតិចតួចដែលបុរសនោះ មិនគប្បីទៅ នរកមានដែរឬ ។ បពិត្រលោកដ៏ចំរើន បើមានហេតុ គឺហេតុ ដែលគួរជឿបាន សូមលោកប្រាប់ដល់យើង យើងស្តាប់ ហើយ យើង(នឹងជឿតាមពាក្យរបស់លោក) ការវិនាស នៃកម្មទាំងនោះ ក៏មិនមាន សេចក្តីវិនាស របស់បុរសនោះ ក៏មិនមាន ក្នុងទីនេះ ព្រោះមិនបានទទួលនូវផល ។

សចេ សោ ធម្មំ(១) សមាចរេយ្យ
សក្កច្ចំ រត្តិន្ទិវំ អប្បមត្តោ
មុញ្ចេយ្យ សោ និរយា ច(២) តម្ហា
កម្មំ សិយា អញ្ញត្រ វេទនីយំ ។
អញ្ញាតោ(៣) ឯសោ បុរិសស្ស អត្ថោ
មមម្បិ ទានិ អនុកម្ប កត្តេ
អនុសាស មំ ឱវទ ភូរិបញ្ញ
យថា អហំ នោ(៤) និរយំ វជេយ្យំ ។
អជ្ជេវ ពុទ្ធំ សរណំ ឧបេហិ
ធម្មញ្ច សង្ឃញ្ច បសន្នចិត្តោ
តថេវ សិក្ខាបទានិ បញ្ច
អខណ្ឌផុល្លានិ សមាទិយស្សុ ។
បាណាតិបាតា វិរមស្សុ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយស្សុ
អមជ្ជបោ មា ច មុសា អភាសិ(៥)
សកេន ទារេន ច ហោហិ តុដ្ឋោ ។

---

១ ឱ. ធម្មានិ ។ ២ ម. សី ។ ៣ ម. ញាតក្ខំ ។ ៤ ម. ចេ ។
៥ ម. អភាណិ ។



បើបុរសនោះ គប្បីប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទ ទាំងយប់ទាំងថ្ងៃ ដោយគោរព ទើបបុរសនោះ គប្បីរួចចាកនរកនោះបាន កម្មនោះនឹងជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។ ប្រយោជន៍របស់បុរសនុ៎ះ ខ្ញុំបានដឹងហើយ បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់អនុគ្រោះខ្ញុំ ក្នុងកាលឥឡូវនេះ បពិត្រលោកមានប្រាជ្ញាដ៏ក្រាស់ សូមលោកម្ចាស់ ទូន្មានប្រៀនប្រដៅខ្ញុំ ឲ្យកុំឲ្យខ្ញុំទៅនរកបាន ។

(ព្រះថេរៈតបថា) ព្រះអង្គមានព្រះហឫទ័យជ្រះថ្លា ចូរដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណៈ ក្នុងថ្ងៃនេះឯងមួយទៀត ព្រះអង្គចូរសមាទាននូវសិក្ខាបទទាំង ៥ កុំឲ្យដាច់ធ្លុះធ្លាយឡើយ ។ ចូរព្រះអង្គវៀរចាកបាណាតិបាតឲ្យឆាប់ ចូរវៀរចាកទ្រព្យដែលគេមិនឲ្យក្នុងលោកចេញ កុំសោយនូវទឹកស្រវឹងផង កុំកុហកផង ចូរត្រេកអរតែនឹងមហេសីរបស់ព្រះអង្គផង

ឥមញ្ច អដ្ឋង្គិកំ ឧបេតំ
សមាទិយាហិ កុសលំ សុខុទ្រ្ទយំ ។
ចីវរំ បិណ្ឌបាតញ្ច   បច្ចយំ សយនាសនំ
អន្នំ បានំ ខាទនីយំ   វត្ថសេនាសនានិ ច
ទទាហិ ឧជុភូតេសុ   សទា បុញ្ញំ បវឌ្ឍតិ
ភិក្ខូ ច សីលសម្បន្នេ   វីតរាគេ ពហុស្សុតេ
តប្បេហិ[១] អន្នបានេន   សទា បុញ្ញំ បវឌ្ឍតិ ។
ឯវញ្ច ធម្មានិ[២] សមាចរន្តោ
សក្កច្ចំ រត្តិទិវំ អប្បមត្តោ
មុញ្ចេយ្យ សោ[៣] និរយា ច តម្ហា
កម្មំ សិយា អញ្ញត្រ វេទនីយំ ។
អជ្ជេវ ពុទ្ធំ សរណំ ឧបេមិ
ធម្មញ្ច សង្ឃញ្ច បសន្នចិត្តោ
តថេវ សិក្ខាបទានិ បញ្ច
អខណ្ឌផុល្លានិ សមាទិយាមិ
បាណាតិបាតា វិរមាមិ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយាមិ
អមជ្ជបោ នោ ច មុសា ភណាមិ

១ ឱ. តប្បេសិ ។ ២ ឱ. ធម្មំ ។ ៣ ឱ. ខុញ្ញ ។



សូមព្រះអង្គសមាទាននូវការបរិសុទ្ធសីលដ៏ប្រសើរ ប្រកប
ដោយអង្គ ៨ នេះ ជាកុសល ឲ្យផលជាសុខចុះ ។
សូមព្រះអង្គប្រគេននូវចីវរបច្ច័យ បិណ្ឌបាតបច្ច័យ សយនា-
សនបច្ច័យ បាយនឹងទឹក បន្លែម សំពត់ សេនាសនៈទាំងឡាយ
ចំពោះពួកបុគ្គលអ្នកមានចិត្តត្រង់ បុណ្យរមែងចំរើន សព្វ ៗ កាល
មួយទៀត សូមព្រះអង្គញុំាងពួកភិក្ខុអ្នកបរិបូណ៌ដោយសីល ប្រាស
ចាករាគៈ ជាពហុស្សូត ឲ្យឆ្អែតដោយបាយ នឹងទឹក បុណ្យរមែង
ចំរើនសព្វ ៗ កាល ។ កាលបើបុរសនោះ ប្រព្រឹត្តនូវធម៌ទាំងឡាយ
មិនប្រមាទទាំងយប់ទាំងថ្ងៃ ដោយគោរពយ៉ាងនេះហើយ ទើបរួច
ចាកនរកបាន កម្មនោះនឹងទៅជាកម្មដែលត្រូវទទួលក្នុងកាលដទៃ ។
(ស្តេចលិច្ឆវីមានព្រះឧត្តរថា) ខ្ញុំមានចិត្តជ្រះថ្លា ដល់នូវ
ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ក្នុងថ្ងៃនេះឯង
មួយទៀត ខ្ញុំសមាទាននូវសិក្ខាបទទាំង ៥ មិនឲ្យដាច់ធ្លុះធ្លាយ
ខ្ញុំវៀរចាកបាណាតិបាត យ៉ាងឆាប់ ខ្ញុំវៀរចាកអទិន្នាទាន
ក្នុងលោក ខ្ញុំមិនផឹកទឹកស្រវឹង មិននិយាយពាក្យមុសា

សកេន ទារេន ច ហោមិ តុដ្ឋោ ។
ឥមញ្ច អរិយំ អដ្ឋង្គិកំ ឧបេតំ
សមាទិយាមិ កុសលំ សុខុទ្រយំ ។
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
អន្នំ បានំ ខាទនីយំ វត្ថំ សេនាសនានិ ច
ភិក្ខូ ច សីលសម្បន្នេ វីតរាគេ ពហុស្សុតេ
ទទាមិ ន វិកម្បាមិ ពុទ្ធានំ សាសនេ រតោ ។
ឯតាទិសោ លិច្ឆវិ អម្ពសក្ខរោ[1]
វេសាលិយំ អញ្ញតរោ ឧបាសកោ
សទ្ធោ មុទុ ការកោ ច ភិក្ខុ-
សង្ឃញ្ច សក្កច្ច តទា ឧបដ្ឋហិ ។
សូលាវុតោ ច អរោគោ ហុត្វា
សេរីសុខី[2] បព្វជ្ជំ ឧបាគមិ
អាគម្ម កប្បិតកុត្តមំ ឧភោបិ
សាមញ្ញផលានិ អជ្ឈគុ ។
ឯតាទិសា សប្បុរិសាន សេវនា
មហាផលា[3] ហោតិ សតំ វិជានតំ

១ ម. អម្ពសក្ខរោ ។ ២ ឱ. សេរីសុខំ ។ ៣ ម. មហប្ផលា ។



ខ្ញុំត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន ។ ខ្ញុំសមាទាននូវឧបោសថសីល ដ៏ឧត្តមប្រកបដោយអង្គ៨ប្រការ ដ៏ប្រសើរនេះ ជាកុសល ឲ្យផលជាសុខ ។

ខ្ញុំឲ្យនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ ទីដេក ទីអង្គុយ បាយ ទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកភិក្ខុ អ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ខ្ញុំជាអ្នកត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធទាំងឡាយ មិនកម្រើកឡើយ ។

(បណ្តាពួកឧបាសក) ក្នុងក្រុងវេសាលី ស្តេចលិច្ឆវីព្រះនាម អម្ពសក្ខរៈ ជាឧបាសកម្នាក់ ក្រៅពីនោះ ក្នុងក្រុងវេសាលី ជាអ្នកមានសទ្ធាផង មានចិត្តទន់ភ្លន់ផង ជាអ្នកធ្វើនូវឧបការៈ ចំពោះភិក្ខុសង្ឃដោយគោរព ក្នុងកាលនោះផង ។ បុរស ដែលត្រូវគេដោតដោយឈើអណ្តោត ឥតមានរោគ មានតែ សេរីនិងសុខ បានចូលទៅកាន់ផ្នួស ផងទាំងពីរនាក់ ក៏បាន សម្រេចនូវសាមញ្ញផលទាំងឡាយ (តាមសមគួរ) ព្រោះ អាស្រ័យនឹងព្រះថេរៈឈ្មោះកប្បិតកៈដ៏ឧត្តម ។ ការសេពគប់ នឹងពួកសប្បុរស អ្នកស្ងប់ អ្នកដឹងច្បាស់ រមែងមានផលច្រើន

សូលាវុតោ អគ្គផលំ ផុស្សិត្វា(១)
ផលំ កនិដ្ឋំ បន អម្ពសក្ខរោតិ ។

អម្ពសក្ខរបេតវត្ថុ បឋមំ ។

## ទុតិយំ សេរីស្សកបេតវត្ថុ

(៣៧) សុណោថ យក្ខស្ស ច វាណិជាន ច

។ បេ ។

(វិមានវត្ថុស្មឹ សត្តមស្ស សុនិក្ខិត្តវគ្គស្ស ទសមវត្ថុស្មឹ ទដ្ឋព្វំ)

សេរីស្សកបេតវត្ថុ ទុតិយំ ។

## តតិយំ នន្ទិកាបេតវត្ថុ

(៣៨) រាជា បិង្គលកោ នាម សុរដ្ឋានំ អធិបតិ អហុ
មោរិយានំ ឧបដ្ឋានំ គន្ត្វា សុរដ្ឋំ បុនាគមា ។
ឧណ្ហេ មជ្ឈន្តិកេ កាលេ រាជា បង្កំ ឧបាគមិ
អទ្ទស មគ្គំ រមណីយំ បេតានំ វណ្ណនាបថំ(២)
សារថឹ អាមន្តយិ រាជា អយំ មគ្គោ រមណីយោ
ខេមោ សោវត្ថិកោ សិវោ
ឥមិនា សារថិ យាហិ សុរដ្ឋានំ សន្តិកេ ឥតោ
តេន បាយាសិ សោរដ្ឋោ សេនាយ ចតុរង្គិនិយា ។

១ ឱ. ផុស្សសិ ។ ម. អនុស្សរិ ។ ២ ម. វណ្ណុបថំ ។



បុរសដែលដេកលើឈើអណ្ដោត បានសម្រេចនូវផលដ៏ប្រសើរ ឯស្តេចលិច្ឆវីអម្ពសក្ខរៈ បានសម្រេចផលតូច (សោតាបត្តិផល) ។

ចប់ រឿងអម្ពសក្ខរប្រេត ទី ១ ។

## រឿងសេរីស្សកប្រេត ទី ២

(៣៧) ការប្រជុំនៃយក្ខនឹងពាណិជទាំងឡាយ អ្នកទាំងឡាយចូរស្តាប់

។ បេ ។

(អ្នកប្រាជ្ញគប្បីមើលក្នុងរឿងទី ១០ នៃសុនិក្ខិត្តវគ្គទី ៧ ក្នុងវិមានវត្ថុ) ។

ចប់ រឿងសេរីស្សកប្រេតទី ២ ។

## រឿងនន្ទិកាប្រេត ទី ៣

(៣៨) ព្រះរាជាព្រះនាមបិង្គលកៈ ជាធំក្នុងសុរដ្ឋប្រទេស ស្តេចទៅកាន់ទីគាល់នៃព្រះបាទមោរិយៈ (ព្រះបាទធម្មាសោក) ហើយស្តេចត្រឡប់មកសុរដ្ឋប្រទេសវិញ ។ ព្រះរាជាស្តេចយាងមកកាត់ក្នុងវេលាថ្ងៃត្រង់ដីក្តៅ ក៏បានទតឃើញផ្លូវគួរជាទីត្រេកអរ ជាផ្លូវដែលប្រេតទាំងឡាយនិម្មិតហើយ ទើបព្រះរាជាទ្រង់ត្រាស់នឹងនាយសារថីថា ផ្លូវនេះគួរជាទីត្រេកអរ ជាផ្លូវដ៏ក្សេមក្សាន្ត ប្រកបដោយសួស្តី ជាផ្លូវមិនមានចង្រៃឡើយ ម្នាលសារថី ចូរអ្នកទៅតាមផ្លូវនេះវិញ (ព្រោះយើង) ទៅតាមផ្លូវនេះ ជិតដល់សុរដ្ឋប្រទេសហើយ ជួនព្រះបាទបិង្គលកៈក្នុងសុរដ្ឋប្រទេស ក៏បានទៅតាមផ្លូវនោះជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។

ឧព្វិគ្គរូបោ បុរិសោ សុរដ្ឋំ ឯតទព្រវិ
កុម្មគ្គំ បដិបន្នម្ហា ភឹសនំ លោមហំសនំ ។
បុរតោ ន ទិស្សតិ មគ្គោ បច្ឆតោ ច ន ទិស្សតិ
កុម្មគ្គំ បដិបន្នម្ហា យមបុរិសាន សន្តិកេ ។
អមានុសោ វាយតិ គន្ធោ ឃោសោ សុយ្យតិ ទារុណោ
សំវិគ្គោ រាជា សុរដ្ឋោ សារថឹ ឯតទព្រវិ
កុម្មគ្គំ បដិបន្នម្ហា ភឹសនំ លោមហំសនំ
បុរតោ ន ទិស្សតិ មគ្គោ បច្ឆតោ ច ន ទិស្សតិ ។
កុម្មគ្គំ បដិបន្នម្ហា យមបុរិសាន សន្តិកេ
អមានុសោ វាយតិ គន្ធោ ឃោសោ សុយ្យតិ ទារុណោ ។
ហត្ថិក្ខន្ធំ សមារុយ្ហ ឱលោកេន្តោ ចតុទ្ទិសា
អទ្ទស រុក្ខំ និគ្រោធំ បាទបំ ឆាយសម្បន្នំ
នីលព្ភវណ្ណសទិសំ មេឃវណ្ណសិរីន្និភំ
សារថឹ អាមន្តយិ រាជា កឹ ឯសោ ទិស្សតិ ព្រហា
នីលព្ភវណ្ណសទិសោ មេឃវណ្ណសិរីន្និភោ ។
សោ និគ្រោធោ សោ មហារាជ បាទបោ ឆាយសម្បន្នោ
នីលព្ភវណ្ណសទិសោ មេឃវណ្ណសិរីន្និភោ ។



*បុរស មានសភាពតក់ស្លុត ចុះក្រាបទូលស្ដេចនៃសុរដ្ឋប្រទេស ដូច្នេះថា យើងដើរទៅតាមផ្លូវមិនស្រួល ជាទីស្ញប់ស្ញែង ព្រឺព្រួចរោម ។ ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ យើងដើរទៅតាមផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសប្រេត ឯក្លិនអមនុស្ស បក់មក ទាំងមានសំឡេងគឹកកងដ៏ខ្លាំង ដ៏អាក្រក់ ក៏ឮមក ។*

*ព្រះរាជាក្នុងសុរដ្ឋប្រទេស ទ្រង់មានសេចក្ដីតក់ស្លុត ទើបត្រាស់ទៅនឹងនាយសារថីដូច្នេះថា យើងដើរទៅកាន់ផ្លូវមិនស្រួល នាំឲ្យស្ញប់ស្ញែង នាំឲ្យព្រឺព្រួចរោម ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ ។ យើងដើរទៅកាន់ផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសហើយ ឯក្លិនសរីរៈអមនុស្សក៏បក់មក ទាំងសំឡេងគឹកកងដ៏អាក្រក់ ក៏ឮមក ។ (ទ្រង់ត្រាស់ដូច្នេះហើយ) ក៏ឡើងគង់លើដំរី ហើយទតមើលទៅទិស ទាំង ៤ បានឃើញដើមជ្រៃមួយដើម ជារុក្ខជាតទីគាប់ចិត្ត ដោយដើម បរិបូណ៌ដោយម្លប់ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូច ផ្ទៃមេឃ ព្រះរាជាត្រាស់ទៅនឹងនាយសារថីថា ដើមឈើធំ ប្រហែល មេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃនុ៎ះ ជាឈើអ្វី ។*

*សារថីក្រាបទូលថា បពិត្រមហារាជ នោះជាដើមជ្រៃ ជារុក្ខជាត ទីគាប់ចិត្តដោយដើម បរិបូណ៌ដោយម្លប់ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។*

តេន បាយាសិ សុរដ្ឋោ យេន សោ និស្សូតិ ព្រហា
នីលព្ភវណ្ណសទិសោ មេឃវណ្ណសិរិន្និភោ ។
ហត្ថិក្ខន្ធតោ ឱរុយ្ហ រាជា រុក្ខំ ឧបាគមិ
និសីទិ រុក្ខមូលស្មឹ សាមច្ចោ សបរិជ្ជនោ
បូរំ បានីយករកំ បូវេ[១] ចិត្តេ ច អទ្ទស ។
បុរិសោ ទេវវណ្ណីតិ សព្វាភរណភូសិតោ
ឧបសង្កមិត្វា រាជានំ សោរដ្ឋំ ឯតទព្រវិ
ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
បិវតុ ទេវោ បានីយំ បូវេ ខាទ អរិន្ទម ។
បិវិត្វា រាជា បានីយំ សាមច្ចោ សបរិជ្ជនោ
បូវេ ខាទិត្វា[២] បិត្វា ច សុរដ្ឋោ ឯតទព្រវិ
ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
អជានន្តា តំ បុច្ឆាម កថំ ជានេមុ តំ មយំ ។
នាម្ហិ ទេវោ ន គន្ធព្វោ នាបិ[៣] សក្កោ បុរិន្ទទោ
បេតោ អហំ មហារាជ សុរដ្ឋា ឥធ មាគតោ[៤] ។

---

១ ម. បូវេ ។ ២ ម. ខាទិត្វាន អរិន្ទមោ គន្ធ ត្វាតិ ទិស្សតិ ។ ៣ ម. នម្ហិ ។ ៤ ម. សុរដ្ឋាហំ ឥធាគតោ ។



ព្រះរាជាក្នុងសុរដ្ឋប្រទេស ស្តេចទៅត្រង់ដើមជ្រៃធំ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចពពកមេឃ ។ ព្រះរាជាស្តេចចុះពីកដំរី ហើយចូលសំដៅទៅកាន់ដើមឈើ ទ្រង់គង់ក្រោមម្លប់ឈើជាមួយនឹងអាមាត្យ និងជនជាបរិវារ ក៏បានទតឃើញក្អមទឹកដ៏ពេញ និងនំនំចំណីផ្សេងៗដ៏វិចិត្រ ។

(ប្រេតនោះ) ក្លាយខ្លួនជាបុរសមានភេទដូចជាទេវតា ស្អិតស្អាងគ្រឿងអាភរណៈទាំងពួង ហើយចូលទៅគាល់ព្រះរាជា ជាធំក្នុងសុរដ្ឋប្រទេស ទូលថា បពិត្រមហារាជ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ដំណើរព្រះអង្គស្តេចមក ឈ្មោះថា មកអំពីទីមិនឆ្ងាយ បពិត្រព្រះអរិន្ទមរាជ សូមព្រះសម្មតិទេពទ្រង់សោយនូវវិសុទ្ធោទក ទ្រង់សោយនូវនំទាំងឡាយ ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ព្រមទាំងអាមាត្យ និងជនជាបរិវារ បានសោយនូវព្រះវិសុទ្ធោទកផង សោយនូវនំទាំងឡាយផង លុះសោយរួចហើយទ្រង់ត្រាស់សួរថា អ្នកជាទេវតា ឬជាគន្ធព្វ ឬមួយជាសក្កបុរិន្ទទៈ យើងមិនស្គាល់ បានជាសួរអ្នក យើងស្គាល់អ្នកដូចម្តេចបាន ។

(ប្រេតទូលថា) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ បពិត្រមហារាជ ជាស្តេចក្នុងសុរដ្ឋប្រទេស ខ្ញុំជាប្រេតទេតើ មកនៅក្នុងទីនេះ ។

កឹសីលោ កឹសមាចារោ សុរដ្ឋស្មឹ បុរេ តុវំ
កេន តេ ព្រហ្មចរិយេន អានុភាវោ អយំ តវ ។
តំ សុណោហិ មហារាជ អរិន្ទម រដ្ឋវឌ្ឍន
អមច្ចា បារិសជ្ជា ច ព្រាហ្មណោ ច បុរោហិតោ ។
សុរដ្ឋស្មឹ[1] អហំ ទេវ បុរិសោ បាបចេតសោ
មិច្ឆាទិដ្ឋិ ច ទុស្សីលោ កទរិយោ បរិភាសកោ
ទទន្តានំ ករោន្តានំ វារយិស្សំ ពហុជ្ជនំ
អញ្ញេសំ ទទមានានំ អន្តរាយំ ករោមហំ ។
វិបាកោ នត្ថិ ទានស្ស សំយមស្ស កុតោ ផលំ
នត្ថិ អាចរិយោ នាម អទន្តំ កោ ទមេស្សតិ ។
សមតុល្យានិ ភូតានិ កុលេ ជេដ្ឋាបចាយិកោ
នត្ថិ ពលំ វិរិយំ វា កុតោ ឧដ្ឋានពោរិសំ ។
នត្ថិ ទានផលំ នាម ន វិសោធេតិ វេរិនំ
លទ្ធេយ្យំ លភតេ មច្ចោ និយតិ បរិណាមជំ ។
នត្ថិ មាតា បិតា ភាតា លោកោ នត្ថិ ឥតោ បរំ
នត្ថិ ទិន្នំ នត្ថិ ហុតំ សុនិហិតំ ច វិន្ទតិ ។

១ ម. សុរដ្ឋស្មា ។



ព្រះរាជាត្រាស់ថា ចុះអ្នកឯង មានសីលដូចម្ដេច មានសមាចារដូចម្ដេច ក្នុងសុរដ្ឋបុរី អ្នកឯងនេះ មានអានុភាពច្រើន ព្រោះអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូចម្ដេចខ្លះ ។

(ប្រេតតបថា) បពិត្រព្រះអរិន្ទមមហារាជ ជាស្ដេចចំរើនក្នុងដែន សូមព្រះអង្គ ព្រមទាំងពួកអាមាត្យ និងព្រាហ្មណ៍ បុរោហិត ទ្រង់ព្រះសណ្ដាប់ពាក្យខ្ញុំនោះ ។ បពិត្រព្រះទេព ខ្ញុំនៅក្នុងសុរដ្ឋប្រទេស ជាបុរសមានចិត្តអាក្រក់ មានសេចក្ដីយល់ខុស ទ្រុស្ដសីល កំណាញ់ ជេរប្រទេចផ្ដាសាពួកជនដែលកំពុងឲ្យ កំពុងធ្វើ ហាមឃាត់ពួកជនច្រើន ធ្វើអន្តរាយដល់ពួកជនដទៃ ដែលកំពុងឲ្យ (ខ្ញុំតែងនិយាយរឿយៗថា) ផលរបស់ទានមិនមានទេ ផលនៃការសង្រួម គឺសីលនឹងមានមកពីណា អាចារ្យមិនមាន អ្នកណានឹងទូន្មានបុគ្គល ដែលគេមិនទាន់ទូន្មានហើយនោះបាន ។ ពួកសត្វស្មើៗគ្នា ទាំបាច់មានបុគ្គលជាអ្នកគោរពកោតក្រែងក្នុងត្រកូលរៀមច្បង(ធ្វើអ្វីទៀត) កំឡាំងក្តី សេចក្ដីព្យាយាមក្តី មិនមានហើយ សេចក្ដីប្រឹងប្រែងរបស់បុរសមានមកអំពីណា ។ ផលរបស់ទានមិនមានទេ បុគ្គលមិនអាចធ្វើសត្រូវដែលមានពៀរឲ្យស្អាតបាន សត្វបានសេចក្ដីសុខទុក្ខដែលត្រូវបាន កើតពីសេចក្ដីប្រែប្រួលនៃធម្មជាតិទៅ (មិនមែនព្រោះកម្មដែលខ្លួនធ្វើទេ) ។ មាតាបិតា បងប្អូន មិនមាន លោកដទៃក្រៅអំពីលោកនេះមិនមាន ការឲ្យទានមិនមាន ការបូជាមិនមាន ការដម្កល់ទាន (ចំពោះសមណព្រាហ្មណ៍) ក៏មិនមាន ។

យោបិ ន ហនាតិ[១] បុរិសំ បុរិសស្ស[២] ឆិន្ទតេ[៣] សិរំ
ន កោចិ កញ្ចិ ហនតិ សត្តន្នំ វិវរន្តរេ
អច្ឆេជ្ជាភេជ្ជោ ជីវោ[៤] អដ្ឋំសោ គុឡបរិមណ្ឌលោ
យោជនានំ[៥] សតា បញ្ច កោ ជីវំ ឆេត្តុមរហតិ ។
យថា សុត្តគុឡេ ខិត្តេ និព្វេឋេន្តំ[៦] បលាយតិ ។
ឯវមេវំបិ សោ ជីវោ និព្វេឋេន្តោ បលាយតិ ។
យថា គាមតោ និក្ខម្ម អញ្ញំ គាមំ បវិសតិ
ឯវមេវំបិ សោ ជីវោ អញ្ញំ កាយំ[៧] បវិសតិ ។
យថា គេហតោ និក្ខម្ម អញ្ញំ គេហំ បវិសតិ
ឯវមេវំបិ សោ ជីវោ អញ្ញំ ពោន្ទិំ បវិសតិ ។
ចុល្លាសីតិ មហាកប្បិនោ សតសហស្សានិ យេ ពាលា
យេ ច បណ្ឌិតា
សំសារំ ខេបយិត្វាន ទុក្ខស្សន្តំ ករិស្សរេ ។
មិតានិ សុខទុក្ខានិ ទោណេហិ បិដកេហិ ច
ជិនោ សព្វំ បជានាតិ សម្មូឡ្ហា ឥតរា បជា ។
ឯវំ ទិដ្ឋិ បុរេ អាសិ សម្មូឡ្ហោ មោហបារុតោ

---

១ ឱ. យោបិ ន ហនេយ្យ ។ ម. យោបិ ហនេយ្យ ។ ២ ឱ. បរស្ស ។ ៣ ម. ឆិន្ទេ ។ ៤ ម. អច្ឆិជ្ជាភិជ្ជោ សជីវោ ។ ៥ ម. យោជនានិ ។ ៦ ឱ. និព្វេឋេន្តំ ។ ៧ ម. ពោន្ទិំ ។





អ្នកណាកាត់ក្បាលបុរស មិនឈ្មោះថា សម្លាប់បុរសទេ (ព្រោះ) គ្មានអ្នកណាសម្លាប់ (អ្នកណា) តិចតួចទេ ទុកដូចជាបៀតបៀន ក្នុងចន្លោះនៃកាយទាំង ៧ (មានផែនដីជាដើម) ដែរ ។ ជីវៈជា សភាវៈកាត់មិនបាន ទំលាយមិនបាន (ព្រោះ) ជួនកាលមានជ្រុង ៨ ជួនកាលមូលជាដុំ (មានកំពស់) ៥០០ យោជន៍ អ្នកណាក៏មិនអាច នឹងកាត់បង់ជីវៈបានឡើយ ។ កាលបើគេបោះហុងអំបោះទៅ អំបោះហុងនោះរមែងរលា យ៉ាងណាមិញ ជីវៈនោះ ក៏រលា យ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីស្រុក ចូលទៅកាន់ស្រុក ដទៃទៀត យ៉ាងណាមិញ ជីវៈនោះ (ចេញពីកាយនេះ) ចូលទៅ កាន់កាយដទៃ យ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីផ្ទះ ចូលទៅ កាន់ផ្ទះដទៃ យ៉ាងណាមិញ ជីវៈនោះ ចូលទៅកាន់កាយដទៃទៀត ក៏យ៉ាងនោះដែរ ។ ពួកពាល ពួកបណ្ឌិត នឹងឆ្លងសង្សារវដ្តអស់ ទៅ ធ្វើទុក្ខឲ្យផុតបាន ពេលកន្លងអស់មហាកប្បទាំងឡាយ ៨ លាន ៤ សែន ។ សុខនិងទុក្ខទាំងឡាយ វាល់បានដោយទោណៈទាំងឡាយ ផង ដោយកញ្ច្រែងទាំងឡាយផង ជិនបុរស រមែងជ្រាបសព្វ ពួកសត្វ ក្រៅនេះប្រកបដោយសេចក្ដីវង្វេង ។ កាលមុន ខ្ញុំជាអ្នកយល់យ៉ាង នេះ ជាអ្នកប្រកបដោយសេចក្ដីវង្វេង មានសេចក្ដីវង្វេងគ្របសង្កត់

មិច្ឆាទិដ្ឋិ ច ទុស្សីលោ កទរិយោ បរិភាសកោ ។
ឆហិ មេ ឥតោ មាសេហិ កាលកិរិយា ភវិស្សតិ ។
ឯកន្តកដុកំ ឃោរំ និរយំ បបតិស្សហំ
ចតុក្កណ្ណំ ចតុទ្វារំ វិភត្តំ ភាគសោ មិតំ
អយោបាការបរិយន្តំ អយសា បដិកុជ្ជិតំ ។
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទា ។
វស្សសតសហស្សានិ ឃោសោ សុយ្យតិ តាវទេ ។
លក្ខោ ឯសោ មហារាជ សតភាគា វស្សកោដិយោ
កោដិសតសហស្សានិ និរយេ បច្ចរេ ជនា
មិច្ឆាទិដ្ឋី ច ទុស្សីលា យេ ច អរិយូបវាទិនោ ។
តត្ថាហំ ទីឃមទ្ធានំ ទុក្ខំ វេទិស្សំ វេទនំ
ផលំ បាបស្ស កម្មស្ស តស្មា សោចាមហំ ភុសំ ។
តំ សុណោហិ មហារាជ អរិន្ទម រដ្ឋវឌ្ឍន
ធីតា មយ្ហំ មហារាជ ឧត្តរា ភទ្ទមត្ថុ តេ ។
ករោតិ ភទ្ទកំ កម្មំ សីលេសុបោសថេ រតា
សញ្ញតា[១] សំវិភាគី ច វទញ្ញូ[២] វីតមច្ឆរា

១ ឱ. ម. សញ្ញតា ។ ២ ឱ. វទញ្ញា ។



មានសេចក្តីយល់ខុស ទ្រុស្តសីល កំណាញ់ ប្រទេចផ្តាសា (សមណៈនិងព្រាហ្មណ៍) ។ តាំងពីនេះទៅ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ។ ខ្ញុំមុខជានឹងធ្លាក់នរក មានការក្តៅក្រហាយដ៏ពន្លឹក ដោយពិត ជានរកមានជ្រុង ៤ មានទ្វារ ៤ ដូចជាកាត់ជាចំណែក ដែលចែកស្មើគ្នា ជានរកមានកំពែងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ភូមិនៃនរកនោះ ជាវិការៈនៃដែក ក្តៅព្រោលព្រាត ប្រកបដោយភ្លើង ផ្សាយផ្សព្វទៅ ១០០ យោជន៍ជុំវិញ សព្វកាល ។ កាលនឹងទៅ ១ សែនឆ្នាំ ឮសូរសំឡេងតែងតែរលឹង ក្នុងកាលនោះ ។ បពិត្រមហារាជ ចំណែកមួយសែនកោដិឆ្នាំ ជាគ្រឿងកំណត់ (អាយុរបស់សត្វដែលឆេះទៅក្នុងនរក) ពួកជនដែលជាមិច្ឆាទិដ្ឋិ ទ្រុស្តសីល តិះដៀលព្រះអរិយៈ តែងឆេះទៅក្នុងនរក អស់ ១ សែនកោដិឆ្នាំ ។ ខ្ញុំនឹងសោយទុក្ខវេទនាក្នុងនរកនោះ អស់កាលជាយូរអង្វែង (ព្រោះ) ផលនៃបាបកម្ម ហេតុនោះបានជាខ្ញុំសោកសៅជាក្រៃលែង ។ បពិត្រអរិន្ទមមហារាជ អ្នកចំរើននូវដែន ព្រះអង្គចូរស្តាប់ដំណើរនោះ បពិត្រមហារាជ ធីតារបស់ខ្ញុំ ឈ្មោះនាងឧត្តរា សេចក្តីចំរើនចូរមានដល់ព្រះអង្គ ។ នាងឧត្តរា តែងធ្វើនូវកម្មដ៏ចំរើន ជាអ្នកត្រេកអរក្នុងសីល និងឧបោសថសីល ត្រេកអរក្នុងទាន ជាអ្នកចែករំលែកទាន ជាអ្នកដឹងនូវពាក្យ (នៃស្មូម) មិនមានកំណាញ់

អខណ្ឌការី សិក្ខាយំ   សុណ្ហា បរកុលេសុ ច
ឧបាសិកា សក្យមុនិនោ   សម្ពុទ្ធស្ស សិរីមតោ ។
ភិក្ខុ ច សីលសម្បន្នោ   គាមំ បិណ្ឌាយ បាវិសិ
ឱក្ខិត្តចក្ខុ[១] សតិមា   គុត្តទ្វារោ សុសំវុតោ
សបទានំ ចរមានោ   អគមា តំ និវេសនំ ។
តមទ្ទស មហារាជ   ឧត្តរា ភទ្ទមត្ថុ តេ
បូរំ បានីយករកំ[២]   បូវេ ចិត្តេ ច សា អទា
បិតា មេ កាលកតោ ភន្តេ   តស្សេតំ ឧបកប្បតុ ។
សមនន្តរានុទ្ទិដ្ឋេ   វិបាកោ ឧទបជ្ជថ
ភុញ្ជាមិ កាមកាមី   រាជា វេស្សវណោ យថា ។
តំ សុណោហិ មហារាជ   អរិន្ទម រដ្ឋវឌ្ឍន
សទេវកស្ស លោកស្ស   ពុទ្ធោ អគ្គោ បវុច្ចតិ
តំ ពុទ្ធំ សរណំ គច្ឆ   សបុត្តទារោ[៣] អរិន្ទម ។
អដ្ឋង្គិកេន មគ្គេន   ផុសន្តិ អមតំ បទំ
តំ ធម្មំ សរណំ គច្ឆ   សបុត្តទារោ[៤] អរិន្ទម ។

១ ឱ. ឱក្ខិត្តចក្ខុ ។ ២ ឱ. បានីយស្ស ករកំ ។ ៣ ៤ ឱ. សបុត្តទារ ។



ធ្វើមិនឲ្យដាច់ក្នុងសិក្ខាបទ ជាកូនប្រសាក្នុងត្រកូលដទៃ ជាឧបាសិកានៃព្រះសក្យមុនីសម្ពុទ្ធមានសិរី ។ ភិក្ខុបរិបូណ៌ដោយសីល ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ជាអ្នកសង្រួមចក្ខុ មានស្មារតីគ្រប់គ្រងទ្វារ បិទបាំងកាយដោយប្រពៃ ត្រាច់ទៅតាមលំដាប់ត្រកូល បានទៅកាន់លំនៅរបស់នាងនោះ ។ បពិត្រមហារាជ សេចក្ដីចំរើនចូរមានដល់ព្រះអង្គ នាងឧត្តរា បានឃើញភិក្ខុនោះហើយ បានប្រគេនក្អមបានីយករក(ក្អមទឹក)ដ៏ពេញផង នំទាំងឡាយដ៏វិចិត្រផង (ហើយឧទ្ទិសផលមកឲ្យខ្ញុំយ៉ាងនេះថា) បពិត្រលោកដ៏ចំរើន បិតារបស់ខ្ញុំធ្វើមរណកាលទៅហើយ ទាននេះ សូមសម្រេចដល់បិតារបស់ខ្ញុំនោះ ។ ផលក៏សម្រេច ក្នុងពេលជាលំដាប់ ដែលឧទ្ទិសហើយ ខ្ញុំជាអ្នកបានកាមតាមប្រាថ្នា បរិភោគដូចជាស្ដេចវេស្សវ័ណ ។ បពិត្រអរិន្ទមមហារាជ ព្រះអង្គអ្នកចំរើនក្នុងដែន សូមព្រះអង្គស្ដាប់នូវដំណើរនោះ ព្រះពុទ្ធគេហៅថា បុគ្គលប្រសើរជាងសត្វលោកព្រមទាំងទេវលោក បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវព្រះពុទ្ធនោះជាសរណៈចុះ ។ ពួកបុរសបុគ្គលបានដល់ព្រះនិព្វាន ដោយសារតែមគ្គប្រកបដោយអង្គ ៨ ប្រការ បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវធម៌ (អដ្ឋង្គិកមគ្គ) នោះជាសរណៈចុះ ។

ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ
តំ សង្ឃំ សរណំ គច្ឆ សបុត្តទារោ[១] អធិដ្ឋហ ។

បាណាតិបាតា វិរមស្សុ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយស្សុ
អមជ្ជបោ នោ ច មុសា ភណាហិ
សកេន ទារេន ច ហោហិ តុដ្ឋោ ។

អត្ថកាមោសិ មេ យក្ខ ហិតកាមោសិ ទេវតេ
ករោមិ តុយ្ហំ វចនំ ត្វមសិ អាចរិយោ មម ។
ឧបេមិ សរណំ ពុទ្ធំ ធម្មញ្ចាបិ អនុត្តរំ
សង្ឃញ្ច នរទេវស្ស គច្ឆាមិ សរណំ អហំ ។

បាណាតិបាតា វិរមាមិ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយាមិ
អមជ្ជបោ នោ ច មុសា ភណាមិ
សកេន ទារេន ហោមិ តុដ្ឋោ ។

១ ម. សបុត្តទារេ ។



ព្រះអរិយបុគ្គល ៤ ពួក ប្រតិបត្តិក្នុងមគ្គ ព្រះអរិយបុគ្គល ៤ ពួកឋិតនៅក្នុងផល ព្រះសង្ឃនាំនុ៎ះ លោកជាអ្នកស្លូតត្រង់ តាំងនៅមាំក្នុងបញ្ញានិងសីល បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គព្រមទាំងព្រះរាជបុត្រា ព្រះអគ្គជាយា ដល់នូវព្រះសង្ឃនោះជាសរណៈចុះ ។

សូមព្រះអង្គ វៀរចាកបាណាតិបាត ឲ្យដាច់ សូមព្រះអង្គ វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ក្នុងលោក សូមព្រះអង្គ កុំសោយនូវទឹកស្រវឹង កុំមានព្រះឱស្ឋកុហក សូមព្រះអង្គត្រេកអរ តែនឹងព្រះអគ្គមហេសីរបស់ព្រះអង្គ ។

(ព្រះរាជាត្រាស់ថា) ម្នាលយក្ស អ្នកជាអ្នកប្រាថ្នាសេចក្តីចំរើនដល់យើង ម្នាលទេវតា អ្នកជាអ្នកប្រាថ្នាប្រយោជន៍ ដល់យើង យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យ របស់យើង ។ យើងសូមដល់ព្រះពុទ្ធជាសរណៈផង ដល់ព្រះធម៌ជាសរណៈផង ដល់ព្រះសង្ឃដ៏ប្រសើរជាងមនុស្សនិងទេវតា ជាសរណៈផង ។

យើងវៀរចាកបាណាតិបាត យ៉ាងដាច់ហើយ យើងលះបង់ការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ក្នុងលោក យើងវៀរនឹងផឹកទឹកស្រវឹង វៀរនិយាយកុហក យើងជាអ្នកត្រេកអរ តែនឹងប្រពន្ធ របស់ខ្លួន ។

និជ្ឈាមិ[1] មហាភាគេ  ឧតិយា ភ សិយលាមិយា
វិមាមិ ចាបកំ ទិដ្ឋិ  ញត្វាន សាសនេ រតា ។
ឥទំ វត្វាន សុរដ្ឋោ  វិរមិត្វា ចាបទស្សនំ
នមោ ករិត្វា តាត្វា  ចាមោទ្វោ រថមារុយ្ហតិ ។

នន្ទិកាបេតវត្ថុ តតិយំ ។

## ចតុត្ថំ រេវតិប្បេតវត្ថុ

(៣៩) ឧដ្ឋេហិ រេវតេ សុបាបធម្មេ

។ បេ ។

(វិមានវត្ថុស្មឹ បញ្ចមស្ស មហារថវគ្គស្ស ទុតិយវត្ថុស្មឹ ឧដ្ឋព្វំ)

រេវតិប្បេតវត្ថុ ចតុត្ថំ ។

## បញ្ចមំ ឧច្ឆុប្បេតវត្ថុ

(៤០) ឥទំ មម ឧច្ឆុវនំ មហន្តំ
និព្វត្តតិ បុញ្ញផលំ អនប្បកំ
តំ ទានិ មេ ន បរិភោគំ ឧបេតិ
អាចិក្ខ ភន្តេ កិស្ស អយំ វិបាកោ ។
វិហញ្ញាមិ ខជ្ជាមិ ច ភយាមិ ច
បរិសក្កាមិ បរិភុញ្ជិតុំ កិញ្ចិ

១ ឱ. និជ្ឈាមិ ។ ម. និព្ភាមិ ។



ម្នាលប្រេត យើងត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធទាំងឡាយ ចុះ (ខ្លួនឯងដឹងថាក្រក់ហោចដូចជាអង្កាម) ក្នុងទីមានខ្យល់ដ៏ផង បន្សាត់ហោច ខ្លួនឯងជាក្រក់ (ដូចជាសម្រាម) ក្នុងទន្លេ មានវិស្វទឹកហើយផង ។ លុះព្រះបាទបិង្គលៈ ជាស្តេចក្នុងដែនសុរដ្ឋ មានព្រះឱស្ឋដូច្នេះហើយក៏បាន វៀរចាកការយល់ខុសអាក្រក់ចោលចេញ ធ្វើនូវកិរិយាថ្វាយបង្គំព្រះមានព្រះភាគ រួចក៏បរព្រះរាជរថទៅកាន់ទីសឹងកើតឡើងគង់លើរថទៅ ។

ចប់ រឿងនន្ទិកាប្រេត ទី ៣ ។

## រឿងរេវតីប្រេត ទី ៤ ។

(៣៩) ម្នាលរេវតី ជាស្រីមានធម៌ដ៏លាមក ចូរក្រោកឡើង

។ បេ ។

រឿងរេវតីប្រេតទី ៤ នេះ សូមមើលក្នុងរឿងទី ២ នៃមហារថវគ្គទី ៥ ក្នុងវិមានវត្ថុចុះ ។

ចប់ រឿងរេវតីប្រេត ទី ៤ ។

## រឿងឧច្ឆុប្រេត ទី ៥

(៤០) (ប្រេតទូលសួរព្រះមោគ្គល្លានថា) ព្រៃអំពៅធំនេះកើតឡើងដល់ខ្ញុំ (ហាក់ដូច) ជាផលបុណ្យច្រើនណាស់ដែរ តែឥឡូវនេះខ្ញុំមិនបានបរិភោគអំពៅនោះសោះ បពិត្រលោកដ៏ចំរើន សូមលោកប្រាប់ខ្ញុំ តើផលនេះជាផលកម្មអ្វី ។ មួយទៀត ខ្ញុំដល់នូវសេចក្តីចង្អៀតចង្អល់ ចង់បរិភោគ (តែបរិភោគមិនកើត) ខ្ញុំទំប្រឹងខ្នះខ្នែងដើម្បីបរិភោគនូវសៅនៃអំពៅតិចតួច

ស្វាហំ ឆិន្នាតុរោ[១] កបណោ សាលជាមិ
តស្ស កម្មស្ស អយំ វិបាកោ ។
វិឃាតោ ទាហំ បរិបតាមិ ឆមាយំ
បរិវត្តាមិ វារិចរោវ ឃម្មេ
រុទតោ ច មេ អស្សុកានិ គលន្តិ[២]
អាចិក្ខ ភន្តេ កិស្ស អយំ វិបាកោ ។
ឆាតោ កិលន្តោ ច បិបាសិតោ ច
សំតាសិតោ សាតសុខំ ន វិន្ទេ
បុច្ឆាមិ តំ ឯតមត្ថំ ភទន្តេ
កថន្នុ ឧច្ឆុបរិភោគំ លភេយ្យំ ។
បុរេ តុវំ កម្មមកាសិ អត្តនា
មនុស្សភូតោ បុរិមាយ ជាតិយា
អហញ្ច តំ ឯតមត្ថំ វទាមិ
សុត្វាន ត្វំ ឯតមត្ថំ វិជាន ។
ឧច្ឆុំ តុវំ ខាទមានោ បយាតោ
បុរិសោ ច តេ បិដ្ឋិតោ អនុគច្ឆិ
សោ ច តំ បច្ចាសន្តោ កថេសិ

១ ម. ជិឃច្ឆាតុរោ ។ ២ ម. រុទតោ ច មេ អស្សុកា និគ្គលន្តិ ។



ខ្ញុំនោះមានអត្តភាពដាច់ហើយ ជាបុគ្គលកំសត់ ប្រកបដោយទុក្ខនេះ ជាផលនៃកម្មអ្វី ។ មួយទៀត ខ្ញុំជាបុគ្គលចង្អៀតចង្អល់ ដួលផ្ការផ្កាប់ទៀតលើផែនដី ដូចត្រីនៅលើគោកដ៏ក្តៅ ទឹកភ្នែកពិតខ្សួយរបស់ខ្ញុំ ហូរចេញអំពីចម្ងាយ បពិត្រលោកដ៏ចំរើន សូមលោកមេត្តាប្រាប់ នេះជាផលនៃកម្មអ្វី ។ ខ្ញុំឃ្លានផង លំបាកផង ស្រេកផង តក់ស្លុតផង មិនបានសេចក្តីសុខស្រួលទេ បពិត្រលោកដ៏ចំរើន ខ្ញុំសូមសួរសេចក្តីនុ៎ះ ចំពោះនឹងលោកម្ចាស់ ធ្វើម្តេចហ្ន៎ ខ្ញុំគប្បីបានបរិភោគអំពៅ(នេះ) ។

(ព្រះមោគ្គល្លានមានថេរកាថាថា) កាលពីដើម អ្នកកើតជាមនុស្សបានធ្វើបាបកម្មដោយខ្លួនឯង ក្នុងកាលមុន អាត្មារៀបរាប់សេចក្តីនោះប្រាប់អ្នក អ្នកស្តាប់ហើយត្រូវដឹងសេចក្តីនោះចុះ ។ (កាលនោះ) អ្នកកំពុងដើរស៊ីអំពៅ មានបុរសម្នាក់ដើរតាមក្រោយខ្នងអ្នក បុរសនោះ ប្រាថ្នាចង់បានអំពៅនោះ ហើយនិយាយសូម

តស្ស តុវំ ច កថំ អាលបិត្វា ។
សោ ច តំ អគណ្ហន្តំ អាយចិ[១]
ទេហយ្យ[២] ឧច្ឆុំ ច តំ អវោច
តស្ស តុវំ បិដ្ឋិតោ ឧច្ឆុំ អទាសិ
តស្សេតំ កម្មស្ស អយំ វិបាកោ ។
អជ្ជ ត្វំ គន្ត្វាន បិដ្ឋិតោ គណ្ហាយ្យាសិ[៣]
គហេត្វាន ខាទស្សុ យាវទត្ថំ
តេនេវ ត្វំ អត្តមនោ ភវិស្សសិ
ហដ្ឋោ ឧទគ្គោ ច បមោទិតោ ច ។
គន្ត្វាន សោ បិដ្ឋិតោ អគ្គហេសិ
គហេត្វាន តំ ខាទិ យាវទត្ថំ
តេនេវ សោ អត្តមនោ អហោសិ
ហដ្ឋោ ឧទគ្គោ ច បមោទិតោ ចាតិ[៤] ។

ឧច្ឆុបេតវត្ថុ អដ្ឋមំ ។

---

១ ម. អគណ្ហិ ។ ២ ម. ទេហិ ។ ឱ. ទេហយ្យ ។ ៣ ម. គន្ត្វា ត្វំ បិដ្ឋិតោ គណ្ហ ឧច្ឆុំ ។ ៤ ម. ហដ្ឋោ ឧទគ្គោ ច បមោទិតោ ចាតិ ។ ៥. ...





អ្នកមិនបាននិយាយពាក្យតិចតួច នឹងបុរសនោះទេ ។ ឯបុរសនោះបាននិយាយសូមចំពោះអ្នកដែលមិននិយាយកេ បាននិយាយនឹងអ្នកថា អ្នកចូរឲ្យអំពៅដល់ខ្ញុំ អ្នកក៏បានឲ្យអំពៅមួយដើម តាមក្រោយខ្នង ដល់បុរសនោះ នេះជាផលរបស់បាបកម្មនោះឯង ។ ហើយបើដូច្នោះ អ្នកចូរទៅចាប់អំពៅពីក្រោយខ្នងចុះ លុះចាប់បានហើយ ចូរស៊ីឲ្យឆ្អែតចុះ អ្នកនឹងមានចិត្តត្រេកអរ រីករាយ អណ្តែតឡើង ស្រោះស្រាយ ព្រោះតែបានទទួលអំពៅនោះ ។ បុរសនោះ ទៅចាប់យកអំពៅពីក្រោយខ្នងរបស់ខ្លួន លុះចាប់យកបានហើយ ក៏ស៊ីអំពៅនោះតាមតែឆ្អែតឆ្អន់ រួចបុរសនោះ មានចិត្តត្រេកអរ រីករាយ អណ្តែតឡើង ស្រោះស្រាយ ។

ចប់ រឿងឧច្ឆុប្រេតទី ៨ ។

## ឆដ្ឋំ កុមារបេតវត្ថុ

[៦១] សាវត្ថិ នាម នគរំ ហិមវន្តស្ស បស្សតោ
តត្ថាសុំ[១] ទ្វេ កុមារា រាជបុត្តាតិ មេ សុតំ ។
បមត្តា រជនីយេសុ[២] កាមស្សាទាភិនន្ទិនោ
បច្ចុប្បន្នេ សុខេ គិទ្ធា ន តេ បស្សឹសុនាគតំ ។
តេ ចុត្តា[៣] ច មនុស្សត្តា បរលោកំ ឥតោ គតា
តេធ[៤] ឃោសេន្តទិស្សន្តា បុព្វេ ទុក្កដមត្តនោ ។
ពហូសុ វត សន្តេសុ ទេយ្យធម្មេ ឧបដ្ឋិតេ
នាសក្ខិម្ហា ច អត្តានំ បរិត្តំ កាតុំ សុខាវហំ ។
កឹ តតោ បាបកំ អស្ស យំ នោ រាជកុលា ចុតា
ឧបបន្នា បេត្តិវិសយំ ខុប្បិបាសា សមប្បិតា ។
សាមិនោ ឥធ ហុត្វាន ហោន្តិ អស្សាមិនោ តហឹ
ចរន្តិ[៥] ខុប្បិបាសាយ មនុស្សា ឧន្នតោនតា ។

---

១ ឱ. តត្ថសុ ។ ម. តត្ថ អាសុំ ។ ២ ម. សម្មត្តា រជនីយេសុ ។ ៣ ឱ. ចុតា ច ។
ម. ចុតា តេ ។ ៤ ឱ. តេធ ។ ម. តេ ហិ ។ ៥ ឱ. ចរន្តិ ។ ម. ភមន្តិ ។



## រឿងកុមារប្រេត ទី ៦

(៦១) (ព្រះមានព្រះភាគត្រាស់ថា) នគរតែមួយក្រុងឈ្មោះ សាវត្ថី នៅក្បែរព្រហិមពាន្ត ក្នុងក្រុងនោះមានកុមារពីរនាក់ ជាព្រះរាជបុត្ររបស់ (ព្រះបាទបសេនទិកោសល) ។ ព្រះរាជបុត្រទាំងពីរអង្គនោះជាអ្នកប្រមាទ ជាអ្នកមានសេចក្តីត្រេកអរ ក្នុងកាមគុណទាំងឡាយជាទីត្រេកអរ ជាប់ចំពាក់នឹងសេចក្តីសុខជាបច្ចុប្បន្ន ព្រះរាជបុត្រទាំងនោះ មិនបានឃើញសេចក្តីសុខទៅក្នុងអនាគតកាលឡើយ ។ ព្រះរាជបុត្រទាំងនោះទៅកាន់លោកខាងមុខ ចាកអត្តភាពជាមនុស្ស ព្រះរាជបុត្រទាំងពីរនោះ មិនប្រាកដរូប ស្រែកប្រកាសតែអំពើអាក្រក់របស់ខ្លួនក្នុងកាលមុន ។ កាលទេយ្យធម៌ក្នុងបុគ្គលទាំងឡាយមានច្រើន កាលទេយ្យធម៌មាន ពួកយើងមិនអាចដើម្បីធ្វើខ្លួនឲ្យមានសួស្តីតិចតួច ជាទីនាំមកនូវសេចក្តីសុខនោះ ។ អំពើអាក្រក់អ្វី ជាអំពើអាក្រក់ជាងអំពើរបស់យើងនោះ ពួកយើងច្យុតចាករាជត្រកូលមកកើតជាប្រេតវិស័យ (ក្នុងទីនេះ) ប្រកបដោយសេចក្តីស្រេក នឹងការឃ្លាន ។ ពួកមនុស្សជាម្ចាស់នៅក្នុងលោកនេះ ពុំមែនជាម្ចាស់ក្នុងលោកឯណោះទៀតទេ បានខ្ពស់ហើយត្រឡប់ទាបវិញ (ព្រោះតណ្ហា) តែងស្ទាប់ដោយសេចក្តីស្រេកឃ្លាន ។

បាបមាចរិតំ ពហុំ   តស្សោទានសទ្ធិ
បហាយ តស្សមេធំ   កតា សគ្គគតោ ឥតោ
កាយស្ស ភេទា សប្បញ្ញោ   សគ្គំ សោ ឧបបជ្ជតីតិ ។

កុមារបេតវត្ថុ ឆដ្ឋំ ។

## សត្តមំ រាជបុត្តបេតវត្ថុ

(៦២) បុព្វេ កតានំ កម្មានំ   វិបាកោ មថយេ មនំ
រូបេ សទ្ទេ រសេ គន្ធេ   ផោដ្ឋព្វេ ច មនោរមេ ។
នច្ចំ គីតំ រតឹ ខិឌ្ឌំ   អនុភុត្វា អនប្បកំ
ឧយ្យានេ បរិចារិត្វា[១]   បវិសន្តោ គិរិព្វជំ ។
ឥសឹ សុនេត្តមទ្ទក្ខិ   អត្តទន្តំ សមាហិតំ
អប្បិច្ឆំ ហិរិសម្បន្នំ   ឧញ្ឆេ បត្តគតេ[២] រតំ ។
ហត្ថិក្ខន្ធតោ ឱរុយ្ហ   លទ្ធា ភន្តេតិ ច អវោ
តស្ស បត្តំ គហេត្វាន   ឧច្ចំ បគ្គយ្ហ ខត្តិយោ ។
ថណ្ឌិលេ[៣] បត្តំ ភិន្ទិត្វា   ហសមានោ អបក្កមិ
រញ្ញោ កិតវស្សាហំ បុត្តោ   កឹ មំ ភិក្ខុ ករិស្សសិ ។

១ ឱ. បរិចារេត្វាន ។ ២ ឱ. ឧញ្ឆេ បត្តាគតេ ។ ៣ ឱ. ថណ្ឌិលេ ។ ម. កុណ្ឌិលេ ។



នរជនដឹងទោស ដែលកើតអំពីសេចក្តីប្រកាន់ជាធំ យ៉ាងនេះហើយគប្បី លះនូវសេចក្តីស្រវឹងជាតិ ពោលពេញ ទើបទៅឋានសួគ៌ នរជននោះជា អ្នកប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយ រមែងកើតក្នុងឋានសួគ៌ ។

ចប់ រឿងកុមារប្រេត ទី ៦ ។

## រឿងរាជបុត្តប្រេត ទី ៧

(៦២) (ព្រះមានព្រះភាគត្រាស់សំដែងរឿងរាជបុត្តប្រេតនេះថា) ផលរបស់បាបកម្មទាំងឡាយ ដែលរាជបុត្រធ្វើហើយ ក្នុងកាលពីដើម គប្បីញាំញីនូវចិត្ត ព្រោះរូបសំឡេងក្លិនរស ផ្សព្វទីជាមនោរម្យ ។ រាជបុត្រ ចូលចិត្តនឹងការរាំ ការច្រៀង ការត្រេកអរ នឹងការលេងចំអក ឲ្យក្រៃលែងដ៏ច្រើន ដើរលេងក្នុងឧទ្យាន រួចចូលទៅក្នុងក្រុងរាជគ្រឹះវិញ ។ រាជបុត្រនោះ បានឃើញឥសី (ព្រះបច្ចេកពុទ្ធ) ឈ្មោះសុនេត្ត លោកមានចិត្តទូន្មានហើយ មានចិត្តតម្កល់មាំ ប្រាថ្នាតិច ប្រកបដោយហិរិ ត្រេកអរតែនឹងបិណ្ឌបាតក្នុងបាត្រដោយការស្វែងរក ។

ក្សត្រិយ៍ចុះពីកដំរីហើយសួរថា បពិត្រលោកដ៏ចំរើន បានបិណ្ឌបាតដែរឬទេ ហើយទទួលយកបាត្ររបស់លោក លើកឡើងឲ្យខ្ពស់ បោកបំបែកបាត្រលោកលើដីដើមផុយ ហើយសើចលេង ដើរចេញទៅ (និយាយថា) ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នែភិក្ខុ លោកនឹងធ្វើអ្វី ដល់ខ្ញុំ ។

តស្ស កម្មស្ស ផរុសស្ស វិបាកោ កដុកោ អហុ
យំ រាជបុត្តោ វេទេសិ និរយម្ហិ សមប្បិតោ ។
ឆឡេវ ចតុរាសីតិ វស្សានិ នហុតានិ ច
ភុសំ ទុក្ខំ និគច្ឆិត្ថោ និរយេ កតកិព្ពិសោ ។
ឧត្តានោបិ ច បច្ចិត្ថ និកុជ្ជោ វាមទក្ខិណោ
ឧទ្ធំ បាទោ ឋិតោ ចេវ ចិរំ ពាលោ អបច្ចថ ។
ពហូនិ វស្សសហស្សានិ បូគានិ នហុតានិ ច
ភុសំ ទុក្ខំ និគច្ឆិត្ថោ និរយេ កតកិព្ពិសោ ។
ឯតាទិសំ ខោ កដុកំ អប្បទុដ្ឋប្បទោសិនំ
បច្ចន្តិ បាបកម្មន្តា ឥសឹ អាសជ្ជ សុព្វតំ ។
សោ តត្ថ ពហុវស្សានិ វេទយិត្វា ពហុំ ទុក្ខំ
ខុប្បិបាសហតោ នាម បេតោ អាសិ តតោ ចុតោ ។
ឯតមាទីនវំ ញត្វា ឥស្សរមទសម្ភវំ
បហាយ ឥស្សរមទំ និវាតមនុវត្តយេ ។
ទិដ្ឋេវ ធម្មេ បាសំសោ យោ[1] ពុទ្ធេសុ សគារវោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតិ ។

រាជបុត្តបេតវត្ថុ សត្តមំ ។

១ ម. យោធ ។



ផលដ៏ក្តៅក្រហាយ របស់បាបកម្មដ៏អាក្រក់នោះឯង ដែលរាជបុត្រទទួល រងទុក្ខវេទនាក្នុងនរក ។ រាជបុត្របានធ្វើអំពើអាក្រក់ គឺដល់នូវសេចក្តីទុក្ខក្រៃលែងក្នុងនរក ប្រាំបួនសែន (៩០០.០០០) ឆ្នាំ ។ ជនពាលទុកជាផ្តេកផ្ងារក្តី ផ្កាប់ក្តី ឈ្មៀងទៅខាងឆ្វេង ខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏យូរ ។ ជនពាលបានធ្វើអំពើអាក្រក់ ក៏ទទួលទុក្ខដ៏ក្រៃលែង ក្នុងនរក ច្រើនពាន់ឆ្នាំផង ច្រើនហ្មឺនឆ្នាំផង ។ បុគ្គលអ្នកមានបាបកម្ម តែងទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ជាទុក្ខក្តៅផ្សា ប្រាកដដូច្នោះ ព្រោះតែប្រទូស្តនឹងឥសី អ្នកមិនបានប្រទូស្តមានវត្តល្អ ។ រាជបុត្រនោះទទួលនូវសេចក្តីទុក្ខដ៏ច្រើន ក្នុងនរកនោះ អស់ឆ្នាំទាំងឡាយដ៏ច្រើន ច្យុតចាកនរកនោះមក មកកើតជាប្រេត មានសេចក្តីស្រេកឃ្លាន បៀតបៀនហើយ ។ បុរសបុគ្គលដឹងទោស ជាដែនកើត នៃសេចក្តីស្រវឹង ព្រោះឥស្សរិយយស យ៉ាងនេះហើយ គប្បីលះបង់នូវសេចក្តីស្រវឹង ព្រោះតែឥស្សរិយយស ហើយប្រព្រឹត្តបន្ទាបបន្ទន់កាយ ។ ជនណាជាបុគ្គលដែលគេសរសើរក្នុងបច្ចុប្បន្ន ជាអ្នកគោរព ក្នុងព្រះពុទ្ធ ជននោះ ជាអ្នកប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយទៅ រមែងកើតក្នុងឋានសួគ៌ ។

ចប់ រឿងរាជបុត្តប្រេត ទី ៧ ។

## អដ្ឋមំ គូថខាទកប្បេតវត្ថុ

(៦៣) គូថកូបតោ ឧគ្គន្ត្វា កោ នុ ទិដ្ឋោ តិដ្ឋសិ[១]
និស្សំសយំ បាបកម្មន្តោ កិន្នុ សទ្ទហសេ តុវត្តិ[២] ។
អហំ ភទន្តេ[៣] បេតោម្ហិ ទុគ្គតោ យមលោកិកោ
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតោ ។
កិំ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន ឥទំ ទុក្ខំ និគច្ឆសិ ។
អហុ អាវាសិកោ មយ្ហំ ឥស្សុកី កុលមច្ឆរី
អជ្ឈោសិតោ[៤] មយ្ហំ ឃរេ កទរិយោ បរិភាសកោ ។
តស្សាហំ វចនំ សុត្វា ភិក្ខវោ បរិភាសិស្សំ
តស្ស កម្មវិបាកេន បេតលោកំ ឥតោ គតោ ។
អមិត្តោ មិត្តវណ្ណេន យោ តេ អាសិ កុលូបកោ
កាយស្ស ភេទា ទុប្បញ្ញោ កិន្នុ បេច្ច គតិំ គតោ ។

---

១ ឱ. ទីនោ តិដ្ឋសិ ។ ម. ទីនោ បតិដ្ឋសិ ។ ២ ម. សទ្ទហសេ តុវំ ។ ៣ ឱ. ភន្តេ ។
៤ ឱ. អជ្ឈោសិតោ ។



## រឿងគូថខាទកប្រេត ទី ៨

(៦៣) (ព្រះមោគ្គល្លានឃើញប្រេតនោះហើយ សួរថា) អ្នកដែលអាត្មាឃើញហើយ តើជាអ្វី ងើបអំពីរណ្តៅលាមក ហើយឈរនៅ អ្នកឯងជាបុគ្គលមានបាបកម្មឥតសង្ស័យ ហេតុអ្វីក៏ស្រែក ។

(ប្រេតតបថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

(ព្រះមោគ្គល្លានសួរថា) អំពើអាក្រក់ដូចម្តេច ដែលប្រេតឯងធ្វើហើយ ដោយកាយ វាចា ចិត្ត អ្នកឯងបានទទួលទុក្ខលំបាកនេះ ព្រោះផលបាបកម្ម ដូចម្តេច ។

(ប្រេតតបថា) លោកជាចៅអាវាសរបស់ខ្ញុំ ជាអ្នកច្រណែន ជាអ្នកកំណាញ់ត្រកូល ស្អិតស្អាញ ជេរប្រទេច នៅអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្មនៃការជេរនោះ បានជាខ្ញុំស្លាប់ពីលោកនេះទៅ ទៅកើតជាប្រេត ។

(ព្រះមោគ្គល្លានសួរថា) ភិក្ខុដែលមិនមែនជាមិត្រចូលទៅរកត្រកូលរបស់អ្នក ដោយតាំងខ្លួនជាមិត្រ ភិក្ខុអ្នកឥតប្រាជ្ញា លុះបែកធ្លាយនៃកាយ ស្លាប់ទៅ តើទៅកាន់គតិដូចម្តេច ក្នុងលោកខាងមុខ ។

តស្សាហំ បាបកម្មស្ស សីសេ តិដ្ឋាមិ មន្ទកោ
សោ ច បរិយាយំ បត្តោ មមេវ បរិចារកោ ។
យំ ភទន្តេ ហទន្តញ្ញេ(១) ឯតំ មេ ហោតិ ភោជនំ
អហញ្ច ខោ យំ ហទាមិ ឯតំ សោ ឧបជីវតីតិ ។

គូថខាទកបេតវត្ថុ អដ្ឋមំ ។

## នវមំ គូថខាទកបេតិវត្ថុ

(៦៦) គូថកូបតោ ឧគ្គន្ត្វា កា នុ ទីនា បតិដ្ឋសិ(២)
និស្សំសយំ បាបកម្មន្តា កិន្នុ សទ្ទហសេ តុវំ(៣) ។
អហំ ភទន្តេ បេតីម្ហិ ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតា ។
កិំ នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន ឥទំ ទុក្ខំ និគច្ឆសិ ។
អហុ អាវាសិកោ មយ្ហំ ឥស្សុកី កុលមច្ឆរី
អជ្ឈោសិតោ(៤) មយ្ហំ ឃរេ កទរិយោ បរិភាសកោ ។
តស្សាហំ វចនំ សុត្វា ភិក្ខវោ បរិភាសិស្សំ

១ ម. ហទន្តញ្ញេ ។ ២ ម. ទីនា បតិដ្ឋសិ ។ ៣ ម. សទ្ទហាសេ តុវំ ។ ៤ ម. អជ្ឈោសិតោ ។



(ប្រេតតបថា) ខ្ញុំឋិតនៅលើទីបំផុតនៃក្បាល នៃភិក្ខុអ្នកមានបាបកម្មនោះ ឯភិក្ខុអ្នកមានបាបកម្មនោះ ទៅកើតជាប្រេត ជាបរិចារករបស់ខ្ញុំ (នេះឯង)។ បពិត្រលោកដ៏ចំរើន ពួកជនឯទៀត បន្ទោបង់នូវវច្ចារៈណា វច្ចារៈនោះឯងជាភោជនរបស់ខ្ញុំ (រាល់ ១ ថ្ងៃ) ខ្ញុំបន្ទោបង់នូវវច្ចារៈណា ភិក្ខុចៅអាវាសនោះ ចិញ្ចឹមជីវិតដោយវច្ចារៈនោះ (រាល់ ១ ថ្ងៃ) ។

ចប់ រឿងគូថខាទកប្រេត ទី ៨ ។

## រឿងគូថខាទកប្រេត ទី ៩

(៦៦) (ព្រះមោគ្គល្លានបានឃើញស្រីប្រេតហើយសួរថា) នាងឯងដែលគេឃើញហើយ តើជាអ្វី ឡើងអំពីរណ្តៅអាចម៍ ហើយឋិតនៅ នាងឯងមានបាបកម្មដោយឥតសង្ស័យ ហេតុអ្វីបានជាស្រេក ។

(នាងប្រេតនោះតបថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាស្រីប្រេត ជាអ្នកទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ហើយច្យុតចាកមនុស្សលោកនេះ ទៅកាន់បេតលោក ។

(ព្រះមោគ្គល្លានសួរថា) អំពើអាក្រក់ដូចម្តេច ដែលនាងធ្វើហើយ ដោយកាយ វាចា ចិត្ត បានជានាងដល់នូវទុក្ខនេះ ព្រោះផលកម្មអ្វី ។

(ស្រីប្រេតតបថា) លោកចៅអាវាសរបស់ខ្ញុំ ជាអ្នកប្រច្រណែន កំណាញ់ត្រកូល ស្អិតស្អាញ ជេរប្រទេច ការស្រឡាញ់នៅក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ

តស្ស កម្មវិបាកេន  បេតលោកំ ឥតោ គតា ។
អមិត្តោ មិត្តវណ្ណេន[១]  យោ តេ អាសិ កុលូបកោ
កាយស្ស ភេទា ទុប្បញ្ញោ  កិន្នុ បេច្ច គតឹ គតោ ។
តស្សេវាហំ បាបកម្មស្ស  សីសេ តិដ្ឋាមិ មត្ថកេ
សោ ច បរវិសយំ បត្តោ  មមេវ បរិចារកោ ។
យំ ភទន្តេ ហនន្តញ្ញេ  ឯតំ មេ ហោតុ ភោជនំ
អហញ្ច ខោ យំ ហនាមិ  ឯតំ សោ ឧបជីវតិ ។

គូថខាទកបេតវត្ថុ នវមំ ។

## ទសមំ គណបេតវត្ថុ

(៤៨) នគ្គា ទុព្វណ្ណរូបាត្ថ  កិសា ធមនិសន្ថតា
ឧប្ផាសុលិកា[២] កិសកា  កេ នុ តុម្ហេត្ថ មារិសា ។
មយំ ភទន្តេ បេតម្ហា  ទុគ្គតា យមលោកិកា
បាបកម្មំ ករិត្វាន  បេតលោកំ ឥតោ គតា ។

១ ម. មិត្តរូបេន ។ ២ ម. ឧប្ផាសុឡិកា ។



ព្រោះហេតុតែផលកម្ម នៃការជេរនោះ បានជាខ្ញុំស្លាប់ពីលោកនេះ ទៅកាន់បេតលោក ។

(ព្រះមោគ្គល្លានសួរថា) ចុះភិក្ខុដែលមិនមែនជាមិត្តអ្នកចូលទៅកាន់ត្រកូលរបស់នាង ដោយភេទដូចជាមិត្ត ភិក្ខុអ្នកឥតប្រាជ្ញានោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តើទៅកាន់គតិដូចម្តេច ក្នុងបរលោក ។

(ស្រីប្រេតតបថា) ខ្ញុំឋិតនៅលើទីបំផុតនៃក្បាល របស់ភិក្ខុអ្នកមានបាបកម្មនោះ ទៅកើតជាប្រេត ហើយជាបរិចារិការបស់ខ្ញុំ ។ បពិត្រលោកដ៏ចំរើន ពួកជនឯទៀត ៗ បន្ទោបង់នូវវច្ចៈណា វច្ចៈនោះឯង ទៅជាភោជនរបស់ខ្ញុំ (រាល់ៗថ្ងៃ) ខ្ញុំបន្ទោបង់នូវវច្ចៈណា ភិក្ខុនៅអាស្រ័យនោះ ចិញ្ចឹមជីវិតនឹងវច្ចៈនោះ(រាល់ៗថ្ងៃ) ។

ចប់ រឿងគូថខាទកប្រេត ទី ៩ ។

## រឿងគណប្រេត ទី ១០

(៤៨) (ព្រះមោគ្គល្លានសួរថា) នែអ្នកទាំងពួង អ្នកទាំងឡាយមានកាយអាក្រាត មានសរីរៈមានសម្បុរមិនល្អ ស្គមរីងដោយសរសៃ មានឆ្អឹងជំនីរ លេចឡើង តើអ្នកទាំងឡាយ ជាអ្វី ។

(ពួកប្រេតតបថា) បពិត្រលោកដ៏ចំរើន យើងខ្ញុំជាប្រេតទុគ៌តកើតក្នុងយមលោក លះបង់លោកនេះ ទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ។

តេ ច កាយេន វាចាយ មនសា ទុក្កដំ កតំ
តស្ស កម្មវិបាកេន បេតលោកំ ឥតោ គតា ។
អនវជ្ជេសុ(១) តិត្ថេសុ វិចិនិម្ហឌ្ឍមាសកំ
សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ ។
នទី ឧបេម តសិតា រិត្តកា បរិវត្តតិ
ឆាយំ ឧបេម ឧណ្ហេសុ អាតបោ បរិវត្តតិ ។
អគ្គិវណ្ណោ ច នោ វាតោ ឌហន្តោ ឧបវាយតិ
ឯតញ្ច ភន្តេ អរហាម អញ្ញញ្ច បាបកំ តតោ ។
អបិ(២) យោជនានិ គច្ឆាម ឆាតា អាហារគិទ្ធិនោ
អលទ្ធាវ និវត្តាម អហោ នោ អប្បបុញ្ញតា ។
ឆាតា បមុច្ឆិតា ភន្តា ភូមិយំ បដិសុម្ភិតា
ឧត្តានា បដិកិរាម អវកុជ្ជា បតាមសេ ។
តេ ច តត្ថេវ បតិតា ភូមិយំ បដិសុម្ភិតា
ឧរំ សីសញ្ច ឃដ្ដេម អហោ នោ អប្បបុញ្ញតា ។

---

១ ម. ភពាវជ្ជេសុ ។ ២ ម. អតិ ។



(ព្រះមោគ្គល្លានសួរថា) ចុះអ្នកអស់គ្នា បានធ្វើអំពើអាក្រក់ដូចម្តេច ដោយកាយ វាចា ចិត្ត លះលោកនេះ ទៅកាន់បេតលោក ព្រោះផលកម្មអ្វី ។

(ពួកប្រេតទូលថា) ពួកយើងបានរើសទ្រព្យកន្លះមាសក នៅត្រង់កំពង់ទឹកដែលឥតទោស (គ្មានម្ចាស់ថែរក្សា) នាកាលទេយ្យធម៌ទាំងឡាយមាន ពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ពួកយើងជាបុគ្គលស្រេកទឹក នាំគ្នាចូលទៅកាន់ស្ទឹង ទើបស្ទឹងនោះក៏ខ្វះប្រែទៅជាស្ងួតទទេ ក្នុងកាលក្តៅ ពួកយើងនាំគ្នាចូលទៅកាន់ម្លប់ ម្លប់នោះក៏ខ្វះប្រែទៅជាកំដៅដ៏ក្តៅវិញ ។ ខ្យល់មានសណ្ឋានដូចជាភ្លើងដ៏ក្តៅ បក់មករកពួកយើង បពិត្រលោកដ៏ចំរើន ពួកយើងទទួលនូវបាបកម្មនោះផង ទទួលនូវបាបកម្មដទៃអំពីនោះផង ។

ទុកជាពួកយើង ដើរទៅកាន់យោជន៍ទាំងឡាយ ជាបុគ្គលឃ្លាន ចង់ស៊ីអាហារក៏រកទទួលបានមិនបាន ហើយក៏ត្រឡប់វិលវិញដោយគិតថា ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចំរើន ពួកយើងជាបុគ្គលឃ្លានច្រុលច្រប់ ដួលដេកលើផែនដី បម្រះខ្ទៀល ផ្ងារផ្កាប់ លើផែនដី ។ លុះពួកយើងដួលទៅក្នុងទីនោះហើយ ក៏ក្រោកឡើង ដួលប្រែទៅលើផែនដីនោះវិញ ទើបទន្ទិចដើមទ្រូងផង ទន្ទិចក្បាលផង ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។

ឯកញ្ញ ករេន្ត អរហាម   អញ្ញញ្ញ ទាយកំ សកោ
សន្តេសុ ទេយ្យធម្មេសុ   ទីបំ នាកម្ហ អត្តនោ ។
តេ ហិ នូន ឥតោ គន្ត្វា   យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នា   កាហាម កុសលំ ពហុន្តិ ។

គណប្បេតវត្ថុ ទសមំ ។

## ឯកាទសមំ បាដលិបុត្តប្បេតវត្ថុ

(៤៦) ទិដ្ឋា តយា និរយា តិរច្ឆានយោនី
បេតា អសុរា អថាបិ មនុស្សទេវា[១]
សយមទ្ទស កម្មវិបាកមត្តនោ
នេស្សាមិ តំ បាដលិបុត្តមក្ខតំ
តត្ថ គន្ត្វា កុសលំ ករោហិ កម្មន្តិ ។
អត្ថកាមោសិ មេ យក្ខ   ហិតកាមោសិ ទេវតេ
ករោមិ តុយ្ហំ វចនំ   ត្វមសិ អាចរិយោ មម ។

១ ម. អថ មានុសាទេវា ។



បពិត្រលោកដ៏ចំរើន ពួកយើងនឹងទទួល នូវបាបកម្មនោះនៃខ្លួននូវបាបកម្មដែលកើតនោះផង ព្រោះកាលទេយ្យធម៌កំពុងមាន ពួកយើងមិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ។ បើដូច្នោះពួកយើង លុះឃ្លាតចាកប្រេតនេះទៅ សូមបានកើតជាមនុស្ស ជាអ្នកបរិច្ចាគ ដោយសីល ធ្វើកុសលឲ្យបានច្រើន អំពីជាតិនេះទៅ ។

ចប់ រឿងគណប្រេត ទី ១០ ។

## រឿងបាដលិបុត្តប្រេត ទី ១១

(៤៦) (ទេវតានិយាយថា) ពួកសត្វនរកក្តី ពួកកំណើតតិរច្ឆានក្តី ពួកប្រេតក្តី ពួកអសុរក្តី ពួកមនុស្សនិងទេវតាក្តី អ្នកបានឃើញហើយ អ្នកបានឃើញផលកម្ម ដែលខ្លួនបានធ្វើហើយដោយខ្លួនឯងហើយ ខ្ញុំនឹងនាំអ្នកទៅបាដលិបុត្រ មិនមានអន្តរាយអ្វីបាន បើអ្នកទៅដល់បាដលិបុត្រនោះហើយ ចូរធ្វើកុសលកម្មចុះ ។

(អ្នកនោះតបថា) បពិត្រយក្ស អ្នកជាបុគ្គលប្រាថ្នាប្រយោជន៍ដល់ខ្ញុំ បពិត្រទេវតា អ្នកជាបុគ្គលប្រាថ្នា សេចក្តីចំរើនដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ។

ទិដ្ឋា មយា និរយា តិរច្ឆានយោនី
បេតា អសុរា អបិ មនុស្សទេវា
សយមទ្ទសំ កម្មវិបាកមត្តនោ
កាហាមិ បុញ្ញានិ អនប្បកានិ ។

ចូឡសេដ្ឋិបេតវត្ថុ ឯកាទសមំ ។

## ទ្វាទសមំ អម្ពវនបេតវត្ថុ

(៤៧) អយញ្ច តេ បោក្ខរណី សុរម្មា
សមា សុប្បតិត្ថា ច មហោទកា ច
សុបុប្ផិតា[1] ភមរគណានុកិណ្ណា
កថំ តយា លទ្ធា អយំ មនុញ្ញា ។
ឥទញ្ច តេ អម្ពវនំ សុរម្មំ
សព្វោតុកំ ធារយតិ ផលានិ
សុបុប្ផិតំ ភមរគណានុកិណ្ណំ
កថំ តយា លទ្ធមិទំ វិមានំ ។
អម្ពបក្កោទកំ យាគុ សីតច្ឆាយំ មនោរមំ[2]
ធីតាយ ទិន្នទានេន តេន មេ ឥធ លព្ភតិ ។
សន្ទិដ្ឋិកំ ឯវំ បស្សថ ទានស្ស

---
១ ឱ. សំបុប្ផិតា ។ ២ ឱ. ម. សីតច្ឆាយា មនោរមា ។



ពួកសត្វនរកក្តី ពួកតិរច្ឆានក្តី ពួកប្រេតក្តី ពួកអសុរក្តី ពួកមនុស្សនិងទេវតាក្តី ខ្ញុំបានឃើញហើយ ខ្ញុំបានឃើញផលកម្មរបស់ខ្លួនដោយខ្លួនឯង ខ្ញុំនឹងធ្វើបុណ្យទាំងឡាយឲ្យច្រើន ។

ចប់ រឿងចូឡសេដ្ឋិប្រេត ទី ១១ ។

## រឿងអម្ពវនប្រេត ទី ១២

(៤៧) (ពួកពាណិជសួរថា) ស្រះបោក្ខរណីរបស់នាងនេះ ជាទីត្រេកអរដោយប្រពៃផង មានផ្ទៃរាបស្មើផង មានកំពង់ល្អផង មានទឹកច្រើនផង មានផ្ការីកល្អផង មានហ្វូងកន្ធំហើររៀលត្បាត់ផង ស្រះបោក្ខរណី ជាទីពេញចិត្តនេះ នាងបានដោយហេតុដូចម្តេច ។ មួយទៀត អម្ពវនរបស់នាងនេះ ជាទីត្រេកអរ ដោយប្រពៃផង កាន់ផ្លែគ្រប់រដូវផង មានផ្ការីកជានិច្ច មានហ្វូងកន្ធំច្រើន ពោមរោមផង វិមាននេះ នាងបានមក ដោយហេតុអ្វី ។ (មាតិកប្រេតតបថា) ខ្ញុំបានស្រះបោក្ខរណីជាទីត្រេកអរនិងអម្ពវនវិមានជាទីត្រេកអរនេះ ព្រោះតែធីតារបស់ខ្ញុំបានប្រគេនទឹកស្វាយទុំនិងបបរ ទីម្លប់ដ៏ត្រជាក់ ជាទីត្រេកអរ ក្នុងទីនេះ ។

ធមស្ស សំយមស្ស វិបាកំ

ទាសី អហំ អយ្យកុលេសុ ហុត្វា

សុណិសា ហោមិ អគារស្ស ឥស្សរាតិ ។

អសាតំ សាតរូបេន បិយរូបេន អប្បិយំ

ទុក្ខំ សុខស្ស រូបេន បមត្តំ អតិវត្តតីតិ ។

ឧត្តរបេតវត្ថុ ទ្វាទសមំ ។

## តេរសមំ អក្ខរុក្ខបេតវត្ថុ

(៤៨) យំ ទទាតិ ន តំ ហោតិ ទេថេវ ទានំ ទត្វាន

ឧភយំ តរតិ ឧភយំ តេន ទានេន គច្ឆតិ

ជាគរថ មា បមជ្ជថាតិ ។

អក្ខរុក្ខបេតវត្ថុ តេរសមំ ។



(ពីតាពោលថា) ចូរអ្នកសំឡឹងមើលផលរបស់ទាន និងការទូន្មានខ្លួនក្នុងឥន្ទ្រិយ និងការសង្រួមដែលឃើញច្បាស់ ដោយខ្លួនឯង ខ្ញុំ (តែដើម) ជាទាសី ឥឡូវបានជាកូនប្រសាស្រីក្នុងត្រកូលរបស់លោក និងជាធំត្រួតត្រាផ្ទះ របស់លោក ។ (ថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ប្រមើលមើលឃើញចរិតអធ្យាស្រ័យនៃស្រីនោះហើយ ត្រាស់ថា) របស់ដែលមិនត្រេកអរ រមែងប្រព្រឹត្តកន្លងនូវបុគ្គលអ្នកប្រមាទ ដោយសភាពនៃរបស់ជាទីត្រេកអរ របស់ដែលមិនស្រឡាញ់ រមែងប្រព្រឹត្តកន្លងនូវបុគ្គលអ្នកប្រមាទដោយសភាពនៃរបស់ជាទីស្រឡាញ់ ទុក្ខតែងប្រព្រឹត្តកន្លងនូវបុគ្គលអ្នកប្រមាទដោយសភាពនៃសេចក្តីសុខ ។

ចប់ រឿងឧត្តរប្រេត ទី ១២ ។

## រឿងអក្ខរុក្ខប្រេត ទី ១៣

(៤៨) (កុមារទេវតានិយាយថា) បុរសបុគ្គលឲ្យរបស់ណា របស់នោះ មិនមាន (ផលត្រឹមតែប៉ុណ្ណោះ) ទេ បុគ្គលគប្បីឲ្យទាន លុះឲ្យទានហើយ រមែងឆ្លងនូវទុក្ខទាំងពីរយ៉ាង (ទុក្ខក្នុងបច្ចុប្បន្ន និងបរលោក) រមែងបាននូវសុខទាំងពីរ ព្រោះតែទាននោះ ចូរអ្នកភ្ញាក់ឡើង ចូរអ្នកកុំធ្វេសប្រហែស (ក្នុងទាន) ឡើយ ។

ចប់ រឿងអក្ខរុក្ខប្រេត ទី ១៣ ។

## ចុទ្ទសមំ ភោគសំហរបេតវត្ថុ

(៦៩) មយំ ភោគេ សំហរិម្ហ សមេន វិសមេន ច
តេ អញ្ញេ បរិភុញ្ជន្តិ មយំ ទុក្ខស្ស ភាគិនី ។

ភោគសំហរបេតវត្ថុ ចុទ្ទសមំ ។

## បណ្ណរសមំ សេដ្ឋិបុត្តបេតវត្ថុ

(៧០) សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។
នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ
តថា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស[១] ។
ទុជ្ជីវិតមជីវិម្ហ យេ សន្តេ ន ទទម្ហសេ[២]
សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ ។
សោ ហិ[៣] នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុន្តិ ។

សេដ្ឋិបុត្តបេតវត្ថុ បណ្ណរសមំ ។

---

១ ឱ. តទា បកតំ បាបំ តុយ្ហំ មយ្ហញ្ច មារិសា ។ ២ ឱ. ទេសំ តេ ន ទទិម្ហសេ ។
៣ ឱ. សោហំ ។



## រឿងភោគសំហរប្រេត ទី ១៤

(៦៩) (ពួកស្រីប្រេតប្រាប់ថា) ពួកយើងបានប្រមូលភោគៈទាំងឡាយដោយសមខ្លះ ដោយមិនសមខ្លះ ពួកជនឯទៀតតែងបរិភោគភោគៈទាំងនោះ ឯពួកយើងគ្រាន់តែបានចំណែកនៃសេចក្តីទុក្ខ ។

ចប់ រឿងភោគសំហរប្រេត ទី ១៤ ។

## រឿងសេដ្ឋិបុត្តប្រេត ទី ១៥

(៧០) (ពួកសត្វនរកប្រាប់ថា) ពួកយើងឆេះនៅក្នុងនរកពេញប្រាំមួយម៉ឺន(៦០.០០០)ឆ្នាំគ្រប់គ្រាន់ហើយ ទីបំផុតនឹងមានក្នុងវេលាណា ។ ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាកដដល់យើងឡើយ ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។ ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន យើងមិនបានឲ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួនសោះ ។ ប្រសិនបើខ្ញុំ បានចេញរួចអំពីនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិច្ចាគដោយសីល ធ្វើកុសលឲ្យច្រើន អំពីកាលនោះទៅ ។

ចប់ រឿងសេដ្ឋិបុត្តប្រេត ទី ១៥ ។

## សោឡសមំ សដ្ឋិកូដសហស្សបេតវត្ថុ

(៥៧) កិន្នុ ឧម្មត្តរូបោវ មិគោ ភន្តោវ ធាវសិ
និស្សំសយំ បាបកម្មំ កិន្នុ សទ្ទាយសេ តុវំ ។
អហំ ភន្តេ បេតោម្ហិ ទុគ្គតោ យមលោកិកោ
បាបកម្មំ ករិត្វាន បេតលោកំ ឥតោ គតោ ។
សដ្ឋី កូដសហស្សានិ បរិបុណ្ណានិ សព្វសោ
សីសេ មយ្ហំ និបតន្តិ តេ ភិន្ទន្តិ ច មត្ថកំ ។
កិន្នុ កាយេន វាចាយ មនសា ទុក្កដំ កតំ
កិស្ស កម្មវិបាកេន បេតលោកំ ឥតោ គតោ[១] ។
សដ្ឋី កូដសហស្សានិ បរិបុណ្ណានិ សព្វសោ
សីសេ តុយ្ហំ និបតន្តិ តេ ភិន្ទន្តិ ច មត្ថកំ ។
អទ្ទសាសឹ សម្ពុទ្ធំ សុនេត្តំ ភាវិតិន្ទ្រិយំ
និសិន្នំ រុក្ខមូលស្មឹ ឈាយន្តំ អកុតោភយំ ។
សាលិត្តកប្បហារេន ភិន្ទិស្សំ តស្ស[២] មត្ថកំ
តស្ស កម្មវិបាកេន ឥទំ ទុក្ខំ និគច្ឆិសំ ។

១ ម. គតំ ទុក្ខំ និគច្ឆសីតិ ទិស្សតិ ។ ២ ឱ. ចេ ភិន្ទិស្សន្តស្ស ។



## រឿងសដ្ឋិកូដសហស្សប្រេត ទី ១៦

(៥៧) (ថ្ងៃមួយព្រះមោគ្គល្លានសួរថា) ហេតុអ្វីអ្នកដូចមនុស្សឆ្កួត ស្ទុះទុះស្ទុះឡើង ដូចម្រឹគភ្ញាក់ផ្អើល អ្នកមានបាបកម្មមិនមានសង្ស័យ ហេតុអ្វី ក៏អ្នកស្រែក ។

(ប្រេតតបថា) បពិត្រលោកដ៏ចំរើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ។ មានញញួរដែកពេញចំនួនប្រាំមួយហ្មឺន (៦០.០០០) ដ៏គ្រប់គ្រាន់ តែងធ្លាក់លើក្បាល របស់ខ្ញុំ ញញួរដែកទាំងនោះ ទំលាយខួរក្បាលរបស់ខ្ញុំ ។

(ព្រះមោគ្គល្លានសួរថា) ចុះអ្នកបានធ្វើអំពើអាក្រក់ដោយកាយ វាចា ចិត្តដូចម្ដេច បានជាអ្នកលះលោកនេះ ទៅកើតក្នុងបេតលោក ព្រោះផលកម្មអ្វី ។ ញញួរដែកពេញប្រាំមួយហ្មឺន (៦០.០០០) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះវាយទំលាយក្បាល ។

(ប្រេតតបថា) កាលណោះ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមសុនេត្ត លោកមានឥន្ទ្រិយចំរើន ដោយអរិយមគ្គ គង់ក្រោមម្លប់ឈើ លោកមានឈាន ឥតមានភ័យភិតមកពីទីណាទេ ។ ខ្ញុំបាញ់ទំលាយព្រះកេសលោក ដោយការប្រហារដោយគ្រួស សេចក្ដីទុក្ខនេះ សម្រេចដល់ខ្ញុំ ព្រោះតែផលកម្មនៃការប្រហារនោះ ។

សដ្ឋី កូដសហស្សានិ បរិបុណ្ណានិ សព្វសោ
សីសេ មយ្ហំ និបតន្តិ តេ ភិន្ទន្តិ ច មត្ថកន្តិ ។
ធម្មេន តេ កាបុរិស
សដ្ឋី កូដសហស្សានិ បរិបុណ្ណានិ សព្វសោ
សីសេ តុយ្ហំ និបតន្តិ តេ ភិន្ទន្តិ ច មត្ថកន្តិ ។

សដ្ឋិកូដសហស្សបេតវត្ថុ សោឡសមំ ។

## ឧទ្ទានំ

អម្ពសក្ខរោ សេរិស្សកោ ច បិង្គលោ រេវតី ឧច្ឆុខាទកោ
ទ្វេ កុមារា ទ្វេ គូថខាទកា គណបាដលិពោក្ខរណី ច
អក្ខោ ភោគសំហារា សេដ្ឋិបុត្តា សដ្ឋីកូដសហស្សានិ
វគ្គោ តេន បវុច្ចតីតិ[១] ។

មហាវគ្គោ ចតុត្ថោ ។

បេតវត្ថុ សមត្តំ ។

---

១ ម. អម្ពសក្ខរ សេរីសកោ បិង្គលោ រេវតិ ឧច្ឆុ-
ខាទកា ទ្វេ កុមារា ទ្វេ គណបាដលិពោក្ខរណី ។
អក្ខរុក្ខភោគសំហារា សេដ្ឋិបុត្តសាលិត្តកា
សដ្ឋីកូដសហស្សានិ វគ្គោ តេន បវុច្ចតិ ។
ឧរគោ ឧបរិវគ្គោ ចូឡមហាតិ ចតុធា
វណ្ណនា ចតុធា ភាណវារតោតិ ។
ភាណំ វីសតិ ។ ម. ននំ ភាណំ ៥ វីសតិ ។



(ព្រោះហេតុនោះ) បានជាញញួរដែកពេញប្រាំមួយហ្មឺន(៦០.០០០) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះវាយទំលាយក្បាល របស់ខ្ញុំ ។

(ព្រះមោគ្គល្លានតបថា) ម្នាលបុរសកំព្រក់ សមតាមសេចក្តីប្រព្រឹត្តរបស់អ្នកហើយ គ្រប់ដែលញញួរដែក ពេញប្រាំមួយហ្មឺន (៦០,០០០) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះក៏វាយទំលាយក្បាល របស់អ្នក ។

ចប់ រឿងសដ្ឋិកូដសហស្សប្រេត ទី ១៦ ។

## ឧទ្ទាន នៃមហាវគ្គ ទី ៤ នោះគឺ

និយាយអំពីរឿងអម្ពសក្ខរប្រេត ១ សេរិស្សកប្រេត ១ នន្ទិកា-ប្រេត ១ រេវតីប្រេត ១ ឧច្ឆុខាទកប្រេត ១ កុមារប្រេត ១ រាជបុត្តប្រេត ១ គូថខាទកប្រេតពីរលើក គណប្រេត ១ បាដលិបុត្តប្រេត ១ អម្ពវនប្រេត ១ អក្ខរុក្ខប្រេត ១ ភោគសំហារប្រេត ១ សេដ្ឋិបុត្តប្រេត ១ សដ្ឋិកូដសហស្សប្រេត ១ ហេតុនោះ បានជាលោកហៅថា វគ្គ ។

ចប់ មហាវគ្គ ទី ៤ ។

ចប់ បេតវត្ថុ ។

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស ថេរគាថា

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(១) សីហានំវ នទន្តានំ ទាឋីនំ គិរិគព្ភរេ
សុណាថ ភាវិតត្តានំ គាថា អត្ថុបនាយិកា[១]
យថានាមា យថាគោត្តា យថាធម្មវិហារិនោ
យថាធិមុត្តា សប្បញ្ញា វិហរឹសុ អតន្ទិតា
តត្ថ តត្ថ វិបស្សិត្វា ផុសិត្វា អច្ចុតំ បទំ
កតន្តំ បច្ចវេក្ខន្តា ឥមមត្ថំ អភាសិសុំ ។

### ឯកនិបាតោ

## ថេរគាថាយ ឯកនិបាតស្ស បឋមវគ្គោ

(២) ឆន្នា មេ កុដិកា សុខា និវាតា វស្ស ទេវ យថាសុខំ ចិត្តំ មេ សុសមាហិតំ វិមុត្តំ អាតាបី វិហរាមិ វស្ស ទេវាតិ ។ ឥត្ថំ សុទំ[២] អាយស្មា សុភូតិ ថេរោ គាថំ អភាសិត្ថាតិ ។

---

១ ឱ. ម. អត្ថុបនាយិកា ។ ២ អដ្ឋកថាយម្បន សុទំ ទិស្សតិ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ថេរគាថា

សូមនមស្ការ ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ។

(១) អ្នកទាំងឡាយ ចូរស្តាប់នូវគាថាទាំងឡាយ ប្រកបដោយប្រយោជន៍ របស់ព្រះថេរៈទាំងឡាយ អ្នកមានចិត្តអប់រំហើយ កាលបន្លឺឡើង ដូចជាសីហៈជាសត្វមានចង្កូម ដែលបន្លឺទៀបគុហានៃភ្នំ ព្រះថេរៈទាំងឡាយ តាមនាម តាមគោត្រ តាមវិហារធម៌ តាមអធ្យាស្រ័យ ប្រកបដោយប្រាជ្ញា ជាបុគ្គលមិនខ្ជិលច្រអូស ចំរើនវិបស្សនា ក្នុងទីនោះ ៗ បានពាល់ត្រូវអច្ចុតបទ គឺព្រះនិព្វាន ពិចារណានូវគុណសម្បត្តិ ដែលលោកបានធ្វើស្រេចហើយ បានសំដែងហើយនូវសេចក្ដីដូចតទៅនេះ

### ឯកនិបាត

## ថេរគាថា ឯកនិបាត បឋមវគ្គ

(២) ខ្ទមក្បៀន របស់អាត្មា បានបិទបាំងហើយ ជាសុខ មិនមានខ្យល់ អ្នកចូរបង្អុរតាមសប្បាយចុះ ចិត្តរបស់អាត្មា ដម្កល់ទុកល្អហើយ ជាចិត្តរួចស្រឡះ (ចាកកាមាសវៈ) អាត្មាមានព្យាយាមដុតកំដៅកិលេសជាប្រក្រតី ម្នាលភ្លៀង អ្នកចូរបង្អុរមកចុះ ។

ឮថា ព្រះសុភូតិត្ថេរមានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

(៣) ឧបសន្តោ ឧបរតោ មន្តភាណី អនុទ្ធតោ
ធុនាតិ បាបកេ ធម្មេ ទុមបត្តំវ មាលុតោតិ ។
ឥត្ថំ សុទំ អាយស្មា មហាកោដ្ឋិតោ ថេរោ គាថំ អភាសិត្ថ[១]

(៤) បញ្ញំ ឥមំ បស្ស តថាគតានំ
អគ្គិ យថា បជ្ជលិតោ និសីធេ[២]
អាលោកទា ចក្ខុទទា ភវន្តិ
យេ អាគតានំ វិនយន្តិ កង្ខន្តិ ។
ឥត្ថំ សុទំ អាយស្មា កង្ខារេវតោ ថេរោ គាថំ អភាសិត្ថ ។

(៥) សព្ភិរេវ សមាសេថ បណ្ឌិតេហត្ថទស្សិភិ
អត្ថំ មហន្តំ គម្ភីរំ ទុទ្ទសំ និបុណំ អណុំ
ធីរា សមធិគច្ឆន្តិ អប្បមត្តា វិចក្ខណាតិ ។
ឥត្ថំ សុទំ អាយស្មា បុណ្ណោ មន្តានិបុត្តោ ថេរោ គាថំ អភាសិត្ថ ។

(៦) យោ ទុទ្ទមយោ ទមេន ទន្តោ
ទព្ពោ សន្តុសិតោ វិតិណ្ណកង្ខោ
វិជិតាវី អបេតភេរវោ ហិ
ទព្ពោ សោ បរិនិព្វុតោ ឋិតត្តោតិ ។
ឥត្ថំ សុទំ អាយស្មា ទព្ពោ ថេរោ គាថំ អភាសិត្ថ ។

១ ម. គាថមភាសិ ។ ២ ឱ. និសីថ ។ ម. និសីថេ ។



(៣) បុគ្គលអ្នកស្ងប់រម្ងាប់ វៀរចាកបាប ពោលពាក្យដោយមន្តប្រាជ្ញា ជាអ្នកមិនរវើរវាយ តែងកំចាត់បង់ នូវបាបធម៌ (ចាកខន្ធសន្តាន) ដូចខ្យល់បក់ផ្ដាច់ស្លឹកឈើ ។
ឮថា មហាកោដ្ឋិតត្ថេរមានអាយុ បានពោលគាថាដោយប្រការដូច្នេះ ។

(៤) អ្នកចូរមើលបញ្ញានេះរបស់ព្រះតថាគតទាំងឡាយដូចជាភ្លើង ដែលរុងរឿងក្នុងរាត្រី ព្រះតថាគតទាំងឡាយ ជាអ្នកប្រទានពន្លឺចក្ខុ តែងកំចាត់បង់សេចក្ដីសង្ស័យរបស់វេនេយ្យជនដែលមក.ហើយ ។
ឮថា កង្ខារេវតត្ថេរ មានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

(៥) បុគ្គលគប្បីនៅរួមជាមួយនឹងពួកសប្បុរសជាបណ្ឌិតអ្នកឃើញប្រយោជន៍ ព្រោះអ្នកប្រាជ្ញទាំងឡាយ អ្នកមានប្រាជ្ញាឈ្លាសវៃ មិនប្រមាទ តែងបានប្រយោជន៍ច្រើន ជ្រៅ ល្អិត ម៉ត់ចត់ ដែលឃើញបានដោយក្រ ។
ឮថា បុណ្ណត្ថេរ មានអាយុ ជាបុត្តនាងមន្តានី បានពោលគាថា ដោយប្រការដូច្នេះ ។

(៦) ភិក្ខុណា ឈ្មោះទព្វៈដែលគេទូន្មានបានដោយក្រ បានទូន្មាន ដោយការទូន្មាន (ឥន្ទ្រិយ) ជាព្រះថេរៈមានចិត្តសន្ដោស ឆ្លងសេចក្ដីសង្ស័យ ឈ្នះវិជ័យធំ ប្រាសចាកសេចក្ដីតក់ស្លុត ភិក្ខុទព្វមល្លបុត្រនោះ មានចិត្តខ្ជាប់ខ្ជួន បរិនិព្វានហើយ ។
ឮថា ទព្វត្ថេរ មានអាយុ បានពោលគាថា ដោយប្រការដូច្នេះ ។

(៧) យោ សីតវនំ ឧបគា ភិក្ខុ
ឯកោ សន្តុសិតោ សមាហិតត្តោ
វិជិតាវី អបេតលោមហំសោ
រក្ខំ កាយគតាសតិំ ធិតិមា ។

ឥត្ថំ សុទំ អាយស្មា សីតវនិយោ ថេរោ ។

(៨) យោ បានុទិ មច្ចុរាជស្ស សេនំ
នឡសេតុំវ សុទុព្វលំ មហោឃោ
វិជិតាវី អបេតភេរវោ ហិ
ទន្តោ សោ បរិនិព្វុតោ ឋិតត្តោ ។

ឥត្ថំ សុទំ អាយស្មា ភល្លិយោ ថេរោ ។

(៩) យោ ទុទ្ទមយោ ទមេន ទន្តោ
ធីរោ[1] សន្តុសិតោ វិតិណ្ណកង្ខោ
វិជិតាវី អបេតលោមហំសោ[2]
ធីរោ សោ[3] បរិនិព្វុតោ ឋិតត្តោ ។

វីរោ ថេរោ ។

---

១ ... វីរោ ។ ២ ម. អបេតលោមហំសោ ។ ៣ ម. វីរោ សោ ។



(៧) ភិក្ខុណា ជាបុគ្គលម្នាក់ឯង ចូលទៅកាន់ព្រៃត្រជាក់ ជាអ្នកសន្តោស មានចិត្តខ្ជាប់ខ្ជួន មានជ័យជំនះ ប្រាសចាកសេចក្តីព្រឺរោម (ភិក្ខុនោះឈ្មោះថា) មានប្រាជ្ញា រក្សាកាយគតាសតិ ។

ឮថា សីតវនិយត្ថេរ មានអាយុ (បានពោល) ដោយប្រការដូច្នេះ ។

(៨) បុគ្គលណា កំចាត់បង់នូវសេនានៃមច្ចុរាជ ដូចជាជំនន់ធំ កំចាត់បង់នូវស្ពានបបុស ដែលមានកំឡាំងថយ ជាអ្នកមានជ័យជំនះ ប្រាសចាកសេចក្តីភ័យស្លុត បុគ្គលនោះឈ្មោះថា មានឥន្ទ្រិយទូន្មានហើយ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ។

ឮថា ភល្លិយត្ថេរ មានអាយុ (បានពោល) ដោយប្រការដូច្នេះ ។

(៩) ភិក្ខុណាដែលគេទូន្មានបានដោយក្រ តែបានទូន្មានខ្លួនឯង ដោយការទូន្មាន (ឥន្ទ្រិយ) ជាអ្នកប្រាជ្ញ មានចិត្តសន្តោស ឆ្លងផុតសេចក្តីសង្ស័យ មានជ័យជំនះ ប្រាសចាកសេចក្តីព្រឺរោម ភិក្ខុនោះ ប្រាសចាកភនៈ មានចិត្តខ្ជាប់ខ្ជួន រំលត់ទុក្ខហើយ ។

វីរត្ថេរ ។

(១០) ស្វាគតំ នាបគតំ នយិទំ ទុម្មន្តិតំ មម

បវិភត្តេសុ[1] ធម្មេសុ យំ សេដ្ឋំ តទុបាគមិំ ។

បិលិន្ទវច្ឆោ ថេរោ ។

(១១) វិហរិ អបេក្ខំ ឥធ វា ហុរំ វា

យោ វេទគូ សមិតោ[2] យតត្តោ

សព្វេសុ ធម្មេសុ អនូបលិត្តោ

លោកស្ស ជញ្ញា ឧទយព្វយញ្ច ។

បុណ្ណមាសោ ថេរោ ។

## ឧទ្ទានំ

សុភូតិ កោដ្ឋិកោ ថេរោ កង្ខារេវតសម្មតោ[3]

មន្តាណិបុត្តោ ទព្វោ ច សីតវនិយោ ច ភល្លិយោ

វីរោ បិលិន្ទវច្ឆោ ច បុណ្ណោ មាសោ តមោនុទោតិ ។

វគ្គោ បឋមោ ។

---

១ ឱ.ម. សំវិភត្តេសុ ។ ២ ឱ.ម. សមិតោ ។ ៣ ឱ. កង្ខារេវតសុត្តោ ។ ម. កង្ខារេវតសម្មតោ ។



[១០] ដំណើរនៃអាត្មាអញមកល្អហើយ មិនមែនប្រាសចាក(បញ្ញា)ទេ សេចក្តីគិត របស់អាត្មាអញនោះ មិនមែនជាការគិតខុសទេ ព្រោះអាត្មាអញ បានសំរេចគុណជាតិប្រសើរនោះ ក្នុងធម៌ទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់ចែកទុកហើយ ។

បិលិន្ទវច្ឆត្ថេរ ។

(១១) បុគ្គលដែលបានដល់នូវវេទ ជាអ្នកសន្តោស មានខ្លួនសង្រួមហើយ មិនជាប់ជំពាក់ក្នុងធម៌ទាំងពួង គឺតណ្ហានិងទិដ្ឋិទេ រមែងកំចាត់ចេញនូវសេចក្តីអាល័យក្នុងលោកនេះ និងលោកខាងមុខបាន ព្រោះដឹងច្បាស់នូវកើតនិងវិនាសនៃលោក ។

បុណ្ណមាសត្ថេរ ។

## ឧទ្ទាន

និយាយអំពីសុភូតិត្ថេរ ១ មហាកោដ្ឋិតត្ថេរ ១ កង្ខារេវតត្ថេរ ១ បុណ្ណមន្តានីបុត្ត ១ ទព្វមល្លបុត្ត ១ សីតវនិយត្ថេរ ១ ភល្លិយត្ថេរ ១ វីរត្ថេរ ១ បិលិន្ទវច្ឆត្ថេរ ១ បុណ្ណមាសត្ថេរ អ្នកកំចាត់បង់ងងឹត ១ ។

ចប់ បឋមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស ទុតិយវគ្គោ

(១២) បាមុជ្ជពហុលោ ភិក្ខុ ធម្មេ ពុទ្ធប្បវេទិតេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខន្តិ ។

(១)
ចូឡវច្ឆោ ថេរោ ។

(១៣) បញ្ញាពលី សីលវតូបបន្នោ
សមាហិតោ ឈានរតោ សតីមា
យទត្ថិយំ ភោជនំ ភុញ្ជមានោ
កង្ខេថ[២] កាលំ ឥធ វីតរាគោ ។

(៣)
មហាវច្ឆោ ថេរោ ។

(១៤) នីលព្ភវណ្ណា រុចិរា សីតវារី សុចិន្ធរា
ឥន្ទគោបកសញ្ឆន្នា តេ សេលា រមយន្តិ មន្តិ ។

វនវច្ឆោ ថេរោ ។

(១៥) ឧបជ្ឈាយោ មំ អវចាសិ ឥតោ គច្ឆាម សីវក
គាមេ មេ វសតិ កាយោ អរញ្ញំ មេ គតោ មនោ
សេមានកោបិ គច្ឆាមិ នត្ថិ សង្គោ វិជានតន្តិ ។

វនវច្ឆស្ស ថេរស្ស សាមណេរោ ។

---

១ ឱ. ចូឡគវច្ឆោ ។ ២ ឱ. កង្ខេត ។ ៣ ឱ. មហាគវច្ឆោ ។



## ថេរគាថា ឯកនិបាត ទុតិយវគ្គ

(១២) ភិក្ខុអ្នកច្រើនដោយសេចក្តីរីករាយ ក្នុងធម៌ ដែលព្រះពុទ្ធទ្រង់ប្រកាសហើយ រមែងបានសន្តិបទ គឺព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារ ជាគុណធម៌នាំមកនូវសេចក្តីសុខ ។

ចូឡវច្ឆត្ថេរ ។

(១៣) ភិក្ខុមានប្រាជ្ញាជាកំឡាំង បរិបូណ៌ដោយសីលនិងវ័ត មានចិត្តតាំងខ្ជាប់ ត្រេកអរ ក្នុងឈាន មានស្មារតី បរិភោគភោជនតាមមាន ជាអ្នកប្រាសចាករាគៈ ក្នុងលោកនេះ តែងរង់ចាំកាលកិរិយាប៉ុណ្ណោះ ។

មហាវច្ឆត្ថេរ ។

(១៤) ភ្នំជាវិការៈនៃថ្មទាំងឡាយនោះ មានពណ៌ខៀវ ដូចពពក ជាភ្នំដ៏រុងរឿង មានទឹកត្រជាក់ ទ្រទ្រង់នូវផ្ទៃដីបរិសុទ្ធ ដេរដាសដោយសត្វអណ្តើកមាស តែងញុំាងយើងឲ្យរីករាយ ។

វនវច្ឆត្ថេរ ។

(១៥) ឧបជ្ឈាយ៍ និយាយនឹងខ្ញុំថា នែសីវកៈ យើងចេញទៅអំពីស្រុកនេះ កាយរបស់យើងនៅក្នុងស្រុក តែចិត្តរបស់យើងទៅកាន់ព្រៃ យើងសូម្បីដេក ក៏ឈ្មោះថាដើរ ការជាប់ចំពាក់ របស់ជនអ្នកដឹង មិនមានទេ ។

សាមណេររបស់វនវច្ឆត្ថេរ ។

(១៦) បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ចុត្តរិ ភាវយេ

បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតីតិ ។

កុណ្ឌធានោ ថេរោ ។

(១៧) យថាបិ ភទ្ទោ អាជញ្ញោ នង្គលាវត្តនី សិខី

គច្ឆតិ អប្បកសិរេន ឯវំ រត្តិន្ទិវា មម

គច្ឆន្តិ អប្បកសិរេន សុខេ លទ្ធេ និរាមិសេតិ ។

ពេលដ្ឋសីសោ ថេរោ ។

(១៨) មិទ្ធី យទា ហោតិ មហគ្ឃសោ ច

និទ្ទាយិតា សម្បរិវត្តសាយី

មហាវរាហោវ និវាបបុដ្ឋោ

បុនប្បុនំ គព្ភមុបេតិ មន្ទោតិ ។

ទាសកោ ថេរោ ។

(១៩) អហុ(១) ពុទ្ធស្ស ទាយាទោ ភិក្ខុ ភេសកឡាវនេ

១ ម. អហូ ។



(១៦) ភិក្ខុគប្បីកាត់បង់សំយោជនៈខាងក្រោម ៥ គប្បីលះបង់សំយោជនៈខាងលើ ៥ គប្បីចំរើនឥន្ទ្រិយ ៥ តទៅ ជាអ្នកកន្លងនូវគ្រឿងជាប់ជំពាក់ ៥(១) ទើបលោកហៅថា ឆ្លងនូវឱឃៈបាន ។

កុណ្ឌធានត្ថេរ ។

(១៧) អាជានេយ្យ(២)ដ៏ចំរើន មាននង្គ័លជាទីប្រព្រឹត្តទៅមក ជាសត្វមានបួក រមែងទៅបានដោយឥតលំបាក យ៉ាងណាមិញ កាលបើនិរាមិសសុខ ដែលខ្ញុំបានហើយ វេលាយប់និងថ្ងៃទាំងឡាយ របស់ខ្ញុំ តែងប្រព្រឹត្តកន្លងទៅ ដោយឥតលំបាក ក៏យ៉ាងនោះដែរ ។

ពេលដ្ឋសីសត្ថេរ ។

(១៨) បុគ្គលណា មានថីនមិទ្ធៈផង ជាអ្នកបរិភោគច្រើនផង ងោកងោកផង ដេកប្រែប្រួល ១ ផង ដូចជ្រូកស្រុកធំដែលគេចិញ្ចឹមដោយចំណី ក្នុងកាលណា បុគ្គលនោះឈ្មោះថា ល្ងង់ខ្លៅ តែងចូលទៅកាន់គភ៌រឿយ ៗ ក្នុងកាលនោះ ។

ទាសកត្ថេរ ។

---

១ គ្រឿងជាប់ជំពាក់ ៥ យ៉ាង គឺរាគៈ១ ទោសៈ១ មោហៈ១ មានៈ១ ទិដ្ឋិ១ ។

២ អាជានេយ្យមាន ៣ យ៉ាងគឺ គោអាជានេយ្យ១ សេះអាជានេយ្យ១ ដំរីអាជានេយ្យ១ ។ អដ្ឋកថា ។ ទីនេះថា មាន ៤ យ៉ាង គប់យកបុរសអាជានេយ្យចូលផង ។

កេវលំ អដ្ឋិសញ្ញាយ អផរី[1] បឋវី ឥមំ
មញ្ញេហំ កាមរាគំ សោ ខិប្បមេវ បហីយតីតិ ។

សិង្គាលបិតា ថេរោ ។

(២០)ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ[2] តេជនំ
ទារុំ នមយន្តិ[3] តច្ឆកា អត្តានំ ទមយន្តិ សុព្វតាតិ។

កុល្លោ ថេរោ ។

(២១)មរណេ មេ ភយំ នត្ថិ និកន្តិ នត្ថិ ជីវិតេ
សន្ទេហំ និក្ខិបិស្សាមិ សម្បជានោ បតិស្សតោតិ។

អជិតោ ថេរោ ។

ឧទ្ទានំ

ចូឡវច្ឆោ មហាវច្ឆោ វនវច្ឆោ ច សិវកោ
កុណ្ឌធានោ ច ពេលដ្ឋិ ទាសកោ ច តតោ បរំ
សិង្គាលបិតិកោ ថេរោ កុល្លោ ច អជិតោ ទសាតិ។

វគ្គោ ទុតិយោ ។

១ ឱ. អផរី ។ ២-៣ កត្ថចិ. ទមយន្តីតិ បាឋោ ទិស្សតិ ។





(១៩) ភិក្ខុជាអ្នកទទួលមរតក របស់ព្រះពុទ្ធ បានពិចារណានូវផែនដី គឺអត្តភាពនេះដោយសំគាល់ថាជាកន្ទ្រីងឆ្អឹងទាំងអស់ ក្នុងភេសកឡាវ័ន ភិក្ខុនោះ នឹងលះបង់កាមរាគបាន ដោយឆាប់រហ័ស ទំនងដូចជា ការគិតឃើញ(នេះ) ។

សិង្គាលបិតាថេរ ។

(២០) ពួកជនអ្នកបង្ហូរទឹក តែងបង្ហូរទឹក ពួកអ្នកធ្វើព្រួញ តែងដំព្រួញ ពួកជាងចាំង តែងចាំងឈើ (យកទៅណាមិញ) ពួកជនអ្នកមានវត្តល្អ តែងទូន្មានខ្លួនឲ្យត្រង់ (ក៏យ៉ាងនោះដែរ) ។

កុល្លត្ថេរ ។

(២១) ខ្ញុំមិនមានមរណភ័យទេ សេចក្ដីអាល័យក្នុងជីវិតក៏មិនមាន ខ្ញុំជាអ្នកមានសតិរលឹកឃើញ ដឹងខ្លួនសព្វគ្រប់ នឹងដាក់ចោលនូវកាយបាន ។

អជិតត្ថេរ ។

ឧទ្ទាន

និយាយអំពីចូឡវច្ឆត្ថេរ ១ មហាវច្ឆត្ថេរ ១ វនវច្ឆត្ថេរ ១ សិវកសាមណេរ ១ កុណ្ឌធានត្ថេរ ១ ពេលដ្ឋសីសត្ថេរ ១ ទាសកត្ថេរ ១ លំដាប់អំពីនោះ ទៅមុខទៀត គឺ សិង្គាលបិតិកត្ថេរ ១ កុល្លត្ថេរ ១ អជិតត្ថេរ ១ រួមជា ១០ ។

ចប់ទុតិយវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស តតិយវគ្គោ

(២២)នាហំ ភយស្ស ភាយាមិ សត្ថា នោ អមតស្ស កោវិទោ
យត្ថ ភយំ នាវតិដ្ឋតិ តេន មគ្គេន វជន្តិ ភិក្ខវោ ។

និគ្រោធោ ថេរោ ។

(២៣)នីលា សុគីវា សិខិនោ មោរា ការវិយំ[១] អភិនទន្តិ
តេ សីតវាតកលិតា[២] សុត្តំ ឈាយិំ[៣] និពោធេន្តិ ។

ចិត្តកោ ថេរោ ។

(២៤)អហំ ខោ វេឡុគុម្ពស្មឹ ភុត្វាន មធុបាយាសំ
បទក្ខិណំ សម្មសន្តោ ខន្ធានំ ឧទយព្វយំ
សានុំ បដិគមិស្សាមិ វិវេកមនុព្រូហយន្តិ ។

គោសាលោ ថេរោ ។

(២៥)អនុវស្សិកោ បព្វជិតោ បស្ស ធម្មសុធម្មតំ[៤]
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

សុគន្ធោ ថេរោ ។

---

១ ម. ការំវិយំ ។ ២ ម. សីតវាតកីឡិតា ។ ៣ ម. ឈាយំ ។ ៤ ម. ធម្មេសុ សុធម្មតំ ។



## ថេរគាថា ឯកនិបាត តតិយវគ្គ

(២២) ខ្ញុំមិនខ្លាចអំពីភ័យទេ ព្រោះសាស្តាចារ្យ របស់យើងទាំងឡាយ ប្រាជ្ញឈ្លាសវៃ ក្នុងព្រះនិព្វាន ឈ្មោះអមតៈ ភ័យមិនឋិតនៅក្នុងព្រះនិព្វានណា ភិក្ខុទាំងឡាយ តែងដល់ (នូវព្រះនិព្វាននោះ) ដោយមគ្គនោះ ។

និគ្រោធត្ថេរ ។

(២៣) ពួកសត្វក្ងោក ជាសត្វមានសម្បុរខៀវ មានកល្អ មានសិខា តែងយំក្នុងព្រៃឈ្មោះការាវី ក្ងោកទាំងនោះ លុះត្រូវខ្យល់ត្រជាក់បក់មក តែងញ៉ាំងបុគ្គលដែលដេកលក់ គឺបុគ្គលអ្នកមានឈានឲ្យភ្ញាក់ឡើង ។

ចិត្តកត្ថេរ ។

(២៤) ខ្ញុំបរិភោគមធុបាយាស ជិតគុម្ពឫស្សី ហើយពិចារណានូវការកើតឡើងនិងការសូន្យទៅ នៃខន្ធទាំងឡាយ (ដោយការទទួល) យកនូវទិស ភាគស្តាំ ខ្ញុំនឹងត្រឡប់ទៅកាន់ប្រកន្លា ហើយចំរើនវិវេកធម៌វិញ ។

គោសាលត្ថេរ ។

(២៥)អ្នកជាបព្វជិតនៅវស្សា ចូរពិចារណាភាពនៃធម៌ជាធម៌ល្អ វិជ្ជាទាំង៣ អ្នកបានសម្រេចហើយ ពុទ្ធសាសនា អ្នកក៏បានធ្វើហើយ ។

សុគន្ធត្ថេរ ។

(៦៦) ឱភាសជាតំ ផលគំ ចិត្តំ យស្ស អភិណ្ហសោ
តាទិសំ ភិក្ខុមាសជ្ជ កណ្ហ ទុក្ខំ និគច្ឆសីតិ ។

ឧត្តិយោ ថេរោ ។

(៦៧) សុត្វា សុភាសិតំ វាចំ ពុទ្ធស្សាទិច្ចពន្ធុនោ
បច្ចព្យាធិំ ហិ និបុណំ វាលគ្គំ ឧសុនា យថាតិ ។

អភយោ ថេរោ ។

(៦៨) ទព្វំ កុសំ បោដកិលំ ឧសីរំ មុញ្ជបព្វជំ
ឧរសា បនុទហិស្សាមិ[១] វិវេកមនុព្រូហយន្តិ ។

លោមសកង្គិយោ ថេរោ ។

(៦៩) កច្ចិ នោ វត្ថបសុតោ កច្ចិ នោ ភូសនារតោ
កច្ចិ សីលមយំ គន្ធំ [២]ត្វំ វាសិ នេតរា បជាតិ ។

ជម្ពុគាមិកបុត្តោ ថេរោ ។

១ ឱ. បនុទិស្សាមិ ។ ២ ម. ឯត្ថ ឋានេ កិំ អត្ថិ ។



(៦៦) ចិត្តដ៏ប្រសើរ ដែលកើតដោយពន្លឺ (វិញ្ញាណ) របស់ ភិក្ខុណាសព្វកាល អ្នកជាមារ មានចិត្តអាក្រក់[១] កាលបៀតបៀន ភិក្ខុសព្វកាលនោះ ហើយដល់នូវសេចក្តីទុក្ខព្រួយ ។

ឧត្តិយត្ថេរ ។

(៦៧) ខ្ញុំបានស្តាប់ព្រះវាចា ជាសុភាសិត របស់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ហើយ បានត្រាស់ដឹង នូវអរិយសច្ចធម៌ដ៏ល្អិត (ដូចខ្មាន់ធ្នូ ជាអ្នកក្លាហាន) បាញ់ចុងរោមកន្ទុយ (នៃសេះ) ដោយព្រួញបាន ។

អភយត្ថេរ ។

(៦៨) កាលខ្ញុំចំរើនវិវេកធម៌ គឺកំចាត់បង់ស្មៅចំពឿន ស្បូវ ភ្នុះឈើ មានបន្លា ស្បូវកណ្តាល ស្មៅដំណាក់ទន្សាយនិងស្មៅឃាស់ផង គឺកិលេស ក្រាស់ក្រាន កណ្តាល ល្អិត ដោយទ្រូងគឺសេចក្តីព្យាយាមបាន ។

លោមសកង្គិយត្ថេរ ។

(៦៩) អ្នកមិនខ្វល់ខ្វាយចំពោះសំពត់ទេឬ មិនត្រេកអរចំពោះការ ស្អិតស្អាងទេឬ អ្នកផ្សាយក្លិនសម្រេចគឺសីលទេឬ ជនដទៃ ក្រៅអំពីនេះ មិនផ្សាយ (ក្លិនដូច្នោះទេ) ។

ជម្ពុគាមិកបុត្តត្ថេរ ។

១ ក្នុងបាលី ប្រើពាក្យថា កណ្ហៈ ជាឈ្មោះរបស់មារ ហេតុនោះ ក្នុងទីនេះទើបប្រែថា មារ មានចិត្តអាក្រក់ ឬចិត្តខ្មៅកំណាន់ ។ អដ្ឋកថា ។

(៣០) សមុន្នមយមត្តានំ ឧសុការោវ តេជនំ
ចិត្តំ ឧជុំ ករិត្វាន អវិជ្ជំ ភិន្ទ[១] ហារិតា ។

ហារិតោ ថេរោ ។

(៣១) អាពាធេ មេ សមុប្បន្នេ សតិ មេ ឧទបជ្ជថ
អាពាធោ មេ សមុប្បន្នោ កាលោ មេ នប្បមជ្ជិតុំ ។

ឧត្តិយោ ថេរោ ។

ឧទ្ទានំ

និគ្រោធោ ចិត្តកោ ថេរោ គោសាលត្ថេរោ[២] សុគន្ធោ
នន្ទិយោ អភយោ ថេរោ ថេរោ លោមសកង្គិយោ
ជម្ពុគាមិកបុត្តោ ច ហារិតោ ឧត្តិយោ ឥសិ ។

វគ្គោ ទសមោ ។

---

១ ឱ. ម. ភិន្ទ ។ ២ ឱ. គោសាលត្ថេរោ ។



(៣០) បុគ្គលកាលពត់ខ្លួន (ឲ្យត្រង់) ដូចជាងធ្វើព្រួញ ពត់ព្រួញ
លុះធ្វើចិត្តឲ្យត្រង់ហើយ ទើបទំលាយ នាំចេញនូវអវិជ្ជាចុះ ។

ហារិតត្ថេរ ។

(៣១) កាលបើអាពាធ កើតឡើងដល់ខ្ញុំ ស្មារតីកើតឡើងដល់ខ្ញុំថា
អាពាធកើតឡើងដល់អញហើយ នេះជាកាលដែលអញមិនគួរប្រមាទ ។

ឧត្តិយត្ថេរ ។

ឧទ្ទាន

និយាយគឺ និគ្រោធត្ថេរ ១ ចិត្តកត្ថេរ ១ គោសាលត្ថេរ ១
សុគន្ធត្ថេរ ១ នន្ទិយត្ថេរ ១ អភយត្ថេរ ១ លោមសកង្គិយត្ថេរ ១
ជម្ពុគាមិកបុត្តត្ថេរ ១ ហារិតត្ថេរ ១ ឧត្តិយត្ថេរ ជាឥសី ១ ។

ចប់ ទសមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស ចតុត្ថវគ្គោ

(៣២) ផុដ្ឋោ ឌំសេហិ មកសេហិ អរញ្ញស្មឹ ព្រហាវនេ
នាគោ សង្គាមសីសេវ សតោ តត្រាធិវាសយេតិ ។

(១) គហ្វរតីរិយោ ថេរោ ។

(៣៣) អជរំ ជីរមានេន តប្បមានេន និព្វុតឹ
និមិយំ[២] បរមំ សន្តឹ យោគក្ខេមំ អនុត្តរន្តិ ។

សុប្បិយោ ថេរោ ។

(៣៤) យថាបិ ឯកបុត្តស្មឹ បិយស្មឹ កុសលី សិយា
ឯវំ សព្វេសុ បាណេសុ សព្វត្ថ កុសលោ សិយាតិ ។

សោបាកោ ថេរោ ។

(៣៥) អនាសន្នវរា ឯតា និច្ចមេវ វិជានតា
គាមា អរញ្ញមាគម្ម តតោ គេហំ ឧបាវិសិ
តតោ ឧដ្ឋាយ បក្កាមិ អនាមន្តេត្វា[៣] បោសិយោតិ ។

បោសិយោ ថេរោ ។

---

១ ឱ. គព្ភរតីរិយោ ពិត្ត ។ ម. គហ្វរតីរិយោ ។ ២ ឱ. និមិយំ ។ ៣ ឱ. អនាមន្តេត្វា ។



## ថេរគាថា ឯកនិបាត ចតុត្ថវគ្គ

(៣២) បុគ្គលដែលត្រូវរបោមទឹងមូសខាំក្នុងព្រៃធំ គប្បីជាអ្នកមានសតិ អត់ធ្មត់ក្នុងព្រៃនោះ ដូចដំរីដែលនៅក្នុងចំណោមនៃសង្គ្រាម ។

គហ្វរតីរិយត្ថេរ ។

(៣៣) បុគ្គលអ្នកចាស់គ្រាំគ្រា បានដល់ព្រះនិព្វាន ជាគុណជាតមិនចាស់គ្រាំគ្រា អ្នកក្ដៅក្រហាយ បានដល់ព្រះនិព្វានជាគុណជាតដ៏ត្រជាក់ ជានិរាមិសសុខ ជាគុណជាតស្ងប់រម្ងាប់ដ៏ក្រៃលែង ជាគុណដ៏ប្រសើរ ជាទីក្សេមចាកយោគៈ ។

សុប្បិយត្ថេរ ។

(៣៤) បុគ្គលមានសេចក្ដីល្អចំពោះបុត្រតែមួយ ជាទីស្រឡាញ់យ៉ាងណា បុគ្គលត្រូវមានសេចក្ដីក្សេមក្សាន្ត មានសោភ័ណភាពចំពោះសព្វសត្វ ក្នុងទិសទាំងពួង ក៏ដូច្នោះដែរ ។

សោបាកត្ថេរ ។

(៣៥) កាលខ្ញុំដឹងច្បាស់អស់កាលជានិច្ច (ស្រីទាំងនុ៎ះ) ដែលមិននៅជិត ប្រសើរ ខ្ញុំចេញអំពីស្រុកទៅកាន់ព្រៃ ចេញអំពីព្រៃនោះ មកកាន់ផ្ទះ ក្រោកចេញចាកផ្ទះនោះ ហើយចៀសចេញទៅ ឈ្មោះបោសិយៈ អ្នកកុំហៅគេ (ស្រីទាំងនោះទៀតឡើយ) ។

បោសិយត្ថេរ ។

(៣៦) សុខំ សុខត្ថោ លភតេ តទាចរំ
កិត្តិញ្ច បប្បោតិ យសស្ស វឌ្ឍតិ
យោ អរិយមដ្ឋង្គិកមញ្ជសំ ឧជុំ
ភាវេតិ មគ្គំ អមតស្ស បត្តិយា ។

សាមញ្ញកានិ ថេរោ ។

(៣៧) សាធុ សុតំ សាធុ ចរិតកំ
សាធុ សទា អនិកេតវិហារោ
អត្ថបុច្ឆនំ បទក្ខិណកម្មំ
ឯតំ សាមញ្ញំ អកិញ្ចនស្សាតិ ។

កុមាបុត្តោ ថេរោ ។

(៣៨) នានាជនបទំ យន្តិ វិចរន្តា អសញ្ញតា
សមាធិញ្ច វិរាធេន្តិ កឹសុ រដ្ឋចរិយា ករិស្សតិ ។



(៣៦) បុគ្គលអ្នកត្រូវការដោយសេចក្តីសុខ[1] កាលបើប្រតិបត្តិ ដើម្បីសេចក្តីសុខនោះ រមែងបានសេចក្តីសុខ (មិនត្រឹមតែប៉ុណ្ណោះ) បុគ្គលណា ចំរើនអរិយមគ្គ ប្រកបដោយអង្គ ៨ ជាមគ្គដ៏ត្រង់ ដើម្បីដល់ព្រះនិព្វានឈ្មោះអមតៈ បុគ្គលនោះ រមែងបានកិត្តិគុណផង យសក៏ចំរើនដល់បុគ្គលនោះផង ។

សាមញ្ញកានិត្ថេរ ។

(៣៧) ការស្តាប់ជាការល្អ ការប្រព្រឹត្តជាការល្អ ការនៅដោយឥតអាល័យ (ក្នុងកាមគុណ) ជាការល្អគ្រប់កាល ការសួរអំពីប្រយោជន៍[2] អំពើការស្តាំ (ជាការល្អ) អំពើទាំងនោះ ឈ្មោះថាជាសាមញ្ញផល របស់បុគ្គលអ្នកមិនមានកង្វល់ ។

កុមាបុត្តត្ថេរ ។

(៣៨) ពួកភិក្ខុ កាលត្រាច់ចរ ដើរដាស ទៅកាន់ជនបទ ផ្សេងៗ ឈ្មោះថា ជាអ្នកមិនសង្រួមផង រមែងញុំាងសមាធិ ឲ្យឃ្លាតផង ការត្រាច់ទៅ ក្នុងដែន នឹងធ្វើប្រយោជន៍ អ្វីកើត ។

---

១ សេចក្តីសុខក្នុងគាថានេះ សំដៅយកនិរាមិសសុខ គឺព្រះនិព្វាន ។ ២ គឺប្រយោជន៍ក្នុងលោកនេះ លោកខាងមុខ និងប្រយោជន៍ដ៏ប្រសើរ គឺព្រះនិព្វាន ។ អដ្ឋកថា ។

តស្មា ភិន្ទេយ្យ សាមគ្គិំ ឈាយេយ្យ អបុរក្ខតោតិ ។

កុមាបុត្តត្ថេរស្ស សហាយកោ ថេរោ ។

(៣៩) យោ ឥទ្ធិយា សរភុំ អដ្ឋបេសិ[១]

គវម្បតិ សោ អសិតោ អនេជោ

តំ សព្វសង្គាតិគតំ មហាមុនិំ

ទេវា នមស្សន្តិ ភវស្ស បារគុន្តិ ។

គវម្បតិ ថេរោ ។

(៤០) សត្តិយា វិយ ឱមដ្ឋោ ឌយ្ហមានោវ មត្ថកេ

កាមរាគប្បហានាយ សតោ ភិក្ខុ បរិព្វជេតិ ។

តិស្សោ ថេរោ ។

(៤១) សត្តិយា វិយ ឱមដ្ឋោ ឌយ្ហមានោវ មត្ថកេ

ភវរាគប្បហានាយ សតោ ភិក្ខុ បរិព្វជេតិ ។

វឌ្ឍមានោ ថេរោ ។

---

១ ឱ. បដ្ឋបេសិ ។



ព្រោះហេតុនោះ បុគ្គលគប្បីបន្ទាបបង់នូវសាមគ្គីកិលេស គប្បីរំពឹង (ក្នុងកម្មដ្ឋាន) ធ្វើកុំឲ្យមានកិលេសតាំងនៅជាប្រធានបានឡើយ ។

ព្រះថេរៈជាសំឡាញ់របស់កុមាបុត្តត្ថេរ ។

(៣៩) ភិក្ខុណា បង្វិលទន្លេសរភូ ដោយឫទ្ធិបាន ភិក្ខុនោះ គឺ គវម្បតិ ជាអ្នកមិនអាស្រ័យ មិនញាប់ញ័រ (ដោយតណ្ហានិងទិដ្ឋិ) ទេវតាទាំងឡាយ តែងនមស្ការនូវព្រះថេរៈនោះ ជាមហាមុនី ជាអ្នកកន្លងនូវសង្គធម៌ទាំងពួង ជាអ្នកដល់នូវត្រើយនៃភព ។

គវម្បតិត្ថេរ ។

(៤០) ភិក្ខុអ្នកមានស្មារតី កាលបើក្ដៅក្រហាយ (ដោយភ្លើងទុក្ខ ភ្លើងកិលេស) ដូចបុគ្គលដែលគេចាក់ ដោយលំពែងត្រង់ក្បាល គប្បីវៀរស្រឡះ ដើម្បីលះបង់កាមរាគៈចេញ ។

តិស្សត្ថេរ ។

(៤១) ភិក្ខុអ្នកមានស្មារតី កាលបើក្ដៅក្រហាយ (ដោយភ្លើងទុក្ខ ភ្លើងកិលេស) ដូចបុគ្គលដែលគេចាក់ ដោយលំពែងត្រង់ក្បាល គប្បីវៀរស្រឡះ ដើម្បីលះបង់ភវរាគៈចេញ ។

វឌ្ឍមានត្ថេរ ។

## ឧទ្ទានំ

គហ្វរតីរិយោ សុប្បិយោ សោបាកោ ចេវ បោសិយោ

សាមញ្ញកានិ កុមាបុត្តោ កុមាបុត្តសហាយកោ

គវម្បតិ តិស្សត្ថេរោ វឌ្ឍមានោ មហាយសោតិ ។

វគ្គោ បញ្ចមោ ។



## ឧទ្ទាន

និយាយអំពី គហ្វរតីរិយត្ថេរ ១ សុប្បិយត្ថេរ ១ សោបាកត្ថេរ ១ បោសិយត្ថេរ ១ សាមញ្ញកានិត្ថេរ ១ កុមាបុត្តត្ថេរ ១ កុមាបុត្តសហាយកត្ថេរ ១ គវម្បតិត្ថេរ ១ តិស្សត្ថេរ ១ វឌ្ឍមានត្ថេរ ជាអ្នកមានយសច្រើន ១ ។

ចប់ បញ្ចមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស បញ្ចមវគ្គោ

(៤២) វិវរមនុបតន្តិ វិជ្ជុតា
វេភារស្ស ច បណ្ឌវស្ស ច
នគវិវរគតោ ច ឈាយតិ
បុត្តោ អប្បដិមស្ស តាទិនោតិ ។

សិរិវឌ្ឍោ ថេរោ ។

(៤៣) ចាលេ ឧបចាលេ សីសុបចាលេ[១]
ចាលា ឧបចាលា សីសុបចាលា[២]
បតិស្សតិកា នុ ខោ វិហរថ
អាគតោ វោ វាលំ វិយ វេធីតិ[៣] ។

ខទិរវនិយោ ថេរោ ។

(៤៤) សុមុត្តិកោ សុមុត្តិកោ សាហុ
សុមុត្តិកោម្ហិ តីហិ ខុជ្ជកេហិ

---

១ ម. ឧ. ចាលេ ឧបចាលេ សីសូបចាលេ ។ ២ ម. ឧ. ក៏មេ ជាហ៖ ខទិរត្តិ ។
៣ ម. ឧ. វេធិ ។



## ថេរគាថា ឯកនិបាត បញ្ចមវគ្គ

(៤២) ផ្លេកបន្ទោរ តែងធ្លាក់ទៅកាន់ចន្លោះភ្នំវេភារៈផង
ភ្នំបណ្ឌវៈផង ចំណែកខាងភិក្ខុជាបុត្រ របស់ព្រះមានព្រះភាគ
ព្រះអង្គជាបុគ្គលនឹងនួន ឥតមានគូប្រៀប ក៏តែងចូលទៅ
កាន់ចន្លោះភ្នំ ចំរើនឈាន ។

សិរិវឌ្ឍត្ថេរ ។

(៤៣) ម្នាលនាងចាលា ម្នាលនាងឧបចាលា ម្នាលនាងសីសុបចាលា
នាងទាំងឡាយ[១] ឈ្មោះចាលា ឈ្មោះឧបចាលា ឈ្មោះសីសុបចាលា
ចូរជាអ្នកមានសតិខ្ជាប់ខ្ជួនចុះ (ព្រោះព្រះសារីបុត្តជាបង) របស់នាង
ទាំងឡាយ បានមកគ្រប់ហើយ ដូចអ្នកបាញ់រោមកន្ទុយក្រោយ ។

ខទិរវនិយត្ថេរ ។

(៤៤) អញរួចស្រឡះហើយ ផុតស្រឡះហើយ ដោយប្រពៃ
អញរួចស្រឡះហើយ ចាកវត្ថុកោង[២] ៣ យ៉ាង គឺ

---

១ នាងសារីព្រាហ្មណី មានកូនជានាងទាំង ៣ ជាប្អូនរបស់ឧបតិស្សកុមារ (សារីបុត្ត) ។ ប្អូនៗ របស់ខទិរវនិយត្ថេរ ឈ្មោះចាលា១ ឧបចាលា១ សីសុបចាលា១ ។ គម្ពីរខ្លះថា ចាលា ឧបចាលា សីសុបចាលា ។ ២ ពាក្យថា អាការកោងក្នុងទីនេះ សំដៅយកពាក្យបំអកឱ្យបន្ទុះបង្អាប់ ព្រោះថា ការកាន់កណ្ដៀវច្រូតស្រូវ កាន់យាមនង្គ័លភ្ជួររាស់ និងការដែលកាន់ចបកាប់ដី ទាំងអស់នេះ សុទ្ធតែខ្ទង់ខ្ទង មិនមានសុខ ។ អដ្ឋកថា ។

អសិតាសុ មយា នង្គលាសុ
មយា ខុទ្ទកុទ្ទាលាសុ មយា
យទិបិ ឥធមេវ ឥធមេវ
អថ វាបិ អលមេវ អលមេវ
ឈាយ សុមង្គល ឈាយ សុមង្គល
អប្បមត្តោ វិហរ សុមង្គលាតិ ។

សុមង្គលោ ថេរោ ។

(៤៥) មតំ វា អម្ម រោទន្តិ យោ វា ជីវំ ន ទិស្សតិ
ជីវន្តំ មំ អម្ម ទិស្សន្តិ កស្មា មំ អម្ម រោទសីតិ ។

សានុ ថេរោ ។

(៤៦) យថាបិ ភទ្រោ អាជញ្ញោ ខលិត្វា បតិតិដ្ឋតិ
ឯវំ ទស្សនសម្បន្នំ សម្មាសម្ពុទ្ធសាវកន្តិ ។

រមណីយវិហារី ថេរោ ។

(៤៧) សទ្ធាយាហំ បព្វជិតោ អគារស្មា អនគារិយំ
សតិ បញ្ញា ច មេ វុឌ្ឍា ចិត្តញ្ច សុសមាហិតំ
កាមំ ករស្សុ រូបានិ នេវ មំ ព្យាធយិស្សសីតិ ។

សមិទ្ធិ ថេរោ ។



កាលអញកាន់កណ្តៀវ ១ កាលអញកាន់នង្គ័ល ១ កាលអញកាន់ចបកូច ១ ទោះការណ៍ (មានកាន់កណ្តៀវជាដើមនោះ) ក្នុងទីនេះៗ ក៏ដោយ ឬក៏ការណ៍ (មានកាន់កណ្តៀវជាដើម) ល្មមហើយ ល្មមហើយនៃសុមង្គល អ្នកចូរពិនិត្យ (ដល់សមាបត្តិចុះ) នៃសុមង្គល អ្នកចូរពិនិត្យចុះ នៃសុមង្គល អ្នកចូរជាអ្នកមិនប្រមាទ ។

សុមង្គលត្ថេរ ។

(៤៥) បពិត្រមាតា ពួកញាតិតែងយំរកបុគ្គលដែលស្លាប់ហើយ ឬបុគ្គលដែលរស់នៅ តែមិនបានជួបប្រទះ បពិត្រមាតា ពួកញាតិឃើញអាត្មាកំពុងរស់នៅ បពិត្រមាតា ព្រោះហេតុអ្វី ទើបអ្នកមាតាយំរកអាត្មា ។

សានុត្ថេរ ។

(៤៦) សេះ អាជានេយ្យដ៏ប្រសើរ ទោះបីភ្លាត់ រមែងឈរស៊ប់វិញបាន យ៉ាងណា (អ្នកទាំងឡាយចូរចំណាំខ្ញុំ)ថាជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ដែលបរិបូណ៌ដោយទស្សនសម្បត្តិ (គ្រប់គ្រាន់ដោយការឃើញ) ក៏យ៉ាងនោះដែរ ។

រមណីយវិហារិត្ថេរ ។

(៤៧) អាត្មាចេញចាកផ្ទះចូលកាន់ផ្នួស បួសដោយសទ្ធា សតិនឹងបញ្ញា របស់ខ្ញុំចំរើនហើយ ទាំងចិត្តក៏ខ្ញុំតម្កល់ទុកប្រពៃហើយ (នែមារចិត្តបាប) អ្នកចូរធ្វើអំពើផ្សេងៗតាមប្រាថ្នាចុះ អ្នកនឹងបៀតបៀនអាត្មាមិនបានទេ ។

សមិទ្ធិត្ថេរ ។

(៤៨) នមោ តេ ពុទ្ធវីរត្ថុ វិប្បមុត្តោសិ សព្វធិ

តុយ្ហាបទានេ វិហរំ វិហរាមិ អនាសវោ ។

ឧត្តិយោ ថេរោ ។

(៤៩) យតោ អហំ បព្វជិតោ អគារស្មា អនគារិយំ

នាភិជានាមិ សង្កប្បំ អនរិយំ ទោសសំហិតន្តិ ។

សញ្ជយោ ថេរោ ។

(៥០) វិហង្គាភិនទិតេ សិប្បិកាភិរុតេហិ ច

ន មេ តំ ផន្ទតិ ចិត្តំ ឯកត្តនិរតំ[1] ហិ មេតិ ។

រាមណេយ្យកោ ថេរោ ។

(៥១) ធរណី សិញ្ចតិ[2] វាតិ មាលុតោ វិជ្ជុតា ចរតិ នភេ

ឧបសម្មន្តិ វិតក្កា ចិត្តំ សុសមាហិតំ មមាតិ ។

វិមលោ ថេរោ ។

១ ម. ឯកត្តនិរតំ ។ ឧ. ឯកត្តនិរតេញ្ហិ ។ ២ ម. ធរណី ច សិញ្ចតិ ។



(៤៨) បពិត្រព្រះពុទ្ធ ជាវីរបុគ្គល ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ ព្រះអង្គជាអ្នកផុតស្រឡះ ចាកកិលេសទាំងពួង ខ្ញុំព្រះអង្គជាអ្នកមិនមានអាសវៈ តែងប្រព្រឹត្តនៅក្នុងសម្បទាទាំង ៣ នៃព្រះអង្គ ។

ឧត្តិយត្ថេរ ។

(៤៩) ក្នុងកាលដែលខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ខ្ញុំមិនធ្លាប់ដឹងនូវសេចក្ដីត្រិះរិះប្រកបដោយទោស ដែលមិនមែនជាអរិយធម៌ទេ ។

សញ្ជយត្ថេរ ។

(៥០) ចិត្តរបស់ខ្ញុំនោះមិនញាប់ញ័រ ព្រោះសំរែកនៃសត្វរៃ ឬព្រោះសត្វព្រៃដែលស្រែកឆាបខេ ព្រោះថា ចិត្តរបស់ខ្ញុំ មានអារម្មណ៍មួយតែមួយ ត្រេកអរមិនដាច់ (ក្នុងព្រះនិព្វាន) ។

រាមណេយ្យកត្ថេរ ។

(៥១) ផែនដីតែងសើមជ្រាប (ដោយសារទឹកភ្លៀង) ខ្យល់តែងបក់ ផ្លេកបន្ទោរតែងចាលចរក្នុងអាកាស ឯវិតក្កៈទាំងឡាយ (មានកាមវិតក្កៈជាដើម) របស់ខ្ញុំតែងរម្ងាប់ ចិត្តរបស់ខ្ញុំក៏តម្កល់ទុកល្អហើយ ។

វិមលត្ថេរ ។

## ឧទ្ទានំ

សិរិវឌ្ឍោ រេវតោ ថេរោ ខទិរវនិយោ សុមង្គលោ

សានុ[1] រមណីយវិហារី ច សមិទ្ធិ ឧជ្ជយសញ្ជយោ[2]

រាមណេយ្យកោ[3] សោ ថេរោ វិមលោ ច រណញ្ជហោតិ[4] ។

វគ្គោ បញ្ចមោ ។

---

១ ឱ. ម. សុមង្គលោ សានុសវ្ហយោតិ ឥមេ បាឋា ទិស្សន្តិ ។ ២ ឱ. ម. សមិទ្ធិឧជ្ជយ-សញ្ជយោ ។ ៣ ឱ. ម. រមណេយ្យោ ច ។ ៤ ឱ. រណញ្ជហោតិ ។



## ឧទ្ទាន

និយាយគឺ សិរិវឌ្ឍត្ថេរ ១ ខទិរវនិយត្ថេរ ១ សុមង្គលត្ថេរ ១

សានុត្ថេរ ១ រមណីយវិហារិត្ថេរ ១ សមិទ្ធិត្ថេរ ១ ឧជ្ជយត្ថេរ ១

សញ្ជយត្ថេរ ១ រាមណេយ្យកត្ថេរ ១ វិមលត្ថេរអ្នកលះបង់កិលេស ១ ។

ចប់ វគ្គទី៥ ។

## ថេរគាថាយ ឯកនិបាតស្ស ឆដ្ឋវគ្គោ

(៥២) វស្សតិ ទេវោ យថា សុគីតំ
ឆន្នា មេ កុដិកា សុខា និវាតា
ចិត្តំ សុសមាហិតញ្ច មយ្ហំ
អថ ចេ បត្ថយសិ បវស្ស ទេវាតិ ។

គោធិកោ ថេរោ ។

(៥៣) វស្សតិ ទេវោ យថា សុគីតំ
ឆន្នា មេ កុដិកា សុខា និវាតា
ចិត្តំ សុសមាហិតញ្ច [១] មយ្ហំ
អថ ចេ បត្ថយសិ បវស្ស ទេវាតិ ។

សុពាហុ ថេរោ ។

(៥៤) វស្សតិ ទេវោ យថា សុគីតំ
ឆន្នា មេ កុដិកា សុខា និវាតា
តស្សំ វិហរាមិ អប្បមត្តោ
អថ ចេ បត្ថយសិ បវស្ស ទេវាតិ ។

វល្លិយោ ថេរោ ។

១ ឱ. ម. កាយេ ។

## ថេរគាថា ឯកនិបាត ឆដ្ឋវគ្គ

(៥២) ភ្លៀង (ទេវតា) ដូចជាច្រៀងពីរោះ រមែងបង្អុរចុះ
ខ្ទមតិចតួចរបស់ខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ
ជាទីនាំមកនូវសេចក្ដីសុខ ទាំងចិត្តរបស់ខ្ញុំក៏តម្កល់ទុកល្អហើយ
ម្នាលភ្លៀង បើអ្នកចង់ (បង្អុរទឹក) ក៏ចូរបង្អុរមកចុះ ។

គោធិកត្ថេរ ។

(៥៣) ភ្លៀង (ទេវតា) ដូចជាច្រៀងពីរោះ រមែងបង្អុរចុះ
ខ្ទមតិចតួចរបស់ខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតខ្យល់ចូលបានទេ
ជាទីនាំមកនូវសេចក្ដីសុខ ទាំងចិត្តរបស់ខ្ញុំក៏តម្កល់ទុកល្អហើយ
ម្នាលភ្លៀង បើអ្នកចង់ (បង្អុរទឹក) ចូរបង្អុរមកចុះ ។

សុពាហុត្ថេរ ។

(៥៤) ភ្លៀង (ទេវតា) ដូចជាច្រៀងពីរោះ រមែងបង្អុរចុះ
ខ្ទមតិចតួចរបស់ខ្ញុំ ខ្ញុំបានបិទបាំងហើយ ឥតមានខ្យល់ចូលបានទេ
ជាទីនាំមកនូវសេចក្ដីសុខ ខ្ញុំជាអ្នកមិនប្រមាទ នៅក្នុងខ្ទមនោះ
ម្នាលភ្លៀង បើអ្នកចង់ (បង្អុរទឹក) ចូរបង្អុរមកចុះ ។

វល្លិយត្ថេរ ។

(៥៤) វស្សតិ ទេវោ យថា សុគីតំ
ឆន្នា មេ កុដិកា សុខា និវាតា
តស្សំ វិហរាមិ អប្បមត្តោ
អថ ចេ បត្ថយសី បវស្ស ទេវាតិ ។

ឧត្តិយោ ថេរោ ។

(៥៥) អាសន្ទិំ កុដិកំ[១] កត្វា ឱគយ្ហ អញ្ជនំ វនំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

អញ្ជនវនិយោ ថេរោ ។

(៥៦) កោ កុដិកាយំ ភិក្ខុ កុដិកាយំ
វីតរាគោ សុសមាហិតចិត្តោ
ឯវំ ជានាហិ អាវុសោ អមោឃា តេ កុដិកា កតាតិ ។

កុដិវិហារី ថេរោ ។

(៥៧) អយមាហុ បុរាណិយា កុដិ[២]
អញ្ញំ បត្ថយសេ នវំ កុដឹ
អាសំ កុដិយា វិរាជយ ទុក្ខា ភិក្ខុ បុន នវា កុដីតិ ។

កុដិវិហារី ថេរោ ។

១ ម. ឆ. អាសន្ទឹ កុដឹ ។ ២ ម. ឆ. កុដី ។



(៥៤) ភ្លៀង (ទេវតា) ដូចជាចម្រៀងដ៏ពីរោះ រមែងបង្អុរចុះ ខ្ទមតូចរបស់ខ្ញុំ ខ្ញុំបានបិទបាំងហើយ ខ្ញុំឥតមានខ្យល់បក់ប៉ះ នៅក្នុងខ្ទមនោះទេ ម្នាលភ្លៀង បើអ្នកចង់ (បង្អុរទឹក) ចូរបង្អុរមកចុះ ។

ឧត្តិយត្ថេរ ។

(៥៥) ខ្ញុំបានចូលទៅកាន់ព្រៃអញ្ជន ហើយធ្វើខ្ទមជាទីគ្រែអាសន្ទិ[១] (ហើយអង្គុយ) ខ្ញុំបានដល់ត្រៃវិជ្ជា ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

អញ្ជនវនិយត្ថេរ ។

(៥៦) (ទេវតាសួរថា) នរណា (អង្គុយនៅ) ក្នុងខ្ទម (ព្រះថេរៈតបថា) ភិក្ខុអ្នកប្រាសចាករាគៈ មានចិត្តតម្កល់ទុកល្អ ហើយ(អង្គុយនៅ) ក្នុងខ្ទម ម្នាលអាវុសោ អ្នកចូរដឹងយ៉ាងនេះថា ខ្ទមដែលអ្នកធ្វើហើយ មិនឥតប្រយោជន៍ទេ ។

កុដិវិហារិត្ថេរ ។

(៥៧) ខ្ទមនេះជារបស់ចាស់ កាលបើ អ្នកប្រាថ្នាខ្ទមថ្មីឯទៀត អ្នកចូរបណ្តោញ នូវសេចក្តីប្រាថ្នាចំពោះខ្ទមចាស់ចេញ ម្នាលភិក្ខុ ខ្ទមថ្មីទៀត តែងនាំមកនូវទុក្ខ ។

កុដិវិហារិត្ថេរ ។

១ គ្រែអាសន្ទិ ជាគ្រែដែលមានជើងខ្ពស់ហួសប្រមាណ ជំរាលអំពីជើងបាតខ្នងឡើងទៅ ដែលភិក្ខុទាំងឡាយ [illegible] ។ អដ្ឋកថា ។

(៥៩) រមណីយា មេ កុដិកា សទ្ធាទេយ្យា មនោរមា
ន មេ អត្ថោ កុមារីហិ យេសំ អត្ថោ តហឹ គច្ឆន្តុ នារិយោ ។

រមណីយកុដិកោ ថេរោ ។

(៦០) សទ្ធាយាហំ បព្វជិតោ អរញ្ញេ មេ កុដិកា កតា
អប្បមត្តោ ច អាតាបី សម្បជានោ បតិស្សតោ ។

កោសល្លវិហារី ថេរោ ។

(៦១) តេ មេ ឥជ្ឈឹសុ សង្កប្បា យទត្ថោ បាវិសឹ កុដឹ
វិជ្ជាវិមុត្តឹ បច្ចេសំ មានានុសយមុជ្ជហន្តិ ។

សីវលី ថេរោ ។

## ឧទ្ទានំ

គោធិកោ ច សុពាហុ ច វល្លិយោ ឧត្តិយោ ឥសិ
អញ្ជនវនិយោ ថេរោ ទុវេ កុដិវិហារិនោ
រមណីយកុដិកោ ថេរោ(១) កោសលវ្ហយសីវលិតិ ។

វគ្គោ ឆដ្ឋោ ។

១ ម. ម. ច ។



(៥៩) កុដិរបស់ខ្ញុំដែលគេឲ្យដោយសទ្ធា ជាកុដិគួរត្រេកអរ ជាទីត្រេកអរនៃចិត្ត ខ្ញុំមិនមានសេចក្តីត្រូវការដោយកុមារីទាំងឡាយទេ ពួកជនណា មានសេចក្តីត្រូវការ ចូរនារីទាំងឡាយទៅក្នុងទីនោះ(របស់ពួកជននោះ)ចុះ ។

រមណីយកុដិកត្ថេរ ។

(៦០) ខ្ញុំបួសដោយសទ្ធា កុដិរបស់ខ្ញុំបានធ្វើទុកក្នុងព្រៃហើយ ខ្ញុំមិនប្រមាទ មានព្យាយាមដុតកិលេស មានសតិខ្ជាប់ខ្ជួន មានការដឹងខ្លួនជាក់លាក់ ។

កោសល្លវិហារិត្ថេរ ។

(៦១) សេចក្តីត្រិះរិះទាំងនោះ (មានធម្មសង្កប្បៈជាដើម) សម្រេចហើយដល់ខ្ញុំ ខ្ញុំមានសេចក្តីត្រូវការនឹងចូលទៅកាន់កុដិ ដែលជាកុដិខ្ញុំ បានដល់នូវវិជ្ជា និងវិមុត្តិ លះបង់នូវមានានុស័យ ។

សីវលិត្ថេរ ។

## ឧទ្ទាន

និយាយគឺ គោធិកត្ថេរ ១ សុពាហុត្ថេរ ១ វល្លិយត្ថេរ ១ ឧត្តិយត្ថេរជាឥសី ១ អញ្ជនវនិយត្ថេរ ១ កុដិវិហារិត្ថេរ ២ លើក រមណីយកុដិកត្ថេរ ១ កោសល្លវិហារិត្ថេរ ១ សីវលិត្ថេរ ១ ។

ចប់ វគ្គ៦ ។

## ថេរគាថាយ ឯកនិបាតស្ស សត្តមវគ្គោ

(៦២) បស្សតិ បស្សោ បស្សន្តំ   អបស្សន្តញ្ច បស្សតិ
អបស្សន្តោ អបស្សន្តំ   បស្សន្តញ្ច ន បស្សតីតិ ។

វប្បោ ថេរោ ។

(៦៣) ឯកកា មយំ អរញ្ញេ វិហរាម
អបវិទ្ធំវ វនស្មឹ ទារុកំ
តស្ស មេ ពហុកា បិហយន្តិ
នេរយិកា វិយ សគ្គគាមិនន្តិ ។

វជ្ជិបុត្តោ ថេរោ ។

(៦៤) ចុតា បតន្តិ បតិតា   គិទ្ធា ច បុនរាគតា
កតំ កិច្ចំ រតំ រម្មំ[១]   សុខេនន្វាគតំ សុខន្តិ ។

បក្ខោ ថេរោ ។

(៦៥) ទុមវ្ហយាយ ឧប្បន្នោ   ជាតោ បណ្ឌរកេតុនា
កេតុហា កេតុនា យេវ   មហាកេតុំ បធំសយីតិ ។

វិមលកោណ្ឌញ្ញោ ថេរោ ។

១ ឱ. ម. កតំ កិច្ចំ រតំ រម្មំ ។



## ថេរគាថា ឯកនិបាត សត្តមវគ្គ

(៦២) បណ្ឌិតអ្នកឃើញ រមែងឃើញនូវបណ្ឌិតអ្នកឃើញ (ផងក្តី)ផង ឃើញកាល អ្នកមិនឃើញផង ឯកាលអ្នកមិនឃើញ រមែងមិនឃើញកាល ដែលមិនឃើញ (ផងក្តី)ផង នូវបណ្ឌិតអ្នកឃើញផង ។

វប្បត្ថេរ ។

(៦៣) យើងម្នាក់ឯងនៅក្នុងព្រៃ ដូចកំណាត់ឈើ ដែលគេចោលក្នុងព្រៃ ពួកកុលបុត្តជាច្រើនរូប រមែងស្រឡាញ់យើង ដូចពួកសត្វនរក ស្រឡាញ់អ្នកដែលទៅកាន់ឋានសួគ៌ ។

វជ្ជីបុត្តត្ថេរ ។

(៦៤) ពួកសត្វ (ឃាតកាកុសលធម៌) ធ្លាក់ចុះហើយ រមែងធ្លាក់ចុះ ឯពួកសត្វដែលជាប់ចំពាក់(ក្នុងកាម)តែងមកវិញ សោឡសកិច្ចដែលអាត្មាអញធ្វើហើយ ជាតម្រេកដែលគួរត្រេកអរ ព្រះនិព្វានជាសុខ ដែលមូលម៉ត្តដោយសេចក្តីសុខ ។

បក្ខត្ថេរ ។

(៦៥) វិមលកោណ្ឌញ្ញៈ កើតអំពីស្រី មានដើមឈើជាឈ្មោះ(អម្ពបាលី) កើតដោយស្តេចដូចជាទង់ពណ៌ស (ព្រះបាទពិម្ពិសារ) សះបង់នូវទង់ គឺមានះ កំចាត់បង់នូវទង់ធំ គឺមានះ ដោយប្រាជ្ញាដូចជាទង់ ។

វិមលកោណ្ឌញ្ញត្ថេរ ។

(៦៦) ឧក្ខេបកតវច្ឆស្ស សង្កលិតំ ពហូហិ វស្សេហិ
តំ ភាសតិ គហដ្ឋានំ សុនិសិន្នោ ឧឡារបាមោជ្ជោតិ ។

ឧក្ខេបកតវច្ឆោ ថេរោ ។

(៦៧) អនុសាសិ មហាវីរោ សព្វធម្មាន បារគូ
តស្សាហំ ធម្មំ សុត្វាន វិហាសឹ សន្តិកេ រតោ[១]
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

មេឃិយោ ថេរោ ។

(៦៨) កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោតិ ។

ឯកធម្មសវនីយោ ថេរោ ។

(៦៩) អធិចេតសោ អប្បមជ្ជតោ
មុនិនោ មោនបថេសុ សិក្ខតោ
សោកា ន ភវន្តិ តាទិនោ
ឧបសន្តស្ស សទា សតីមតោតិ ។

ឯកុទានិយោ ថេរោ ។

១ ឥទ្ធិ សន្តាវិបិ បាឋោ ទិស្សតិ ។



(៦៦) ពុទ្ធវចនៈដែលប្រមូលរៀនក្នុងសំណាក់នៃឧក្ខេបកតវច្ឆត្ថេរ ព្រះថេរៈនោះ រមែងសំដែងនូវពុទ្ធវចនៈនោះ ដល់គ្រហស្ថទាំងឡាយ បាន អស់ឆ្នាំជាច្រើន លោកជាអ្នកមានសេចក្តីរីករាយដ៏លើសលុប អង្គុយនៅដ៏ស្ងប់ស្ងៀម ។

ឧក្ខេបកតវច្ឆត្ថេរ ។

(៦៧) ព្រះសម្ពុទ្ធ ជាមហាវីរបុរស ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រៀនប្រដៅហើយ ខ្ញុំបានស្តាប់ធម៌របស់ព្រះអង្គ ជាអ្នកត្រេកអរ នៅក្នុងសំណាក់(ព្រះអង្គ) ត្រៃវិជ្ជាខ្ញុំបានដល់ហើយ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

មេឃិយត្ថេរ ។

(៦៨) កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានដក ចោលហើយ ជាតិសំសារក៏អស់ហើយ ភពថ្មីទៀត មិនមានក្នុងកាលឥឡូវនេះទេ ។

ឯកធម្មសវនីយត្ថេរ ។

(៦៩) សេចក្តីសោក រមែងមិនមានដល់អ្នកប្រាជ្ញ មានចិត្តដ៏ខ្ពង់ខ្ពស់ ជាអ្នកមិនប្រមាទ សិក្សាក្នុងធម៌ជាគន្លងនៃការរបស់មុនី មានតាទិគុណ ជាអ្នកស្ងប់រម្ងាប់ មានសតិគ្រប់កាល ។

ឯកុទានិយត្ថេរ ។

(៧០) សុត្វាន ធម្មំ មហតោ មហារសំ
សព្វញ្ញុតញ្ញាណវរេន ទេសិតំ
មគ្គំ បបជ្ជិំ អមតស្ស បត្តិយា
សោ យោគក្ខេមស្ស បថស្ស កោវិទោតិ ។

ជេន្តោ ថេរោ ។

(៧១) សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ
មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោ ជយន្តិ ។

បុណ្ណោ ថេរោ ។

## ឧទ្ទានំ

វជ្ជោ ច វឌ្ឍមុត្តោ ច បក្ខោ វិមលកោណ្ឌញ្ញោ
ឧក្ខេបកដវច្ឆោ ច មេឃិយោ ឯកធម្មិកោ
ឯកុទានិយឆន្នោ ច បុណ្ណត្ថេរោ មហាពលោតិ ។

វគ្គោ សត្តមោ ។



(៧០) ខ្ញុំបានស្តាប់សច្ចធម៌ មានរសដ៏ប្រសើរ របស់ព្រះមានព្រះភាគជាបុគ្គលប្រសើរ ដែលព្រះពុទ្ធមានសព្វញ្ញុតញ្ញាណប្រសើរ សំដែងហើយ ប្រតិបត្តិតាមអដ្ឋង្គិកមគ្គ ដើម្បីដល់ព្រះនិព្វានឈ្មោះអមតៈ ព្រះមានព្រះភាគនោះ ព្រះអង្គជាបុគ្គលឈ្លាសវៃក្នុងផ្លូវនៃព្រះនិព្វាន ដ៏ក្សេមចាកយោគៈ ។

ជេន្តត្ថេរ ។

(៧១) សីលហ្នឹងឯង ជាកំពូលក្នុងសាសនានេះ ចំណែកបុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ជ័យជំនះក្នុងមនុស្សនិងទេវតាទាំងឡាយ រមែងមានព្រោះសីលនិងប្រាជ្ញា ។

បុណ្ណត្ថេរ ។

## ឧទ្ទាន

និយាយអំពីវជ្ជត្ថេរ ១ វឌ្ឍមុត្តត្ថេរ ១ បក្ខត្ថេរ ១ វិមលកោណ្ឌញ្ញត្ថេរ ១ ឧក្ខេបកដវច្ឆត្ថេរ ១ មេឃិយត្ថេរ ១ ឯកធម្មសវនិយត្ថេរ ១ ឯកុទានត្ថេរ ១ ឆន្នត្ថេរ ១ បុណ្ណត្ថេរ ជាអ្នកមានកំឡាំងច្រើន ១ ។

ចប់ សត្តមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស អដ្ឋមវគ្គោ

(៧២) សុសុខុមនិបុណត្ថទស្សិនា
មតិកុសលេន និវាតវុត្តិនា
សំសេវិតវុឌ្ឍសីលិនា
និព្ពានំ ន ហិ តេន ទុល្លភំ ។

វច្ឆបាលោ ថេរោ ។

(៧៣) យថា កឡីរោ សុសុ វឌ្ឍិតគ្គោ
ទុន្និក្ខមោ(១) ហោតិ បសាខជាតោ
ឯវំ អហំ ភរិយាយានីតាយ
អនុមញ្ញ មំ បព្វជិតោម្ហិ ទានិ ។

អាតុមោ ថេរោ ។

(៧៤) ជិណ្ណញ្ច ទិស្វា ទុខិតញ្ច ព្យាធិតំ
មតញ្ច ទិស្វា គតមាយុសង្ខយំ
តតោ អហំ និក្ខមិតូន បព្វជឹ
បហាយ កាមានិ មនោរមានិ ។

មាណវោ ថេរោ ។

---

១ ឱ. ម. ទុន្និក្ខមោ ។



## ថេរគាថា ឯកនិបាត អដ្ឋមវគ្គ

(៧២) បុគ្គលអ្នកយល់ឃើញប្រយោជន៍ដ៏ល្អិតសុខុមក្រៃលែង ជាអ្នកឈ្លាសវៃដោយប្រាជ្ញា មានកិរិយាប្រព្រឹត្តទន់ទាប ជាអ្នកសេពគប់ហើយនូវសីលនៃព្រះពុទ្ធនោះ មិនមែនបានព្រះនិព្វានដោយក្រទេ ។

វច្ឆបាលត្ថេរ ។

(៧៣) ទំពាំងឫស្សីនៅខ្ចី មានពន្លកលូតលាស់ រែកដៃចេញហើយ បុគ្គលដកចេញបានដោយក្រ យ៉ាងណាមិញ ខ្ញុំកាលបើមាតាគាត់នាំភរិយាមកឲ្យ ក៏យ៉ាងនោះដែរ សូមញោមយល់តាមខ្ញុំចុះ ព្រោះឥឡូវនេះ ខ្ញុំបួសហើយ ។

អាតុមត្ថេរ ។

(៧៤) ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខ ព្រមទាំងឃើញមនុស្សដល់នូវការអស់ទៅនៃអាយុ ស្លាប់ហើយ ទើបខ្ញុំលះបង់កាមជាទីត្រេកអរនៃចិត្ត ហើយចេញបួស ។

មាណវត្ថេរ ។

(៧៤) កាមច្ឆន្ទោ ច ព្យាបាទោ ថីនមិទ្ធញ្ច ភិក្ខុនោ
ឧទ្ធច្ចំ វិចិកិច្ឆា ច សព្វសោវ ន វិជ្ជតិ ។

សុយាមនោ ថេរោ ។

(៧៥) សាធុ សុវិហិតាន ទស្សនំ
កង្ខា ឆិជ្ជតិ ពុទ្ធិ វឌ្ឍតិ
ពាលម្បិ ករោន្តិ បណ្ឌិតំ
តស្មា សាធុ សតំ សមាគមោ ។

សុសារទោ ថេរោ ។

(៧៦) ឧប្បតន្តេសុ និបតេ និបតន្តេសុ ឧប្បតេ
វសេ អវសមានេសុ រមមានេសុ នោ រមេ ។

បិយញ្ជហោ ថេរោ ។

(៧៧) ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហេស្សាមិ យោនិសោ
ហត្ថឹ បភិន្នំ វិយ អង្កុសគ្គាហោ ។

ហត្ថារោហបុត្តោ ថេរោ ។



(៧៤) កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា រមែងមិនមានដល់ភិក្ខុ ដោយសព្វគ្រប់ ។

សុយាមនត្ថេរ ។

(៧៥) ការឃើញនូវព្រះអរិយៈទាំងឡាយ មានគន្លងការរៀបចំល្អហើយ ជាការប្រពៃ (ព្រោះថា) សេចក្តីសង្ស័យរមែងដាច់ បញ្ញារមែងចំរើនឡើង ព្រះអរិយៈទាំងនោះរមែងធ្វើសូម្បីនូវជនពាលឲ្យជាបណ្ឌិតបាន ព្រោះហេតុនោះ ការសមាគមនៃសប្បុរសទាំងឡាយជាការប្រពៃ ។

សុសារទត្ថេរ ។

(៧៦) កាលពួកសត្វកំពុងប៉ោងឡើង បណ្ឌិតតែងឱនលំទោន កាលពួកសត្វធ្លាក់ចុះ (ដោយអំណាចកោសជ្ជៈ) បណ្ឌិតតែងប្រឹងឡើង កាលពួកសត្វមិនបាននៅ (ព្រហ្មចរិយធម៌) បណ្ឌិតតែងនៅ កាលពួកសត្វត្រេកអរ (ក្នុងកាមគុណ) បណ្ឌិតមិនត្រេកអរទេ ។

បិយញ្ជហត្ថេរ ។

(៧៧) ចិត្តនេះ ក្នុងកាលមុន បានត្រាច់ទៅកាន់ចារិក តាមសេចក្តីប្រាថ្នា តាមចំណង់ តាមសេចក្តីស្រួល ថ្ងៃនេះ ខ្ញុំនឹងផ្ចាញ់ផ្ចាល់ចិត្តនោះដោយឧបាយ ដូចជាហ្មដំរីអ្នកកាន់កង្វេរ សង្កត់សង្កិនដំរីដែលចុះប្រេង ។

ហត្ថារោហបុត្តត្ថេរ ។

(៧៩) អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
តស្ស មេ ទុក្ខជាតស្ស ទុក្ខក្ខន្ធោ បរទ្ធោ[1]តិ ។

មេណ្ឌសិរោ ថេរោ ។

(៨០) សព្វោ រាគោ បហីនោ មេ សព្វោ ទោសោ សមូហតោ
សព្វោ មេ វិគតោ មោហោ សីតិភូតោស្មិ និព្វុតោតិ ។

រក្ខិតោ ថេរោ ។

(៨១) យំ មយា បកតំ កម្មំ អប្បំ វា យទិ វា ពហុំ
សព្វមេតំ បរិក្ខីណំ នត្ថិ ទានិ បុនព្ភវោតិ ។

ឧគ្គោ ថេរោ ។

## ឧទ្ទានំ

វច្ឆបាលោ ច យោ ថេរោ អាតុមោ មាណវោ ឥសិ
សុយាមនោ សុសារទោ ថេរោ យោ ច បិយញ្ជហោ
អារោហបុត្តោ មេណ្ឌសិរោ រក្ខិតោ ឧគ្គសវ្ហយោតិ ។

វគ្គោ អដ្ឋមោ ។

១ ឱ. ម. អបរទ្ធោតិ ។



(៧៩) កាលខ្ញុំមិនបានជួប (ញាណ) តែងអន្ទោលទៅកាន់សំសារ អស់ជាតិមិនតែមួយទេ គំនរនៃសេចក្តីទុក្ខរបស់ខ្ញុំ ដែលខ្ញុំចូលដល់ហើយនោះ ជាគំនរទុក្ខប្រាសចេញទៅហើយ ។

មេណ្ឌសិរត្ថេរ ។

(៨០) រាគៈទាំងពួង ខ្ញុំលះបង់ហើយ ទោសៈទាំងពួង ខ្ញុំក៏ដកចោលហើយ មោហៈទាំងពួងរបស់ខ្ញុំ ក៏ប្រាសចេញហើយ ខ្ញុំជាបុគ្គលត្រជាក់ រលត់ទុក្ខហើយ ។

រក្ខិតត្ថេរ ។

(៨១) អំពើណា ទោះតិចឬច្រើន ដែលខ្ញុំធ្វើហើយ អំពើទាំងអស់នុ៎ះ ក៏អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

ឧគ្គត្ថេរ ។

## ឧទ្ទាន

និយាយអំពី វច្ឆបាលត្ថេរ១ អាតុមត្ថេរ១ មាណវត្ថេរជាឥសី១ សុយាមនត្ថេរ១ សុសារទត្ថេរ១ បិយញ្ជហត្ថេរ១ អារោហបុត្តត្ថេរ១ មេណ្ឌសិរត្ថេរ១ រក្ខិតត្ថេរ១ ព្រះថេរឈ្មោះឧគ្គៈ១ ។

ចប់ អដ្ឋមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស នវមវគ្គោ

(៨២) យំ មយា បកតំ បាបំ បុព្វេ អញ្ញាសុ ជាតិសុ

ឥធេវ តំ វេទនីយំ វត្ថុ អញ្ញំ ន វិជ្ជតីតិ ។

សមិទ្ធិគុត្តោ ថេរោ ។

(៨៣) យេន យេន សុភិក្ខានិ សិវានិ អភយានិ ច

តេន បុត្តក គច្ឆស្សុ មា សោកាបហតោ ភវាតិ ។

កស្សបោ ថេរោ ។

(៨៤) សីហប្បមត្តោ វិហរ រត្តិន្ទិវមតន្ទិតោ

ភាវេហិ កុសលំ ធម្មំ ជហ សីឃំ សមុស្សយន្តិ ។

សីហោ ថេរោ ។

(៨៥) សព្វរត្តឹ សុបិត្វាន ទិវា សង្គណិកេ រតោ

កុទាស្សុ នាម ទុម្មេធោ ទុក្ខស្សន្តំ ករិស្សតីតិ ។

នីតោ ថេរោ ។

(៨៦) ចិត្តនិមិត្តស្ស កោវិទោ បវិវេករសំ វិជានិយ



## ថេរគាថា ឯកនិបាត នវមវគ្គ

(៨២) អំពើលាមកណា ដែលខ្ញុំបានធ្វើហើយ ក្នុងជាតិទាំងឡាយ

ដទៃ ក្នុងកាលមុន អំពើលាមកនោះ ខ្ញុំគប្បីទទួលផលក្នុងជាតិ

នេះឯង វត្ថុដទៃមិនមានឡើយ ។

សមិទ្ធិគុត្តត្ថេរ ។

(៨៣) ទីណាមានភិក្ខាហារដ៏សម្បូណ៌ផង ទីដ៏ក្សេមក្សាន្ត មិនមានភ័យផង

មានក្នុងទិសណាៗ ម្នាលកូន អ្នកចូរទៅក្នុងទិសនោះចុះ សូម

កុំឲ្យអ្នកមានសេចក្តីសោកបៀតបៀនបានឡើយ ។

កស្សបត្ថេរ ។

(៨៤) ម្នាលភិក្ខុឈ្មោះសីហៈ ចូរអ្នកកុំប្រមាទ កុំខ្ជិលច្រអូស អស់

យប់និងថ្ងៃ ចូរអ្នកចំរើនកុសលធម៌ចុះ ចូរអ្នកលះបង់នូវគ្រឿងកាយ

គឺអត្តភាពដោយឆាប់ចុះ ។

សីហត្ថេរ ។

(៨៥) បុគ្គលដេកលក់ពេញមួយរាត្រីទាំងអស់ ត្រេកអរក្នុងពួកគណៈ ក្នុង

វេលាថ្ងៃ ជាអ្នកអប្បប្បញ្ញា កាលណានឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

នីតត្ថេរ ។

(៨៦) បុគ្គលឈ្លាសវៃ ក្នុងនិមិត្តរបស់ចិត្ត ដឹងច្បាស់នូវរសនៃវិវេក

ឈាយំ និបកោ បតិស្សតោ អធិគច្ឆេយ្យ សុខំ និរាមិសន្តិ ។

សុនាគោ ថេរោ ។

(៨៧) ឥតោ ពហិទ្ធា បុថុអញ្ញវាទិនំ

មគ្គោ ន និព្វានគមោ យថា អយំ

ឥតិស្ស សង្ឃំ ភគវានុសាសតិ

សត្ថា សយំ បាណិតលេវ ទស្សយន្តិ ។

នាគិតោ ថេរោ ។

(៨៨) ខន្ធា ទិដ្ឋា យថាភូតំ ភវា សព្វេ បទាលិតា

វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោតិ ។

បវិដ្ឋោ ថេរោ ។

(៨៩) អសក្ខឹ វត អត្តានំ ឧទ្ធាតុំ ឧទកា ថលំ

វុយ្ហមានោ មហោឃេវ សច្ចានិ បដិវិជ្ឈហន្តិ[១] ។

អជ្ជុនោ ថេរោ ។

(៩០) ឧត្តិណ្ណា បង្កា បលិបា បាតាលា បរិវជ្ជិតា

មុត្តោ ឱឃា ច គន្ថា ច សព្វេ មានា វិសំហតាតិ ។

ទេវសភោ ថេរោ ។

១ ម. អ. បដិវិជ្ឈន្តិ ។



ផុតកំដៅកិលេស ជាអ្នកមានប្រាជ្ញារក្សាខ្លួន មានស្មារតីតាំងមាំ គប្បីបាននូវនិរាមិសសុខ គឺព្រះនិព្វាន ។

សុនាគត្ថេរ ។

(៨៧) ព្រះមានព្រះភាគជាសាស្តាចារ្យ កាលសំដែងដោយព្រះ

អង្គឯង (ដូចផ្លែកន្ទួតព្រៃ) ក្នុងបាតដៃ តែងប្រៀនប្រដៅសង្ឃ

យ៉ាងនេះថា ផ្លូវដ៏ប្រសើរនេះ ជាផ្លូវទៅកាន់ព្រះនិព្វានមិនមែន

ដូចផ្លូវរបស់ពួកអ្នកពោលវាទផ្សេងៗ ខាងក្រៅសាសនានេះទេ ។

នាគិតត្ថេរ ។

(៨៨) ខន្ធទាំងឡាយខ្ញុំឃើញច្បាស់ហើយ តាមសេចក្តីពិត ភពទាំងពួង ខ្ញុំទំលាយហើយ ជាតិសង្សារអស់ហើយ ឥឡូវនេះភពថ្មីមិនមានទេ ។

បវិដ្ឋត្ថេរ ។

(៨៩) ខ្ញុំកាលយល់ច្បាស់នូវសច្ចធម៌ទាំងឡាយ ទើបអាចនឹងរើខ្លួនឡើង ចាកទឹកគឺសំសារ ឡើងកាន់គោកគឺព្រះនិព្វាន ដូចជាជនដ៏ កាលបន្សាត់ទៅ ។

អជ្ជុនត្ថេរ ។

(៩០) ខ្ញុំឆ្លងឡើងផុត ចាកភក់ ចាកល្បាប់ គឺកិលេសហើយ វៀរ ស្រឡះហើយចាកបាតាល (ទំនាប) គឺឃោរៈ រួចផុតហើយ ចាកឱឃៈផង គន្ថៈផង មានះទាំងពួង ខ្ញុំកំចាត់បង់ហើយ ។

ទេវសភត្ថេរ ។

[៩១] បញ្ចក្ខន្ធា បរិញ្ញាតា តិដ្ឋន្តិ ឆិន្នមូលកា

វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោតិ ។

សាមិទត្តោ ថេរោ ។

## ឧទ្ទានំ

ថេរោ សមិតិគុត្តោ ច កស្សបោ សីហសវ្ហយោ

នីតោ សុនាគោ នាគិតោ បវិដ្ឋោ អជ្ជុនោ ឥសិ

ទេវសភោ ច យោ ថេរោ សាមិទត្តោ មហព្ភយោតិ ។

វគ្គោ នវមោ ។



[៩១] ខន្ធ ៥ ខ្ញុំកំណត់ដឹងហើយ ខន្ធ៥មានឫសគល់ដាច់ហើយ ជាតិ-

សំសារអស់ហើយ ភពថ្មីទៀត (របស់ខ្ញុំ)មិនមានក្នុងកាលឥឡូវនេះ ។

សាមិទត្តត្ថេរ ។

## ឧទ្ទាន

និយាយអំពី សមិតិគុត្តត្ថេរ ១ កស្សបត្ថេរ ១ សីហត្ថេរ ១

នីតត្ថេរ ១ សុនាគត្ថេរ ១ នាគិតត្ថេរ ១ បវិដ្ឋត្ថេរ ១ អជ្ជុនៈជាឥសី ១

ទេវសភត្ថេរ ១ សាមិទត្តត្ថេរ មានភ័យច្រើន ១ ។

ចប់ នវមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស ទសមវគ្គោ

(៩២) ន តថាមតំ សតរសំ សុធន្នំ    យំ មយជ្ជ បរិភុត្តំ
អបរិមិតទស្សិនា គោតមេន    ពុទ្ធេន ទេសិតោ ធម្មោតិ ។

បរិបុណ្ណកោ ថេរោ ។

(៩៣) យស្សាសវា បរិក្ខីណា    អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច    វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ    បទន្តស្ស ទុរន្នយន្តិ ។

វិជយោ ថេរោ ។

(៩៤) ទុក្ខា កាមា ឯរក    ន សុខា កាមា ឯរក
យោ កាមេ កាមយតិ    ទុក្ខំ សោ កាមយតិ ឯរក
យោ កាមេ ន កាមយតិ ទុក្ខំ សោ ន កាមយតិ ឯរកាតិ ។

ឯរកោ ថេរោ ។



## ថេរគាថា ឯកនិបាត ទសមវគ្គ

(៩២) សុធាភោជនមានរសទាំងរយ អាត្មាអញមិនសរសើរដូចភោជន គឺនិព្វានសុខ ដែលអាត្មាអញបរិភោគហើយក្នុងថ្ងៃនេះទេ ធម៌ដែលព្រះពុទ្ធគោតម ព្រះអង្គឃើញដោយបញ្ញាកំណត់មិនបាន ទ្រង់សំដែងហើយ (ទើបជាធម៌មានរសច្រើន) ។

បរិបុណ្ណកត្ថេរ ។

(៩៣) ភិក្ខុណា មានអាសវៈអស់ហើយ មិនជាប់ក្នុងអាហារ ភិក្ខុណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ (អប្បណិហិតវិមោក្ខ) ជាអារម្មណ៍ ស្នាមដើររបស់ភិក្ខុនោះៗ បុគ្គលតាមរកឃើញបានដោយក្រ ដូចស្នាមដើរនៃសត្វស្លាបក្នុងអាកាស ។

វិជយត្ថេរ ។

(៩៤) ម្នាលឯរកៈ កាមទាំងឡាយ ជាទុក្ខ ម្នាលឯរកៈ កាមទាំងឡាយ មិនមែនជាសុខទេ ម្នាលឯរកៈ បុគ្គលណា ប្រាថ្នារកកាម បុគ្គលនោះ ឈ្មោះថាប្រាថ្នាទុក្ខ ម្នាលឯរកៈ បុគ្គលណាមិនប្រាថ្នារកកាម បុគ្គលនោះ ឈ្មោះថាមិនប្រាថ្នាទុក្ខទេ ។

ឯរកត្ថេរ ។

(៩៥) នមោ ហិ តស្ស ភគវតោ សក្យបុត្តស្ស សិរីមតោ

យេនាយំ អគ្គប្បត្តេន អគ្គធម្មោ សុទេសិតោតិ ។

មេត្តជិ ថេរោ ។

(៩៦) អន្ធោហំ ហតនេត្តោស្មិ កន្តារទ្ធានបក្ខន្តោ[1]

សយមានោបិ គមិស្សំ ន សហាយេន បាបេនាតិ ។

ចក្ខុបាលោ ថេរោ ។

(៩៧) ឯកំ បុប្ផំ ចជិត្វាន អសីតិ[2] វស្សកោដិយោ

សគ្គេសុ បរិចារេត្វា សេសកេនម្ហិ និព្វុតោតិ ។

ខណ្ឌសុមនោ ថេរោ ។

(៩៨) ហិត្វា សតបលំ កំសំ សោវណ្ណំ សតរាជិកំ

អគ្គហឹ មត្តិកាបត្តំ ឥទំ ទុតិយាភិសេចនន្តិ ។

តិស្សោ ថេរោ ។

---

១ ម. បក្ខន្នោ ។ ២ ម. អសីតិ ... ។

១៦៦

សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា

(៩៥) សូមនមស្ការ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាសក្យបុត្ត មានសិរី ព្រះធម៌ដ៏ប្រសើរនេះ ព្រះពុទ្ធដល់នូវធម៌ដ៏ប្រសើរនោះ ទ្រង់សំដែងទុកល្អហើយ ។

មេត្តជិត្ថេរ ។

(៩៦) ខ្ញុំជាមនុស្សខ្វាក់ មានភ្នែកដែលគេសកចាក់បង់ហើយ ទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ទោះបីកាលដេក ក៏ខ្ញុំមិនទៅជាមួយនឹងសំឡាញ់ ជាបាបមិត្តទេ ។

ចក្ខុបាលត្ថេរ ។

(៩៧) ខ្ញុំបានបូជាផ្កាមួយ រួចក៏បានឡើងទៅបំរើ ក្នុងឋានសួគ៌អស់ ៨០ កោដិឆ្នាំ (កប់ដោយឆ្នាំមនុស្ស) ខ្ញុំរលត់ទុក្ខដោយផលនៃកម្មដ៏សេសសល់ ។

ខណ្ឌសុមនត្ថេរ ។

(៩៨) ខ្ញុំលះភាជន៍សំរិទ្ធិដែលមានក្បាច់ ១០០ ស្រទាប់ នឹងភាជន៍មាសមានបន្ទាត់ ១០០ ជាន់ ហើយត្រឡប់មកកាន់យកបាត្រដីវិញ ការចូលកាន់ផ្នួសរបស់ខ្ញុំនេះ ឈ្មោះថាជាការអភិសេកទីពីរ ។

តិស្សត្ថេរ ។

(៩៩) រូបំ ទិស្វា សតិ មុដ្ឋា  បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ  តញ្ច អជ្ឈោសវ តិដ្ឋតិ
តស្ស វឌ្ឍន្តិ អាសវា  ភវមូលោបគាមិនោតិ ។

អភយោ ថេរោ ។

(១០០) សទ្ទំ សុត្វា សតិ មុដ្ឋា  បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ  តញ្ច អជ្ឈោសវ តិដ្ឋតិ
តស្ស វឌ្ឍន្តិ អាសវា  សំសារំ ឧបគាមិនោតិ

ឧត្តិយោ ថេរោ ។

(១០១) សម្មប្បធានសម្បន្នោ  សតិបដ្ឋានគោចរោ
វិមុត្តិកុសុមសញ្ឆន្នោ  បរិនិព្វាយិស្សត្យនាសវោតិ ។

ទេវសភោ ថេរោ ។

## ឧទ្ទានំ

បរិបុណ្ណកោ ច វិជយោ  ឯរកោ មេត្តជី មុនិ
ចក្ខុបាលោ ខណ្ឌសុមនោ  តិស្សោ អភយោ ច
ឧត្តិយោ មហាបញ្ញោ  ថេរោ ទេវសភោបិ ចាតិ ។

វគ្គោ ទសមោ ។



(៩៩) បុគ្គលកាលឃើញរូបហើយធ្វើទុកក្នុងចិត្ត នូវនិមិត្តជាទីស្រឡាញ់ សតិ រមែងភាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរ ទទួលយក លេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយ ដែលជាគ្រឿងនាំចូលទៅកាន់ឫសគល់នៃភព រមែងចំរើនដល់បុគ្គលនោះ ។

អភយត្ថេរ ។

(១០០) បុគ្គលកាលស្តាប់សំឡេង ហើយធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ សតិ រមែងភាំងភ្លាត់ បុគ្គលនោះមានចិត្តត្រេកអរ ទទួលយក លេបយកនូវអារម្មណ៍នោះ អាសវៈទាំងឡាយ ដែលជាគ្រឿងនាំចូលទៅកាន់សង្សារ រមែងចំរើនដល់បុគ្គលនោះ ។

ឧត្តិយត្ថេរ ។

(១០១) បុគ្គលប្រកបដោយសម្មប្បធាន មានសតិប្បដ្ឋានជាអារម្មណ៍ ដ៏ផេរផាសដោយផ្កានៃវិមុត្តិ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ទេវសភត្ថេរ ។

## ឧទ្ទាន

និយាយអំពី បរិបុណ្ណកត្ថេរ ១ វិជយត្ថេរ ១ ឯរកត្ថេរ ១ មេត្តជិត្ថេរ ជាអ្នកប្រាជ្ញ ១ ចក្ខុបាលត្ថេរ ១ ខណ្ឌសុមនត្ថេរ ១ តិស្សត្ថេរ ១ អភយត្ថេរ ១ ឧត្តិយត្ថេរមានបញ្ញាច្រើន ១ ទេវសភត្ថេរ ១ ។

ចប់ ទសមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស ឯកាទសមវគ្គោ

(១០២) ហិត្វា គិហិត្តំ អនវោសិតត្តោ
មុខនង្គលី ឱទរិកោ កុសីតោ
មហាវរាហោវ និវាបបុដ្ឋោ
បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

ពេលដ្ឋកានិ[១] ថេរោ ។

(១០៣) មានេន វញ្ចិតាសេ[២]
សង្ខារេសុ សង្កិលិស្សមានាសេ
លាភាលាភេន មថិតា សមាធិំ នាធិគច្ឆន្តិ ។

សេតុច្ឆោ ថេរោ ។

(១០៤) នាហំ ឯតេន អត្ថិកោ
សុខិតោ ធម្មរសេន តប្បិតោ
បិត្វាន រសគ្គមុត្តមំ ន ច កាហាមិ វិសេន សន្ថវំ[៣] ។

ពន្ធុរោ ថេរោ ។

(១០៥) លហុកោ វត មេ កាយោ
ផុដ្ឋោ ច បីតិសុខេន វិបុលេន
តូលមិវ ឯរិតំ មាលុតេន បិលវតីវ មេ កាយោ ។

ខិតកោ ថេរោ ។

---

១ ម. ពេលដ្ឋិកោ ។ ២ ម. វញ្ចិកា មានសេ ។ ៣ ម.ម. វិសេន ។



## ថេរគាថា ឯកនិបាត ឯកាទសមវគ្គ

(១០២) បុរសបុគ្គលល្ងង់ខ្លៅ លះបង់សភាព ជាគ្រហស្ថ (ចូលកាន់ផ្នួស) ជាអ្នកមិនបានអប់រំខ្លួន ជាអ្នកមានមាត់ដូចជានង្គ័ល ខ្ជិលច្រអូស បានតែកាន់ចិញ្ចឹមពោះ ដូចជ្រូកស្រុកធំ ដែលគេចិញ្ចឹមដោយចំណី តែងចូលទៅកាន់គភ៌រឿយៗ ។

ពេលដ្ឋកានិត្ថេរ ។

(១០៣) ជនទាំងឡាយដែលត្រូវមានៈបញ្ឆោត សៅហ្មងក្នុងសង្ខារ ត្រូវលាភៈ អលាភៈ ញាំញីហើយ រមែងមិនបាននូវសមាធិ ។

សេតុច្ឆត្ថេរ ។

(១០៤) ខ្ញុំមិនត្រូវការដោយលាភនុ៎ះទេ ខ្ញុំបានសេចក្ដីសុខ ឆ្អែតដោយធម្មរស ក្រេបផឹករសដ៏ប្រសើរវិសេស មិនធ្វើនូវការជាប់ដោយពិសទេ ។

ពន្ធុរត្ថេរ ។

(១០៥) ឱហ្ន៎ កាយរបស់ខ្ញុំស្រាល កាលខ្ញុំត្រូវបីតិនិងសុខដ៏ទូលាយ ពាល់ត្រូវហើយ កាយរបស់ខ្ញុំ រមែងអណ្ដែតឡើងបាន ដូចប៉ុយដែលរេរីដោយខ្យល់ ។

ខិតកត្ថេរ ។

(១០៦) ឧក្កណ្ឋិតោបិ ន វសេ រមមានោបិ បក្កមេ
ន ត្វេវានត្ថសំហិតំ វសេ វាសំ វិចក្ខណោតិ ។

មលិតវម្ភោ ថេរោ ។

(១០៧) សតលិង្គស្ស អត្ថស្ស សតលក្ខណធារិនោ
ឯកង្គទស្សី ទុម្មេធោ សតទស្សី ច បណ្ឌិតោតិ ។

សុហេមន្តោ ថេរោ ។

(១០៨) បព្វជឹ តុលយិត្វាន អគារស្មា អនគារិយំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

ធម្មសវោ ថេរោ ។

(១០៩) ស វីសវស្សសតិកោ បព្វជឹ អនគារិយំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

ធម្មសវបិតុត្ថេរោ[១] ។

(១១០) ន នូនាយំ បរមហិតានុកម្បិនោ
រហោគតោ អនុវិគណេតិ សាសនំ
តថាហយំ វិហរតិ បាកតិន្ទ្រិយោ
មិគី យថា តរុណជាតិកា វនេតិ ។

សង្ឃរក្ខិតោ ថេរោ ។

១. ម. ធម្មសវបិតុ ថេរោ ។



(១០៦) បុគ្គលអ្នកឈ្លាសវៃ ទោះបីអផ្សុក ក៏មិនគួរនៅ(ក្នុងអាវាស ដែលមិនសប្បាយ) សូម្បីកាលត្រេកអរក៏ចៀសចេញ មិនគប្បីនៅ គ្រប់គ្រងលំនៅ ដែលប្រកបដោយអំពើមិនជាប្រយោជន៍ទេ ។

មលិតវម្ភត្ថេរ ។

(១០៧) អត្ថមានអាថ៌កំបាំងច្រើន ទ្រទ្រង់លក្ខណៈដ៏ច្រើន ជនឥតប្រាជ្ញ ឃើញអង្គនៃអត្ថតែមួយ ចំណែកបណ្ឌិតជាអ្នកឃើញអត្ថដ៏ច្រើន ។

សុហេមន្តត្ថេរ ។

(១០៨) ខ្ញុំពិចារណាឃើញហើយ ទើបចេញចាកផ្ទះ ចូលកាន់ផ្នួស វិជ្ជា៣ខ្ញុំបានហើយ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

ធម្មសវត្ថេរ ។

(១០៩) ខ្ញុំមានអាយុប្រកបដោយឆ្នាំ១២០ ទើបចេញចាកផ្ទះ ចូលកាន់ផ្នួស វិជ្ជា៣ខ្ញុំបានហើយ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

ធម្មសវបិតុត្ថេរ ។

(១១០) ភិក្ខុនេះត្រេកអរ ក្នុងទីស្ងាត់ហើយ តែក្រែងមិនតើពិនិត្យសាសនា របស់ព្រះមានព្រះភាគ ព្រះអង្គជាអ្នកអនុគ្រោះដោយប្រយោជន៍ដ៏ក្រៃលែងទេឬ ភិក្ខុនេះជាអ្នកមានឥន្ទ្រិយតាំងនៅជាប្រក្រតី នៅក្នុងទីស្ងាត់ដូច្នោះ ដូចជាម្រឹគញីប្រកបដោយជាតិនៅក្មេងដែលនៅក្នុងព្រៃ ។

សង្ឃរក្ខិតត្ថេរ ។

(១២០) នគា នគគ្គេសុ សុសំវិរូឡ្ហា
ឧទគ្គមេឃេន នវេន សិត្តា
វិវេកកាមស្ស អរញ្ញសញ្ញិនោ
ជនេតិ ភិយ្យោ ឧសភស្ស កល្យតន្តិ ។

ឧសភោ ថេរោ ។

ឧទ្ទានំ

ពេលដ្ឋកានិ សេតុច្ឆោ ពន្ធុរេ[១] ខិតកោ ឥសិ
មលិតវម្ភោ សុហេមន្តោ ធម្មសវោ ធម្មសវបិតា[២]
សង្ឃរក្ខិតត្ថេរោ ច ឧសភោ ច មហាមុនិ ។

វគ្គោ ឯកាទសមោ ។

---

១ ម. ពន្ធុរោ ។ ២ ឱ. ម. ធម្មសវោ ធម្មសវបិតា ។



(១២០) ឈើទាំងឡាយ លូតលាស់ឡើងលើកំពូលភ្នំ ត្រូវទឹកភ្លៀងថ្មីធ្លាក់ចុះជោគស្រោចស្រប់ហើយ រមែងញុំាងចិត្តរបស់កាលនាកម្មឲ្យកើតឡើងដោយក្រៃលែងដល់ភិក្ខុឈ្មោះឧសភៈ អ្នកប្រាថ្នាវិវេកធម៌ អ្នកមានសេចក្ដីសំគាល់ក្នុងព្រៃ ។

ឧសភត្ថេរ ។

ឧទ្ទាន

និយាយអំពី ពេលដ្ឋកានិត្ថេរ ១ សេតុច្ឆត្ថេរ ១ ពន្ធុរត្ថេរ ១ ខិតកត្ថេរ ជាឥសី ១ មលិតវម្ភត្ថេរ ១ សុហេមន្តត្ថេរ ១ ធម្មសវត្ថេរ ១ ធម្មសវបិតុត្ថេរ ១ សង្ឃរក្ខិតត្ថេរ ១ ឧសភត្ថេរ ជាមហាមុនី ១ ។

ចប់ ឯកាទសមវគ្គ ។

## ថេរគាថាយ ឯកនិបាតស្ស ទ្វាទសមវគ្គោ

(១១២) ទុប្បព្វជ្ជំ វេ ទុរធិវាសា គេហា

ធម្មោ គម្ភីរោ ទុរធិគមា ភោគា

កិច្ឆា វុត្តិ នោ ឥតរីតរេនេវ

យុត្តំ ចិន្តេតុំ សតតមនិច្ចតន្តិ ។

ជេន្តោ ថេរោ ។

(១១៣) តេវិជ្ជោហំ មហាឈាយី ចេតោសមថកោវិទោ

សទត្ថោ មេ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនន្តិ ។

វច្ឆគោត្តោ ថេរោ ។

(១១៤) អច្ឆោទិកា បុថុសិលា គោនង្គុលមិគាយុតា

អម្ពុសេវាលសញ្ឆន្នា តេ សេលា រមយន្តិ មន្តិ ។

វនវច្ឆោ ថេរោ ។

(១១៥) កាយទុដ្ឋុល្លគរុនោ ហីយមានម្ហិ ជីវិតេ

សរីរសុខគិទ្ធស្ស កុតោ សមណសាធុតាតិ ។

អធិមុត្តោ ថេរោ ។



## ថេរគាថា ឯកនិបាត ទ្វាទសមវគ្គ

(១១២) ការបួសជាការក្រពិត គ្រឹះស្ថានបុគ្គលគ្រប់គ្រងបានដោយក្រ ព្រះធម៌ជាសភាពជ្រាលជ្រៅ ភោគៈទាំងឡាយ គេបានដោយក្រ ការប្រព្រឹត្តិ(ចិញ្ចឹមជីវិត) របស់យើង ដោយបច្ច័យតាមមានតាមបាន ក៏ជាការក្រ យើងគួរគិតនូវអនិច្ចតាធម៌ឲ្យរឿយៗវិញ ។

ជេន្តត្ថេរ ។

(១១៣) ខ្ញុំមានវិជ្ជា៣ មានការដុតកិលេសច្រើន ជាអ្នកឈ្លាសវៃក្នុងចេតោសមថៈ (ការស្ងប់រម្ងាប់ចិត្ត) ប្រយោជន៍របស់ខ្លួន ខ្ញុំបានដល់ហើយ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

វច្ឆគោត្តត្ថេរ ។

(១១៤) ភ្នំទាំងនោះមានទឹកថ្លា មានថ្មដ៏ក្រាស់ ដែលប្រកបដោយម្រឹគមានកន្ទុយដូចគោ (ស្វាខ្មៅ) ដ៏ដេរដាសដោយសារាយក្នុងទឹក តែងញុំាងខ្ញុំឲ្យត្រេកអរ (សប្បាយចិត្តនៅបាន) ។

វនវច្ឆត្ថេរ ។

(១១៥) កាលបើជីវិតសូន្យថយទៅ សេចក្តីល្អរបស់សមណៈ នឹងមានមកក្នុងទីណា ដល់បុគ្គលអ្នកធ្ងន់ក្នុងកាយដ៏អាក្រក់ ជាប់ដោយសេចក្តីសុខក្នុងសរីរៈ ។

អធិមុត្តត្ថេរ ។

(១១៦)បិសាចហិយ្យសេ បត្តេន គាហុកុជនសល្លិកោ[១]
ជេសាធនេន ភិរិតា យសស្សិតា បរិព្វជនាតិ ។

ឧហោតាមោ ថេរោ ។

(១១៧)ឆ ផស្សាយតនេ ហិត្វា គុត្តទ្វារោ សុសំវុតោ
អឃមូលំ វមិត្វាន[២] បត្តោ មេ អាសវក្ខយោតិ ។

ឈាបរិយោ[៣] ថេរោ ។

(១១៨) សុវិលិត្តោ សុវសនោ សព្វាភរណភូសិតោ
តិស្សោ វិជ្ជា អជ្ឈគមឹ កតំ ពុទ្ធស្ស សាសនន្តិ ។

យសោ ថេរោ ។

(១១៩) អភិសត្តោវ និបតតិ វយោ
រូបំ អញ្ញមិវ តថេវ សន្តំ
តស្សេវ សតោ អវិប្បវសតោ
អញ្ញស្សេវ សរាមិ អត្តានន្តិ ។

កិម្ពិលោ[៤] ថេរោ ។

(១២០) រុក្ខមូលគហនំ បសក្កិយ[៥]
និព្វានំ ហទយស្មឹ ឱបិយ[៦]

---

១ ឱ. ម. គហុកុជនសល្លិកេន ។ ២ ឱ. ម. វមិត្វាន ។ ៣ ប. ឈាវិរិយោ ។
៤ ម. កិម្ពិលោ ។ ៥ ឱ. ម. បសក្កិយ ។ ៦ ឱ. ឱសិយ ។



(១១៦) អ្នកទុំនឹងស្របស្ទួយតាកន្លែងឈ្មោះទេសាទក: (ទីនៅនៃអ្នកទេសាទ) ជាកំពង់មានយស បិទបាំងដោយដើមខ្ទឹងគង់ ទីដើមពោធិច្រើនណាស់ ។

ឧហោតាមត្ថេរ ។

(១១៧) បុគ្គលគ្រប់គ្រងទ្វារ សង្រួមដោយល្អ ខ្ជាក់ចោលនូវឫសគល់នៃសេចក្តីទុក្ខ ព្រោះលះបង់ផស្សាយតនៈទាំង ៦ ប្រការ ការអស់ទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ។

ឈាបរិយត្ថេរ ។

(១១៨) ខ្ញុំមានខ្លួនប្រោះព្រំល្អ ស្លៀកពាក់ល្អ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង បាននូវវិជ្ជា ៣ ប្រការ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

យសត្ថេរ ។

(១១៩) វ័យ(របស់សត្វ) តែងធ្លាក់ចុះ ហាក់ដូចជាត្រូវគេផ្តាសាទុក រូប(របស់យើង) កាលមាននៅ ដោយប្រការដូច្នោះ តែហាក់ដូចជារូបអ្នកដទៃ ខ្លួនខ្ញុំនោះ កាលមានពិតតែហាក់ដូចជាមិនមាន ខ្ញុំរឭកឃើញខ្លួន(របស់ខ្ញុំ) ហាក់ដូចជារឭកឃើញខ្លួន របស់អ្នកដទៃដែរ ។

កិម្ពិលត្ថេរ ។

(១២០) អ្នកចូលទៅកាន់គល់ឈើ ដ៏ជាព្រៃញាតស្អាត ហើយក្រសោបយកព្រះនិព្វាន(មកដាក់)ក្នុងហឫទ័យបាន

ឈាយ គោតម មា ច បមាទោ
កិំ តេ ពិឡិពិឡិកា ករិស្សតីតិ ។

វជ្ជិបុត្តោ ថេរោ ។

(១២០) បញ្ចក្ខន្ធា បរិញ្ញាតា តិដ្ឋន្តិ ឆិន្នមូលកា
ទុក្ខក្ខយោ អនុប្បត្តោ បត្តោ មេ អាសវក្ខយោតិ ។

ឥសិទត្តោ ថេរោ ។

## ឧទ្ទានំ

ជេន្តោ ច វច្ឆគោត្តោ ច វច្ឆោ ច វនវច្ឆយោ[១]
អធិមុត្តោ មហានាមោ ចារបរិយោ[២] យសោជោ ច
កិម្ពិលោ[៣] វជ្ជិបុត្តោ ច ឥសិទត្តោ មហាយសោតិ ។

ទ្វាទសមោ វគ្គោ ។

## វគ្គុទ្ទានំ ភវតិ

វិសុត្តរសតំ ថេរា កតកិច្ចា អនាសវា
ឯកកេវ និបាតម្ហិ សុសង្គីតា មហេសិភីតិ ។

ឯកនិបាតោ និដ្ឋិតោ ។

---

១ ឱ. វនវច្ឆយោ ។ ម. វនវច្ឆកោ ។ ២ ម. បារាបរិយោ ។ ៣ ម. កិម្ពិលោ ។



នែគោតម អ្នកចូរពិនិត្យចុះ កុំមានសេចក្ដីប្រមាទឡើយ
សេចក្ដីរាយមាយចិត្ត នឹងធ្វើអ្វី ដល់អ្នកកើត ។

វជ្ជិបុត្តត្ថេរ ។

(១២០) ខន្ធទាំង៥មានឫសដាច់ ដែលខ្ញុំកំណត់ដឹងច្បាស់ហើយ
ការអស់ទៅនៃទុក្ខ ខ្ញុំបានដល់ហើយ ការអស់ទៅនៃអាសវៈ ខ្ញុំក៏
បានដល់ហើយដែរ ។

ឥសិទត្តត្ថេរ ។

## ឧទ្ទាន

និយាយអំពី ជេន្តត្ថេរ១ វច្ឆគោត្តត្ថេរ១ វនវច្ឆត្ថេរ អ្នកមាននាមដ៏ប្រសើរ១ អធិមុត្តត្ថេរ១ មហានាមត្ថេរ១ បារាបរិយត្ថេរ១ យសោជត្ថេរ១ កិម្ពិលត្ថេរ១ វជ្ជិបុត្តត្ថេរ១ ឥសិទត្តត្ថេរ ជាអ្នកមានយសធំ១ ។

ចប់ ទ្វាទសវគ្គ ។

## ឧទ្ទាន ក្នុងឯកនិបាតនោះ គឺ

ព្រះថេរៈ១២០អង្គ មានសេចក្ដីស្រេចកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ ដែលព្រះសង្គីតិកាចារ្យ អ្នកស្វែងរកគុណធំ បានលើកឡើងទុកដោយល្អ ក្នុងឯកនិបាត ។

ចប់ ឯកនិបាត ។

## ថេរគាថាយ ទុកនិបាតស្ស បឋមវគ្គោ

(១២២) នត្ថិ កោចិ ភវោ និច្ចោ សង្ខារា វាបិ សស្សតា
ឧប្បជ្ជន្តិ ច តេ ខន្ធា ចវន្តិ អបរាបរំ ។
ឯតមាទីនវំ ញត្វា ភវេនម្ហិ អនត្ថិកោ
និស្សដោ សព្វកាមេហិ បត្តោ មេ អាសវក្ខយោតិ ។

ឥត្ថំ សុទំ អាយស្មា ឧត្តរោ ថេរោ គាថាយោ អភាសិត្ថាតិ ។

(១២៣) នយិទំ អនយេន ជីវិតំ
នាហារោ ហទយស្ស សន្តិកោ
អាហារដ្ឋិតិកោ សមុស្សយោ
ឥតិ ទិស្វាន ចរាមិ ឯសនំ ។
បង្កោតិ[១] ហិ នំ អវេទយុំ
យាយំ វន្ទនបូជនា កុលេសុ
សុខុមំ សល្លំ ទុរុព្វហំ
សក្ការោ កាបុរិសេន ទុជ្ជហោតិ ។

ឥត្ថំ សុទំ អាយស្មា បិណ្ឌោលភារទ្វាជោ ថេរោ គាថាយោ អភាសិត្ថាតិ ។

១ ម. បង្កោតិ ។



## ថេរគាថា ទុកនិបាត បឋមវគ្គ

(១២២) ភពណាមួយ ជាសភាពទៀងទាត់មិនមានទេ សូម្បីសង្ខារទាំងឡាយ ជាសភាពទៀងទាត់ ក៏មិនមាន ខន្ធទាំងឡាយនោះ រមែងកើតឡើង ច្យុតទៅមក ៗ ។ ខ្ញុំបានដឹងច្បាស់នូវទោសនុ៎ះហើយ ជាអ្នកមិនត្រូវការ ដោយភពទេ បានរលាស់ចាកកាមទាំងពួងហើយ ការអស់ទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ។

ឮថា ឧត្តរត្ថេរមានអាយុ បានសំដែងនូវគាថាទាំងឡាយដោយប្រការដូច្នេះ ។

(១២៣) ជីវិត (របស់ខ្ញុំ)នេះ រមែងមិនមាន ព្រោះការមិនប្រព្រឹត្តទៅ អាហារមិនមែនធ្វើឲ្យស្ងប់ដល់ហឫទ័យបានទេ គ្រោងកាយ តាំងនៅបានដោយអាហារ ខ្ញុំប្រព្រឹត្តនូវការស្វែងរក ព្រោះឃើញដូច្នេះ ។ ការសំពះនិងការបូជាណា ដែលមាន ក្នុងត្រកូលទាំងឡាយ បណ្ឌិតទាំងឡាយ បានពោលនូវការ សំពះនិងបូជានោះថាដូចជាភក់ សរគឺកិលេសដ៏ល្អិត ដែលដក បានដោយក្រ សក្ការៈក៏បុរសអាក្រក់លះបានដោយក្រ ។

ឮថា បិណ្ឌោលភារទ្វាជត្ថេរមានអាយុ បានសំដែងនូវគាថាទាំងឡាយ ដោយប្រការដូច្នេះ ។

(១២៥)មក្កដោ បញ្ចទ្វារាយំ កុដិកាយំ បសក្កិយ[១]
ទ្វារេន អនុបរិយេតិ ឃដ្ដយន្តោ មុហុំ មុហុំ ។
តិដ្ឋ មក្កដ មា ធាវិ ន ហិ តេ តំ យថា បុរេ
និគ្គហីតោសិ បញ្ញាយ នេវ[២] ទូរំ គមិស្សសីតិ ។

វល្លិយោ ថេរោ ។

(១២៨)តិណ្ណំ មេ តាលបត្តានំ គង្គាតីរេ កុដី កតា
ឆវសិត្តោវ មេ បត្តោ បំសុកូលញ្ច ចីវរំ ។
ទ្វិន្នំ អន្តរវស្សានំ ឯកា វាចា មេ ភាសិតា
តតិយេ អន្តរវស្សម្ហិ តមោក្ខន្ធោ បទាលិតោតិ ។

គង្គាតីរិយោ ថេរោ[៣] ។

(១២៦)អបិ ចេ ហោតិ តេវិជ្ជោ មច្ចុហាយី អនាសវោ
អប្បញ្ញាតោតិ នំ ពាលា អវជានន្តិ អជានកា[៤] ។
យោ ច ខោ អន្នបានស្ស លាភី ហោតីធ បុគ្គលោ
បាបធម្មោបិ ចេ ហោតិ សោ នេសំ ហោតិ សក្កតោតិ ។

អជិនោ ថេរោ ។

(១២៧)យថាហំ ធម្មមស្សោសឹ ភាសមានស្ស សត្ថុនោ
ន កង្ខមភិជានាមិ សព្វញ្ញូ អបរាជិតេ

---

១ ឱ. ម. បសក្កិយា ។ ២ ឱ. ម. នេតោ ។ ៣ ឱ. ភិក្ខុ ។ ៤ ឱ. ម. អជានតា ។



(១៦៥) ស្វា គឺចិត្ត តែងចូលទៅកាន់ខ្ទម គឺអត្តភាព មានទ្វារ ៥ កាលញាប់ញ័រស្ទុះចុះឡើង តែងត្រាច់ទៅតាមទ្វារ ។ ម្នាលស្វា អ្នកចូរឈប់ អ្នកកុំស្ទុះទៅឡើយ ខ្ទមរបស់អ្នកនោះមិនមានដូចក្នុងកាលមុននោះទៀតទេ អ្នកត្រូវខ្ញុំសង្កត់សង្កិនដោយបញ្ញា អ្នកនឹងទៅកាន់ទីឆ្ងាយមិនបានទេ ។

វល្លិយត្ថេរ ។

(១៦៨) ខ្ទមដែលខ្ញុំធ្វើទៀបឆ្នេរទន្លេគង្គា ដោយស្លឹកត្នោត ៣ ធាង ក៏មាន បាត្ររបស់ខ្ញុំ ដូចជាភាជន៍ស្រោចទឹកដោះស្រស់ឲ្យខ្មោច ក៏មាន សំពត់បង្សុកូលក៏មាន ។ ក្នុងរវាងពីរវស្សា ខ្ញុំនិយាយពាក្យតែ ១ ម៉ាត់ ក្នុងរវាងវស្សាទី ៣ គំនរងងឹត (អវិជ្ជា) ខ្ញុំក៏បានទំលាយហើយ ។

គង្គាតីរិយត្ថេរ ។

(១៦៦) បើបុគ្គលជាត្រៃវិជ្ជា លះបង់មច្ចុបាន មិនមានអាសវៈ ពួកជនពាលអ្នកមិនចេះដឹង រមែងមើលងាយបុគ្គលនោះថាជាអ្នកមិនមានកេរ្តិ៍ឈ្មោះល្បីល្បាញទៅវិញ ។ បុគ្គលណា ក្នុងលោកនេះ លុះតែជាអ្នកបានលាភ ចំពោះបាយទឹក ទោះបីមានធម៌លាមក បុគ្គលនោះរមែងពួកជនពាលទាំងនោះធ្វើសក្ការៈ ។

អជិនត្ថេរ ។

(១៦៧) កាលណា ខ្ញុំបានស្តាប់សច្ចធម៌ របស់ព្រះសាស្តា កាលទ្រង់សំដែង (កាលនោះ) ខ្ញុំមិនដឹងនូវសេចក្តីសង្ស័យ ជាបុគ្គលដឹងសព្វ ចំពោះព្រះសាស្តា ព្រះអង្គជាអ្នកឈ្នះមារ

សត្ថុកាយេ មហាវីរេ   សារថីនំ វរុត្តមេ

មគ្គេ បដិបទាយំ វា   កង្ខា មយ្ហំ ន វិជ្ជតីតិ ។

មេឡជិនោ ថេរោ ។

(១២៨) យថា អគារំ ទុច្ឆន្នំ   វុដ្ឋិ សមតិវិជ្ឈតិ

ឯវំ អភាវិតំ ចិត្តំ   រាគោ សមតិវិជ្ឈតិ ។

យថា អគារំ សុច្ឆន្នំ   វុដ្ឋិ ន សមតិវិជ្ឈតិ

ឯវំ សុភាវិតំ ចិត្តំ   រាគោ ន សមតិវិជ្ឈតីតិ ។

រាធោ ថេរោ ។

(១២៩) ខីណា ហិ មយ្ហំ ជាតិ   វុសិតំ ជិនសាសនំ

បហីនោ ជាលសង្ខាតោ[1]   ភវនេត្តិ សមូហតា ។

យស្សត្ថាយ បព្វជិតោ   អគារស្មា អនគារិយំ

សោ មេ អត្ថោ អនុប្បត្តោ   សព្វសំយោជនក្ខយោតិ ។

សុរាធោ ថេរោ ។

(១៣០) សុខំ សុបន្តិ មុនយោ   យេ ឥត្ថីសុ ន ពជ្ឈរេ

សទា វេ រក្ខិតព្វាសុ   យាសុ សច្ចំ សុទុល្លភំ ។

---

១ អដ្ឋកថាយម្បន ជាលសង្ខាតោតិ ទិស្សតិ ។



ជាអ្នកដឹកនាំពួក ជាមហាវីរបុរស ជាសារថីដ៏ប្រសើរខ្ពង់ខ្ពស់ ជាងសារថីទាំងឡាយ ឬសេចក្តីសង្ស័យ ក្នុងអរិយមគ្គ និងបដិបទា ក៏មិនមានដល់ខ្ញុំដែរ ។

មេឡជិនត្ថេរ ។

(១២៨) ភ្លៀង រមែងលេចធ្លុះនូវផ្ទះដែលប្រក់មិនល្អ យ៉ាងណាមិញ រាគៈរមែងចាក់ធ្លុះចិត្តដែលមិនបានអប់រំល្អ ក៏យ៉ាងនោះដែរ ។ ភ្លៀង រមែងមិនលេចធ្លុះ នូវផ្ទះដែលប្រក់ល្អ យ៉ាងណាមិញ រាគៈរមែងមិនចាក់ធ្លុះចិត្តដែលបានអប់រំល្អ ក៏យ៉ាងនោះដែរ ។

រាធត្ថេរ ។

(១២៩) ជាតិរបស់ខ្ញុំអស់ហើយ សាសនាព្រះជិនស្រី ខ្ញុំបានប្រព្រឹត្តចប់ហើយ ឃ្លាប (តណ្ហាញៀនចិត្ត) ខ្ញុំបានលះបង់ហើយ តណ្ហាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏ដកចោលហើយ កុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណវិសេសណា ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈទាំងអស់នោះ ខ្ញុំក៏បានដល់ហើយ ។

សុរាធត្ថេរ ។

(១៣០) ពាក្យសច្ចៈ ចំពោះស្ត្រីណា ដែលគេរក្សា គ្រប់កាលទាំងពួង ជាពាក្យដែលគេរកបាន ដោយក្រៃលែង ពួកជនណាមិនជាប់ជំពាក់ចំពោះស្ត្រីទាំងនោះ ពួកជននោះឈ្មោះថា មុនី រមែងដេកនៅជាសុខ ។

វធំ ចរិម្ហ តេ កាម អនណា ទានិ តេ មយំ

គច្ឆាម ទានិ និព្វានំ យត្ថ គន្ត្វា ន សោចតីតិ។

គោតមោ ថេរោ ។

(១៣១) បុព្វេ ហនតិ អត្តានំ បច្ឆា ហនតិ សោ បរេ

សុហតំ ហន្តិ អត្តានំ វីតំសេនេវ បក្ខិមា ។

ន ព្រាហ្មណោ ពហិវណ្ណោ អន្តោវណ្ណោ ហិ ព្រាហ្មណោ

យស្មឹ បាបានិ កម្មានិ ស វេ កណ្ហោ សុជម្បតីតិ។

វសភោ ថេរោ ។

ឧទ្ទានំ

ឧត្តរោ ចេវ បិណ្ឌោលោ វល្លិយោ តីរិយោ ឥសិ

អជិនោ ច មេឡជិនោ រាធោ សុរាធោ គោតមោ ច

វសភេន ឥមេ ហោន្តិ ទស ថេរា មហិទ្ធិកាតិ។

វគ្គោ បឋមោ ។



នែកាម យើងបានប្រព្រឹត្តនូវការសម្លាប់អ្នកហើយ ឥឡូវនេះ យើងមិនជាប់បំណុលទីនឹងអ្នកទេ យើងនឹងទៅកាន់ព្រះនិព្វានឥឡូវនេះ ដែលជាទីទៅហើយមិនសោយសោក ។

គោតមត្ថេរ ។

(១៣១) កុហកបុគ្គលនោះ សម្លាប់ខ្លួនឯង (ដោយការប្រព្រឹត្តលាមក) មុន សម្លាប់បុគ្គលដទៃក្រោយ បុគ្គលបំផ្លាញខ្លួនឯង បំផ្លាញបានដោយងាយ ដូចព្រានបក្សីសម្លាប់ (សត្វស្លាប) ដោយត្រាក់ ។ បុគ្គលមានតែវណ្ណៈខាងក្រៅ[១] មិនឈ្មោះជាព្រាហ្មណ៍ទេ លុះតែមានវណ្ណៈខាងក្នុង[២] ទើបឈ្មោះជាព្រាហ្មណ៍ បពិត្រសុជម្បតិ បាបកម្មមានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះជាបុគ្គលខ្មៅ ។

វសភត្ថេរ ។

ឧទ្ទាន

និយាយអំពី ឧត្តរត្ថេរ១ បិណ្ឌោលភារទ្វាជត្ថេរ១ វល្លិយត្ថេរ១ គង្គាតីរិយត្ថេរ ជាឥសី១ អជិនត្ថេរ១ មេឡជិនត្ថេរ១ រាធត្ថេរ១ សុរាធត្ថេរ១ គោតមត្ថេរ១ វសភត្ថេរ១ ព្រះថេរៈទាំង១០នេះ ជាអ្នកមានឫទ្ធិច្រើន ។

ចប់ បឋមវគ្គ ។

---

១ វណ្ណៈខាងក្រៅ សំដៅការស្លៀកចង់ដោយនិយមជម្មស្រស់ស្រង់ជាដើម ។ ២ វណ្ណៈខាងក្នុង សំដៅយកគុណសម្បត្តិមានសីលជាដើម ។ អដ្ឋកថា ។

## ថេរគាថាយ ទុកនិបាតស្ស ទុតិយវគ្គោ

(១៣៦) សុស្សូសា សុតវឌ្ឍនី សុតំ បញ្ញាយ វឌ្ឍនំ
បញ្ញាយ អត្ថំ ជានាតិ ញាតោ អត្ថោ សុខាវហោ ។

សេវេថ បន្តានិ សេនាសនានិ
ចរេយ្យ សំយោជនវិប្បមោក្ខំ
សចេ រតឹ នាធិគច្ឆេយ្យ តត្ថ
សង្ឃេ វសេ រក្ខិតត្តោ សតីមាតិ ។

មហាចុន្ទោ ថេរោ ។

(១៣៧) យេ ខោ តេ វេឋមិស្សេន នានត្តេន ច កម្មុនា
មនុស្សេ ឧបរុន្ធន្តិ ផរុសូបក្កមា ជនា
តេបិ តត្ថេវ កីរន្តិ ន ហិ កម្មំ បនស្សតិ ។
យំ ករោតិ នរោ កម្មំ កល្យាណំ យទិ បាបកំ
តស្ស តស្សេវ ទាយាទោ យំ យំ កម្មំ បកុព្វតីតិ ។

ជោតិទាសោ ថេរោ ។

(១៣៨) អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ
អាយុ ខីយតិ មច្ចានំ កុន្នទីនំវ ឱទកំ ។



## ថេរគាថា ទុកនិបាត ទុតិយវគ្គ

(១៣៦) ការស្តាប់ដោយល្អ ជាការចំរើននៃអ្នកស្តាប់ ការស្តាប់ជាការចំរើន នៃបញ្ញា (ព្រោះ) បុគ្គល រមែងយល់សេចក្តីបាន ដោយសារបញ្ញា សេចក្តីដែលយល់ហើយ រមែងនាំសុខមកឲ្យ ។ បុគ្គលគួរសេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តធម៌ ដែលជាហេតុរួចស្រឡះចាកសំយោជនៈ បើមិនបានសេចក្តីត្រេកអរក្នុងទីស្ងាត់នោះទេ គប្បីជាអ្នកមានសតិរក្សាខ្លួននៅក្នុងពួកចុះ ។

មហាចុន្ទត្ថេរ ។

(១៣៧) ពួកជនណាបៀតបៀនពួកមនុស្ស ដោយកម្មដែលច្រឡំ ដោយកម្មភ្ជាប់ផង ដោយកម្មផ្សេងៗផង ពួកជនទាំងនោះ ឈ្មោះថាមានព្យាយាមអាក្រក់ ជនទាំងនោះតែងត្រូវជន (ឯទៀត) ធ្វើ (ឲ្យដល់នូវសេចក្តីទុក្ខ) តាមដំណើរដូច្នោះ ព្រោះថាកម្ម (របស់ជននោះ) មិនចេះវិនាសទេ ។ ជនធ្វើនូវកម្មណា ទោះបីល្អឬអាក្រក់ ធ្វើនូវកម្មណាៗ រមែងជាទាយាទ (ទទួលផល) នៃកម្មនោះៗ ។

ជោតិទាសត្ថេរ ។

(១៣៨) ថ្ងៃនិងយប់ កន្លងទៅ ជីវិត រមែងរលត់ទៅ អាយុរបស់សត្វទាំងឡាយ រមែងអស់ទៅ ដូចទឹកស្ទឹងតូច ។

អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ
បច្ឆាស្ស កដុកំ ហោតិ វិបាកោ ហិស្ស បាបកោ ។

ហេរញ្ញកានិ ថេរោ ។

(១៣៥) បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម សាធុជីវីបិ សីទតិ ។
តស្មា តំ បរិវជ្ជេយ្យ កុសីតំ ហីនវីរិយំ
បវិវិត្តេហិ[១] អរិយេហិ បហិតត្តេហិ ឈាយិហិ
និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាវសេ ។

សោមមិត្តោ ថេរោ ។

(១៣៦) ជនោ ជនម្ហិ សម្ពទ្ធោ ជនមេវស្សិតោ ជនោ
ជនោ ជនេន ហេឋីយតិ ហេឋេតិ ច ជនោ ជនំ ។
កោ ហិ តស្ស ជនេនត្ថោ ជនេន ជនិតេន វា
ជនំ ឱហាយ គច្ឆំ តំ ហេឋយិត្វា ពហុំ ជនំ ។

សព្ពមិត្តោ ថេរោ ។

១ ឱ. ម. បវិវេកេហិ ។





ជនពាលដែលកំពុងធ្វើបាបទាំងឡាយ គឺមិនភ្ញាក់រលឹក (ហេតុផល) ផលដ៏ក្តៅក្រហាយមានដល់គេក្នុងកាលជាខាងក្រោយ ព្រោះថា វិបាករបស់កម្មនោះ ជាវិបាកដ៏លាមក ។

ហេរញ្ញកានិត្ថេរ ។

(១៣៥) បុគ្គលតោងកាន់ឈើតូច រមែងលិចចុះក្នុងទឹកសមុទ្រធំ យ៉ាងណា មិញ បុគ្គលអាស្រ័យនូវបុគ្គលខ្ជិល ទុកជាមានការរស់នៅដោយល្អ ក៏រមែងលិចចុះ (ក្នុងសង្សារវដ្ត) យ៉ាងនោះដែរ ។ ព្រោះហេតុនោះបុគ្គល គប្បីវៀរបុគ្គលខ្ជិល ឥតមានព្យាយាមថោកទាបនោះចេញ គប្បីនៅរួមជាមួយនឹងពួកអរិយៈ ជាបុគ្គលស្ងប់ស្ងាត់ មានឈាន មានចិត្តស្ទុះ (ទៅកាន់ព្រះនិព្វាន) ជាបណ្ឌិតមានព្យាយាមតឹងរឹងអស់កាលជានិច្ច ។

សោមមិត្តត្ថេរ ។

(១៣៦) ជន[១]ជាប់ចំពាក់នឹងជន ជនអាស្រ័យនូវជន ជនត្រូវជនបៀតបៀនផង ជនបៀតបៀនជនផង ។ ព្រោះថាប្រយោជន៍អ្វី ដោយជនរបស់ជននោះ ឬដោយជនដែលឲ្យកើតហើយ អាត្មាអញគប្បីលះនូវជន ដែលបៀតបៀនជនច្រើន ហើយទៅ ។

សព្ពមិត្តត្ថេរ ។

១ ពាក្យថា ជន ក្នុងគាថានេះ សំដៅយកមនុស្សអន្ធពាល ។ អដ្ឋកថា ។

(១៣៧) កាឡី ឥត្ថី ព្រហតី ធង្ករូបា
សត្ថិញ្ច ភេត្វា អបរញ្ច សត្ថឹ
ពាហញ្ច ភេត្វា អបរញ្ច ពាហុំ
សីសញ្ច ភេត្វា ទធិថាលកំវ
ឯសា និសិន្នា អភិសន្ទហិត្វា[១]
យោ វេ អវិទ្វា[២] ឧបធឹ ករោតិ
បុនប្បុនំ ទុក្ខមុបេតិ មន្ទោ
តស្មា បជានំ ឧបធឹ ន កយិរា
មាហំ បុន ភិន្នសិរោ សយិស្សន្តិ ។

មហាកាឡោ ថេរោ ។

(១៣៨) ពហូ សបត្តេ លភតិ មុណ្ឌោ សង្ឃាដិបារុតោ
លាភី អន្នស្ស បានស្ស វត្ថស្ស សយនស្ស ច ។
ឯតមាទីនវំ ញត្វា សក្ការេសុ មហព្ភយំ
អប្បលាភោ អនវស្សុតោ សតោ ភិក្ខុ បរិព្វជេ ។

តិស្សោ ថេរោ ។

(១៣៩) បាចីនវំសទាយម្ហិ សក្យបុត្តា សហាយកា
បហាយនប្បកេ ភោគេ ឧញ្ឆាបត្តាគតេ រតា

១ ឱ. ម. អភិសន្ទហិត្វា ។ ២ ឱ. អវិទ្វូ ។



(១៣៧) ស្រីឈ្មោះនាងកាឡី មានសរីរៈធំ មានរូបរាងដូចក្អែក បំបាក់ភ្លៅម្ខាង ហើយបំបាក់ភ្លៅម្ខាងទៀត បំបាក់ដៃម្ខាង ហើយបំបាក់ដៃម្ខាងទៀត ទំលាយខួរក្បាល (របស់មនុស្សស្លាប់ ធ្វើឲ្យមានខួរហូរចេញ) ដូចឆ្នាំងទឹកដះ ស្រីនុះអង្គុយរៀបចំ (សរីរៈសពនោះ) បុគ្គលណា អ្នកមិនឈ្លាសវៃ តែងធ្វើឧបធិក្កិលេស បុគ្គលនោះជាមនុស្សល្ងង់ រមែងដល់នូវសេចក្តីទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹង មិនគួរធ្វើឧបធិឡើយ អាត្មាអញ សូមកុំឲ្យមានក្បាលបែកធ្លាយ ដេក (ស្តូកស្តឹង) ទៀតឡើយ ។

មហាកាឡោ ។

(១៣៨) បុគ្គលអ្នកមានក្បាលត្រងោល ដណ្តប់សង្ឃាដី ជាអ្នកបានបាយ ទឹក សំពត់ ទីដេក ឈ្មោះថាបានសត្រូវច្រើន ។ ភិក្ខុអ្នកមានសតិ លុះឃើញទោសនុះ ថាជាភ័យធំក្នុងសក្ការៈទាំងឡាយ ហើយ គួរជាអ្នកមានលាភតិច មិនឈ្លក់ដោយលាភ វៀរឲ្យស្រឡះ ។

តិស្សោ ។

(១៣៩) សក្យបុត្តទាំងឡាយ ជាសំឡាញ់នឹងគ្នា បានលះបង់នូវភោគសម្បត្តិជាច្រើន (ទៅនៅ) ក្នុងព្រៃឈ្មោះបាចីនវង្សទាយៈ ត្រេកអរចំពោះភត្ត ដែលកើតនៅក្នុងបាត្រ ដោយការស្វែងរក

អារទ្ធវីរិយា បហិតត្តា និច្ចំ ទឡ្ហបរក្កមា
រមន្តិ ធម្មរតិយា ហិត្វាន លោកិយំ រតិំ ។

កិម្ពិលោ[1] ថេរោ ។

(១៥០) អយោនិសោមនសិការា មណ្ឌនំ អនុយុញ្ជិសំ
ឧទ្ធតោ ចបលោ ចាសិំ កាមរាគេន អដ្ដិតោ ។
ឧបាយកុសលេនាហំ ពុទ្ធេនាទិច្ចពន្ធុនា
យោនិសោ បដិបជ្ជិត្វា ភវេ ចិត្តំ ឧទព្ពហិន្តិ ។

នន្ទោ ថេរោ ។

(១៥១) បរេ ច នំ បសំសន្តិ អត្តា ចេ អសមាហិតោ
មោឃំ បរេ បសំសន្តិ អត្តា ហិ អសមាហិតោ ។
បរេ ច នំ គរហន្តិ អត្តា ចេ សុសមាហិតោ
មោឃំ បរេ គរហន្តិ អត្តា ហិ សុសមាហិតោតិ ។

សិរិមា ថេរោ ។

ឧទ្ទានំ

ចុន្ទោ ច ជោតិទាសោ ច ថេរោ ហេរញ្ញកានិ យោ
សោមមិត្តោ សព្វមិត្តោ កាលោ តិស្សោ ច កិម្ពិលោ
នន្ទោ ច សិរិមា ថេរា ទស ថេរា មហិទ្ធិកាតិ ។

វគ្គោ តតិយោ ។

[1] ម. កិមិលោ ។



មានព្យាយាមប្រារព្ធ មានចិត្តបញ្ជូនទៅ មានការខិតខំមាំមួន កាលជានិច្ច លះបង់នូវតម្រេកក្នុងលោក ហើយត្រេកអរដោយតម្រេកក្នុងធម៌ ។

កិម្ពិលត្ថេរ ។

(១៥០) ខ្ញុំកាលប្រកបនូវគ្រឿងប្រដាប់ (កាយ) ជាបុគ្គលអណ្ដែត អណ្ដែតឃ្លេងឃ្លោង ត្រូវតម្រេកក្នុងកាមបៀតបៀន ព្រោះមិនមានយោ-និសោមនសិការៈ ។ (តែឥឡូវនេះ) ខ្ញុំដកចិត្តក្នុងភពបានហើយ ព្រោះប្រតិបត្តិដោយយោនិសោមនសិការៈ តាមព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានកុសលោបាយ (ឧបាយល្អ) ។

នន្ទត្ថេរ ។

(១៥១) បើពួកបរជន (មនុស្សផ្សេងគ្នា) សរសើរនូវបុគ្គល ដែលមិនតំកល់ខ្លួនខ្ជាប់ខ្ជួន ពួកបរជន សរសើរនូវបុគ្គលដែលមិនតំកល់ខ្លួនខ្ជាប់ខ្ជួននោះឯង ជាការឥតអំពើ ។ បើពួកបរជន តិះដៀលនូវបុគ្គល ដែលតំកល់ខ្លួនខ្ជាប់ខ្ជួនល្អ ពួកបរជន តិះដៀលនូវបុគ្គលដែលតំកល់ខ្លួនខ្ជាប់ខ្ជួនល្អនោះឯង ជាការឥតអំពើ ។

សិរិមត្ថេរ ។

ឧទ្ទាន

និយាយអំពី មហាចុន្ទត្ថេរ១ ជោតិទាសត្ថេរ១ ហេរញ្ញកានិត្ថេរ១ សោមមិត្តត្ថេរ១ សព្វមិត្តត្ថេរ១ មហាកាឡត្ថេរ១ តិស្សត្ថេរ១ កិម្ពិលត្ថេរ១ នន្ទត្ថេរ១ សិរិមត្ថេរ១ ត្រូវជាថេរៈ ១០ អង្គមានឫទ្ធិច្រើន ។

ចប់ តតិយវគ្គ ។

## ថេរគាថាយ ទុកនិបាតស្ស តតិយវគ្គោ

(១៦២) ខន្ធា មយា បរិញ្ញាតា តណ្ហា មេ សុសមូហតា
ភាវិតា មម ពោជ្ឈង្គា បត្តោ មេ អាសវក្ខយោ ។
សោហំ ខន្ធេ បរិញ្ញាយ អព្ពុហិត្វាន[១] ជាលិនឹ
ភាវយិត្វាន ពោជ្ឈង្គេ និព្វាយិស្សំ អនាសវោតិ ។

ឧត្តរោ ថេរោ ។

(១៦៣) បនាទោ នាម សោ រាជា យស្ស យូបោ សុវណ្ណយោ
តិរិយំ សោឡសុព្ពេធោ ឧព្ភមាហុ[២] សហស្សធា ។
សហស្សកណ្ឌោ សតគេណ្ឌុ[៣] ធជាលុ ហរិតាមយោ
អនច្ចុំ តត្ថ គន្ធព្វា ឆសហស្សានិ សត្តធាតិ ។

ភទ្ទជិ ថេរោ ។

(១៦៤) សតិមា បញ្ញវា ភិក្ខុ អារទ្ធពលវីរិយោ
បញ្ច កប្បសតានាហំ ឯករត្តឹ អនុស្សរឹ ។

---

១ ឱ. អព្ពុហិត្វាន ។ ម. អព្ពុហិត្វាន ។ ២ ឱ. ម. ឧព្ភមាហុ ។ ៣ ឱ. សហស្សកណ្ឌុ សតគេណ្ឌុ ។ ម. សហស្សកណ្ឌោ សតគេណ្ឌុ ។



## ថេរគាថា ទុកនិបាត តតិយវគ្គ

(១៦២) ខន្ធទាំងឡាយខ្ញុំកំណត់ដឹងហើយ តណ្ហាខ្ញុំដកចេញស្រឡះហើយ ពោជ្ឈង្គខ្ញុំបានចំរើនហើយ ការក្ស័យទៅនៃអាសវៈ ខ្ញុំក៏បានដល់ហើយ ។ ខ្ញុំនោះ លុះកំណត់ដឹងនូវខន្ធហើយ លុះដកចេញនូវបណ្ដាញគឺតណ្ហាហើយ លុះចំរើនពោជ្ឈង្គហើយ ក៏នឹងទៅជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ឧត្តរត្ថេរ ។

(១៦៣) ប្រាសាទមាស ទទឹងទំហំ មានសន្ទុះនៃសរ ១៦[១] ទាំងកំពស់ មានសន្ទុះនៃសរ ១ ពាន់[២] របស់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះទ្រង់ព្រះនាមថា បនាទៈ ។ ប្រាសាទនោះមានសន្ទុះនៃសរ ១ ពាន់ មានជាន់ជាច្រើន មានទង់ជ័យជាច្រើន សំរេចដោយកែវមណីខៀវ អ្នករបាំក៏បានរាំលើប្រាសាទនោះ អ្នករបាំ ៦.០០០ នាក់ (ចែកជា) ក្នុងជាន់ទាំង ៧ ។

ភទ្ទជិត្ថេរ ។

(១៦៤) ខ្ញុំជាភិក្ខុមានស្មារតី មានបញ្ញា មានកម្លាំងព្យាយាមម៉ឺងម៉ាត់ បានរលឹកឃើញអស់ ៥០០ កប្ប ដោយ មួយ រាត្រី ។

---

១ សន្ទុះសរ ១៦ នោះ បើគិតជាយោជន៍ ត្រូវកន្លះយោជន៍ ។
២ សន្ទុះសរ ១ពាន់ បើគិតជាយោជន៍ បាន ៥ យោជន៍ ។ អដ្ឋកថា ។

ចត្តារោ សតិបដ្ឋានេ សត្ត អដ្ឋ ច ការយឹ
បញ្ច កប្បសតានាហំ ឯករត្តឹ អនុស្សរឹ ។

សោភិតោ ថេរោ ។

(១៦៥)យំ កិច្ចំ ទឡ្ហវីរិយេន យំ កិច្ចំ ពោទ្ធុមិច្ឆតា
ករិស្សំ នាវរជ្ឈិស្សំ បស្ស វីរិយំ បរក្កមំ ។
ត្វញ្ច[១] មេ មគ្គមក្ខាហិ អញ្ជសំ អមតោគធំ
អហំ មោនេន មោនិស្សំ គង្គាសោតោវ សាគរំ ។

វីរិយោ ថេរោ ។

(១៦៦)កេសេ មេ ឱលិខិស្សន្តិ កប្បកោ ឧបសង្កមិ
តតោ អាទាសមាទាយ សរីរំ បច្ចវេក្ខិសំ ។
តុច្ឆោ កាយោ អទិស្សិត្ថ អន្ធការេ[២] តមោ ព្យគា
សព្វេ ចោឡា សមុច្ឆិន្នា នត្ថិ ទានិ បុនព្ភវោ ។

វីតសោកោ ថេរោ ។

(១៦៧)បញ្ចិន្ទ្រិយានិ ភាវេត្វា យោគក្ខេមស្ស បត្តិយា
ធម្មាទាសំ គហេត្វាន ញាណទស្សនមត្តនោ

---

១ ម. ត្វញ្ច ។ ២ ម. អន្ធការោ ។



ខ្ញុំបានចំរើនសតិប្បដ្ឋាន ៤ ពោជ្ឈង្គ ៧ និងមគ្គ ៨ បានរលឹកឃើញអស់ ៨០០ កប្ប ដូចមួយរាត្រី ។

សោភិតត្ថេរ ។

(១៦៥) អំពើណាដែលបុគ្គលគួរធ្វើ ដោយព្យាយាមដ៏មាំ អំពើណាដែលបុគ្គលប្រាថ្នាដើម្បីត្រាស់ដឹងគប្បីធ្វើ ខ្ញុំនឹងធ្វើអំពើនោះៗ មិននឿយណាយទេ អ្នកចូរមើលសេចក្តីព្យាយាម សេចក្តីប្រឹងប្រែងចុះ អ្នកចូរប្រាប់ផ្លូវ ដែលជាផ្លូវឈមទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈដល់ខ្ញុំ ខ្ញុំនឹងដឹងបានដោយញាណជាគ្រឿងដឹង ដូចខ្សែទឹកទន្លេគង្គា (មិននឿយណាយ) នឹងសាគរ ។

វិរិយត្ថេរ ។

(១៦៦) កាលកប្បកបុរស ចូលមកនិយាយថា ខ្ញុំនឹងកោរសក់របស់ខ្ញុំ (លំដាប់នោះ) ខ្ញុំទាញយកកញ្ចក់អំពីដៃកប្បកបុរសនោះ ហើយឆ្លុះមើលសរីរៈ ។ កាយប្រាកដជារបស់ទទេ ងងឹតគឺទីងងឹត គឺអវិជ្ជាក៏ប្រាសចេញហើយ កិលេសដូចជាកំណាត់សំពត់ទាំងអស់ ខ្ញុំបានផ្តាច់ចោលអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

វីតសោកត្ថេរ ។

(១៦៧) ខ្ញុំលះបង់នីវរណៈទាំង ៥ ដើម្បីដល់ព្រះនិព្វានជាក្សេមចាកយោគៈ កាន់យកកញ្ចក់គឺធម៌ ជាញាណទស្សនៈរបស់ខ្លួន

បច្ចវេក្ខិំ ឥមំ កាយំ សព្វំ សន្តរពាហិរំ
អជ្ឈត្តញ្ច ពហិទ្ធា ច តុច្ឆោ កាយោ អទិស្សថាតិ

បុណ្ណមាសោ ថេរោ ។

(១៧៨) យថាបិ ភទ្ទោ អាជញ្ញោ ខលិត្វា បតិតិដ្ឋតិ
ភិយ្យោ លទ្ធាន សំវេគំ អទីនោ វហតេ ធុរំ
ឯវំ ទស្សនសម្បន្នំ សម្មាសម្ពុទ្ធសាវកំ
អាជានិយំ មំ ធារេថ បុត្តំ ពុទ្ធស្ស ឱរសន្តិ ។

នន្ទកោ ថេរោ ។

(១៧៩) ឯហិ នន្ទក គច្ឆាម ឧបជ្ឈាយស្ស សន្តិកំ
សីហនាទំ នទិស្សាម ពុទ្ធសេដ្ឋស្ស សម្មុខា ។
យាយ នោ អនុកម្បាយ អម្ហេ បព្វាជយី មុនិ
សោ នោ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោតិ ។

ភារតោ[1] ថេរោ ។

(១៨០) នទន្តិ ឯវំ សប្បញ្ញា សីហាវ គិរិគព្ភរេ
ធីរា[2] វិជិតសង្គាមា ជេត្វា មារំ សវាហិនំ ។

១ ឱ. ម. ភរតោ ថេរោ ។ ២ ឱ. ម. វីរា ។



ខ្ញុំពិចារណាកាយនេះទាំងអស់ ទាំងខាងក្នុងទាំងខាងក្រៅកាយ ប្រាកដជារបស់ទទេ ទាំងខាងក្នុងទាំងខាងក្រៅ ។

បុណ្ណមាសត្ថេរ ។

(១៧៨) សេះអាជានេយ្យដ៏ចំរើន ភ្លាត់ហើយរមែងឈរស៊ប់ឡើងវិញ លុះបានខ្លាចសេចក្តីតក់ស្លុត ក៏ជាសត្វមានចិត្តមិនរួញរា រមែងនាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវខ្ញុំ ថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាបុត្ត ជាឱរស របស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។

នន្ទកត្ថេរ ។

(១៧៩) ម្នាលនន្ទកៈ អ្នកចូរមក យើងនឹងទៅកាន់សំណាក់នៃព្រះឧបជ្ឈាយ៍ នឹងបន្លឺឡើងនូវសីហនាទ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធដ៏ប្រសើរ ។ ព្រះពុទ្ធជាមុនីទ្រង់បំបួសយើងដោយសេចក្តីអនុគ្រោះយើង ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ យើងបានដល់ហើយ ការអស់ទៅនៃសំយោជនៈទាំងពួង (យើងក៏បានដល់ហើយ) ។

ភារតត្ថេរ ។

(១៨០) ពួកអ្នកប្រាជ្ញប្រកបដោយប្រាជ្ញា ជាអ្នកឈ្នះសង្គ្រាមគឺកិលេស ឈ្នះមារ ព្រមទាំងពលវាហនៈរបស់មារ តែងបន្លឺឡើងយ៉ាងនេះដូចជាសីហៈបន្លឺលើគុហាភ្នំ ។

សត្ថា ច បរិចិណ្ណោ មេ ធម្មោ សង្ឃោ ច បូជិតោ
អហញ្ច វិត្តោ[១] សុមនោ បុត្តំ ទិស្វា អនាសវំ ។

ភារទ្វាជោ ថេរោ ។

(១៨១) ឧបាសិតា សប្បុរិសា សុតា ធម្មា អភិណ្ហសោ
សុត្វាន បដិបជ្ជិស្សំ អញ្ជសំ អមតោគធំ ។
ភវរាគហតស្ស មេ សតោ ភវរាគោ បុន មេ ន វិជ្ជតិ
ន ចាហុ ន ច មេ ភវិស្សតិ ន ច មេ ឯតរហិ វិជ្ជតីតិ ។

កណ្ហទិន្នោ ថេរោ ។

ឧទ្ទានំ

ឧត្តរោ ភទ្ទជិ ថេរោ សោភិតោ វល្លិយោ ឥសិ
វីតសោកោ ច សោ ថេរោ បុណ្ណមាសោ ច នន្ទកោ
ភារតោ[២] ភារទ្វាជោ ច កណ្ហទិន្នោ មហាមុនីតិ ។

វគ្គោ ទុតិយោ ។

១ ឧ. ម. វិត្តោ ។ ២ ឧ. ម. ភារតោ ។



ព្រះសាស្តាខ្ញុំបានគោរពហើយ ព្រះធម៌និងព្រះសង្ឃ ខ្ញុំបានបូជាហើយ មួយទៀត ខ្ញុំមានចិត្តត្រេកអរពេកពន់ ព្រោះឃើញកូនជាអ្នកមិនមានអាសវៈ ។

ភារទ្វាជត្ថេរ ។

(១៨១) ពួកសប្បុរស ខ្ញុំបានចូលទៅគាល់ហើយ ធម៌ខ្ញុំក៏បានស្តាប់ហើយរឿយៗ លុះខ្ញុំស្តាប់ហើយ ក៏ដើរតាមផ្លូវធម៌ ដែលឈមទៅកាន់ព្រះនិព្វានឈ្មោះ អមតៈ ។ ខ្ញុំត្រូវភវរាគៈបៀតបៀន (ឥឡូវនេះ) ភវរាគៈមិនមានដល់ខ្ញុំទៀតទេ ភវរាគៈ (ក្នុងអតីតកាល) មិនមានហើយដល់ខ្ញុំ (ក្នុងអនាគត) ក៏នឹងមិនមានទេ ក្នុងបច្ចុប្បន្ននេះទៀត ក៏មិនមានដល់ខ្ញុំដែរ ។

កណ្ហទិន្នត្ថេរ ។

ឧទ្ទាន

និយាយអំពី ឧត្តរត្ថេរ ១ ភទ្ទជិត្ថេរ ១ សោភិតត្ថេរ ១ វល្លិយត្ថេរ ជាឥសី ១ វីតសោកត្ថេរ ១ បុណ្ណមាសត្ថេរ ១ នន្ទកត្ថេរ ១ ភារតត្ថេរ ១ ភារទ្វាជត្ថេរ ១ កណ្ហទិន្នត្ថេរ ជាមហាមុនី ១ ។

ចប់ ទុតិយវគ្គ ។

## ថេរគាថាយ ទុកនិបាតស្ស បញ្ចមវគ្គោ

(១៨២) យតោ អហំ បព្វជិតោ(១) សម្មាសម្ពុទ្ធសាសនេ
វិមុច្ចមានោ ឧគ្គច្ឆឹ កាមធាតុំ ឧបច្ចគំ
ព្រហ្មុនោ បេក្ខមានស្ស តតោ ចិត្តំ វិមុច្ចិ មេ
អកុប្បា មេ វិមុត្តីតិ សព្វសំយោជនក្ខយាតិ។

មិគសិរោ ថេរោ ។

(១៨៣) អនិច្ចានិ គហកានិ តត្ថ តត្ថ បុនប្បុនំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា(២) ភគ្គា ថូណិកា ច បទាលិតា(៣)
វិមរិយាទិកតំ ចិត្តំ ឥធេវ វិធមិស្សតិ ។

សិវកោ ថេរោ ។

(១៨៤) អរហំ សុគតោ លោកេ វាតេហាពាធិតោ មុនិ
សចេ ឧណ្ហោទកំ អត្ថិ មុនិនោ ទេហិ ព្រាហ្មណ។

១. ម. បព្វជិតោ ។ ២. ម. ផាសុកា ។ ៣. ម. ថូណិកា វិទាលិតា ។
ម. តុណ្ហិកា វិទាលិតា ។



## ថេរគាថា ទុកនិបាត បញ្ចវគ្គ

(១៨២) កាលដែលខ្ញុំបួសក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ក៏បានរួចស្រឡះ (ចាកកិលេស) បានកន្លងនូវកាមធាតុ កាលព្រះព្រហ្មជាបុគ្គលប្រសើរ កំពុងពិនិត្យពិចារណា ចិត្តរបស់ខ្ញុំក៏បានរួចផុតចាកកិលេស វិមុត្តិរបស់ខ្ញុំលែងកំរើក ព្រោះអស់ទៅនៃសំយោជនៈទាំងពួង ។

មិគសិរត្ថេរ(១) ។

(១៨៣) ផ្ទះគឺអត្តភាពទាំងឡាយ (ដែលកើត) រឿយៗ ក្នុងភពនោះៗ ជារបស់មិនទៀង ខ្ញុំនេះ កាលស្វែងរកនូវជាងធ្វើផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ការកើតរឿយៗ ជាហេតុនាំមកនូវសេចក្តីទុក្ខ ។ នែជាងផ្ទះ អ្នកគឺយើងបានឃើញច្បាស់ហើយ អ្នកនឹងធ្វើផ្ទះទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នក យើងបានបំបាក់អស់ហើយ ទាំងហោជាងគឺអវិជ្ជាទៀតសោត យើងបានរុះរោលអស់ហើយ ចិត្តដែលយើងធ្វើឲ្យវិនស្ទូក ក៏នឹងរលត់ក្នុងភពនេះឯង ។

សិវកត្ថេរ ។

(១៨៤) ព្រះមុនី ជាព្រះអរហន្ត មានព្រះដំណើរល្អ ក្នុងលោក ទ្រង់អាពាធព្រោះខ្យល់ ម្នាលព្រាហ្មណ៍ ប្រសិនបើអ្នកមានទឹកក្តៅ ចូរអ្នកថ្វាយដល់ព្រះមុនី ។

១ បានជាឈ្មោះថា មិគសិរត្ថេរ ព្រោះលោកកើតក្នុងថ្ងៃមិគសិរ ។ អដ្ឋកថា ។

បូជិតោ បូជនេយ្យានំ សក្ការេយ្យាន សក្កតោ

អបចិតោ អបចិនេយ្យានំ[១] តស្ស កិត្តិ បវឌ្ឍតិ ។

ខុជ្ជិតោ ថេរោ ។

(១៨៧) ទិដ្ឋា មយា ធម្មធរ ឧបាសកា

កាមា អនិច្ចា ឥតិ ភាសមានា

សារត្តរត្តា មណិកុណ្ឌលេសុ

បុត្តេសុ ទារេសុ ច តេ អបេក្ខា ។

អទ្ធា ន ជានន្តិ យតោ ច ធម្មំ[២]

កាមា អនិច្ចា ឥតិ ចាបិ អាហុ

រាគញ្ច តេសំ ន ពលត្ថិ ឆេត្តុំ

តស្មា សិតា បុត្តទារំ ធនញ្ចាតិ ។

ឥសិទិន្នោ ថេរោ ។

(១៨៨) នេកោ ច វស្សតិ នេកោ ច គជ្ជតគជ្ជយតិ

ឯកកោ ចាហំ កោរេ ពិលេ វិហរាមិ

តស្ស មយ្ហំ ឯកកស្ស កោរេ ពិលេ វិហរតោ

នត្ថិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា ។

---

១ ឱ. បចាយ្យានំ ។ ២ ម. យថា ? ធម្មំ ។ ម. យតោ ធម្មំ ។



(ព្រោះថា) ព្រះពុទ្ធ ត្រូវពួកបូជនេយ្យបុគ្គលបូជាហើយ ត្រូវពួកសក្ការេយ្យបុគ្គល (បុគ្គលដែលគេគប្បីធ្វើសក្ការៈ) ធ្វើសក្ការៈហើយ ត្រូវពួកអបចិនេយ្យបុគ្គល (បុគ្គលដែលគេគប្បីកោតក្រែង) គោរពក្រែងហើយ កាត្តាប្រាជ្ញធំនិងកិត្តិសព្ទផ្សាយព្រះអង្គ ។

ខុជ្ជិតោ ថេរោ ។

(១៨៧) ពួកឧបាសក អ្នកទ្រទ្រង់ព្រះបរិយត្តិធម៌ដែលខ្ញុំជួបហើយបាននិយាយថា កាមទាំងឡាយ ជារបស់មិនទៀង តែពួកឧបាសកនោះនៅត្រេកអរក្រៃពេក ក្នុងកែវមណីនិងកណ្ឌលទាំងឡាយផង ជាអ្នកការឡាអាល័យក្នុងកូននិងប្រពន្ធផង ។ ពួកឧបាសកទាំងនោះមិនបានដឹងធម៌ពិតទេ គ្រាន់តែចេះនិយាយថា កាមទាំងឡាយជារបស់មិនទៀង ឧបាសកទាំងនោះ មិនបានមានកម្លាំងញាណ ដើម្បីកាត់ផ្តាច់នូវរាគៈទេ ព្រោះហេតុនោះបានជានៅជាប់ស្អិតចំពោះកូន ប្រពន្ធ និងទ្រព្យសម្បត្តិ ។

ឥសិទិន្នោ ថេរោ ។

(១៨៨) ភ្លៀងបង្អុរចុះផងរមេឃគ្រហឹមលាន់ឮសូរផង (ក្នុងពេលនោះ) អាត្មាអញ នៅតែម្នាក់ឯង ក្នុងរូងភ្នំ ដែលគួរខ្លាច កាលដែលអាត្មាអញនោះ នៅក្នុងរូងភ្នំដែលគួរខ្លាច តែម្នាក់ឯង ក៏ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានទេ ។

ធម្មតា មមេសា យស្ស មេ ឯកកស្ស ភេរវេ ពិលេ

វិហរតោ នត្ថិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វាតិ ។

សម្ពុលកច្ចានោ ថេរោ ។

(១៩៧) កស្ស សេលូបមំ ចិត្តំ ឋិតំ នានុបកម្បតិ

វិរត្តំ រជនីយេសុ កុប្បនីយេ ន កុប្បតិ ។

យស្សេវំ ភាវិតំ ចិត្តំ កុតោ តំ ទុក្ខមេស្សតិ ។

មម សេលូបមំ ចិត្តំ ឋិតំ នានុបកម្បតិ

វិរត្តំ រជនីយេសុ កុប្បនីយេ ន កុប្បតិ ។

មមេវំ ភាវិតំ ចិត្តំ កុតោ មំ ទុក្ខមេស្សតីតិ ។

និតកោ ថេរោ ។

(១៩៨) ន តាវ សុបិតុំ ហោតិ រត្តិ នក្ខត្តមាលិនី[១]

បដិជគ្គិតុមេវេសា រត្តិ ហោតិ វិជានតា ។

ហត្ថិក្ខន្ធាវបតិតំ កុញ្ជរោ ចេ អនុក្កមេ

សង្គាមេ មេ មតំ សេយ្យោ យញ្ចេ ជីវេ បរាជិតោ ។

សោណោ បោដិរិយបុត្តោ ថេរោ ។

១ ឱ. រត្តិ នក្ខត្តមាលិនី ។



កាលអាត្មាអញនៅម្នាក់ឯង ក្នុងរូងភ្នំដែលគួរខ្លាច ភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី មិនមានឡើយ នេះជាធម្មតារបស់អាត្មាអញ ។

សម្ពុលកច្ចានត្ថេរ ។

(១៩៧) ចិត្តរបស់បុគ្គលណាមួយ មានឧបមាដោយភ្នំថ្ម តាំងនៅស៊ប់ រមែងមិនញាប់ញ័រ (ដោយលោកធម៌) ចិត្តដែលប្រាសចាកសេចក្តីត្រេកអរ ក្នុងអារម្មណ៍ទាំងឡាយដែលគួរត្រេកអរ រមែងមិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត ។ បុគ្គលណា អប់រំចិត្តបានយ៉ាងនេះ បុគ្គលនោះ នឹងដល់នូវសេចក្តីទុក្ខអំពីណាបាន ។ ចិត្តរបស់អាត្មាអញ មានឧបមាដោយភ្នំថ្ម តាំងនៅស៊ប់ រមែងមិនញាប់ញ័រ ចិត្តអាត្មាអញប្រាសចាកសេចក្តីត្រេកអរក្នុងអារម្មណ៍ទាំងឡាយ ដែលគួរត្រេកអរ រមែងមិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត ។ អាត្មាអញ អប់រំចិត្តបានយ៉ាងនេះ អាត្មាអញនឹងដល់នូវសេចក្តីទុក្ខអំពីណាបាន ។

និតកត្ថេរ ។

(១៩៨) រាត្រី ជារបៀបនៃនក្ខត្តឫក្ស (មានកត្តិកាជាដើម) វិញ្ញូជនមិនគួរដេកលក់ក្នុងពេលនោះទេ រាត្រីនុ៎ះ វិញ្ញូជនគួរប្រាថ្នាដើម្បីប្រតិបត្តិ ។ ប្រសិនបើ ដំរីជាន់អញ ដែលធ្លាក់ចុះចាកកដំរី សេចក្តីស្លាប់របស់អញ ក្នុងសង្គ្រាម (យ៉ាងនេះ) ប្រសើរជាង អាត្មាអញដែលចាញ់ហើយរស់នៅ មិនប្រសើរសោះឡើយ ។

សោណបោដិរិយបុត្តត្ថេរ ។

(១៥៩) បញ្ច កាមគុណេ ហិត្វា បិយរូបេ មនោរមេ
សទ្ធាយ ឃរា និក្ខម្ម ទុក្ខស្សន្តករោ ភវេ ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ សម្បជានោ បតិស្សតោតិ ។

និសភោ ថេរោ ។

(១៦០) អម្ពបល្លវសង្កាសំ អំសេ កត្វាន ចីវរំ
និសិន្នោ ហត្ថិគីវាយំ គាមំ បិណ្ឌាយ បាវិសឹ ។
ហត្ថិក្ខន្ធតោ ឱរុយ្ហ សំវេគំ អលភឹ តទា
សោហំ ទិត្តោ តទា សន្តោ បត្តោ មេ អាសវក្ខយោតិ ។

ឧសភោ ថេរោ ។

(១៦១) អយមិតិ កប្បដោ កប្បដកុរោ
អច្ឆាយ អតិភរិតាយ[១]
អមតឃដិកាយំ ធម្មកដបត្តោ[២]
កតបទំ ឈានានិ ឱចេតុំ ។

---

១ ម. ឧ. អតិភរិតាយ ។ ម. អតិភរិយាយ ។ ២ ម ធម្មកដមត្តោ ។





(១៥៩) វិញ្ញូជន គប្បីលះបង់កាមគុណទាំង ៥ ដែលមានសភាពគួរស្រឡាញ់ គួរពេញចិត្ត ហើយចេញចាកផ្ទះ (ទៅបួស) ដោយសទ្ធា ហើយធ្វើនូវទីបំផុតនៃទុក្ខ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំ (គ្រាន់តែ) ជាអ្នកដឹងខ្លួន មានស្មារតី រង់ចាំតែកាល (បរិនិព្វាន) ប៉ុណ្ណោះ ។

និសភត្ថេរ ។

(១៦០) ខ្ញុំធ្វើចីវរ មានពណ៌ដូចជាពណ៌នៃត្រួយស្វាយ លើស្មា ហើយអង្គុយលើកនៃដំរី ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ។ ខ្ញុំចុះពីកដំរី ក៏បាននូវសេចក្តីសង្វេគក្នុងកាលនោះ តែខ្ញុំនោះ ជាមនុស្សកំពុងស្រវឹង (ដោយជាតិជាដើម) ហើយខ្ញុំបានដល់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ក្នុងកាលនោះដែរ ។

ឧសភត្ថេរ ។

(១៦១) កប្បដកុរៈ (មានសេចក្តីត្រេកអរខ្ពស់ក្រៃលែងយ៉ាងនេះ) ថា នេះជាកន្ទប របស់តណ្ហាឥញ កាលបើភ្ជួសម្រាប់ដាក់ទឹកអម្រឹត (របស់តថាគត) ពេញហើយក្រៃពេក (តថាគតសំដែងធម៌ ដើម្បីឱ្យបាននូវទឹកអម្រឹត) កប្បដកុរភិក្ខុ ក៏ដល់នូវការឃ្លាតចាកធម៌ (របស់តថាគត) នេះជាសាសនា របស់តថាគត ជាផ្លូវការពារផ្សេង ៗ ប្រព្រឹត្តទៅ ដើម្បីចំរើននូវឈានទាំងឡាយ ។

មា ខោ ត្វំ កប្បដ បចាលេសិ
មា តំ ឧបកណ្ណម្ហិ តាឡេស្សំ
ន ហិ(១) ត្វំ កប្បដ មត្តមញ្ញាសិ
សង្ឃមជ្ឈម្ហិ បចលាយមានោតិ ។

កប្បដកុរោ ថេរោ ។

ឧទ្ទានំ

មិគសិរោ សិវកោ ច ឧបវាណោ ច បណ្ឌិតោ
ឥសិទិន្នោ ច កច្ចានោ និតកោ ច មហាវសី
បោដិរិយបុត្តោ និសភោ ឧសភោ កប្បដកុរោតិ ។

វគ្គោ ចតុត្ថោ ។

១ ម. ន ភិ ។



ម្នាលកប្បដៈ អ្នកកុំងោកងក់ កុំឲ្យតថាគតបានវាយត្រូវអ្នក ក្នុងទីជិតត្រចៀកទេ ម្នាលកប្បដកុរៈ ព្រោះថា អ្នកមិនស្គាល់ប្រមាណ បានជាអ្នកចេះតែងោកងក់ ក្នុងកណ្ដាលសង្ឃ ។

កប្បដកុរត្ថេរ ។

ឧទ្ទាន

និយាយអំពី មិគសិរត្ថេរ ១ សិវកត្ថេរ ១ ឧបវាណបណ្ឌិតត្ថេរ ១ ឥសិទិន្នត្ថេរ ១ សម្ពុលកច្ចានត្ថេរ ១ និតកត្ថេរមានវសី ១ សោណ-បោដិរិយបុត្តត្ថេរ ១ និសភត្ថេរ ១ ឧសភត្ថេរ ១ កប្បដកុរត្ថេរ ១ ។

ចប់វគ្គទី ៤ ។

## ថេរគាថាយ ទុកនិបាតស្ស បញ្ចមវគ្គោ

(១៦២)អហោ ពុទ្ធា អហោ ធម្មា អហោ នោ សត្ថុ សម្បទា
យត្ថ ឯតាទិសំ ធម្មំ សាវកោ សច្ឆិកាហិតិ ។
អសង្ខេយ្យេសុ កប្បេសុ សក្កាយាធិគតា អហុំ
តេសមយំ បច្ឆិមកោ ចរិមោយំ សមុស្សយោ
ជាតិមរណសំសារោ នត្ថិ ទានិ បុនព្ភវោ ។

កុមារកស្សបោ ថេរោ ។

(១៦៣)យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
ជាគរោ ស ហិ សុត្តេសុ[១] អមោឃន្តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធាន សាសនំ ។

ធម្មបាលោ ថេរោ ។

(១៦៤) កស្សិន្ទ្រិយានិ[២] សមថំ គតានិ
អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

---

១ ម. ជាគរោ បតិសុត្តេសុ ។ ២ យស្សិន្ទ្រិយានីតិបិ បាឋោ ។



## ថេរគាថា ទុកនិបាត បញ្ចមវគ្គ

(១៦២) ឱ! ព្រះពុទ្ធ ឱ! ព្រះធម៌ ឱ! សម្បទា របស់ព្រះសាស្តា នៃយើងទាំងឡាយ ដែលសាវកនឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ប្រាកដ ដូច្នោះ ។ សក្កាយ គឺបញ្ចុបាទានក្ខន្ធ អាត្មាអញបានហើយក្នុងកប្បទាំងឡាយ រាប់ មិនបាន កំណើតនេះ ជាទីបំផុតរបស់បញ្ចុបាទានក្ខន្ធទាំងនោះ កំណើតនេះ ជាខាងក្រោយរបស់បញ្ចុបាទានក្ខន្ធទាំងនោះ សង្សារប្រកបដោយ ជាតិនិងមរណៈ ឥឡូវនេះ ភពថ្មីមិនមានទេ ។

កុមារកស្សបត្ថេរ ។

(១៦៣) ភិក្ខុណាទៅក្មេង ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា កាលពួកសត្វកំពុងដេកលក់ ភិក្ខុនោះជាអ្នកភ្ញាក់រលឹក ជីវិតរបស់ភិក្ខុនោះ មិនសោះសូន្យទេ ។ ហេតុនោះ អ្នកមានប្រាជ្ញា កាលរលឹកឃើញ នូវសាសនានៃព្រះពុទ្ធទាំងឡាយហើយ គួរប្រកបរឿយៗ នូវសទ្ធា សីល សេចក្តីជ្រះថ្លា និងការឃើញធម៌ ។

ធម្មបាលត្ថេរ ។

(១៦៤) ភិក្ខុណាមួយ បានលះបង់មានះ ជាអ្នកមិនមានអាសវៈ មាន ឥន្ទ្រិយដល់នូវសេចក្តីស្ងប់ម្ងាប់ ដូចសេះដែលសារថីបង្ហាត់ល្អ ហើយ ទុកជាពួកទេវតា ក៏ស្រឡាញ់ភិក្ខុអ្នកមិនញាប់ញ័រនោះៗ

មយ្ហំ ប្រិយានិ សមណ កតានិ
រស្មា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ មយ្ហំ បិហយន្តិ តាទិនោតិ ។

ព្រហ្មាលិ ថេរោ ។

(១៦៥) ឆវិបាបក ចិត្តភទ្ទក
មោឃរាជ សតតំ សមាហិតោ
ហេមន្តិកសីតកាលរត្តិយោ (១)
ភិក្ខុ ត្វំសិ កថំ ករិស្សសិ ។
សម្បន្នសស្សា មគធា កេវលា ឥតិ មេ សុតំ
បលាលច្ឆន្នកោ សេយ្យំ យថញ្ញេ សុខជីវិនោតិ ។

មោឃរាជា ថេរោ ។

(១៦៦) ន ឧក្ខិបេ នោ ច បរិក្ខិបេ បរេ
ន ឱក្ខិបេ បារគតំ ន ឯរយេ
ន ចត្តវណ្ណំ បរិសាសុ ព្យាហរេ
អនុទ្ធតោ សម្មិតភាណី សុព្វតោ ។

១ ម. ហេមន្តិកកាលរត្តិយោ ។





គ្នាអញបានលះបង់មានះ មិនមានអាសវៈ ទាំងឥន្ទ្រិយដល់នូវសេចក្តីស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីបង្ហាត់ល្អហើយ ទុកជាទេវតាទាំងឡាយក៏ស្រឡាញ់គ្នាអញអ្នកមិនញាប់ញ័រដែរ ។

ព្រហ្មាលិត្ថេរ ។

(១៦៥) (ព្រះសាស្តាទ្រង់ស្តាប់) ម្នាលមោឃរាជ ជាអ្នកមានសម្បុរអាក្រក់ តែមានចិត្តល្អ អ្នកជាភិក្ខុមានចិត្តដំកល់មាំរឿយៗ អស់រាត្រីទាំងឡាយ ក្នុងកាលត្រជាក់ ប្រកបដោយហេមន្តរដូវ តើអ្នកនឹងធ្វើដោយឧបាយដូចម្តេច ។

(មោឃរាជត្ថេរក្រាបទូលថា) ខ្ញុំព្រះអង្គបានឮដូច្នេះថា ដែនមគធៈទាំងមូល ជាដែនមានសន្ទូងបរិបូណ៌ ពួកភិក្ខុដទៃ មានការរស់នៅជាសុខ (ដោយក្រាលដីនឹងគ្រឿងស្លៀកដណ្តប់ដ៏ល្អ) យ៉ាងណា ខ្ញុំព្រះអង្គ (ក្រាល)បិទបាំងនឹងស្លឹកឈើ សម្រេចនូវការដេក (យ៉ាងនោះដែរ) ។

មោឃរាជត្ថេរ ។

(១៦៦) បុគ្គល មិនគប្បីលើកដំកើងខ្លួន មិនគប្បីបង្អាប់គេ មិនគប្បីផ្ចាលទោសនៃពួកបុគ្គលដទៃ មិនគប្បីបៀតបៀនបុគ្គលអ្នកដល់នូវត្រើយគឺព្រះនិព្វាន មិនគប្បីអួតគុណរបស់ខ្លួន ក្នុងកណ្តាលពួកបរិស័ទ គប្បីជាអ្នកប្រាសចាកឧទ្ធច្ចៈ ជាអ្នកពោលពាក្យល្មមកំណត់ ជាអ្នកមានវត្តល្អចុះ ។

សុសុខុមនិបុណត្ថទស្សិនា មតិកុសលេន និវាតវុត្តិនា
សំសេវិតវុទ្ធសីលិនា និព្វានំ ន ហិ តេន ទុល្លភន្តិ ។

វិសាខោ បញ្ចាលីបុត្តោ[១] ថេរោ ។

(១៦៧) នទន្តិ មោរា សុសិខា សុបេខុណា
សុនីលគីវា សុមុខា សុគជ្ជិនោ
សុសទ្ទលា ចាបិ មហាមហី អយំ
សុព្យាបិតម្ពុ សុវលាហកំ នភំ ។
សុកល្លរូបោ សុមនស្ស ឈាយិតំ
សុនិក្ខមោ[២] សាធុ សុពុទ្ធសាសនេ
សុសុក្កសុក្កំ និបុណំ សុទុទ្ទសំ
ផុសាហិ តំ ឧត្តមមច្ចុតំ បទន្តិ ។

ចូឡកោ ថេរោ ។

(១៦៨) នន្ទមានាគតំ ចិត្តំ សូលមារោបមានកំ
តេន តេនេវ វជសិ យេន សូលំ កលិង្គរំ ។
តាហំ[៣] ចិត្ត កលឹ ព្រូមិ តំ ព្រូមិ ចិត្តទុព្ភកំ

១ ម. បញ្ចាលបុត្តោ ។ ២ ម. សុនិក្ខមោ ។ ៣ ម. សាហំ ។



ព្រោះថា បុគ្គលមានប្រាជ្ញាក់នេះ បានឃើញអត្ថដ៏សុខុម
ក្រៃលែង បានប្រព្រឹត្តបន្ទាបបន្ថោកខ្លួន សេពនូវសីលដ៏ចំរើន
មិនមែនបានព្រះនិព្វានដោយក្របឡើយ ។

វិសាខបញ្ចាលីបុត្តត្ថេរ ។

(១៦៧) ពួកក្ងោក ជាសត្វមានកំពូលល្អ មានសំណុំកន្ទុយល្អ
មានករទៀល្អ មានមុខល្អ មានសម្រែកពីរោះ តែងបន្លឺ
ឡើងផង ទេសភាពធំនេះ មានស្មៅខៀវល្អ មានទឹកជ្រះ
ថ្លាបរិបូណ៌ផង អាកាសមានពពកល្អផង ។ អ្នកជាបុគ្គលមាន
សភាពគួរសមដោយប្រពៃ (ចូរចំរើន) នូវឈាន របស់ព្រះ
យោគាវចរអ្នកមានចិត្តល្អ ចូរមានព្យាយាមល្អ ក្នុងព្រះ
ពុទ្ធសាសនាដោយប្រពៃ ចូរបាននូវព្រះនិព្វាន ជាបទដ៏
ឧត្តម ជាធម៌មានពណ៌សល្អក្រៃពេក ជាធម៌ល្អិត
ជាធម៌ដែលគេកម្រឃើញដោយក្រ ។

ចូឡកត្ថេរ ។

(១៦៨) ចិត្តមកកាន់សេចក្តីត្រេកត្រអាល ដែលកម្មកិលេសលើក
ឡើង ហើយកាន់ដែកស្រួចតំកល់ ដែកស្រួចតំកល់ទីនឹកណាត់
ឈើគឺកាមគុណ មាននៅក្នុងទីណា អ្នកតែងទៅក្នុងទីនោះៗ
នែចិត្តចង្រៃ អញប្រាប់ឯង នែចិត្តកំណាច អញប្រាប់ឯង

សត្ថា តេ ទុល្លភោ លទ្ធោ មានត្ថេ មំ បយោជយីតិ ។

អនូបមោ ថេរោ ។

(១៦៩) សំសរំ ទីឃមទ្ធានំ គតីសុ បរិវត្តិសំ
អបស្សំ អរិយសច្ចានិ អន្ធភូតោ បុថុជ្ជនោ ។
តស្ស មេ អប្បមត្តស្ស សំសារា វិនឡីកតា
សព្វា គតី សមុច្ឆិន្នា នត្ថិ ទានិ បុនព្ភវោតិ ។

វជ្ជិតោ ថេរោ ។

(១៧០) អស្សត្ថេ ហរិតោភាសេ សំវិរូឡ្ហម្ហិ បាទបេ
ឯកំ ពុទ្ធគតំ សញ្ញំ អលភិត្ថំ បតិស្សតោ[1] ។
ឯកត្តិំសេ ឥតោ កប្បេ យំ សញ្ញំ អលភឹ តទា
តស្សា សញ្ញាយ វាហសា បត្តោ មេ អាសវក្ខយោតិ ។

សន្ធិតោ ថេរោ ។

១ ម. អលភឹហំ បតិស្សតោ ។



ព្រះសាស្តា ដែលគេបានដោយក្រ (ឥឡូវនេះ) អ្នកបានហើយ អ្នកកុំដឹកនាំអញទៅក្នុងកំពើឥតប្រយោជន៍ឡើយ ។

អនុបមត្ថេរ ។

(១៦៩) អាត្មាអញ កាលនៅជាបុថុជ្ជន មានទីងងឹតគឺអវិជ្ជាកើតហើយ មិនបានឃើញអរិយសច្ចទាំងឡាយ ក៏អន្ទោលទៅ អស់កាលជាអង្វែង វិលវល់ទៅក្នុងគតិទាំងឡាយ ។ អាត្មាអញនោះ ជាអ្នកមិនប្រមាទ បានធ្វើសង្សារទាំងឡាយឲ្យវិនាសហើយ បានកាត់ផ្តាច់គតិទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានឡើយ ។

វជ្ជិតត្ថេរ ។

(១៧០) ខ្ញុំជាបុគ្គលមានសតិដ៏កល់ខ្ជាប់ គឺបាននូវសញ្ញាមួយ ដែលប្រព្រឹត្តទៅក្នុងព្រះពុទ្ធគុណ ជិតដើមអស្សត្ថព្រឹក្ស[1] ជាឈើមានពណ៌ខៀវ លូតលាស់ត្រសាយត្រសុំល្អ ។ ក្នុងកប្បទី ៣១ អំពីភទ្រកប្បនេះទៅ កាលនោះ ខ្ញុំបាននូវសញ្ញាណា ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈ ព្រោះនាំមកនូវសញ្ញានោះ ។

សន្ធិតត្ថេរ ។

១ បានជាហៅថាដើមអស្សត្ថ ព្រោះជាកន្លែងធ្វើនូវការដកដង្ហើមស្រួលរបស់ពួកសត្វឲ្យកើត ។ អដ្ឋកថា ។

## ឧទ្ទានំ

កុមារកស្សបោ ថេរោ ធម្មបាលោ ច ព្រហ្មាលិ
មោឃរាជា វិសាខោ ច ចូឡកោ ច អនូបមោ
វជ្ជិតោ សន្ធិតោ ថេរោ កិលេសរជវាហនោ ។

វគ្គោ បញ្ចមោ ។

គាថា ទុកនិបាតម្ហិ នវុតិ ចេវ អដ្ឋ ច
ថេរា ឯកូនបញ្ញាសំ ភាសិតា នយកោវិទា ។

ទុកនិបាតោ និដ្ឋិតោ ។



## ឧទ្ទាន

និយាយអំពី កុមារកស្សបត្ថេរ១ ធម្មបាលត្ថេរ១ ព្រហ្មាលិត្ថេរ១ មោឃរាជត្ថេរ១ វិសាខត្ថេរ១ ចូឡកត្ថេរ១ អនូបមត្ថេរ១ វជ្ជិតត្ថេរ១ សន្ធិតត្ថេរកំចាត់បង់នូវធូលីគឺកិលេស១ ។

ចប់វគ្គទី ៥ ។

គាថាក្នុងទុកនិបាតមាន ៩៨ ព្រះថេរៈ ៤៩ អង្គ អ្នកឈ្លាសក្នុងន័យ បានពោលហើយ ។

ចប់ទុកនិបាត ។

## ថេរគាថាយ តិកនិបាតោ

(១៧១) អយោនិសុទ្ធិមន្វេសំ អគ្គឹ បរិចរឹ វនេ
សុទ្ធិមគ្គំ អជានន្តោ អកាសឹ អមរំ[1] តបំ ។
តំ សុខេន សុខំ លទ្ធំ បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ[2] ។
ព្រហ្មពន្ធុ បុរេ អាសឹ ឥទានិ ខោម្ហិ ព្រាហ្មណោ
តេវិជ្ជោ ន្ហាតកោ ចម្ហិ សោត្តិយោ ចម្ហិ វេទគូតិ ។

អង្គណិកភារទ្វាជោ ថេរោ ។

(១៧២) បញ្ចាហាហំ បព្វជិតោ សេក្ខោ អប្បត្តមានសោ
វិហារំ មេ បវិដ្ឋស្ស ចេតសោ បណិធី អហុ
នាសិស្សំ ន បិវិស្សាមិ វិហារតោ ន និក្ខមេ
ន បិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេ ។
តស្ស មេវំ វិហរតោ បស្ស វីរិយបរក្កមំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

បច្ចយោ ថេរោ ។

---

១ ម. អកាសឹ អមរំ ។ ឱ. អកាសិមមតំ ។ ២ ម. សាសនន្តិ ។



## ថេរគាថា តិកនិបាត

(១៧១) កាលខ្ញុំស្វែងរកសេចក្តីបរិសុទ្ធិ ដោយខុសចំនង បានបំរើភ្លើងក្នុងព្រៃ មិនបានដឹងនូវផ្លូវនៃសេចក្តីបរិសុទ្ធិ ហើយក៏ធ្វើនូវតបៈដទៃ (ដែលញុំាងខ្លួនឲ្យលំបាក) ។ ខ្ញុំបានសុខនោះ អាត្មាអញបានដោយស្រួលហើយ អ្នកចូរមើលនូវភាពនៃធម៌ដ៏ល្អចុះ វិជ្ជា ៣ អាត្មាអញបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។ ពីដើម អាត្មាអញជាផៅពង្សនៃព្រហ្ម (ជាព្រាហ្មណ៍ដោយសម្មតិ) ឥឡូវនេះ អាត្មាជាព្រាហ្មណ៍មែន ព្រោះអាត្មាអញជាអ្នកបានវិជ្ជា ៣ ផង មានមន្ទិលគឺកិលេសបានលាងហើយផង ជាអ្នកមានសួស្តីផង ដល់នូវវេទផង ។

អង្គណិកភារទ្វាជត្ថេរ ។

(១៧២) ខ្ញុំបួសបាន ៥ ថ្ងៃ នៅជាសេក្ខបុគ្គល មិនទាន់សម្រេចព្រះអរហត្តនៅឡើយ កាលខ្ញុំចូលទៅក្នុងកុដិ មានចិត្តតាំងមាំថា អាត្មាអញនឹងមិនបរិភោគ នឹងមិនផឹក មិនចេញអំពីកុដិ កាលបើសរគឺតណ្ហា អាត្មាអញមិនទាន់ដកចេញទេ អាត្មាអញនឹងមិនប្រែខ្សៀងឡើយ ។ អ្នកចូរមើលសេចក្តីព្យាយាមប្រឹងប្រែងរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះចុះ វិជ្ជា ៣ អាត្មាអញបានដល់ ដោយលំដាប់ហើយ ពិធីសាសនារបស់ព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ។

បច្ចយត្ថេរ ។

(១៧៣) យោ បុព្វេ ករណីយានិ   បច្ឆា សោ កាតុមិច្ឆតិ

សុខា សោ ធំសតេ ឋានា   បច្ឆា ច អនុតប្បតិ ។

យញ្ហិ កយិរា តញ្ហិ វទេ   យំ ន កយិរា ន តំ វទេ

អករោន្តំ ភាសមានំ   បរិជានន្តិ បណ្ឌិតា ។

សុសុខំ វត និព្វានំ   សម្មាសម្ពុទ្ធទេសិតំ

អសោកំ វិរជំ ខេមំ   យត្ថ ទុក្ខំ និរុជ្ឈតីតិ ។

ពាកុលោ ថេរោ ។

(១៧៤) សុខញ្ចេ ជីវិតុំ ឥច្ឆេ   សាមញ្ញស្មឹ អបេក្ខវា

សង្ឃិកំ នាតិមញ្ញេយ្យ   ចីវរំ បានភោជនំ ។

សុខញ្ចេ ជីវិតុំ ឥច្ឆេ   សាមញ្ញស្មឹ អបេក្ខវា

អហិ មូសិកសោព្ភំវ   សេវេថ សយនាសនំ ។

សុខញ្ចេ ជីវិតុំ ឥច្ឆេ   សាមញ្ញស្មឹ អបេក្ខវា

ឥតរីតរេន តុស្សេយ្យ   ឯកធម្មញ្ច ភាវយេ ។

ធនិយោ ថេរោ ។

(១៧៥) អតិសីតំ អតិឧណ្ហំ   អតិសាយមិទំ អហុ

ឥតិ វិស្សដ្ឋកម្មន្តេ   ខណា អច្ចេន្តិ មាណវេ ។



(១៧៣) បុគ្គលណា (មិនធ្វើ)នូវអំពើដែលគួរធ្វើ ក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះរមែងឃ្លាតចាកឋានៈជាសុខផង តែងក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា គួរនិយាយតែអំពើនោះ មិនធ្វើអំពើណា មិនគួរនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គលកាលមិនធ្វើ បាននិយាយ ។ សេចក្ដីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ ជាគុណជាតមិនមានសេចក្ដីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត ដ៏មកនូវសេចក្ដីសុខ ដោយប្រពៃមែនពិត ។

ពាកុលត្ថេរ ។

(១៧៤) បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល មិនគប្បីមើលងាយចីវរ ទឹកនឹងភោជនជារបស់សង្ឃទេ ។ បើបុគ្គលស្រឡាញ់ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីសេពទីដេកនិងទីអង្គុយ ដូចជាពស់សេពនូវរន្ធរបស់កណ្ដុរ ។ បើបុគ្គលស្រឡាញ់ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីត្រេកអរដោយបច្ច័យតាមមានតាមបានផង គប្បីចំរើនធម៌ឯកផង ។

ធនិយត្ថេរ ។

(១៧៥) ខណៈរមែងប្រព្រឹត្តកន្លងនូវមាណពទាំងឡាយ ដែលមានការងារលះបោល (ដោយគិតថា) ត្រជាក់ពេក ក្ដៅពេក ល្ងាចពេក ។

យោ ច សីតញ្ច ឧណ្ហញ្ច តិណា ភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ សោ សុខា ន វិហាយតិ ។
ទព្វំ កុសំ បោដកិលំ ឧសីរំ មុញ្ជបព្វជំ
ឧរសា បនុទហិស្សាមិ វិវេកមនុព្រូហយន្តិ ។

មាតង្គបុត្តោ ថេរោ ។

(១៧៦) យេ ចិត្តកថី ពហុស្សុតា
សមណា បាតលិបុត្តវាសិនោ
តេសញ្ញតរោយមាយុវា
ទ្វារេ តិដ្ឋតិ ខុជ្ជសោភិតោ ។
យេ ចិត្តកថី ពហុស្សុតា
សមណា បាតលិបុត្តវាសិនោ
តេសញ្ញតរោយមាយុវា
ទ្វារេ តិដ្ឋតិ មាលុតេរិតោ ។
សុយុទ្ធេន សុយិដ្ឋេន សង្គាមវិជយេន ច
ព្រហ្មចរិយានុចិណ្ណេន ឯវាយំ សុខមេធតីតិ ។

ខុជ្ជសោភិតោ ថេរោ ។



បុគ្គលណាមួយ កាលធ្វើនូវកិច្ចរបស់បុរស មិនអើពើចំពោះត្រជាក់ និងក្តៅឲ្យក្រៃលែងជាងស្មៅ បុគ្គលនោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។ អាត្មាអញកាលចំរើននូវវិវេក នឹងកំចាត់បង់បាននូវស្មៅចំពោះ ស្បូវ ត្រែងឈើមានបម្លា ស្បូវល្ពាស ស្មៅដំណេកទន្សាយ និងស្មៅឃាប្ញូន (កិលេសគ្រោតគ្រាត-កណ្ដាល-ល្អិត) ដោយទ្រូង (សេចក្តីព្យាយាម) ។

មាតង្គបុត្តត្ថេរ ។

(១៧៦) ពួកសមណៈណា ជាអ្នកមានសំដីវិចិត្រ ជាពហុស្សូត នៅក្នុងក្រុងបាតលិបុត្តជាប្រក្រតី បណ្ដាពួកសមណៈទាំងនោះ ខុជ្ជសោភិតត្ថេរមានអាយុនេះ ជាសមណៈមួយរូបដែរ ឈរជិតទ្វារ ។

ពួកសមណៈណា ជាអ្នកមានសំដីវិចិត្រ ជាពហុស្សូត នៅក្នុងក្រុងបាតលិបុត្ត ជាប្រក្រតី បណ្ដាសមណៈទាំងនោះ ខុជ្ជសោភិតត្ថេរ មានអាយុនេះ ជាសមណៈមួយរូបដែរ ជាអ្នកមកដោយខ្យល់ គឺមកដោយកម្លាំងនៃឫទ្ធិហើយឈរជិតទ្វារ ។

ខុជ្ជសោភិតត្ថេរនេះ បានដល់នូវសេចក្តីសុខ ដោយការច្បាំង (នឹងពួកកិលេស)ផង ដោយបូជាល្អផង ដោយការឈ្នះសង្គ្រាមផង ដោយការសន្សំនូវព្រហ្មចរិយធម៌ផង ។

ខុជ្ជសោភិតត្ថេរ ។

(១៧៧) យោធ កោចិ មនុស្សេសុ បរបាណានិ ហឹសតិ
អស្មា លោកា បរម្ហា ច ឧភយា ធំសតេ នរោ ។
យោ ច មេត្តេន ចិត្តេន សព្វបាណានុកម្បតិ
ពហុំ ហិ សោ បសវតិ បុញ្ញំ តាទិសកោ នរោ ។
សុភាសិតស្ស សិក្ខេថ សមណុបាសនស្ស ច
ឯកាសនស្ស ច រហោ ចិត្តវូបសមស្ស ចាតិ ។

វារណោ ថេរោ ។

(១៧៨) ឯកោបិ សទ្ធោ មេធាវី អស្សទ្ធានំ[១] ចញាតិនំ
ធម្មដ្ឋោ សីលសម្បន្នោ ហោតិ អត្ថាយ ពន្ធុនំ ។
និគ្គយ្ហ អនុកម្បាយ ចោទិតា ញាតយោ មយា
ញាតិពន្ធវបេមេន ការំ កត្វាន ភិក្ខុសុ ។
តេ អព្ភតីតា កាលកតា បត្តា តេ តិទិវំ សុខំ
ភាតរោ មយ្ហំ មាតា ច មោទន្តិ កាមកាមិនោតិ ។

បស្សិកោ ថេរោ ។

១ ឱ. ម. អស្សទ្ធានិធ ។



(១៧៧) បណ្ដាពួកមនុស្ស ក្នុងលោកនេះ ជនណាមួយ បៀតបៀនសត្វដទៃ ជននោះរមែងសាបសូន្យ ចាកប្រយោជន៍ទាំងសេចក្ដីសុខក្នុងលោកនេះនិងលោកខាងមុខ ។ លុះតែជនណាអនុគ្រោះដល់សត្វទាំងពួង ដោយចិត្តប្រកបដោយមេត្តា ជនប្រាកដដូច្នោះនោះ ទើបបានបុណ្យដ៏ច្រើន ។ បុគ្គលគប្បីសិក្សាសុភាសិតផង នូវការចូលទៅកាន់សមណៈផង នូវការអង្គុយតែម្នាក់ឯងក្នុងទីស្ងាត់ផង នូវការញ៉ាំងចិត្តឲ្យស្ងប់ខ្ជាប់ផង ។

វារណត្ថេរ ។

(១៧៨) បុគ្គលអ្នកមានសទ្ធា មានប្រាជ្ញា ឋិតនៅក្នុងធម៌ បរិបូណ៌ដោយសីល សូម្បីតែម្នាក់ឯង ក៏រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ពួកញាតិនិងផៅពង្ស ដែលជាអ្នកមិនមានសទ្ធា ។ ញាតិទាំងឡាយ ដែលខ្ញុំផ្ចាញ់ផ្ចាល់រឭកដាស់តឿន ដោយសេចក្ដីអនុគ្រោះ ក៏បានធ្វើសក្ការៈចំពោះពួកភិក្ខុ ដោយសេចក្ដីស្រឡាញ់ជាញាតិ ជាផៅពង្ស ។ ពួកញាតិទាំងនោះ លុះធ្វើមរណកាលកន្លងលោកនេះទៅហើយ ក៏បានដល់នូវសេចក្ដីសុខក្នុងទេវលោក ទាំងបងប្អូនទាំងមាតារបស់ខ្ញុំ ក៏ជាអ្នកបរិបូណ៌ដោយកាមគុណ រមែងត្រេកអរដែរ ។

បស្សិកត្ថេរ ។

(១៧៩) កាលាបព្វង្គសង្កាសោ កិសោ ធមនិសន្ថតោ[១]
មត្តញ្ញូ អន្នបានម្ហិ អទីនមនសោ[២] នរោ ។
ផុដ្ឋោ ឌំសេហិ មកសេហិ អរញ្ញស្មឹ ព្រហាវនេ
នាគោ សង្គាមសីសេវ សតោ តត្រាធិវាសយេ ។
យថា ព្រហ្មា តថា ឯកោ យថា ទេវោ តថា ទុវេ
យថា គាមោ តថា តយោ កោលាហលំ តតុត្តរិំ ។

យសោជោ ថេរោ ។

(១៨០) អហុ តុយ្ហំ បុរេ សទ្ធា សា តេ អជ្ជ ន វិជ្ជតិ
យំ តុយ្ហំ តុយ្ហមេវេតំ នត្ថិ ទុច្ចរិតំ មម ។
អនិច្ចា ហិ ចលា សទ្ធា ឯវំ ទិដ្ឋា ហិ សា មយា

១ ឱ. ធមនិសន្ថតោ ។ ម. ធមនិសន្ថតោ ។ ២ ឱ. អាទីនមនសោ ។ ម. អាទីន-មានសោ ។



(១៧៩) (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) នរៈមិនមានចិត្តរួញរា មាន សរីរៈប្រាកដស្មើដោយថ្នាំងនៃវល្លិ៍ មានខ្លួនស្គមរីងរៃដោយ សរសៃ ដឹងប្រមាណក្នុងបាយនឹងទឹក ជាអ្នកមានចិត្តមិនរួញរា ។ យសោជត្ថេរ ពោលថា ភិក្ខុ (នៅ) ក្នុងព្រៃតូចឬព្រៃធំ បើទុកជា សត្វរបោមនិងមូសខាំហើយ គប្បីជាអ្នកមានស្មារតី អត់ទ្រាំ ចំពោះអន្តរាយ មានរបោមជាដើម ក្នុងព្រៃនោះ ដូចដំរីដ៏ប្រសើរ អត់ទ្រាំ ក្នុងទីជាប្រធាន នៃសង្គ្រាម ។ ភិក្ខុ តែម្នាក់ឯង (រមែង នៅជាសុខ) ដូចគ្នានឹងព្រហ្ម ភិក្ខុនៅរួមគ្នាពីររូប (រមែងមាន សេចក្តីត្រេកអរ) ដូចគ្នានឹងទេវតា ភិក្ខុ (នៅរួមគ្នា) ៣ រូប ដូចគ្នា នឹងជនអ្នកស្រុក ភិក្ខុមានចំនួនច្រើនរូបលើសពីនោះទៅ ជាហេតុ នាំឲ្យជ្រួលច្រើម (ដូចគ្នានឹងពួកមហាជនដែលប្រជុំគ្នា) ។

យសោជត្ថេរ ។

(១៨០) សទ្ធារបស់អ្នក មានក្នុងកាលមុន ប៉ុន្តែក្នុងថ្ងៃនេះ សទ្ធានោះ បែរជាមិនមានដល់អ្នកវិញ បច្ច័យណា ដែលជារបស់អ្នក បច្ច័យ នោះ ចូរជារបស់អ្នកវិញចុះ ទុច្ចរិត មិនមានដល់អាត្មាទេ ។ ព្រោះថា សទ្ធា (របស់បុថុជ្ជន) ជាធម្មជាតិ មិនទៀង ឃ្លេងឃ្លោង មិនទៀង សទ្ធា យ៉ាងនេះ អាត្មា បានឃើញជាក់ច្បាស់ហើយ

វុដ្ឋិតំ ភិន្ទិតំ   គន្ត្វា តំ បិយ្យតេ បុនំ ។
បក្កតិ ឧបលោ ភត្តំ   ថោកំ ថោកំ កាលេ កាលេ
បិណ្ឌិកាយ ចរិស្សាមិ   អត្ថិ ជង្ឃពលំ មមាតិ ។

សាមិទត្តោ ថេរោ ។

(១៨១) សទ្ធាយ អភិនិក្ខម្ម   នវបព្វជិតោ នវោ
មិត្តេ ភជេយ្យ កល្យាណេ   សុទ្ធាជីវេ អតន្ទិតេ ។
សទ្ធាយ អភិនិក្ខម្ម   នវបព្វជិតោ នវោ
សង្ឃស្មឹ វិហរំ ភិក្ខុ   សិក្ខេថ វិនយំ ពុធោ ។
សទ្ធាយ អភិនិក្ខម្ម   នវបព្វជិតោ នវោ
កប្បាកប្បេសុ កុសលោ   ចរេយ្យ អបុរក្ខតោ ។

ឧបាលិ ថេរោ ។

(១៨២) បណ្ឌិតំ វត មំ សន្តំ   អលមត្ថវិចិន្តកំ
បញ្ច កាមគុណា លោកេ   សម្មោហា បាតយិំសុ មំ ។



សត្វទាំងឡាយ ជួនកាលត្រេកអរ ជួនកាលប្រាសចាកសេចក្តីត្រេកអរ (ព្រោះហេតុនោះ) អ្នកប្រាជ្ញ ទីនឈ្មះ ចំពោះការត្រេកអរនឹងមិនត្រេកអរនោះ ដូចម្តេចកើត ។ ភត្តដែលគេចំអិន បំរុងអ្នកប្រាជ្ញ បន្តិចៗ រាល់ៗត្រកូល អាត្មានឹងត្រាច់ទៅ ដើម្បីដុំបាយ (ព្រោះ)កម្លាំងស្មងរបស់អាត្មាមាននៅឡើយ ។

សាមិទត្តិយត្ថេរ ។

(១៨១) កុលបុត្តចេញ(ចាកឃរាវាស)ដោយសទ្ធាហើយបួសថ្មី ជានវកភិក្ខុ គប្បីគប់រកកល្យាណមិត្រទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។ កុលបុត្ត ចេញ(ចាកឃរាវាស) ដោយសទ្ធា បួសថ្មី ជានវកភិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួក គប្បីសិក្សាក្នុងវិន័យ ។ កុលបុត្ត ចេញ(ចាកឃរាវាស) ដោយសទ្ធា បួសថ្មី ជានវកភិក្ខុ ជាអ្នកឈ្លាស ក្នុងហេតុដែលគួរនឹងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យ (ពួកកិលេស មានតណ្ហាជាដើម) ប្រព្រឹត្តទៅក្នុងខាងមុខបាន ។

ឧបាលិត្ថេរ ។

(១៨២) ខ្ញុំ កាមគុណទាំង៥ ញុំាងអាត្មាអញជាបណ្ឌិតមានសមត្ថភាពគិតនូវប្រយោជន៍ ឲ្យធ្លាក់ចុះក្នុងលោក ព្រោះតែសេចក្តីវង្វេងទេតើ ។

បក្ខន្ទោ មារវិសយេ ទឡ្ហសល្លសមប្បិតោ
អសក្ខិំ មច្ចុរាជស្ស អហំ បាសា បមុច្ចិតុំ ។
សព្វេ កាមា បហីនា មេ ភវា សព្វេ បទាលិតា
វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោ ។

ឧត្តរបាលោ ថេរោ ។

(១៨៣) សុណាថ ញាតយោ សព្វេ យាវន្តេត្ថ សមាគតា
ធម្មំ វោ ទេសយិស្សាមិ ទុក្ខា ជាតិ បុនប្បុនំ ។
អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ
ធុនាថ មច្ចុនោ សេនំ នឡាគារំវ កុញ្ជរោ ។
យោ ឥមស្មិំ ធម្មវិនយេ អប្បមត្តោ វិហស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតិ ។

អភិភូតោ ថេរោ ។

(១៨៤) សំសរំ ហិ និរយំ អគច្ឆិសំ
បេតលោកមគមំ បុនប្បុនំ
ទុក្ខមម្ហិបិ តិរច្ឆានយោនិយា[១]
នេកធា ហិ វុសិតំ ចិរំ មយា ។
មានុសោបិ ច ភវោភិរាធិតោ

១ ម. តិរច្ឆានយោនិយំ ។



អាត្មាអញ ចូលទៅក្នុងវិស័យនៃកិលេសមារ ត្រូវសរគឺកន្លះមុតជាប់ហើយ តែអាចរួចចាកអន្ទាក់នៃមច្ចុរាជបាន ។ កាមទាំងពួង អាត្មាអញបានលះបង់ហើយ ភពទាំងពួង អាត្មាអញបានទំលាយចោលហើយ ជាតិសង្សារអស់ហើយ ឥឡូវនេះ ភពថ្មីមិនមាន ។

ឧត្តរបាលត្ថេរ ។

(១៨៣) នែពួកញាតិទាំងអស់ ដែលមកជួបជុំក្នុងទីនេះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ចុះ អាត្មាសូមសំដែងធម៌ដល់អ្នកទាំងឡាយថា ការកើតរឿយៗ ជាហេតុនាំមកនូវទុក្ខ ។ អ្នកទាំងឡាយ ចូរប្រារព្ធព្យាយាម ចូរចេញចេញ (ចាកសេចក្តីខ្ជិល) ចូរប្រកប (នូវសិក្ខាមានអធិសីលសិក្ខាជាដើម) ក្នុងព្រះពុទ្ធសាសនា ចូរកំចាត់បង់នូវសេនានៃមច្ចុ ឲ្យដូចដំរីកំចាត់បង់នូវផ្ទះដែលធ្វើដោយដើមបបុស ដូច្នោះចុះ ។ បុគ្គលណា ជាអ្នកមិនមានសេចក្តីប្រមាទក្នុងធម្មវិន័យនេះ បុគ្គលនោះនឹងលះបង់នូវជាតិសង្សារ ធ្វើនូវទីបំផុតនៃទុក្ខបាន ។

អភិភូតត្ថេរ ។

(១៨៤) អាត្មាអញ កាលអន្ទោលទៅ (ក្នុងសង្សារ) បានទៅ
កាន់នរកញយ ៗ ផង ទៅកាន់ប្រេតវិស័យញយ ៗ ផង
បានកើតក្នុងកំណើតតិរច្ឆានដ៏ទុក្ខជាញយ ៗ ផង ហើយ
អាត្មាអញនៅ (ដោយទុក្ខ) អស់កាលយូរអង្វែង ។ ម្យ៉ាង
ទៀត ភពជារបស់មនុស្ស អាត្មាអញ ធ្លាប់បានហើយ

សត្តកាយមេតំ សតី សតី

រូបធាតុសុ អរូបធាតុសុ

នេវសញ្ញីសុ អសញ្ញីសុដ្ឋិតំ ។

សម្ភវ សុវិទិតា អសារកា

សង្ខតា បចលិតា សទេរិតា

តំ វិទិត្វាមហមត្តសម្ភវំ

សន្តិមេវ សតិមា សមជ្ឈគន្តិ ។

គោតមោ ថេរោ ។

(១៨៥) យោ បុព្វេ ករណីយានិ បច្ឆា សោ កាតុមិច្ឆតិ

សុខា សោ ធំសតេ ឋានា បច្ឆា ច មនុតប្បតិ ។

យញ្ហិ កយិរា តញ្ហិ វទេ យំ ន កយិរា ន តំ វទេ

អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា ។

សុសុខំ វត និព្វានំ សម្មាសម្ពុទ្ធទេសិតំ

អសោកំ វិរជំ ខេមំ យត្ថ ទុក្ខំ និរុជ្ឈតីតិ ។

ហារិតោ ថេរោ ។



ចូនកាល អាត្មាអញបានទៅកើត ក្នុងពួកនៃទេវតាក្នុងឋានសួគ៌ ចូនកាល អាត្មាអញបានទៅកើតក្នុងរូបភព ក្នុងអរូបភព ក្នុងនេវសញ្ញីភព ក្នុងអសញ្ញីភព (ទីនេវសញ្ញីនាសញ្ញីភព) ។ ភពទាំងឡាយដែលប្រកបដោយបច្ច័យ អាត្មាបានដឹងច្បាស់ហើយ ថាជារបស់ឥតខ្លឹម ជារបស់បច្ច័យ តាក់តែងហើយ ជារបស់ឃ្លើនឃ្លោង (ដោយអំណាចផលជាដើម) ជារបស់ប្រព្រឹត្តទៅ ដោយការបែកធ្លាយសព្វកាល អាត្មាអញដឹងច្បាស់នូវសភាវៈនៃសង្ខតធម៌នោះ ជាសភាវៈកើតក្នុងខ្លួន ហើយជាអ្នកមានស្មារតី បាននូវសេចក្តីស្ងប់រម្ងាប់មែនពិត ។

គោតមត្ថេរ ។

(១៨៥) បុគ្គលណា មិនធ្វើនូវកិច្ចដែលគួរធ្វើក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខផង ក្តៅក្រហាយក្រោយៗក្នុងកាលជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គល មិនធ្វើបានតែនិយាយ ។ សេចក្តីសុខក្រៃលែងនៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ ជាគុណជាត មិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសុខដោយប្រពៃមែនពិត ។

ហារិតត្ថេរ ។

[៤៦] បាបមិត្តេ វិវជ្ជេត្វា ភជេយ្យុត្តមបុគ្គលំ[១]
ឱវាទេ ចស្ស តិដ្ឋេយ្យ បត្ថេន្តោ អចលំ សុខំ ។
បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម សាធុជីវីបិ[២] សីទតិ ។
តស្មា តំ បរិវជ្ជេយ្យ កុសីតំ ហីនវីរិយំ ។
បវិវិត្តេហិ អរិយេហិ បហិតត្តេហិ ឈាយិហិ
និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាវសេ ។

វិមលោ ថេរោ ។

## ឧទ្ទានំ

អង្គណិកោ ភារទ្វាជោ បច្ចយោ ពាកុលោ ឥសិ
ធនិយោ មាតង្គបុត្តោ ច សោភិតោ វារណោ ឥសិ
វស្សិកោ ច យសោជោ ច សាដិមត្តិយុបាលិ ច
ឧត្តរបាលោ អភិភូតោ គោតមោ ហារិតោបិ ច
ថេរោ តិកនិបាតម្ហិ និព្វានេ វិមលោ កតោ
អដ្ឋតាលីស គាថាយោ ថេរា សោឡស កិត្តិតាតិ ។

តិកនិបាតោ និដ្ឋិតោ ។

---

១ ម. បត្តុំ ។ ២ ម. សាធុជីវីបិ ។



(១៥៤) កុលបុត្រ កាលប្រាថ្នានូវសេចក្ដីសុខមិនកម្រើក គប្បីវៀរចាកនូវបាបមិត្តទាំងឡាយ ហើយគប់រកនូវបុគ្គលខ្ពង់ខ្ពស់ គប្បីតាំងនៅក្នុងឱវាទរបស់កល្យាណមិត្តនោះផង ។ បុគ្គលឡើងកាន់ឈើតូច រមែងលិចចុះ ក្នុងសមុទ្រធំ យ៉ាងណា កុលបុត្រអាស្រ័យនូវបុគ្គលខ្ជិលច្រអូសហើយ ទុកជាមានការរស់នៅស្រួល ក៏រមែងលិចចុះ យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បុគ្គលគប្បីវៀរចាកនូវបុគ្គលអ្នកខ្ជិលច្រអូស មានព្យាយាមថោកថយនោះចេញ ។ កុលបុត្រគប្បីនៅរួមជាមួយនឹងពួកអរិយៈ អ្នកមានចិត្តស្ងប់ស្ងាត់ អ្នកចំរើនឈាន មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាបណ្ឌិតមានព្យាយាម តឹងរឹងជានិច្ច ។

វិមលត្ថេរ ។

## ឧទ្ទាន

និយាយអំពី លោកអ្នកស្ដែងនូវគុណធំ អង្គណិកភារទ្វាជត្ថេរ១ បច្ចយត្ថេរ១ ពាកុលត្ថេរ១ ធនិយត្ថេរ១ មាតង្គបុត្តត្ថេរ១ ខុជ្ជសោភិតត្ថេរ១ វារណត្ថេរ១ ម្យ៉ាងទៀត លោកអ្នកធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺវស្សិកត្ថេរ១ យសោជត្ថេរ១ សាដិមត្តិយត្ថេរ១ ឧបាលិត្ថេរ១ ឧត្តរបាលត្ថេរ១ អភិភូតត្ថេរ១ គោតមត្ថេរ១ ហារិតត្ថេរ១ វិមលត្ថេរ១ ព្រះថេរៈទាំងឡាយ ១៦ អង្គ បានសំដែងនូវគាថា ៤៨ ដែលមកក្នុងតិកនិបាត ។

ចប់ តិកនិបាត ។

## ថេរគាថាយ ចតុក្កនិបាតោ

(១៨៧) អលង្កតា សុវសនា   មាលិនី ចន្ទនុស្សទា
មជ្ឈេ មហាបថេ នារី   តុរិយេ នច្ចតិ នដ្ដកី ។
បិណ្ឌិកាយ បវិដ្ឋោហំ   គច្ឆន្តោ នំ ឧទិក្ខិសំ
អលង្កតំ សុវសនំ   មច្ចុបាសំវ ឱឌ្ឌិតំ ។
តតោ មេ មនសីការោ   យោនិសោ ឧទបជ្ជថ
អាទីនវោ បាតុរហុ   និព្វិទា សមតិដ្ឋថ[1] ។
តតោ ចិត្តំ វិមុច្ចិ មេ   បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនន្តិ ។

នាគសមាលោ ថេរោ ។

(១៨៨) អហំ មិទ្ធេន បកតោ   វិហារា ឧបនិក្ខមឹ
ចង្កមំ អភិរូហន្តោ   តត្ថេវ បបតឹ ឆមា ។
គត្តានិ បរិមជ្ជិត្វា   បុន បារុយ្ហ ចង្កមំ
ចង្កមេ ចង្កមឹ សោហំ   អជ្ឈត្តំ សុសមាហិតោ ។
តតោ មេ មនសីការោ   យោនិសោ ឧទបជ្ជថ

[1] ឱ. សមតិដ្ឋិ ។

## ថេរគាថា ចតុក្កនិបាត

(១៨៧) ស្ត្រីម្នាក់ មានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ទ្រទ្រង់ផ្កាកម្រង ប្រោះព្រំដោយខ្លឹមចន្ទន៍ រាំក្នុងតូរ្យតន្ត្រី ក្រនីកណ្តាលថ្នល់ធំ ។ អាត្មាអញកំពុងដើរចូលទៅ (កាន់ក្រុង) ដើម្បីបិណ្ឌបាត ហើយក្រឡេកមើលទៅឃើញស្ត្រីនោះ ដែលមានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមច្ចុដាំឡើងហើយ ។ លំដាប់នោះការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតឡើងប្រាកដដល់អាត្មាអញ និព្វិទាញាណ ក៏តាំងនៅព្រម ។ ចិត្តរបស់អាត្មាអញក៏រួចស្រឡះ(ចាកកិលេស) ព្រោះវិបស្សនាញាណនោះ អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។

នាគសមាលត្ថេរ ។

(១៨៨) ខ្ញុំព្រះអង្គត្រូវមិទ្ធៈគ្របសង្កត់ហើយចេញអំពីវិហារ ឡើងកាន់ទីចង្ក្រម ក៏ដួលចុះលើផែនដីក្នុងទីចង្ក្រមនោះឯង ។ ខ្ញុំព្រះអង្គមានចិត្តដំកល់មាំល្អខាងក្នុង ហើយបោសសំអាតខ្លួន ឡើងកាន់ទីចង្ក្រម ដើរចង្ក្រមក្នុងទីចង្ក្រមម្តងទៀត ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់ខ្ញុំព្រះអង្គ

អាទីនវោ បាតុរហុ និព្វិទា សមតិដ្ឋថ ។
តតោ ចិត្តំ វិមុច្ចិ មេ បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

ភគុ ថេរោ ។

(១៨៩) បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។
យទា ច អវិជានន្តា ឥរិយន្ត្យមរា វិយ[1]
វិជានន្តិ ច យេ ធម្មំ អាតុរេសុ អនាតុរា ។
យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។
យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
អារកា ហោតិ សទ្ធម្មា នភំ បថវិយា[2] យថា តិ ។

សភិយោ ថេរោ ។

១ ឱ. ឥរិយន្ត្យមរា វិយ ។ ម. ឥរិយន្តាមរា វិយ ។



ទោសក៏ពិតប្រាកដ និព្វិទាញាណក៏តាំងនៅព្រម ។ ចិត្តរបស់ខ្ញុំព្រះអង្គ ក៏រួចស្រឡះ (ចាកកិលេស) ព្រោះហេតុនោះញាណនោះ អ្នកចូរមើលនូវសភាវៈនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ ខ្ញុំព្រះអង្គបានដល់លំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំព្រះអង្គបានធ្វើហើយ ។

ភគុត្ថេរ ។

(១៨៩) ពួកជនដទៃឡើយ រមែងមិនដឹងថា យើងទាំងឡាយនឹងវិនាស ក្នុងកណ្ដាលនៃពួកនេះ ដូច្នេះឡើយ ចំណែកឯជនទាំងឡាយណា ជាបណ្ឌិតក្នុងពួកនោះ រមែងដឹងច្បាស់ ឯការឈ្លោះប្រកែក តែងស្ងប់រម្ងាប់អំពីសំណាក់នៃជនទាំងឡាយជាបណ្ឌិតនោះ ។ កាលណាបើជនទាំងឡាយមិនដឹង (នូវឧបាយនៃការស្ងប់រម្ងាប់នៃវិវាទ) រមែងប្រព្រឹត្តទៅ ហាក់ដូចជាមិនស្លាប់ (កាលនោះ វិវាទក៏មិនស្ងប់រម្ងាប់ឡើយ) ចំណែកជនទាំងឡាយណា ដឹងច្បាស់ធម៌ (ជនទាំងឡាយនោះ) កាលបើពួកសត្វ មានសេចក្ដីក្ដៅក្រហាយ ក៏នៅជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយឡើយ ។ កម្មណាមួយធូរថយក្ដី វ័តណាមួយសៅហ្មងក្ដី ព្រហ្មចរិយៈណាមួយដែលបុគ្គលរលឹក ដោយសេចក្ដីរង្កៀសក្ដី កម្មទាំងនោះ ជារបស់មិនមានផលច្រើនឡើយ ។ បុគ្គលណា មិនមានសេចក្ដីគោរព ក្នុងព្រហ្មចារីបុគ្គលទាំងឡាយ (បុគ្គលនោះ) រមែងជាអ្នកឆ្ងាយ ចាកព្រះសទ្ធម្ម ដូចជាមេឃឆ្ងាយអំពីផែនដី ។

សភិយត្ថេរ ។

(១៩០) ធិរត្ថុ[១] បូរេ ទុគ្គន្ធេ មារបក្ខេ អវស្សុតេ
នវសោតានិ តេ កាយេ យានិ សន្ទន្តិ សព្វទា ។
មា បុរាណំ អមញ្ញិត្ថោ មាសាទេសិ តថាគតេ
សគ្គេបិ តេ ន រជ្ជន្តិ កិមង្គំ បន មានុសេ ។
យេ ច ខោ ពាលា ទុម្មេធា ទុម្មន្តី មោហបារុតា
តាទិសា តត្ថ រជ្ជន្តិ មារខិត្តស្មិំ ពន្ធនេ ។
យេសំ រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា ។
តាទី តត្ថ ន រជ្ជន្តិ[២] ឆិន្នសុត្តា អពន្ធនា ។

នន្ទកោ ថេរោ ។

(១៩១) បញ្ចបញ្ញាស វស្សានិ រជោជល្លមធារយឹ
ភុញ្ជន្តោ មាសិកំ ភត្តំ កេសមស្សុំ អលោចយឹ ។
ឯកបាទេន អដ្ឋាសឹ អាសនំ បរិវជ្ជយឹ
សុក្ខគូថានិ ច ខាទឹ ឧទ្ទេសញ្ច ន សាទិយឹ ។
ឯតាទិសំ ករិត្វាន ពហុំ ទុគ្គតិគាមិនំ
វុយ្ហមានោ មហោឃេន ពុទ្ធំ សរណមាគមំ ។

១ ធិ ។ ២ ម. តាទិសា តត្ថ រជ្ជន្តិ ។



(១៩០) ធ្មីយរ នែនាង ជាស្រីពេញ (ដោយរបស់មិនស្អាត) មានក្លិនស្អុយ ជាពួកនៃមារ មានកាយទទឹក (ដោយកិលេស) រន្ធទាំង ៩ ក្នុងកាយរបស់នាង តែងហូរហៀរសព្វ ១ កាល ។ នាងកុំសំគាល់រឿងចាស់ កុំញុំាងព្រះតថាគតទាំងឡាយ ឲ្យត្រេកអរឡើយ សូម្បីក្នុងឋានសួគ៌ក្តី ព្រះតថាគតទាំងឡាយនោះ ក៏មិនត្រេកអរទៅហើយ នឹងបាច់និយាយទៅថ្វី ក្នុងឋានមនុស្ស ។ បណ្តាបុគ្គលទាំងឡាយណា ជាមនុស្សល្ងង់ខ្លៅ ឥតប្រាជ្ញា មានគំនិតអាក្រក់ ដែលមោហៈបិទបាំងហើយ ពួកបុគ្គលប្រាកដដូច្នោះ រមែងត្រេកអរក្នុងអន្ទាក់ ដែលមារដាក់ឡើងហើយនោះ ។ រាគៈ ទោសៈ និងអវិជ្ជា ជនទាំងឡាយណា លះបង់បានហើយ ជនទាំងឡាយនោះឈ្មោះថាមានខ្សែនៃតណ្ហាកាត់ផ្តាច់ហើយ ឈ្មោះថាមិនមានចំណង រមែងមិនត្រេកអរ ក្នុងអន្ទាក់នៃមារនោះឡើយ ។

នន្ទកត្ថេរ ។

(១៩១) ខ្ញុំព្រះអង្គទ្រទ្រង់នូវធូលី បរិភោគភត្ត១ខែម្តង បានដកសក់នឹងពុកមាត់អស់ ៥៥ ឆ្នាំ ។ ខ្ញុំបានឈរដោយជើងតែម្ខាង វៀរការអង្គុយ ស៊ីលាមកក្រៀម មិនត្រេកអរនឹងការនិមន្តចំពោះ ។ ខ្ញុំបានធ្វើបាបកម្មដ៏ច្រើន ដែលជាអំពើនាំទៅកាន់ទុគ៌តិប្រាកដដូច្នេះ ក៏ត្រូវជំនន់ធំគឺទិដ្ឋិ បណ្តែតទៅហើយ បានដល់នូវព្រះពុទ្ធជាទីពឹង ។

សរណាគមនំ បស្ស បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

ជម្ពុកោ ថេរោ ។

(១៩៦) ស្វាគតំ វត មេ អាសិ គយាយំ គយផគ្គុយា
យំ អទ្ទសាសឹ សម្ពុទ្ធំ ទេសេន្តំ ធម្មមុត្តមំ
មហប្បភំ គណាចរិយំ អគ្គប្បត្តំ វិនាយកំ
សទេវកស្ស លោកស្ស ជិនំ អតុលទស្សនំ
មហានាគំ មហាវីរំ មហាជុតិមនាសវំ
សព្វាសវបរិក្ខីណំ សត្ថារមកុតោភយំ ។
ចិរសង្កិលិដ្ឋំ វត មំ ទិដ្ឋិសន្ទានសន្ទិតំ[១]
វិមោចយិ សោ ភគវា សព្វគន្ថេហិ សេនកន្តិ ។

សេនកោ ថេរោ ។

(១៩៧) យោ ទន្ធកាលេ តរតិ តរណីយេ ច ទន្ធយេ

១ ម. ទិដ្ឋិសន្ទានសន្ទិតំ ។ ឱ. ទិដ្ឋិសន្តានគន្ថិតំ ។



អ្នកចូរមើល នូវការដល់សរណៈ ចូរមើលភាពនៃធម៌ ជាធម៌ល្អ វិជ្ជា៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ជម្ពុកត្ថេរ ។

(១៩៦) ឱ ការដែលខ្ញុំមកល្អហើយ ដើម្បីនូវផគ្គុមហោស្រព[១] ជិតកំពង់ឈ្មោះគយា ការដែលខ្ញុំបានឃើញព្រះសម្ពុទ្ធ កំពុងតែសំដែងធម៌ដ៏ឧត្តម ព្រះអង្គមានពន្លឺច្រើន ជាគណាចារ្យ ដល់នូវឋានៈដ៏ប្រសើរ ដឹកនាំសត្វលោក ទ្រង់ឈ្នះមនុស្សលោកព្រមទាំងទេវលោក ទ្រង់មានការឃើញថ្លឹងមិនបាន ជាមហានាគ មានព្យាយាមធំ មានសេចក្តីរុងរឿងធំ មិនមានអាសវៈ មានអាសវៈទាំងពួង អស់រលីងហើយជាសាស្តាមិនមានភ័យអំពីណាឡើយ ។ ព្រះមានព្រះភាគអង្គនោះ បានញុំាងខ្ញុំឈ្មោះសេនកៈ អ្នកមានសេចក្តីសៅហ្មងអស់កាលយូរ ដែលចំណងគឺទិដ្ឋិចងទុកហើយ ឲ្យរួចស្រឡះចាកកិលេសគ្រឿងចាក់ស្រែះទាំងពួងបាន ។

សេនកត្ថេរ ។

(១៩៧) បុគ្គលណា ប្រញាប់ប្រញាល់ ក្នុងកាលដែលគួរសន្សឹម តែជាសន្សឹម ក្នុងកាលដែលគួរប្រញាប់ប្រញាល់

១ ជាឈ្មោះមហោស្រព១ ដែលលេងកាន់ក្នុងថ្ងៃផល្គុន នៅកំពង់នទីគយាគ្រប់ឆ្នាំ ។ អដ្ឋកថា ។

អយោនិសោ សំវិធានេន ពាលោ ទុក្ខំ និគច្ឆតិ ។
តស្សត្ថា បរិហាយន្តិ កាឡបក្ខេវ ចន្ទិមា
អាយសក្យញ្ច បប្បោតិ មិត្តេហិ ច វិរុជ្ឈតិ[១] ។
យោ ទន្ធកាលេ ទន្ធេតិ តរណីយេ ច តារយេ
យោនិសោ សំវិធានេន សុខំ បប្បោតិ បណ្ឌិតោ ។
តស្សត្ថា បរិបូរេន្តិ សុក្កបក្ខេវ ចន្ទិមា
យសោ កិត្តិញ្ច បប្បោតិ មិត្តេហិ ន វិរុជ្ឈតិ ។

សម្ភូតោ ថេរោ ។

(២៩៥) ឧភយេនេវ សម្បន្នោ រាហុលភទ្ទោតិ មំ វិទូ
យញ្ចម្ហិ បុត្តោ ពុទ្ធស្ស យញ្ច ធម្មេសុ ចក្ខុមា ។
យញ្ច មេ អាសវា ខីណា យញ្ច នត្ថិ បុនព្ភវោ
អរហា ទក្ខិណេយ្យោម្ហិ តេវិជ្ជោ អមតទ្ទសោ ។
កាមន្ធា ជាលសញ្ឆន្នា តណ្ហាឆទនឆាទិតា
បមត្តពន្ធុនា ពទ្ធា មច្ឆាវ កុមិនាមុខេ ។

១ ម. ន. វិរុជ្ជតិ ។



បុគ្គលនោះឈ្មោះថា ពាល រមែងបានទុក្ខ ព្រោះការចាត់ចែងមិនដែលដោយឧបាយនៃប្រាជ្ញា ។ ប្រយោជន៍ទាំងឡាយរបស់បុគ្គលនោះរមែងសាបសូន្យ ដូចព្រះចន្ទក្នុងកាឡបក្ខ បុគ្គលនោះរមែងដល់នូវភាពជាអ្នកមិនមានយសផង បែកពាក់ពួកមិត្រផង ។ បុគ្គលណាសន្សឹមក្នុងកាលដែលគួរសន្សឹម ប្រញាប់ប្រញាល់ក្នុងកាលដែលគួរប្រញាប់ប្រញាល់ បុគ្គលនោះ ឈ្មោះថាបណ្ឌិត រមែងបាននូវសេចក្ដីសុខ ព្រោះការចាត់ចែងដោយឧបាយនៃប្រាជ្ញា ។ ប្រយោជន៍របស់បុគ្គលនោះ រមែងពេញបរិបូណ៌ដូចជាព្រះចន្ទក្នុងសុក្កបក្ខ បុគ្គលនោះរមែងដល់នូវយសនិងកេរ្តិ៍ឈ្មោះផង មិនបែកពាក់ពួកមិត្រផង ។

សម្ភូតត្ថេរ ។

(២៩៥) សព្វព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថារាហុលដ៏ចំរើន ជាអ្នកប្រកបដោយគុណទាំងពីរយ៉ាងគឺ ជាតិ និងប្រតិបត្តិ ព្រោះអាត្មាអញជាកូននៃព្រះពុទ្ធផង ជាអ្នកមានចក្ខុ ក្នុងធម៌ទាំងឡាយផង អាសវៈរបស់អាត្មាអញអស់ហើយផង ភពថ្មីទៀតអាត្មាអញមិនមានផង អាត្មាអញជាព្រះអរហន្ត គួរដល់ទក្ខិណា មានវិជ្ជា ៣ ឃើញព្រះនិព្វានឈ្មោះអមតៈ ។ សត្វទាំងឡាយជាអ្នកងងឹតព្រោះកាម ត្រូវបណ្ដាញរួបរឹតហើយ ត្រូវដំបូលគឺតណ្ហាបិទបាំងហើយ ត្រូវមារចងហើយ ដូចត្រីជាប់នៅក្នុងមាត់លបដូច្នោះ ។

តំ កាមំ អហមុជ្ឈិត្វា ឆេត្វា មារស្ស ពន្ធនំ
សមូលំ តណ្ហំ អព្ពុយ្ហ សីតិភូតោស្មិ និព្វុតោតិ ។

រាហុលោ ថេរោ ។

(១៩៥) ជាតរូបេន សញ្ឆន្នា ទាសីគណបុរក្ខតា
អង្កេន បុត្តមាទាយ ភរិយា មំ ឧបាគមិ ។
តញ្ច ទិស្វាន អាយន្តិំ សកបុត្តស្ស មាតរំ
អលង្កតំ សុវសនំ មច្ចុបាសំវ ឱឌ្ឌិតំ ។
តតោ មេ មនសីការោ យោនិសោ ឧទបជ្ជថ
អាទីនវោ បាតុរហុ និព្វិទា សមតិដ្ឋថ ។
តតោ ចិត្តំ វិមុច្ចិ មេ បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

ចន្ទនោ ថេរោ ។

(១៩៦) ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតិំ គច្ឆតិ ធម្មចារី ។



អាត្មាអញលះបង់កាមនោះហើយ បានកាត់នូវចំណងនៃមារ ដកតណ្ហាព្រមទាំងឫសចេញហើយ ជាអ្នកមានសេចក្តីត្រជាក់ត្រជំហើយ មានទុក្ខរលត់ហើយ ។

រាហុលត្ថេរ ។

(១៩៥) ប្រពន្ធ (របស់ខ្ញុំ) ស្លៀកស្លាប់ដោយមាស មានពួកទាសីដើរហែតាមក្រោយ ពកូនដោយចង្កេះ ចូលមករកខ្ញុំ ។ លុះខ្ញុំឃើញមាតារបស់កូនខ្លួននោះ ប្រដាប់ដោយគ្រឿងអាភរណៈ មានការស្លៀកពាក់ល្អ ហើយដើរមក ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមារដាក់ឡើងហើយ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់ខ្ញុំ ទោសក៏កើតឡើងប្រាកដ សេចក្តីធុញទ្រាន់ណាស់ ក៏តាំងនៅមាំ ។ តពីនោះមក ចិត្តរបស់ខ្ញុំរួចស្រឡះ អ្នកចូរមើលនូវភាពនៃធម៌ជាធម៌ល្អ វិជ្ជាបី ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ចន្ទនត្ថេរ ។

(១៩៦) ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគ្គតឹ ។
តស្មា ហិ ធម្មេសុ ករេយ្យ ឆន្ទំ
ឥតិ មោទមានោ សុគតេន តាទិនា
ធម្មេ ឋិតា សុគតវរស្ស សាវកា
និយ្យន្តិ ធីរា សរណវរគ្គគាមិនោ ។
វិប្ផោដិតោ គណ្ឌមូលោ តណ្ហាជាលោ សមូហតោ ។
សោ ខីណសំសារោ ន ចត្ថិ កិញ្ចនំ
ចន្ទោ យថា ទោសិនាបុណ្ណមាសិយន្តិ ។

ធម្មិកោ ថេរោ ។

(១៩៧) យទា ពលាកា សុចិបណ្ឌរច្ឆទា
កាឡស្ស មេឃស្ស ភយេន តជ្ជិតា
បលេហិតិ អាលយមាលយេសិនី
តទា នទី អជករណី រមេតិ[១] មំ ។
យទា ពលាកា សុវិសុទ្ធបណ្ឌរា
កាឡស្ស មេឃស្ស ភយេន តជ្ជិតា
បរិយេសតិ លេណមលេណទស្សិនី
តទា នទី អជករណី រមេតិ[២] មំ ។

១.២ ម. យមេតិ ។



សភាវៈទាំងពីរគឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែនមានផលស្មើគ្នាទេ អកុសលធម៌ នាំសត្វទៅកាន់នរក កុសលធម៌ ញុំាងសត្វឲ្យដល់នូវសុគតិ ។
ព្រោះហេតុនោះ បុគ្គលកាលមានចិត្តរីករាយចំពោះព្រះសុគត ជាតាទិបុគ្គលយ៉ាងនេះ គប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងធម៌ទាំងឡាយ សាវ័កទាំងឡាយរបស់ព្រះសុគតដ៏ប្រសើរ ឋិតនៅក្នុងធម៌ ជាអ្នកប្រាជ្ញ បានដល់នូវទីពឹង ដ៏ប្រសើរលើស រមែងនាំខ្លួនចេញ (ចាកវដ្តទុក្ខបាន) ។
ឫសគល់នៃបូសគឺអវិជ្ជា ខ្ញុំព្រះអង្គបានគាស់បង់ហើយ បណ្ដាញគឺតណ្ហា ខ្ញុំព្រះអង្គបានដកចោលហើយ ។
ខ្ញុំព្រះអង្គនោះ មានសង្សារអស់ហើយ កិលេសជាគ្រឿងខ្វល់ មិនមានដល់ខ្ញុំព្រះអង្គឡើយ ដូចជាព្រះចន្ទ្រ ក្នុងថ្ងៃពេញបូណ៌មី ដែលប្រាសចាកទោស គឺពពកជាដើម ។

ធម្មិកត្ថេរ ។

(១៩៧) កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅគំរាមហើយ ក៏ស្វែងរកសំបុក ហើរទៅកាន់សំបុក ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជករណី ក៏ញុំាងអាត្មាអញឲ្យត្រេកអរ ។
កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅ គំរាមហើយ មិនឃើញទីពួន ក៏ស្វែងរកទីពួន ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជករណី ញុំាងអាត្មាអញឲ្យត្រេកអរ ។

កន្នុ តត្ថ ន រមេន្តិ ជម្ពុយោ ឧភតោ តហឹ
សោភេន្តិ អាបគាកូលំ មហាលេណស្ស បច្ឆតោ ។
តាមតមទសង្ឃសុប្បហីនា[1]
ភេកា មន្ទវតី បនាទយន្តិ ។
នាជ្ជ គិរិនទីហិ វិប្បវាសសមយោ
ខេមា អជករណី សិវា សុរម្មា ។

សព្វកោ ថេរោ ។

(១៩៨) បព្វជឹ ជីវិកត្ថោហំ លទ្ធាន ឧបសម្បទំ
តតោ សទ្ធំ បដិលភឹ ទឡ្ហវីរិយោ បរក្កមឹ ។
កាមំ ភិជ្ជតុយំ កាយោ មំសបេសី វិសីយរុំ[2]
ឧភោ ជណ្ណុកសន្ធីហិ ជង្ឃាយោ បបតន្តុ មេ ។
នាសិស្សំ ន បិវិស្សាមិ វិហារា ច ន និក្ខមេ[3]
ន បិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេ ។
តស្ស មេវំ វិហរតោ បស្ស វីរិយបរក្កមំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

មុទិតោ ថេរោ ។

១ ម. សុប្បហិតា ។ អដ្ឋកថាថេរគាថា: តាមតមទសង្ឃសុប្បហិតា ។ ២ ម. វិសិយន្តុ ។ ៣ ម. និក្ខមឹ ។



ដើមព្រីងទាំងឡាយ ញុំាងច្រាំងនៃស្ទឹងទាំងពីរ ក្នុងទីនោះ (ដែលបិតនៅ) ខាងក្រោយនៃគុហាធំល្អ មិនមែនញុំាងសត្វណាមួយ ក្នុងទីនោះឲ្យត្រេកអរបានទេ ។

កង្កែបទាំងឡាយ មានសំឡេងពីរោះ ប្រាសចាកពួកនៃពស់ រមែងយំកងរំពង ។ ថ្ងៃនេះ មិនមែនជាសម័យនៅប្រាសចាកភ្នំនឹងស្ទឹងទេ ព្រោះស្ទឹងអជករណី ជាទីក្សេមសប្បាយ រីករាយដោយប្រពៃ ។

សព្វកត្ថេរ ។

(១៩៨) ខ្ញុំត្រូវការចិញ្ចឹមជីវិត បព្វជ្ជាបានឧបសម្បទាហើយ តែតពីនោះមក ក៏ត្រឡប់បាននូវសទ្ធា មានព្យាយាមមាំប្រឹងប្រែងមាំ ។ កាយនេះចូរបែកធ្លាយចុះ ដុំនៃសាច់ទាំងឡាយ ចូរខ្ទាតខ្ចាយទៅចុះ សន្លាក់ទាំងឡាយរបស់ខ្ញុំ ចូរបែកធ្លាក់ចាកកំណាត់នៃជង្គង់ទាំងពីរចុះ ។ កាលបើសរគឺតណ្ហា មិនទាន់ខ្ញុំដកចេញទេ ខ្ញុំនឹងមិនស៊ី មិនផឹក នឹងមិនចេញអំពីកុដិ ទាំងមិនទម្រេត សូម្បីតែមួយចំហៀងឡើយ ។ អ្នកចូរមើលសេចក្ដីព្យាយាម ប្រឹងប្រែងដ៏មាំរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះ វិជ្ជា៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

មុទិតត្ថេរ ។

## ឧទ្ទានំ

នាគសមាលោ ភគុ ច សភិយោ នន្ទកោបិ ច
ជម្ពុកោ សេនកោ ថេរោ សម្ភូតោ រាហុលោបិ ច
ភវតិ ចន្ទនោ ថេរោ ទសេតេ ពុទ្ធសាវកា ។
ធម្មិកោ សប្បកោ ថេរោ មុទិតោ ចាបិ តេ តយោ
គាថាយោ ទ្វេ ច បញ្ញាស[1] ថេរា សព្វេបិ តេរសាតិ[2] ។

ចតុក្កនិបាតោ និដ្ឋិតោ ។

---

១-២ ឥទំ ឧភយំ វិរុទ្ធំ មញ្ញេ ។ ឥមស្មឹ ហិ ចតុក្កនិបាតេ ទ្វាទស ថេរា ហោន្តិ ន តេរស ថេរា ។ នវ ហិ ឯតេ ថេរា ទសេតិ មញ្ញេ ។



## ឧទ្ទាន

និយាយអំពីព្រះថេរៈទាំងឡាយ ជាសាវ័កនៃព្រះពុទ្ធ ១០[1] អង្គនេះ គឺនាគសមាលត្ថេរ១ ភគុត្ថេរ១ សភិយត្ថេរ១ នន្ទកត្ថេរ១ ជម្ពុកត្ថេរ១ សេនកត្ថេរ១ សម្ភូតត្ថេរ១ រាហុលត្ថេរ១ ចន្ទនត្ថេរ១ ។ ព្រះថេរៈ ៣ អង្គទៀត គឺ ធម្មិកត្ថេរ១ សប្បកត្ថេរ១ មុទិតត្ថេរ១ ឯគាថាមាន ៥២[2] ចំណែកខាងព្រះថេរៈទាំងអស់មាន ១៣[3] អង្គ ។

ចប់ ចតុក្កនិបាត ។

---

១ ចំនួនព្រះថេរៈក្នុងឧទ្ទាននេះថាជា ១០ អង្គនោះឃើញតែ ៩ ទេ ។ ២ ឃើញតែ ៥១ គាថាទេ ។ ៣ ថែវរួមជា១៣ អង្គនោះ ឃើញតែ ១២ អង្គទេ ។

## ថេរគាថាយ បញ្ចកនិបាតោ

(១៩៩) ភិក្ខុ សីវថិកំ គន្ត្វា អទ្ទស[១] ឥត្ថិមុជ្ឈិតំ
អបវិទ្ធំ សុសានស្មឹ ខជ្ជន្តឹ កិមិហី ផុដំ ។
យំ ហិ ឯកេ ជិគុច្ឆន្តិ មតំ ទិស្វាន បាបកំ
កាមរាគោ បាតុរហុ អន្ធោវ សវតី អហុ ។
ឱរំ ឱទនបាកម្ហា តម្ហា ឋានា អបក្កមឹ
សតិមា សម្បជានោហំ ឯកមន្តំ ឧបាវិសឹ ។
តតោ មេ មនសីការោ យោនិសោ ឧទបជ្ជថ
អាទីនវោ បាតុរហុ និព្វិទា សមតិដ្ឋថ ។
តតោ ចិត្តំ វិមុច្ចិ មេ បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

រាជទត្តោ ថេរោ ។

(២០០) អយោគេ យុញ្ជមត្តានំ បុរិសោ កិច្ចមិច្ឆកោ
ចរំ ចេ នាធិគច្ឆេយ្យ តំ មេ[២] ទុព្ភគលក្ខណំ ។

---

១ ម. ឱ. អទ្ទសំ ។ ២ ម. ឱ. ចេ ។



## ថេរគាថា បញ្ចកនិបាត

(១៩៩) ភិក្ខុទៅកាន់ទីស្មសាន បានឃើញសាកសពស្ត្រី ដែលគេលះបង់ចោលក្នុងព្រៃស្មសាន ត្រូវពួកដង្កូវកេតខ្ចៅស៊ីផុះផុយ ។ ពួកជនខ្លះដែលឃើញសាកសពស្លាប់ដ៏លាមក ក៏ខ្ពើមរអើម តែកាមរាគៈកើតឡើងប្រាកដ (ក្នុងសាកសពនោះ) ដូចជាបុគ្គលខ្វាក់ អសុចិ ហូរហៀរ (តាមទ្វារទាំង៩) ។ តែអាត្មាអញ ចៀសចេញអំពីទីនោះថយជាងមួយចំអិនបាយ ជាអ្នកមានស្មារតី ដឹងខ្លួន ចូលទៅកាន់ទីសមគួរ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតប្រាកដ (ដល់អាត្មាអញ) សេចក្តីនឿយណាយក៏តាំងនៅព្រម (ក្នុងហឫទ័យនៃអាត្មាអញ) លំដាប់នោះ ចិត្តរបស់អាត្មាអញ ក៏រួចស្រឡះ (ចាកកិលេស) អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជាទាំង ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ។

រាជទត្តត្ថេរ ។

(២០០) បុរសអ្នកប្រាថ្នានូវកិច្ច ប្រកបខ្លួន ក្នុងអំពើដែលមិនគួរប្រកប ប្រសិនបើត្រាច់ទៅ មិនគប្បីបាន(នូវប្រយោជន៍នោះទេ) នោះឯង ជាលក្ខណៈនៃចំណែកអាក្រក់ ។

អត្តត្ថំ អយតជីវិតំ
ឯកញ្ចេ និស្សជ្ជេយ្យ កលិំ សិយា
សព្វានិបិ ចេ និស្សជ្ជេយ្យ អន្ធោវ
សិយា សមវិសមស្ស អទស្សនតោ ។

យញ្ហិ កយិរា តញ្ហិ វទេ យំ ន កយិរា ន តំ វទេ
អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា ។
យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ
ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។
យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ
ឯវំ សុភាសិតា វាចា សផលា ហោតិ សកុព្វតោ ។

សុភូតោ ថេរោ ។

(៦០១) វស្សតិ ទេវោ យថា សុគីតំ

ឆន្នា មេ កុដិកា សុខា និវាតា
តស្សំ វិហរាមិ វូបសន្តោ
អថ ចេ បត្ថយសិ បវស្ស ទេវ ។





ការដែលរស់នៅដោយលំបាក គាត្មានអញបានដកចោល ហើយ បើបុគ្គលណា លះបង់ធម៌យ៉ាងឯកតិអប្បមាទ បុគ្គលនោះ ទុកដូចជាមនុស្សចង្រៃម្យ៉ាងទៀត បើបុគ្គលណា លះបង់នូវគ្រឿងទាំងអស់ (សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា) បុគ្គលនោះ ទុកដូចជាមនុស្សខ្វាក់ ព្រោះមិនឃើញនូវរបស់ដែលស្មើគ្នានឹងមិនស្មើគ្នា ។

ពិតណាស់ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើនោះ មិនធ្វើនូវអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងនូវបុគ្គលអ្នកមិនធ្វើបានតែនិយាយ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ តែមិនមានក្លិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងឥតផល ដល់បុគ្គលអ្នកមិនធ្វើតាម ក៏យ៉ាងនោះដែរ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ ប្រកបដោយក្លិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងមានផល ដល់បុគ្គលអ្នកធ្វើតាម ក៏យ៉ាងនោះដែរ ។

សុភូតត្ថេរ ។

(៦០១) ភ្លៀងបង្អុរចុះតាមសមគួរដល់កាលគ្រួហាក់ដូចជាតន្ត្រីពីរោះ កុដិរបស់អាត្មាប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ អាត្មាមានចិត្តស្ងប់រម្ងាប់ នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេចហ្ន៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។

វស្សតិ ទេវោ យថាសុគីតំ

ឆន្នា មេ កុដិកា សុខា និវាតា

តស្សំ វិហរាមិ សន្តចិត្តោ

អថ ចេ បត្ថយសិ បវស្ស ទេវ ។

។បេ។

តស្សំ វិហរាមិ វីតរាគោ

។បេ។

តស្សំ វិហរាមិ វីតទោសោ

។បេ។

តស្សំ វិហរាមិ វីតមោហោ

អថ ចេ បត្ថយសិ បវស្ស ទេវាតិ ។

គិរិមានន្ទោ ថេរោ ។

(៦០៦) យំ បត្ថយានោ[១] ធម្មេសុ ឧបជ្ឈាយោ អនុគ្គហិ

អមតំ អភិកង្ខន្តំ កតំ កត្តព្វកំ មយា ។

អនុប្បត្តោ សច្ឆិកតោ សយំ[២] ធម្មោ អនីតិហោ

វិសុទ្ធញាណោ និក្កង្ខោ ព្យាករោមិ តវន្តិកេ ។

---

១ ម. បត្ថយាតោ ។ ២ ម. សយំ ។



ភ្លៀងបង្អុរចុះ តាមសមគួរដល់ការស្រែកហៅនៃមេឃ ដ៏ពីរោះ

កុដិតូចរបស់ខ្ញុំប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ

ខ្ញុំ មានចិត្តស្ងប់រម្ងាប់ នៅក្នុងកុដិនោះ ម្នាលមេឃ

ម្តេចហ៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។បេ។

ខ្ញុំ ជាអ្នកប្រាសចាករាគៈ នៅក្នុងកុដិនោះ ។បេ។

ខ្ញុំ ជាអ្នកប្រាសចាកទោសៈ នៅក្នុងកុដិនោះ ។បេ។

ខ្ញុំ ជាអ្នកប្រាសចាកមោហៈ នៅក្នុងកុដិនោះ ម្នាលមេឃ

ម្តេចហ៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។

គិរិមានន្ទត្ថេរ ។

(៦០៦) បណ្តាធម៌ទាំងឡាយ ព្រះឧបជ្ឈាយ៍ប្រាថ្នាចំពោះធម៌ណា

អនុគ្រោះខ្ញុំ អ្នកប្រាថ្នាព្រះនិព្វានឈ្មោះអមតៈ សោឡសកិច្ច

ដែលគួរធ្វើ ខ្ញុំក៏បានធ្វើហើយ ។ ធម្មជាតជាធម៌មិនមាន

អន្តរាយ ខ្ញុំបានដល់ដោយលំដាប់ហើយ បានធ្វើឲ្យជាក់

ច្បាស់ហើយ ដោយខ្លួនឯង ខ្ញុំមានញាណដ៏បរិសុទ្ធ ឥត

សង្ស័យ បានធ្វើឲ្យជាក់ច្បាស់ក្នុងសំណាក់នៃលោក ។

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សទត្ថោ មេ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ ។
អប្បមត្តស្ស មេ សិក្ខា សុស្សុតា តវ សាសនេ
សព្វេ មេ អាសវា ខីណា នត្ថិ ទានិ បុនព្ភវោ ។
អនុសាសិ មំ អរិយវតា អនុកម្បិ អនុគ្គហិ
អមោឃោ តុម្ហមោវាទោ[១] អន្តេវាសិម្ហិ សិក្ខិតោតិ ។

សុនីតោ ថេរោ ។

(៦០៣) សាធុ ហិ កិរ មេ មាតា បតោទំ ឧបទំសយិ
យស្សាហំ វចនំ សុត្វា អនុសិដ្ឋោ ជនេត្តិយា
អារទ្ធវីរិយោ បហិតត្តោ បត្តោ សម្ពោធិមុត្តមំ ។
អរហា ទក្ខិណេយ្យោម្ហិ តេវិជ្ជោ អមតទ្ទសោ
ជេត្វា[២] នមុចិនោ សេនំ វិហរាមិ អនាសវោ ។
អជ្ឈត្តញ្ច ពហិទ្ធា ច យេ មេ វិជ្ជឹសុ អាសវា
សព្វេ អសេសា ឧច្ឆិន្នា ន ច ឧប្បជ្ជរេ បុន ។
វិសារទា ខោ ភគិនី ឯតមត្ថំ អភាសយិ

១ ឱ. តុម្ហមោវាទោ ។ ម. តុម្ហំ ឱវាទោ ។ ២ ឱ. ម. ជិត្វា ។



ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជំរះស្អាតហើយ ប្រយោជន៍របស់ខ្លួនគឺព្រះអរហត្ត ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានស្តាប់បានរៀនល្អនូវសិក្ខា ក្នុងពាក្យប្រៀនប្រដៅរបស់លោក អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ភពថ្មីមិនមានទេ ។ លោកប្រៀនប្រដៅខ្ញុំដោយតែដ៏ប្រសើរ ជាអ្នកអនុគ្រោះទំនុកបម្រុង (នូវខ្ញុំ) ឱវាទរបស់លោកមិនឥតអំពើឡើយ ខ្ញុំជាសិស្សបានរៀនសូត្រហើយ ។

សុនីតត្ថេរ ។

(៦០៣) មានសេចក្តីដំណាលថា ឱហ្ន៎ មាតាបានបង្ហាញនូវជន្លួញ (ទាំង) ដល់អាត្មាអញ អាត្មាអញដែលមាតាប្រៀនប្រដៅ បានស្តាប់ពាក្យរបស់លោកហើយ ជាអ្នកមានព្យាយាមប្រឹងប្រែងហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានដល់នូវសម្ពោធិដ៏ឧត្តម ។ អាត្មាអញជាអរហន្ត ទក្ខិណេយ្យបុគ្គល មានវិជ្ជា៣ ឃើញព្រះនិព្វានឈ្មោះអមតៈ អាត្មាអញឈ្នះសេនានៃមារ ជាអ្នកមិនមានអាសវៈ ។ អាសវៈទាំងឡាយណា របស់អាត្មាអញ ខាងក្នុងក្តី ខាងក្រៅក្តី អាសវៈទាំងអស់នោះ អាត្មាអញកាត់ផ្តាច់ហើយ ឥតមានសេសសល់ ទាំងមិនកើតទៀតទេ ។ បងស្រី មានសេចក្តីក្លៀវក្លា បាននិយាយនូវសេចក្តីនេះ

អបិហា នូន មយិបិ វនថោ តេ ន វិជ្ជតិ ។
បរិយន្តកតំ ទុក្ខំ អន្តិមោយំ សមុស្សយោ
ជាតិមរណសំសារោ នត្ថិ ទានិ បុនព្ភវោ ។

វឌ្ឍោ ថេរោ ។

(៦០៦) អត្ថាយ វត មេ ពុទ្ធោ នទឹ នេរញ្ជរំ អគា
យស្សាហំ ធម្មំ សុត្វាន មិច្ឆាទិដ្ឋឹ វិវជ្ជយឹ ។
យជឹ ឧច្ចាវចេ យញ្ញេ អគ្គិហុត្តំ ជុហឹ អហំ
ឯសា សុទ្ធីតិ មញ្ញន្តោ អន្ធភូតោ បុថុជ្ជនោ ។
ទិដ្ឋិគហណបក្ខន្ទោ បរាមាសេន មោហិតោ
អសុទ្ធឹ មញ្ញិសំ សុទ្ធឹ អន្ធភូតោ អវិទ្ទសុ ។
មិច្ឆាទិដ្ឋិ បហីនា មេ ភវា សព្វេ បទាលិតា[1]
ជុហាមិ ទក្ខិណេយ្យគ្គឹ នមស្សាមិ តថាគតំ ។
មោហា សព្វេ បហីនា មេ ភវតណ្ហា បទាលិតា
វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោ ។

នទីកស្សបោ ថេរោ ។

[1] ម. ឱ. វិទាលិតា ។



នាងទំនងពិតមិនមានសេចក្តីស្រឡាញ់ចំពោះអាត្មាជាប្រាកដ ព្រៃ (មាន តណ្ហាជាដើម) មិនមាន (ក្នុងសន្តានរបស់នាង) ទេ ។ សេចក្តីទុក្ខមាន ទីបំផុតដូច្នេះ អាត្មាបានធ្វើហើយ រាងកាយនេះជាទីបំផុត (របស់អាត្មា) សង្សារគឺជាតិនិងមរណៈមិនមាន ឥឡូវនេះភពថ្មីមិនមានទេ ។

វឌ្ឍត្ថេរ ។

(៦០៦) អាត្មាអញបានស្តាប់ធម៌ របស់ព្រះពុទ្ធណា ហើយវៀរចាកមិច្ឆាទិដ្ឋិ ព្រះពុទ្ធនោះ យាងមកហើយកាន់ស្ទឹងនេរញ្ជរា ដើម្បីប្រយោជន៍ដល់អាត្មាអញពិត ។ អាត្មាអញបានបូជាយញ្ញទាំងឡាយខ្ពស់ទាប បានបូជាភ្លើង កាលនៅជាបុថុជ្ជន ងងឹតងងល់ សំគាល់ថា ការបូជានេះឯង ជាសេចក្តីបរិសុទ្ធិ ។ អាត្មាអញស្ទុះទៅកាន់ព្រៃស្បាតគឺទិដ្ឋិ ត្រូវសេចក្តីស្ទាបអង្អែល (ខុស) ឲ្យដល់នូវសេចក្តីវង្វេង ងងឹតមិនដឹង សំគាល់នូវមិនបរិសុទ្ធថាជានូវបរិសុទ្ធ ។ មិច្ឆាទិដ្ឋិ អាត្មាអញបានលះបង់ហើយ ភពទាំងពួង អាត្មាអញបានទំលុះទំលាយហើយ អាត្មាអញបូជាភ្លើង គឺព្រះសម្មាសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ថ្វាយបង្គំនូវព្រះតថាគត ។ មោហៈទាំងពួង អាត្មាអញបានលះបង់ហើយ ភវតណ្ហា អាត្មាអញបានទំលុះទំលាយចេញហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះភពថ្មីទៀត នៃអាត្មាអញ មិនមានទេ ។

នទីកស្សបត្ថេរ ។

(៦០៥) បាតោ មជ្ឈន្តិកំ សាយំ តិក្ខត្តុំ ទិវសស្សហំ
ឱតរឹ ឧទកំ សោហំ(១) គយាយ គយផគ្គុយា
យំ មយា បកតំ បាបំ បុព្វេ អញ្ញាសុ ជាតិសុ
តន្ទានិ បវាហេមិ ឯវំទិដ្ឋិ បុរេ អហុ(២) ។
សុត្វា សុភាសិតំ វាចំ ធម្មត្ថសហិតំ បទំ
តថំ យាថាវតំ(៣) អត្ថំ យោនិសោ បច្ចវេក្ខិសំ ។
និន្ហាតសព្វបាបោម្ហិ និម្មលោ បយតោ(៤) សុចិ
សុទ្ធោ សុទ្ធស្ស(៥) ទាយាទោ បុត្តោ ពុទ្ធស្ស ឱរសោ ។
ឱគយ្ហដ្ឋង្គិកំ សោតំ សព្វំ បាបំ បវាហយឹ
តិស្សោ វិជ្ជា អជ្ឈគមឹ កតំ ពុទ្ធស្ស សាសនន្តិ ។

គយាកស្សបោ ថេរោ ។

(៦០៦) វាតរោគាភិនីតោ ត្វំ វិហរំ កាននេ វនេ
បវិទ្ធគោចរេ(៦) លូខេ កថំ ភិក្ខុ ករិស្សសិ ។

១ ឱ. សោធំ ។ ២ ឱ. ម. អហុំ ។ ៣ ឱ. យថាវកំ ។ ម. យាថាវកំ ។
៤ ម. សស្សតោ ។ ៥ ឱ. សុទ្ធស្ស ។ ៦ ឱ. បវិទ្ធគោចរេ ។



(៦០៥) កាលខ្ញុំចុះទឹកក្នុងកំពង់ឈ្មោះគយា ក្នុងមួយថ្ងៃៗបីដង គឺពេលព្រឹក ថ្ងៃត្រង់ ល្ងាច ក្នុងកាលមហាស្រុកឈ្មោះគយផគ្គុ បាបណាដែលខ្ញុំធ្វើហើយ ក្នុងជាតិទាំងឡាយដទៃ អំពីកាលមុន ឥឡូវនេះ ខ្ញុំបណ្តែតចោលនូវបាបនោះ ក្នុងកំពង់ឈ្មោះគយានេះ ទិដ្ឋិយ៉ាងនេះ មានហើយក្នុងកាលមុន ។ ខ្ញុំស្តាប់វាចាជាសុភាសិត ជាបទប្រកបដោយធម៌និងអត្ថ ហើយពិចារណានូវសេចក្តីតាមនូវផលការពិត ដោយឧបាយនៃប្រាជ្ញា ។ ខ្ញុំ មានបាបទាំងពួងលាងចេញហើយ មិនមានមន្ទិល មានកិលេសលាងចេញហើយ ជាអ្នកស្អាតបរិសុទ្ធ ជាពុទ្ធទាយាទ (អ្នកគួរទទួលនូវមត៌កនៃព្រះពុទ្ធ) ជាកូនកើតអំពីព្រះឱរសនៃព្រះពុទ្ធ ។ ខ្ញុំ ចុះកាន់ខ្សែនៃមគ្គប្រកបដោយអង្គ ៨ ហើយ បណ្តែតចោលនូវបាបទាំងពួង ដល់នូវវិជ្ជា ៣ ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

គយាកស្សបត្ថេរ ។

(៦០៦) (ព្រះមានព្រះភាគត្រាស់សួរថា) ម្នាលភិក្ខុ អ្នកត្រូវរោគដែលកើតអំពីខ្យល់គ្របសង្កត់ហើយ នៅក្នុងព្រៃ មានគោចរលះបង់ហើយ (ក្រចតុប្បច្ច័យ) ជាទីសៅហ្មង តើនឹងធ្វើដូចម្តេច ។

បីតិសុខេន វិបុលេន ផរមានោ សមុស្សយំ
លូខម្បិ អភិសម្ភោន្តោ(១) វិហរិស្សាមិ កាននេ ។
ភាវេន្តោ សតិបដ្ឋានេ ឥន្ទ្រិយានិ ពលានិ ច
ពោជ្ឈង្គានិ ច ភាវេន្តោ វិហរិស្សាមិ កាននេ ។
អារទ្ធវីរិយេ បហិតត្តេ និច្ចំ ទឡ្ហបរក្កមេ
សមគ្គេ សហិតេ ទិស្វា វិហរិស្សាមិ កាននេ ។
អនុស្សរន្តោ សម្ពុទ្ធំ អគ្គំ ទន្តំ(២) សមាហិតំ
អតន្ទិតោ រត្តិន្ទិវំ វិហរិស្សាមិ កាននេតិ ។

វក្កលិ ថេរោ ។

(២០៧) ឱលគ្គេស្សាមិ តេ ចិត្ត អាណិទ្វារេវ ហត្ថិនំ
ន តំ បាបេ និយោជេស្សំ កាមជាលំ សរីរជំ(៣) ។
ត្វំ ឱលគ្គោ ន គច្ឆសិ(៤)
ទ្វារវិវរំ គជោវ អលភន្តោ
ន ច ចិត្តកលិ បុនប្បុនំ
បសហំ(៥) បាបរតោ ចរិស្សសិ ។

---

១ ម. អភិសម្ភោន្តោ ។ ២ ឱ. ម. អន្តទន្តំ ។ ៣ ឱ. កាមជាល សរីរជ ។ ម. កាមជាលសរីរជ ។ ៤ ឱ. គច្ឆិសិ ។ ៥ ឱ. បសក្ក ។



(ព្រះវក្កលិត្ថេរក្រាបបង្គំទូលថា) ខ្ញុំព្រះអង្គផ្សាយចិត្តទៅកាន់កាយភាពទាំងមូល ដោយសុខៈដែលកើតអំពីបីតិដ៏លើសលុប អត់ទ្រាំនូវបច្ច័យដ៏សៅហ្មង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គចំរើនសតិប្បដ្ឋានទាំងឡាយផង សម្មប្បធានផង ឥទ្ធិបាទផង ឥន្ទ្រិយផង ពលៈផង ចំរើនពោជ្ឈង្គផង អដ្ឋង្គិកមគ្គផង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គឃើញ (នូវសព្រហ្មចារីបុគ្គលទាំងឡាយ) អ្នកមានព្យាយាមតឹងតែងហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានព្យាយាមប្រឹងប្រែង ដ៏មាំអស់កាលជានិច្ច មានសេចក្តីព្រមព្រៀងគ្នា ប្រកបដោយភាពជាសមណៈនៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គនឹករឿយៗ នូវព្រះសម្ពុទ្ធ ព្រះអង្គមានខ្លួនទូន្មានបានហើយ មានព្រះទ័យតាំងមាំហើយ មិនខ្ជិលច្រអូស អស់យប់ទាំងថ្ងៃ នៅក្នុងព្រៃធំ ។

វក្កលិត្ថេរ ។

(៦០៧) ម្នាលចិត្ត អញនឹងហាមឃាត់ឯង ដូចជាគេបិទដំរីទុកក្នុងក្រោលមានទ្វារប្រកបដោយខ្នុក អញមិនបណ្តោយឯង ដែលជាបណ្តាញនៃកាម ដែលកើតអំពីសរីរៈ ឲ្យទៅក្នុងបាបធម៌ទេ ។ ឯងអញហាមឃាត់ហើយ នឹងទៅណាមិនបានទេ ដូចជាដំរីដែលមិនបាននូវចន្លោះទ្វារ (ដើម្បីចេញ) ម្នាលចិត្តទាលខូច ឯងនឹងប្រព្រឹត្តល្មោភកាម ត្រេកអរក្នុងបាបធម៌រឿយៗទៀតមិនបានទេ ។

យថា កុញ្ជរំ អទន្តំ
នវគ្គហំ អង្កុសគ្គហោ
ពលវា អាវត្តេតិ អកាមំ
ឯវំ អាវត្តយិស្សន្តិ ។
យថា វរហយទមកុសលោ
សារថិ បវរោ ទមេតិ អាជញ្ញំ
ឯវំ ទមយិស្សន្តិ
បតិដ្ឋិតោ បញ្ចសុ ពលេសុ ។
សតិយា តំ និពន្ធិស្សំ
បយតត្តោ[1] តេ ទមិស្សាមិ
វិរិយធុរនិគ្គហិតោ ន យិតោ
ទូរំ គមិស្សសេ ចិត្តាតិ ។

តាលបុដោ ថេរោ ។

(២០៨) ឧបារម្ភចិត្តោ ទុម្មេធោ សុណាតិ ជិនសាសនំ
អារកា ហោតិ សទ្ធម្មា នភសោ បថវី យថា ។
ឧបារម្ភចិត្តោ ទុម្មេធោ សុណាតិ ជិនសាសនំ

១ ម. បយុត្តោ ។



ហ្មដំរីអ្នកមានកំឡាំង ធ្វើដំរីដែលមិនទាន់ពង្រាប ទើបចាប់បានថ្មី ជាសត្វមិនប្រាថ្នាឲ្យត្រឡប់វិលបានយ៉ាងណា អញនឹងឲ្យឯងវិលត្រឡប់យ៉ាងនោះដែរ ។ នាយសារថីដ៏ប្រសើរ ជាអ្នកឈ្លាសក្នុងការបង្ហាត់សេះដ៏ប្រសើរ បង្ហាត់សេះអាជានេយ្យយ៉ាងណា អញនឹងតាំងនៅក្នុងពលធម៌ ៥ ហើយទូន្មានឯងយ៉ាងនោះដែរ ។ អញនឹងចងឯងដោយសតិ អញមានខ្លួនប្រុងប្រយ័ត្នហើយ នឹងទូន្មានឯង ម្នាលចិត្ត ឯងអញសង្កត់សង្កិនក្នុងធុរៈ គឺព្យាយាម កុំទៅឆ្ងាយអំពីទីនេះឡើយ ។

ចប់តាលបុដត្ថេរ ។

(២០៨) បុគ្គលអប្បឥតប្រាជ្ញ មានចិត្តប្រកួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គង់ជាអ្នកឆ្ងាយអំពីព្រះសទ្ធម្ម ដូចផែនដីឆ្ងាយអំពីមេឃ ។ បុគ្គលអប្បឥតប្រាជ្ញ មានចិត្តប្រកួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅ របស់ព្រះជិនស្រី

បរិហាយតិ សទ្ធម្មា កាឡបក្ខេវ ចន្ទិមា ។
ឧបារម្ភចិត្តោ ទុម្មេធោ សុណាតិ ជិនសាសនំ
បរិសុស្សតិ សទ្ធម្មេ មច្ឆោ អប្បោទកេ យថា ។
ឧបារម្ភចិត្តោ ទុម្មេធោ សុណាតិ ជិនសាសនំ
ន វិរូហតិ សទ្ធម្មេ ខេត្តេ ពីជំវ បូតិកំ[1] ។
យោ ច តុដ្ឋេន[2] ចិត្តេន សុណាតិ ជិនសាសនំ
ខេបេត្វា អាសវេ សព្វេ សច្ឆិកត្វា អកុប្បតំ
បប្បុយ្យ បរមំ សន្តឹ បរិនិព្វាតិ អនាសវោតិ ។

យសទត្តោ ថេរោ ។

(៦០៩) ឧបសម្បទា ច មេ លទ្ធា វិមុត្តោ ចម្ហិ អនាសវោ
សោ ច មេ ភគវា ទិដ្ឋោ វិហារេ ច សហាវសឹ ។
ពហុទេវ រត្តឹ ភគវា អព្ភោកាសេតិនាមយិ
វិហារកុសលោ សត្ថា វិហារំ បាវិសី តទា ។
សន្ថរិត្វាន សង្ឃាដឹ សេយ្យំ កប្បេសិ គោតមោ
សីហោ សេលគុហាយំវ បហីនភយភេរវោ ។

---

១ ឧ. បូតិកា ។ ២ ម. ឱ. តុដ្ឋេន ។



ក៏តង់សាបសូន្យចាកព្រះសទ្ធម្ម ដូចព្រះចន្ទក្នុងកាឡបក្ខ (រនោច) ។ បុគ្គលអ័ប្បឥតប្រាជ្ញ មានចិត្តប្រទូស្តប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ក៏តង់រីងស្ងួតក្នុងព្រះសទ្ធម្ម ដូចជាត្រីរីងស្ងួតក្នុងទឹកតិច ។ បុគ្គលអ័ប្បឥតប្រាជ្ញ មានចិត្តប្រទូស្តប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គង់មិនលូតលាស់ក្នុងព្រះសទ្ធម្ម ដូចជាពូជស្អុយមិនដុះក្នុងស្រែ ។ លុះតែបុគ្គលណា មានចិត្តត្រេកត្រអាលហើយ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី បុគ្គលនោះទើបញ៉ាំងអាសវៈទាំងពួងឲ្យអស់ទៅ ធ្វើឲ្យជាក់ច្បាស់នូវធម៌មិនកំរើក (អរហត្តផល) ដល់នូវសេចក្តីស្ងប់ដ៏ឧត្តម គឺអនុបាទិសេសនិព្វាន ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

យសទត្តត្ថេរ ។

(៦០៩) ខ្ញុំបានឧបសម្បទាផង បានផុតស្រឡះ ជាអ្នកមិនមានអាសវៈផង ខ្ញុំបានឃើញព្រះមានព្រះភាគអង្គនោះផង ទាំងបាននៅជាមួយក្នុងកុដិផង ។ ព្រះមានព្រះភាគទ្រង់ធ្វើរាត្រីជាច្រើន (យប់ជ្រៅ) ឲ្យកន្លងទៅ ក្នុងទីវាល ព្រះសាស្តាឈ្លាសក្នុងការនៅ បានស្តេចចូលទៅកាន់កុដិក្នុងពេលនោះ ។ ព្រះគោតមទ្រង់ក្រាលសង្ឃាដិ ហើយសម្រេចសីហសេយ្យា ដូចជាសត្វសីហៈ ដែលលះបង់សេចក្តីភ័យស្ញប់ស្ញែង នៅក្នុងគុហាថ្ម ។

ឥតោ កល្យាណវាក្ករណោ សម្មាសម្ពុទ្ធសាវកោ
សោណោ អភាសិ សទ្ធម្មំ ពុទ្ធសេដ្ឋស្ស សម្មុខា ។
បញ្ចក្ខន្ធេ បរិញ្ញាយ ភាវយិត្វាន អញ្ជសំ
បប្បុយ្យ បរមំ សន្តិំ បរិនិព្វាយិស្សត្យនាសវោតិ[1] ។

សោណោ កុដិកណ្ណោ ថេរោ ។

(២១០) យោ វេ គរូនំ វចនញ្ញូ ធីរោ
វសេ ច តម្ហិ ជនយេថ បេមំ
សោ ភត្តិមា នាម ច ហោតិ បណ្ឌិតោ
ញត្វា ច ធម្មេសុ វិសេសិ អស្ស ។
យំ អាបទា ឧប្បតិតា ឧឡារា
នក្ខម្ភយន្តេ បដិសង្ខយន្តំ
សោ ថាមវា នាម ច ហោតិ បណ្ឌិតោ
ញត្វា ច ធម្មេសុ វិសេសិ អស្ស ។
យោ វេ សមុទ្ទោវ ឋិតោ អនេជោ
គម្ភីរបញ្ញោ និបុណត្ថទស្សី
អសំហារិកោ[2] នាម ច ហោតិ បណ្ឌិតោ
ញត្វា ច ធម្មេសុ វិសេសិ អស្ស ។

១ ឱ. ម បរិនិព្វិស្សត្យនាសវោតិ ។ ម. បរិនិព្វិស្សត្យនាសវោ ។ ២ ឱ. ម. អសំហារិយោ ។



លំដាប់នោះ ព្រះសោណៈ ជាសាវ័កនៃព្រះសម្មាសម្ពុទ្ធ អ្នកពោលពាក្យពីរោះ បានពោលនូវព្រះសទ្ធម្ម ចំពោះព្រះភក្ត្រព្រះពុទ្ធដ៏ប្រសើរ ។ បានកំណត់ដឹងនូវបញ្ចក្ខន្ធ បានចំរើននូវមគ្គដ៏ប្រសើរ ហើយដល់នូវស្ងប់ដ៏ឧត្តម ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វានទៅ

សោណកុដិកណ្ណត្ថេរ ។

(២១០) បុគ្គលណាជាអ្នកប្រាជ្ញ អ្នកដឹងនូវពាក្យ របស់គ្រូទាំងឡាយ គប្បីនៅក្នុងពាក្យរបស់គ្រូនោះផង គប្បីញ៉ាំងសេចក្ដីស្រឡាញ់ឲ្យកើតផង បុគ្គលនោះឈ្មោះថាជាអ្នកមានភក្ដីផង ឈ្មោះថាជាអ្នកប្រាជ្ញផង តាំងពីបុគ្គលនោះ មុខជានឹងមានសេចក្ដីវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង (នូវសច្ចធម៌) ។ អន្តរាយទាំងឡាយ ដ៏ខ្លាំងក្លាកើតឡើងហើយ តែមិនបានគ្រប់សង្កត់នូវបុគ្គលណា ជាអ្នកពិចារណា បុគ្គលនោះ ឈ្មោះថាជាអ្នកមានកំឡាំងផង ឈ្មោះថាជាអ្នកប្រាជ្ញផង តាំងពីជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង (នូវសច្ចធម៌) ។ បុគ្គលណា នឹងដឹងមិនញាប់ញ័រ ជាអ្នកមានប្រាជ្ញាជ្រៅ ដូចសមុទ្រ ឃើញនូវសេចក្ដីល្អិត បុគ្គលនោះ ឈ្មោះថាជាអ្នកដែលកិលេសដឹកនាំមិនបានផង ជាអ្នកប្រាជ្ញផង តាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង (នូវសច្ចធម៌) ។

ពហុស្សុតោ ធម្មធរោ ច ហោតិ
ធម្មស្ស ហោតិ អនុធម្មចារី
សោ តាទិសោ នាម ច ហោតិ បណ្ឌិតោ
ញត្វា ច ធម្មេសុ វិសេសិ អស្ស ។
អត្ថញ្ច យោ ជានាតិ ភាសិតស្ស
អត្ថញ្ច ញត្វាន តថា ករោតិ
អត្ថន្តរោ[១] នាម ស ហោតិ បណ្ឌិតោ
ញត្វា ច ធម្មេសុ វិសេសិ អស្សាតិ ។

កោសិយោ ថេរោ ។

## ឧទ្ទានំ

រាជទត្តោ សុភូតោ ច គិរិមានន្ទសុមនោ
វឌ្ឍោ ច កស្សបោ ថេរោ គយាកស្សបវក្កលិ
វិជិតោ យសទត្តោ ច សោណោ កោសិយសវ្ហយោ
សដ្ឋី ច បញ្ចគាថាយោ ថេរា ច ឯត្ថ ទ្វាទសាតិ ។

បញ្ចកនិបាតោ និដ្ឋិតោ ។

១ អត្ថត្ថកោ ។



បុគ្គលណា ជាអ្នកចេះដឹងច្រើន ជាអ្នកចាំទុកនូវធម៌ ទាំងជាអ្នកប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះ ឈ្មោះថាជាអ្នកប្រាកដស្មើដោយគ្រានោះផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង (នូវសច្ចធម៌) ។

បុគ្គលណា ដឹងនូវសេចក្ដីនៃភាសិតផង លុះដឹងនូវសេចក្ដីនៃភាសិត ហើយធ្វើតាមផង បុគ្គលនោះ ឈ្មោះថាជាអ្នកកន្លងផុតនូវសេចក្ដីសង្ស័យផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង (នូវសច្ចធម៌) ។

កោសិយត្ថេរ ។

## ឧទ្ទាន

គាថា ៦០ ក្នុងគាថាទាំងនោះ ព្រះថេរៈ ១២ អង្គសំដែងគឺ រាជ-ទត្តត្ថេរ ១ សុភូតត្ថេរ ១ គិរិមានន្ទត្ថេរ ១ សុមនត្ថេរ ១ វឌ្ឍត្ថេរ ១ នទីកស្សបត្ថេរ ១ គយាកស្សបត្ថេរ ១ វក្កលិត្ថេរ ១ វិជិតសេនត្ថេរ ១ យសទត្តត្ថេរ ១ សោណកុដិកណ្ណត្ថេរ ១ កោសិយត្ថេរ ១ ។

ចប់ បញ្ចកនិបាត ។

## ថេរគាថាយ ឆក្កនិបាតោ

(៦១១) ទិស្វាន បាដិហីរានិ គោតមស្ស យសស្សិនោ
ន តាវាហំ បណិបតឹ ឥស្សាមានេន វញ្ចិតោ ។
មម សង្កប្បមញ្ញាយ ចោទេសិ នរសារថិ
តតោ មេ អាសិ សំវេគោ អព្ភុតោ លោមហំសនោ ។
បុព្វេ ជដិលភូតស្ស យា មេ សិទ្ធិ បរិត្តិកា
តាហំ តទា និរាកត្វា បព្វជឹ ជិនសាសនេ ។
បុព្វេ យញ្ញេន សន្តុដ្ឋោ កាមធាតុ បុរក្ខតោ
បច្ឆា រាគញ្ច ទោសញ្ច មោហញ្ចាបិ សមូហនឹ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
ឥទ្ធិមា បរចិត្តញ្ញូ ទិព្វសោតញ្ច បាបុណឹ ។
យស្ស ចត្ថាយ បព្វជិតោ អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។

ឧរុវេលកស្សបោ ថេរោ ។

(៦១២) អតិហិតា វីហិ ខលគតា សាលិ
ន ច លភេ បិណ្ឌំ កថមហំ កស្សំ ។



## ថេរគាថា ឆក្កនិបាត

(៦១១) ខ្ញុំឃើញបាដិហារ្យរបស់ព្រះគោតម ព្រះអង្គមានយសដ៏រុងរឿង ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្តីច្រណែន និងសេចក្តីប្រកាន់ខ្លួនបញ្ឆោត ។ ព្រះសាស្តាជាសារថីរបស់ជន ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ បានដាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគនិងសេចក្តីព្រឺរោម ដែលមិនធ្លាប់កើតហើយ ។ កាលខ្ញុំនៅជាជដិលក្នុងកាលមុន ការសម្រេចលាភសក្ការៈណាតិចតួច គ្រានោះ ខ្ញុំលះបង់នូវការសំរេចលាភសក្ការៈនោះហើយ មកបួសក្នុងសាសនាព្រះជិនស្រី ។ កាលពីដើម ខ្ញុំជាអ្នកត្រេកអរ ដោយការបូជាធ្វើកាមធាតុជាប្រធាន កាលខាងក្រោយមក ខ្ញុំបានដកគាស់រាគៈ ទោសៈ និងមោហៈចោលហើយ ។ ខ្ញុំដឹងនូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលពីដើម បានជម្រះទិព្វចក្ខុឲ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។ មួយទៀត កុលបុត្រចេញចាកផ្ទះមកបួសក្នុងផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយតាមលំដាប់ គឺការក្ស័យអស់សំយោជនធម៌ទាំងពួង ។

ឧរុវេលកស្សបត្ថេរ ។

(៦១២) (មារនិយាយថា) ស្រូវគេនាំទៅទុកដាក់ហើយ ស្រូវគេគរទុកក្នុងលានហើយ ខ្ញុំនៅតែមិនបានដុំបាយ តើខ្ញុំនឹងធ្វើដូចម្តេច ។

ពុទ្ធមប្បមេយ្យំ អនុស្សរ បសន្នោ
បីតិយា ផុដ្ឋសរីរោ ហោហិសិ សតតមុទគ្គោ ។
ធម្មមប្បមេយ្យំ ។ បេ ។
សង្ឃមប្បមេយ្យំ ។ បេ ។
អព្ភោកាសេ ច វិហរសិ
សីតា ហេមន្តិកា ឥមា រត្តិយោ ។
មា សីតេន បរេតោ វិហញ្ញិត្ថោ
បវិស[1] ត្វំ វិហារំ ផុសិតគ្គឡំ ។
ផុសិស្សំ ចតស្សោ អប្បមញ្ញាយោ
តាហិ ច សុខិតោ វិហរិស្សំ
នាហំ សីតេន វិហញ្ញិស្សំ
អនិញ្ជិតោ វិហរន្តោ ។

សេរិព្ហកានិ ថេរោ ។

(២១៣)យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
បរិហាយតិ សទ្ធម្មា មច្ឆោ អប្បោទកេ យថា ។
យស្ស សព្រហ្មចារីសុ គារវោ ឧបលព្ភតិ
ស វិរូហតិ សទ្ធម្មេ ខេត្តេ ពីជំវ វុត្តំ ។

[1] ម. បវិសន្តិ ។



(ព្រះថេរៈនិយាយថា) អ្នកចូរជ្រះថ្លារឭកចំពោះព្រះពុទ្ធមានគុណមិនមានប្រមាណ អ្នកនឹងជាបុគ្គលមានសរីរៈដែលបីតិពាល់ត្រូវ មានចិត្តរីករាយរឿយៗ មិនខាន ។ ចំពោះធម៌មានគុណមិនមានប្រមាណ ។ បេ ។ ចំពោះសង្ឃមានគុណមិនមានប្រមាណ ។ បេ ។

(មារនិយាយថា) លោកនៅក្នុងទីវាលល្ហល្ហេវផង រាត្រីនេះត្រជាក់ មានសន្សើមធ្លាក់ចុះផង ។ លោកកុំបណ្តោយឲ្យត្រជាក់គ្របសង្កត់ឲ្យលំបាកឡើយ ចូរលោកចូលទៅក្នុងកុដិដែលមានទ្វារខ្ទាស់គន្លឹះជាប់មាំ ។

(ព្រះថេរៈតបថា) អាត្មាពាល់ត្រូវអប្បមញ្ញាទាំង៤ ដល់នូវសេចក្តីសុខដោយសារអប្បមញ្ញាទាំងនោះ មិនញាប់ញ័រ មិនលំបាក ដោយត្រជាក់ទេ ។

សេរិព្ហកានិត្ថេរ ។

(២១៣) បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីក្នុងទីមានទឹកតិច ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងលូតលាស់ក្នុងព្រះសទ្ធម្ម ដូចពូជល្អ (ដែលលូតលាស់) ក្នុងស្រែ ។

យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
អារកា ហោតិ និព្វានា ធម្មរាជស្ស សាសនេ ។
យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
បរិហាយតិ សទ្ធម្មា មច្ឆោ អប្បោទកេ យថា ។
យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
សោ វិរូហតិ សទ្ធម្មេ ខេត្តេ ពីជំវ ភទ្ទកំ ។
យស្ស សព្រហ្មចារីសុ គារវោ ឧបលព្ភតិ
សន្តិកេ ហោតិ និព្វានំ ធម្មរាជស្ស សាសនេតិ ។

មហានាគោ ថេរោ ។

(២០៤) កុល្លោ សិវថិកំ គន្ត្វា អទ្ទសំ ឥត្ថិមុជ្ឈិតំ
អបវិទ្ធំ សុសានស្មឹ ខជ្ជន្តឹ កិមិហី ផុដំ ។
អាតុរំ អសុចឹ បូតឹ បស្ស កុល្ល សមុស្សយំ
ឧគ្ឃរន្តំ បគ្ឃរន្តំ ពាលានំ អភិនន្ទិតំ ។
ធម្មាទាសំ គហេត្វាន ញាណទស្សនបត្តិយា
បច្ចវេក្ខឹ ឥមំ កាយំ តុច្ឆំ សន្តរពាហិរំ ។
យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ



បុគ្គលដែលមិនមានសេចក្ដីគោរព ក្នុងពួកសព្រហ្មចារី រមែងឆ្ងាយអំពីព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធជាស្ដេចនៃធម៌ ។ បុគ្គលដែលគានសេចក្ដីគោរព ក្នុងពួកសព្រហ្មចារី រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីនៅក្នុងទីមានទឹកច្រើន ។ បុគ្គលដែលមានសេចក្ដីគោរព ក្នុងពួកសព្រហ្មចារី ទើបដុះដាល ក្នុងព្រះសទ្ធម្ម ដូចពូជដ៏ល្អ (លូតលាស់) ក្នុងស្រែ ។ បុគ្គលដែលមានសេចក្ដីគោរព ក្នុងពួកសព្រហ្មចារី រមែងឋិតនៅក្នុងទីជិតព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធជាស្ដេចនៃធម៌ ។

មហានាគត្ថេរ ។

(៦៩៤) កុល្លភិក្ខុ ទៅកាន់ព្រៃខ្មោច បានឃើញរាងស្រីដែលគេបោះបង់ក្នុងព្រៃស្មសាន មានដង្កូវកកុញដែលប្រជែងគ្នាស៊ីផេរផាស ។ (ព្រះសាស្ដាត្រាស់ថា) ម្នាលកុល្លៈ អ្នកចូរមើលសរីរៈដែលក្ដៅក្រហាយមិនស្អាត មានក្លិនស្អុយ មានកេរ្តិ៍មិនស្អាត ដែលហូរចេញ ហូរចុះ ជាសរីរៈដែលពួកមនុស្សពាល តែងត្រេកអរក្រៃពេក ។ (ព្រះកុល្លត្ថេរពោលថា) ខ្ញុំកាន់កញ្ចក់គឺធម៌ ដើម្បីមើលកាយនេះជារបស់ទទេ ទាំងខាងក្នុងខាងក្រៅ ព្រោះបានសម្រេចនូវញាណទស្សនៈ ។ សរីរៈនៃខ្ញុំនេះយ៉ាងណា សរីរៈនៃស្រីនុះយ៉ាងនោះដែរ សរីរៈស្រីនុះយ៉ាងណា សរីរៈនៃខ្ញុំនេះ ក៏យ៉ាងនោះដែរ

យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ ។
យថា ទិវា តថា រត្តិំ យថា រត្តិំ[1] តថា ទិវា
យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ ។
បញ្ចង្គិកេន តុរិយេន ន រតិ ហោតិ តាទិសី
យថា ឯកគ្គចិត្តស្ស សម្មា ធម្មំ វិបស្សតោ តិ ។

កុល្លោ ថេរោ ។

[៦១៨] មនុជស្ស បមត្តចារិនោ តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បវតិ ហុរាហុរំ ផលមិច្ឆំវ វនស្មិ វានរោ ។
យំ ឯសា សហតេ ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវុឌ្ឋំវ ពីរណំ ។
យោ ចេតំ សហតេ ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។

---
១ ម. តថា រត្តិំ យថា រត្តិំ ។



សភាវៈខាងក្រោមយ៉ាងណា សភាវៈខាងលើយ៉ាងនោះ សភាវៈខាងលើយ៉ាងណា សភាវៈខាងក្រោមយ៉ាងនោះដែរ ។ វេលាថ្ងៃយ៉ាងណា វេលាយប់យ៉ាងនោះដែរ វេលាយប់យ៉ាងណា វេលាថ្ងៃយ៉ាងនោះដែរ ខាងមុខយ៉ាងណា ខាងក្រោយយ៉ាងនោះដែរ ខាងក្រោយយ៉ាងណា ខាងមុខយ៉ាងនោះដែរ ។ សេចក្តីត្រេកអរដោយតូរ្យតន្ត្រីប្រកបដោយអង្គ៥ប្រាកដដូច្នោះ ក៏មិនដូចសេចក្តីត្រេកអរ របស់អ្នកមានចិត្តមូលតែមួយ ឃើញច្បាស់នូវធម៌ដោយប្រពៃទេ ។

កុល្លត្ថេរ ។

(៦១៨) តណ្ហាតែងចំរើនដល់មនុស្ស អ្នកប្រព្រឹត្តប្រមាទជាប្រក្រតី ដូចវល្លិព្រៃ បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វាកាលប្រាថ្នាផ្លែឈើ ស្ទុះទៅក្នុងព្រៃដូច្នោះ ។ តណ្ហានុ៎ះ ជាធម្មជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកតែងចំរើន ដល់បុគ្គលនោះ ដូចស្បូវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជ្រោកហើយ តែងចំរើនឡើងដូច្នោះ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលឆ្លងដោយកម្រនុ៎ះបាន សេចក្តីសោក តែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹក ធ្លាក់ចុះចាកស្លឹកឈូក ។

តំ វោ វទាមិ ភទ្ទំ វោ   យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ   ឧសីរត្ថោវ វីរណំ
មា វោ នឡំវ សោតោវ   មារោ ភញ្ជិ បុនប្បុនំ ។
ករោថ ពុទ្ធវចនំ   ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ   និរយម្ហិ សមប្បិតា ។
បមាទោ រជោ[១]   បមាទានុបតិតោ រជោ
អប្បមាទេន វិជ្ជាយ   អព្ពហេ សល្លមត្តនោតិ ។

មាលុង្ក្យបុត្តត្ថេរោ ។

(២១៦) បណ្ណវីសតិវស្សានិ   យតោ បព្វជិតោ អហំ
អច្ឆរាសង្ឃាតមត្តម្បិ   ចេតោសន្តិមនជ្ឈគំ ។
អលទ្ធា ចិត្តស្សេកគ្គំ   កាមរាគេន អដ្ដិតោ
ពាហា បគ្គយ្ហ កន្ទន្តោ   វិហារា ឧបនិក្ខមឹ ។
សត្ថំ វា អាហរិស្សាមិ   កោ អត្ថោ ជីវិតេន មេ
កថំ ហិ សិក្ខំ បច្ចក្ខំ   កាលំ កុព្វេថ មាទិសោ ។

---

១ ម. បមាទោ រជោ សព្វទា ។



ហេតុនោះបានជា តថាគតប្រាប់ដល់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មាននាក់ ដែលមកប្រជុំក្នុងទីនេះ សេចក្ដីចំរើន ចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះរូបចុះ អ្នកទាំងឡាយ ចូររំលើងឫសនៃតណ្ហាចោលចេញ ដូចបុគ្គលដែលត្រូវការដោយស្បូវភ្លាំង ជីកស្បូវឈ្នួសចោលចេញ មារកុំកេងកេនអ្នកទាំងឡាយឡើយ ។ ដូចខ្សែទឹកកាច់បំបាក់ ដើមបបុសដូច្នោះឡើយ ។ អ្នកទាំងឡាយ ចូរធ្វើតាមពុទ្ធវចនៈ កុំឲ្យខណៈ កន្លងនូវអ្នកទាំងឡាយបាន ព្រោះថាបុគ្គលទាំងឡាយ ដែលខណៈកន្លងហើយ តែងសោកសៅពេញបន្ទុកក្នុងនរក ។ សេចក្ដីប្រមាទទុកជាធូលី ធូលីកើតឡើងព្រោះសេចក្ដីប្រមាទ (ព្រោះហេតុនោះ) បុគ្គលគួរតែដកនូវសរ គឺសេចក្ដីប្រមាទរបស់ខ្លួនចេញ ដោយសេចក្ដីមិនប្រមាទដោយវិជ្ជា ។

មាលុង្ក្យបុត្តត្ថេរ ។

(២១៦) ចាប់ដើមតាំងពីខ្ញុំបួសមក ២៥ ឆ្នាំ មិនដែលបានសេចក្ដីស្ងប់ចិត្តអស់កាលសូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃសោះ ។ ខ្ញុំត្រូវកាមរាគគ្របសង្កត់ មិនបាននូវឯកគ្គតាចិត្ត ផ្គងដៃកន្ទក់កន្ទេញ ហើយចេញពីលំនៅទៅ ។ តត្ថាអញ (នឹងទម្លាក់ខ្លួនអំពីដើមឈើ) ឬនឹងយកកាំបិតមក (ចាក់សម្លាប់) ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ មនុស្សប្រហែលយ៉ាងអញ មិនសមបើធ្វើមរណកាលដោយការលាសិក្ខាទេ ។

តទាហំ ខុរមាទាយ មញ្ចកម្ហិ ឧបាវិសឹ
បរិនីតោ ខុរោ អាសិ ធមនឹ ឆេត្តុមត្តនោ ។
តតោ មេ មនសីការោ យោនិសោ ឧទបជ្ជថ
អាទីនវោ បាតុរហុ និព្វិទា សមតិដ្ឋថ ។
តតោ ចិត្តំ វិមុច្ចិ មេ បស្ស ធម្មសុធម្មតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

(១)
សប្បទាសោ ថេរោ ។

(២១៧) ឧដ្ឋាហិ និសីទ កាតិយាន
មា និទ្ទាពហុលោ[២] អហុ ជាគរស្សុ
មា តំ អលសំ បមត្តពន្ធុ
កូដេនេវ ជិនាតុ មច្ចុរាជា ។
សេយ្យថាបិ មហាសមុទ្ទវេគោ
ឯវំ ជាតិជរាតិវត្តតេ តំ
សោ ករោហិ សុទីបមត្តនោ[៣] ត្វំ
ន ហិ តាណំ តវ វិជ្ជតេវ អញ្ញំ ។
សត្ថា ហិ វិជេសិ មគ្គមេតំ
សង្គា ជាតិជរាភយា អតីតំ

១ ឱ. សព្វទាសត្ថេរោ ។ ២ មា និទ្ទាពហុលោតិ អន្តរបាឋោ ។ ៣ ម. បុរិសមត្តនោ ។



គ្រានោះ ខ្ញុំយកកាំបិតកោរ ចូលទៅអង្គុយលើគ្រែតូចដាក់កាំបិតកោរ (ត្រង់បំពង់ក) ដើម្បីកាត់សរសៃបំពង់ករបស់ខ្លួន ។ លំដាប់នោះ ខ្ញុំមានការធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ទោសកើតឡើងប្រាកដ សេចក្តីនឿយណាយ ក៏តាំងឡើងព្រម ។ តពីនោះមក ចិត្តខ្ញុំក៏ផុតស្រឡះ អ្នកចូរឃើញធម៌ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើស្រេចហើយ ។

សប្បទាសត្ថេរ ។

(២១៧)(ព្រះសាស្តាត្រាស់ថា) ម្នាលកាតិយានៈ ចូរអ្នកក្រោកអង្គុយឡើង កុំដេកច្រើនពេក ចូរភ្ញាក់រលឹកឡើង មច្ចុរាជមារ ចូរកុំឈ្នះអ្នកជាបុគ្គលខ្ជិលច្រអូស ដូចជានាយនេសាទ ប្រហារសត្វដោយញញួរ ។ ជាតិនិងជរា តែងប្រព្រឹត្តកន្លងអ្នក ដូចជារលកនៃមហាសមុទ្រ អ្នកនោះ ចូរធ្វើនូវទីពឹង ដ៏ល្អដល់ខ្លួន ព្រោះថា គ្រឿងការពារដទៃរបស់អ្នកក្នុងលោកនេះ មិនមានទេ ។ ត្បិតព្រះសាស្តាទ្រង់ឈ្នះផ្លូវច្បាប់អរិយមគ្គនុ៎ះ ជាផ្លូវកន្លងនូវគ្រឿងជាប់ ជាភ័យគឺជាតិនិងជរា

បុញ្ញាបវត្តមប្បមត្តោ
អនុយុញ្ជស្សុ ជគ្ឃិ កាមេហិ យោគំ ។
បុរិមានិ បមុញ្ច ពន្ធនានិ
សព្ពានិ ទុរមុណ្ឌិកច្ចកោជី
មា ទិត្តកេតិញ្ច មា និទ្ទិ
អនុយុញ្ជិត្ត ឈាយាយ កាតិយានេ ។
ឈាយាហិ និឆាហិ កាតិយានេ
យោគក្ខេមបថេ សុកោវិទាសិ
លប្ធុយ្យ អនុត្តរំ វិសុទ្ធិំ
បរិនិព្វាហិសិ វារិនាវ ជោតិ ។
បជ្ជោតកោ បរិត្តរំសោ
ភវេន វិនមេយ្យេ[១] លតាវ
ឯវម្បិ តុវំ អនាទិយមានោ
មារំ ឥន្ទសគោត្ត និទ្ធុនាហិ ។
សោ វេទយិតាសុ វីតរាគោ
កាលំ កង្ខ ឥធេវ សីតិភូតោ ។

កាតិយានោ ថេរោ ។

១ ម. វិនមេយ្យ ។



ចូរអ្នកកុំប្រមាទអស់ក្រើនថ្ងៃនិងយប់ ចូរប្រឹងធ្វើព្យាយាមឲ្យមាំមួន ។ ខ្លួនអ្នកជាអ្នកប្រព្រឹត្តសមាធិ កោរសក់ដោយកាំបិតកោរទាំងបរិភោគភិក្ខាហារ ចូរលះបង់កាមគុណ ដែលជាចំណង់ក្នុងកាលមុនចេញ ម្នាលកាតិយាន អ្នកកុំប្រកបការត្រេកអរក្នុងល្បែងផង កុំប្រកបការលក់ផង ចូរចំរើនឈាន ។ ម្នាលកាតិយាន អ្នកចូរដុត ចូរឈ្នះ (នូវកិលេស) អ្នកជាមនុស្សឈ្លាសវៃ ក្នុងផ្លូវជាទីក្សេមចាកយោគៈ នឹងដល់នូវព្រះនិព្វានដ៏បរិសុទ្ធដ៏ប្រសើរ ហើយរលត់ ដូចជាគំនរភ្លើង ដែលរលត់ដោយទឹក ។ ម្នាលឥន្ទសគោត្រ កាលបើអ្នកមិនប្រកាន់យកភពនេះ ចូរកំចាត់បង់មារឲ្យអស់ចេញ ដូចប្រទីបដែលមានពន្លឺតិច ឬដូចវល្លិតូច ដែលខ្យល់កំចាត់បង់បានដូច្នោះ ។ អ្នកនោះប្រាសចាកតម្រេកក្នុងវេទនាទាំងឡាយ ដែលខ្លួនទទួលហើយ មានសេចក្ដីត្រជាក់ ចូររង់ចាំនិព្វានកាល ក្នុងទីនេះចុះ ។

កាតិយានត្ថេរ ។

(៤១៨)សុទេសិតោ ចក្ខុមតា   ពុទ្ធេនាទិច្ចពន្ធុនា
សព្វសំយោជនាតីតោ   សព្វវដ្ដវិនាសនោ
និយ្យានិកោ ឧត្តរណោ   តណ្ហាមូលវិសោសនោ
វិសមូលំ អាឃាតនំ   ឆេត្វា បាបេតិ និព្វុតឹ
អញ្ញាណមូលភេទាយ   កម្មយន្តវិឃាដនោ
វិញ្ញាណានំ បរិគ្គហេ   ញាណវជិរនិបាតនោ
វេទនានំ វិញ្ញាបនោ   ឧបាទានប្បមោចនោ
ភវំ អង្គារកាសុំវ   ញាណេន អនុបស្សនោ(១)
មហារសោ សុគម្ភីរោ   ជរាមច្ចុនិវារណោ
អរិយោ អដ្ឋង្គិកោ មគ្គោ   ទុក្ខូបសមនោ សិវោ
កម្មំ កម្មន្តិ ញត្វាន   វិបាកញ្ច វិបាកតោ
បដិច្ចុប្បន្នធម្មានំ   យថាវាលោកទស្សនោ
មហាខេមង្គមោ សន្តោ   បរិយោសានភទ្ទកោតិ ។

មិគជាលោ ថេរោ ។

១ ម. អនុបស្សកោ ។



(៤១៨) មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ មានចក្ខុ ទ្រង់សំដែងហើយដោយប្រពៃ ជាធម៌កន្លងចាកសំយោជនៈទាំងអស់ ញុំាងវដ្តៈទាំងអស់ឲ្យវិនាស នាំសត្វចេញចាកវដ្តៈ ញុំាងសត្វឲ្យឆ្លងចាកឱឃៈ ញុំាងឫសគល់នៃទុក្ខគឺតណ្ហាឲ្យរីងស្ងួត ទំលាយនូវតណ្ហា មានឫសជាពិស ជាគ្រឿងបៀតបៀន ញុំាងសត្វឲ្យដល់នូវទីរលត់ទុក្ខ ជាគ្រឿងកំចាត់បង់នូវយន្តគឺអត្តភាព ដែលកើតអំពីកម្ម ព្រោះទំលាយនូវឫសគល់នៃអវិជ្ជាបាន ជាទីធ្លាក់ចុះនៃញាណដ៏មុតដូចកែវវជិរ គឺកិរិយាកំណត់នូវវិញ្ញាណ ញុំាងសត្វឲ្យដឹងនូវវេទនាទាំងឡាយ ដោះសត្វឲ្យរួចចេញចាកឧបាទាន ជាគ្រឿងឃើញភពដូចជារណ្តៅរងើកភ្លើង ដោយបញ្ញាញាណ ជាធម៌មានរសដ៏ប្រសើរ ជាធម៌ជ្រៅ ជាធម៌ហាមឃាត់នូវជរានិងមច្ចុ ជាធម៌រម្ងាប់បង់នូវទុក្ខ ជាធម៌ដ៏ក្សេម ជាទីឃើញនូវពន្លឺតាមពិត ព្រោះដឹងនូវកម្ម ថាជាកម្ម នូវផលថាជាផល នៃធម៌ទាំងឡាយ អាស្រ័យបច្ច័យកើតត ៗ គ្នា រមែងជាធម៌ដល់នូវទីដ៏ក្សេមប្រសើរ ជាធម៌ស្ងប់ចាកកិលេស ជាធម៌ចំរើនក្នុងទីបំផុត ។

មិគជាលត្ថេរ ។

(៦១៤) ជាតិមទេន មត្តោហំ   ភោគឥស្សរិយេន ច
សណ្ឋានវណ្ណរូបេន   មទមត្តោ អចារិហំ[១] ។
នាត្តនោ សមកំ កញ្ចិ   អតិរេកញ្ច មញ្ញិសំ
អតិមានហតោ ពាលោ   បត្ថទ្ធោ ឧស្សិតទ្ធជោ ។
មាតរំ បិតរំ ចាបិ   អញ្ញេបិ គរុសម្មតេ
ន កញ្ចិ អភិវាទេសិំ   មានត្ថទ្ធោ អនាទរោ ។
ទិស្វា វិនាយកំ អគ្គំ   សារថីនំ វរុត្តមំ
តបន្តមិវ អាទិច្ចំ   ភិក្ខុសង្ឃបុរក្ខតំ
មានំ មទញ្ច ឆឌ្ឌេត្វា   វិប្បសន្នេន ចេតសា
សិរសា អភិវាទេសិំ   សព្វសត្តានមុត្តមំ ។
អតិមានោ ច ឱមានោ   បហីនា សុសមូហតា
អស្មិមានោ សមុច្ឆិន្នោ   សព្វេ មានវិធា ហតា ។

ជេន្តោ បុរោហិតបុត្តោ ថេរោ ។

១ ម. ចរិហំ ។



(៦១៤) ខ្ញុំស្រវឹងដោយសេចក្តីស្រវឹង ព្រោះជាតិផង ដោយភោគៈនិងឥស្សរិយយសផង ដោយសណ្ឋានវណ្ណៈនិងរូប (ល្អ)ផង ខ្ញុំជាបុគ្គលប្រព្រឹត្តស្រវឹងជ្រប់ហើយ ។ ខ្ញុំត្រូវអតិមានះកំចាត់បង់ហើយ ជាមនុស្សពាល ជាអ្នករឹងរូស មានមានះដូចជាទង់ជ័យ ដែលគេលើកឡើងហើយ មិនបានសំគាល់អ្នកណាមួយ ថាជាបុគ្គលស្មើនឹងខ្លួនផង ថាជាបុគ្គលក្រៃលែងជាងខ្លួនផង ។ ខ្ញុំជាអ្នកមានមានះរឹងរូស មិនអើពើ មិនក្រាបសំពះអ្នកណាមួយ ទោះជាមាតាក្តី បិតាក្តី ឬអ្នកដទៃដែលសន្មតថាគួរគោរព ។ ខ្ញុំបានឃើញព្រះសាស្តាជាអ្នកទូន្មានសត្វ ប្រសើរខ្ពង់ខ្ពស់ជាងនាយសារថីទាំងឡាយ ព្រះអង្គរុងរឿងដូចព្រះអាទិត្យ មានភិក្ខុសង្ឃហែហម ក៏មានចិត្តជ្រះថ្លា បានលះមានះនិងសេចក្តីស្រវឹងចេញអស់ហើយ ទើបថ្វាយបង្គំព្រះសាស្តា ព្រះអង្គខ្ពង់ខ្ពស់ជាងសព្វសត្វដោយត្បូង ។ ខ្ញុំបានលះបង់គាស់រំលើងនូវសេចក្តីប្រកាន់ថា វិសេសជាងគេផង នូវសេចក្តីប្រកាន់ថាថោកទាបជាងគេផង បានផ្តាច់ផ្តិលអស្មិមានះ ចោលអស់ហើយ ទាំងមានះផ្សេងៗទាំងអស់ ខ្ញុំក៏បានកំចាត់បង់ស្រឡះហើយ ។

ជេន្តបុរោហិតបុត្តត្ថេរ ។

(៦៦០) យទា នវោ បព្វជិតោ ជាតិយា សត្តវស្សិកោ
ឥទ្ធិយា អភិភោត្វាន បន្នគិន្ទំ[១] មហិទ្ធិកំ
ឧបជ្ឈាយស្ស ឧទកំ អនោតត្តា មហាសរា
អាហរាមិ តតោ ទិស្វា មំ សត្ថា ឯតទព្រវិ
សារីបុត្ត ឥមំ បស្ស អាគច្ឆន្តំ កុមារកំ
ឧទកកុម្ភមាទាយ អជ្ឈត្តំ សុសមាហិតំ ។
បាសាទិកេន វត្តេន កល្យាណឥរិយាបថោ
សាមណេរោនុរុទ្ធស្ស ឥទ្ធិយា ច វិសារទោ
អាជានីយេន អាជញ្ញោ សាធុនា សាធុការិតោ
វិនីតោ អនុរុទ្ធេន កតកិច្ចេន សិក្ខិតោ
សោ បត្វា បរមំ សន្តឹ សច្ឆិកត្វា អកុប្បតំ
សាមណេរោ ស សុមនោ មា មំ ជញ្ញាតិ ឥច្ឆតិ ។

សុមនោ ថេរោ ។

(៦៦១) វាតរោគាភិនីតោ ត្វំ វិហរំ កាននេ វនេ
បវិទ្ធគោចរេ លូខេ កថំ ភិក្ខុ ករិស្សសិ ។

---
១ ម. សិន្ទុកិន្ទំ ។



(៦៦០) ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ទើបនឹងបួសថ្មីៗ បានសង្កត់សង្កិន នាគរាជមានឫទ្ធិច្រើន ដោយឫទ្ធិ ហើយដងយកទឹកពីស្រះធំឈ្មោះ អនោតត្ត មកប្រគេនព្រះឧបជ្ឈាយ៍ក្នុងគ្រាណា គ្រានោះព្រះសាស្តា ទ្រង់ទតឃើញខ្ញុំហើយ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលសារីបុត្ត អ្នកចូរមើលកុមារតូចនេះ កំពុងនាំយកក្អមទឹកមក មានចិត្តតាំងខ្ជាប់ខ្ជួនខាងក្នុង ។ សាមណេររបស់ព្រះអនុរុទ្ធ មានវត្តគួរជ្រះថ្លា មានឥរិយាបថបរិបូណ៌ ទាំងជាអ្នកក្លៀវក្លាដោយឫទ្ធិ ជាបុរសអាជានេយ្យ ដែលព្រះអនុរុទ្ធ ជាបុរសអាជានេយ្យ ជាសប្បុរស ឲ្យធ្វើនូវអំពើល្អ ណែនាំតែខាងផ្លូវល្អ មានកិច្ចធ្វើរួចហើយ មានសិក្ខាឲ្យសិក្សាហើយ សុមនសាមណេរនោះ បានដល់នូវព្រះនិព្វាន ជាទីស្ងប់ម្ងាប់ក្រៃលែង បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ជាធម៌មិនកម្រើក ប្រាថ្នាថា សូមកុំឲ្យជនណាមួយ ស្គាល់អញឡើយ ។

សុមនត្ថេរ ។

(៦៦១) (ព្រះសាស្តាត្រាស់សួរថា) ម្នាលភិក្ខុ អ្នកត្រូវរោគខ្យល់គ្របសង្កត់ហើយ កាលនៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ជាព្រៃសៅហ្មង នឹងធ្វើដូចម្តេចកើត ។

បីតិសុខេន វិបុលេន ផរិត្វាន សមុស្សយំ
លូខេបិ អភិសម្ភោន្តោ វិហរិស្សាមិ កាននេ ៕
ភាវេន្តោ សត្ត ពោជ្ឈង្គេ ឥន្ទ្រិយានិ ពលានិ ច
ឈានសុខុមសម្បន្នោ វិហរិស្សំ អនាសវោ ៕
វិប្បមុត្តំ កិលេសេហិ សុទ្ធចិត្តំ អនាវិលំ
អភិណ្ហំ បច្ចវេក្ខន្តោ វិហរិស្សំ អនាសវោ ៕
អជ្ឈត្តញ្ច ពហិទ្ធា ច យេ មេ វិជ្ជិំសុ អាសវា
សព្វេ អសេសា ឧច្ឆិន្នា ន ច ឧប្បជ្ជរេ បុន ៕
បញ្ចក្ខន្ធា បរិញ្ញាតា តិដ្ឋន្តិ ឆិន្នមូលកា
ទុក្ខក្ខយោ អនុប្បត្តោ នត្ថិ ទានិ បុនព្ភវោតិ ៕

ន្ហាតកមុនិ ថេរោ ៕

(៦៦៦) អក្កោធស្ស កុតោ កោធោ ទន្តស្ស សមជីវិនោ
សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ៕
តស្សេវ តេន បាបិយោ យោ កុទ្ធំ បដិកុជ្ឈតិ
កុទ្ធំ អប្បដិកុជ្ឈន្តោ សង្គាមំ ជេតិ ទុជ្ជយំ ៕



(ព្រះន្ហាតកមុនិត្ថេរទូលថា) ខ្ញុំព្រះអង្គមានបីតិនិងសុខៈបរិបូណ៌ ផ្សាយទៅកាន់រាងកាយ ហើយអត់សង្កត់នូវអារម្មណ៍ ដ៏សៅហ្មង ចាំនឹងនៅក្នុងព្រៃ ៗ ខ្ញុំព្រះអង្គចំរើននូវពោជ្ឈង្គ ៧ ផង ឥន្ទ្រិយផង ពលៈផង បរិបូណ៌ដោយឈានដ៏សុខុម ជាអ្នកមិនមានអាសវៈ ៗ ខ្ញុំព្រះអង្គបានពិចារណាឃើញចិត្តដ៏ស្អាត ផុតស្រឡះចាកកិលេស ជាចិត្តមិនល្អក់រឿយៗ ជាអ្នកមិនមានអាសវៈ ៗ អាសវៈទាំងឡាយណា ខាងក្នុងក្ដី ខាងក្រៅក្ដី ចាក់ដោតហើយដល់ខ្ញុំព្រះអង្គ អាសវៈទាំងអស់នោះ ខ្ញុំព្រះអង្គបានផ្ដាច់ផ្ដិលមិនឲ្យសេសសល់ មិនកើតទៅទៀតបានទេ ៗ បញ្ចក្ខន្ធ ខ្ញុំព្រះអង្គកំណត់ដឹងហើយ ខ្ញុំព្រះអង្គកាត់ឫសគល់ដាច់ហើយ ខ្ញុំព្រះអង្គបានដល់នូវការអស់ទុក្ខហើយ ឥឡូវនេះភពថ្មី មិនមានទៀតទេ ៗ

ន្ហាតកមុនិត្ថេរ ៕

(៦៦៦) បុគ្គលមិនមានសេចក្ដីក្រោធ បានទូន្មានចិត្ត ចិញ្ចឹមជីវិតស្មើ (ត្រូវ) មានចិត្តរួចចាកអាសវៈ ព្រោះដឹងដោយប្រពៃ មានចិត្តស្ងប់ចាកកិលេស មិនញាប់ញ័រដោយលោកធម៌ នឹងមានសេចក្ដីក្រោធពីណា ៗ បុគ្គលណាខឹងតបចំពោះបុគ្គលដែលខឹង បុគ្គលនោះនឹងមានសេចក្ដីអាក្រក់ ព្រោះតែការខឹងតបនោះ បុគ្គលមិនខឹងតបនឹងបុគ្គលដែលខឹង ឈ្មោះថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រ ៗ

ឧភិន្នមត្ថំ ចរតិ អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា យោ សតោ ឧបសម្មតិ។
ឧភិន្នំ តិកិច្ឆន្តានំ[1] អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ យេ ធម្មស្ស អកោវិទា។
ឧប្បជ្ជតេ សចេ កោធោ អាវជ្ជ កកចូបមំ
ឧប្បជ្ជេ ចេ រសេ តណ្ហា បុត្តមំសូបមំ សរ ។
សចេ ធាវតិ តេ ចិត្តំ កាមេសុ ច ភវេសុ ច
ខិប្បំ និគ្គណ្ហ សតិយា កិដ្ឋាទំ វិយ ទុប្បសុំ។

ព្រហ្មទត្តោ ថេរោ ។

(៤៤៧) ឆន្នមតិវស្សតិ វិវដំ នាតិវស្សតិ
តស្មា ឆន្នំ វិវរេថ ឯវន្តំ នាតិវស្សតិ ។
មច្ចុនាព្ភហតោ លោកោ ជរាយ បរិវារិតោ
តណ្ហាសល្លេន ឱតិណ្ណោ ឥច្ឆាធូបាយិតោ សទា។
មច្ចុនាព្ភហតោ លោកោ បរិក្ខិត្តោ ជរាយ ច

[1] ម. តិកិច្ឆន្តំ ។



បុគ្គលណា ដឹងថា បុគ្គលដទៃខឹងហើយ មានស្មារតីអត់សង្កត់ បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ ដើម្បីជនទាំងពីរ គឺ ដើម្បីខ្លួន ១ ដើម្បីអ្នកដទៃ ១ ។ ពួកជនមិនឈ្លាសក្នុងធម៌ រមែងសំគាល់ជនទាំងពីរ គឺខ្លួន ១ អ្នកដទៃ ១ ដែលជាអ្នកព្យាបាលព្យាធិគឺក្រោធបាន ថាជាមនុស្សពាល ។ បើសេចក្តីក្រោធកើតឡើងដល់អ្នក ចូរអ្នកពិចារណានូវទំនង ដែលឧបមាដោយរណារ បើចំណង់ក្នុងរសកើតឡើងដល់អ្នក ចូរអ្នករលឹកនូវទំនងដែលឧបមាដោយសាច់កូន ។ បើចិត្តរបស់អ្នកស្ទុះទៅក្នុងកាមទាំងឡាយក្តី ក្នុងភពទាំងឡាយក្តី ចូរអ្នកប្រញាប់សង្កត់សង្កិនចិត្តនោះដោយសតិ ដូចជាបុរសសង្កត់សង្កិនគោកាចដែលស៊ីសំណាប ។

ព្រហ្មទត្តត្ថេរ ។

(៤៤៧) ភ្លៀងគឺអាបត្តិ តែងធ្លាក់ស្រោចនូវបុគ្គល អ្នកបិទបាំងអាបត្តិទុក មិនធ្លាក់ស្រោចនូវបុគ្គល អ្នកបើកអាបត្តិ ព្រោះហេតុនោះ បុគ្គលត្រូវបើកអាបត្តិ ដែលខ្លួនបិទបាំងហើយ កាលបើធ្វើយ៉ាងនេះ ទើបភ្លៀងគឺអាបត្តិ មិនធ្លាក់ស្រោចនូវបុគ្គលនោះ ។ សត្វលោកត្រូវមច្ចុ កំចាត់បង់ហើយ ត្រូវជរា ចោមរោមហើយ ត្រូវសរគឺតណ្ហាមុតហើយ ត្រូវឥច្ឆា ឲ្យក្តៅក្រហាយហើយសព្វកាល ។ សត្វលោកត្រូវមច្ចុ កំចាត់បង់ហើយ ត្រូវជរា បិទបាំងហើយ

ហញ្ញតិ និច្ចមត្តាណោ  បត្តទណ្ឌោវ តក្ករោ ។
អាគច្ឆន្តគ្គិខន្ធាវ  មច្ចុព្យាធិជរា តយោ
បច្ចុគ្គន្តុំ ពលំ នត្ថិ  ជវោ នត្ថិ បលាយិតុំ ។
អមោឃំ ទិវសំ កយិរា  អប្បេន ពហុកេន វា
យំ យំ វិវហតេ រត្តិ(១)  តទូនន្តស្ស ជីវិតំ ។
ចរតោ តិដ្ឋតោ វាបិ  អាសីនសយនស្ស វា
ឧបេតិ ចរិមា រត្តិ  ន តេ កាលោ បមជ្ជិតុំ ។

សិរិមណ្ឌោ ថេរោ ។

(២២៦)ទិបាទកោយំ អសុចិ  ទុគ្គន្ធោ បរិហីរតិ
នានាកុណបបរិបូរោ  វិស្សវន្តោ តតោ តតោ ។
មិគំ និលីនំ កូដេន  ពលិសេនេវ អម្ពុជំ
វានរំ វិយ លេបេន  ពាធយន្តិ បុថុជ្ជនំ
រូបា សទ្ទា រសា គន្ធា  ផោដ្ឋព្វា ច មនោរមា
បញ្ច កាមគុណា ឯតេ  ឥត្ថីរូបស្មិំ ទិស្សរេ ។

១ ម. ឧ វិជហតេ រត្តិ ។



ជាសត្វឥតមានទីពឹង តែងលំបាកជានិច្ច ដូចជាមនុស្សអ្នកធ្វើកំហុស នោះដែលមានគេជាប់សំពៅហើយ ។ មច្ចុ ព្យាធិ និងជរាទាំង ៣ នេះ ដូចជាគំនរភ្លើងកំពុងរាលមក កំឡាំង ដើម្បីតទល់មិនមាន សន្ទុះសម្រាប់រត់ចេញ ក៏មិនមាន ។ បុគ្គលគប្បីធ្វើថ្ងៃ កុំឲ្យឥតអំពើ ដោយកិច្ចតិចក្តី ច្រើនក្តី ព្រោះរាត្រីរមែងអស់ទៅយ៉ាងណាៗ ជីវិតរបស់បុគ្គលនោះ រមែងថយទៅយ៉ាងនោះៗ ដែរ ។ រាត្រីខាងក្រោយរបស់បុគ្គលអ្នកដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី រមែងកន្លងចូលមកជិត កាលនេះ មិនមែនជាកាលគួរអ្នកប្រមាទទេ ។

សិរិមណ្ឌត្ថេរ ។

(២២៦) កាយមានជើងពីរនេះ មិនស្អាត មានក្លិនស្អុយ ពេញដោយសាកសពផ្សេង ៗ ចហ្អូរ(ខ្ទុះតែមិនស្អាត)ចេញតាមទ្វារនោះៗ ដែលមនុស្សទាំងឡាយថែទាំ(ជានិច្ច) ។ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ជាទីត្រេកអរនៃចិត្ត តែងបៀតបៀនបុថុជ្ជន ដូចអ្នកនេសាទធ្វើឲ្យកំបាំងហើយ(ចាប់)ម្រឹគដោយគ្រឿងចង(១)(ចាប់)ត្រីដោយសន្ទូច(ចាប់)ស្វាដោយជ័រ កាមគុណទាំង៥ នេះឯងតែងប្រាកដក្នុងរូបនៃស្រី ។

១. មានអន្ទាក់ ទំពក់ចង្កាក់ជាដើម ។

យេ ឯតា ឧបសេវន្តិ រត្តចិត្តា បុថុជ្ជនា
វឌ្ឍេន្តិ កដសឹ ឃោរំ អាចិនន្តិ បុនព្ភវំ ។
យោ ចេតា បរិវជ្ជេតិ សប្បស្សេវ បទា សិរោ
សោមំ វិសត្តិកំ លោកេ សតោ សមតិវត្តតិ ។
កាមេស្វាទីនវំ ទិស្វា នេក្ខម្មំ ទដ្ឋុ ខេមតោ
និស្សដោ សព្វកាមេហិ បត្តោ មេ អាសវក្ខយោតិ ។

សព្វកាមោ ថេរោ ។

## ឧទ្ទានំ

ឧរុវេលកស្សបោ ច ថេរោ តេកិច្ឆការិ ច
មហានាគោ ច កុល្លោ ច មាលុង្ក្យោ សប្បទាសកោ
កាតិយានោ ច មិគជាលោ ជេន្តោ សុមនសវ្ហយោ
ន្ហាតមុនិ ព្រហ្មទត្តោ សិរិមណ្ឌោ សព្វកាមកោ
គាថាយោ ចតុរាសីតិ ថេរា ចេត្ថ ចតុទ្ទសាតិ ។

ឆក្កនិបាតោ និដ្ឋិតោ ។





ពួកបុថុជ្ជនណា មានចិត្តត្រេកអរ ហើយចូលទៅគប់រកស្រីទាំងនុ៎ះ ពួកបុថុជ្ជនទាំងនោះឈ្មោះថា ធ្វើសង្សារវដ្ដ ដែលមានទុក្ខដ៏កាចខ្លាំងឲ្យចំរើនឡើង ទាំងឈ្មោះថា សន្សំនូវភពថ្មី ។ មួយទៀត បុគ្គលណាវៀរចេញចាកស្រីទាំងនុ៎ះបាន ដូចគេវៀរសក់នៃក្បាលពស់ដោយជើង បុគ្គលនោះ ឈ្មោះថាជាអ្នកមានស្មារតី ប្រព្រឹត្តកន្លងនូវតណ្ហា ជាគ្រឿងផ្សាយទៅក្នុងលោកនេះបាន ។ ខ្ញុំឃើញទោសក្នុងកាមទាំងឡាយ ឃើញការចេញចាកកាម ដោយក្សេមក្សាន្ត រលាស់ចេញចាកកាមទាំងអស់ បានដល់នូវការអស់អាសវៈហើយ ។

សព្វកាមត្ថេរ ។

## ឧទ្ទាន

និយាយអំពី ឧរុវេលកស្សបត្ថេរ ១ តេកិច្ឆការិត្ថេរ ១ មហានាគត្ថេរ ១ កុល្លត្ថេរ ១ មាលុង្ក្យបុត្តត្ថេរ ១ សប្បទាសត្ថេរ ១ កាតិយានត្ថេរ ១ មិគជាលត្ថេរ ១ ជេន្តបុរោហិតបុត្តត្ថេរ ១ សុមនត្ថេរ ១ ន្ហាតកមុនិត្ថេរ ១ ព្រហ្មទត្តត្ថេរ ១ សិរិមណ្ឌលត្ថេរ ១ សព្វកាមត្ថេរ ១ ក្នុងឆក្កនិបាតនេះ ព្រះថេរៈ ១៤ អង្គ (បានពោល) គាថា ៨៤ ។

ចប់ ឆក្កនិបាត ។